ការណែនាំសម្រាប់អ្នកប្រើ

សូមអានឯកសារណែនាំនេះដោយប្រុងប្រយ័ត្នសិន មុននឹងដំណើរការទូរទស្សន៍របស់អ្នក
និងរក្សាវាទុកជាឯកសារយោងនាពេលអនាគត។

www.lg.com

តារាងមាតិកា

ចាប់ផ្តើម webOS

កម្មវិធីបង្រៀនលើអេក្រង់ដើម 5
គ្រប់គ្រងអេក្រង់ដើម 6
ការមើលការផ្សាយ 8
ការភ្ជាប់ទៅបណ្តាញ 8
ការគ្រប់គ្រងគណនី LG របស់អ្នក 10
អំពី ការណែនាំសម្រាប់អ្នកប្រើប្រាស់ 12
ការប្រើប្រាស់ឧបករណ៍យ៉ាងងាយស្រួល 13

របៀបបើកដំណើរការឧបករណ៍

ផ្គូផ្គង Magic Remote 14
ការប្រើ Magic Remote 15
ការប្រើប្រាស់មុខងារឧបករណ៍តាមរយៈការនិយាយ 17
ការបម្លែងពីការនិយាយទៅជាអត្ថបទ 20
របៀបប្រើ Alexa នៅលើឧបករណ៍ 22
ការប្រើ សកម្មភាពច្រើនទៀត 22
ការកំណត់ការបញ្ជាសកល 23
ការប្រើ មុខងារចូលប្រើរហ័ស 24
ការភ្ជាប់ទៅ SIMPLINK (HDMI-CEC) 25
ការប្រើប្រាស់ក្តារចុច ម៉ៅស៍ និងដៃហ្គេម 26
ការប្រើប្រាស់មីក្រូហ្វូនបញ្ចូល USB 28

រីករាយនឹង Live Channel

ការប្រើ ម៉ឺនុយផ្សាយផ្ទាល់ 28
ការមើល ការណែនាំ 29
ការពិនិត្យមើលព័ត៌មានអំពីប៉ុស្តិ៍ 31
Live Playback 32
ការថត 33
ការចាប់យកតន្ត្រី 35
ការប្រើ កម្មវិធីកាលវិភាគទូរទស្សន៍ 36
ការបើកស្តាប់ការថត 37
កំពុងមើល LG Channels 39
អក្សរសន្ទស្សន៍ 40
HbbTV 42

កម្មវិធី និងមាតិកា

ការដំឡើងកម្មវិធី 43
ដើម្បីប្រើ កម្មវិធីរុករកវេទមន្ត 45

ការស្វែងរកមាតិកា 45
ការប្រើ ការិយាល័យនៅផ្ទះ 46
ការរីករាយប្រើប្រាស់ ហ្គេម 48
ការប្រើសេវាកម្ម ការស្វែងយល់ 49
ការរីករាយប្រើប្រាស់ តន្ត្រី 50
ការប្រើសេវាកម្ម កីឡា 51

ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ

ការប្រើ មណ្ឌលទំព័រដើម 52
ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយប្រើ LG ThinQ 55
ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយដាក់ស្លាក NFC 56
ការបញ្ចាំងអេក្រង់របស់ឧបករណ៍ឆ្លាតវៃ 57
ការចាក់សំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈឧបករណ៍បំពងសំឡេងខាងក្នុង 58
ការតភ្ជាប់កាមេរ៉ា 59
ការភ្ជាប់ឧបករណ៍ផ្ទុក USB 61
ការចែករំលែកខ្លឹមសារនៅលើកុំព្យូទ័រ 62
ការបញ្ចាំងអេក្រង់កុំព្យូទ័រ 63

ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីមុខងារឆ្លាតវៃ

ការប្រើ មុខងារមើលច្រើន 65
ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី វិចិត្រសាល 67
ការប្រើ កម្មវិធីរុករកលើអ៊ីនធឺណិត 68
កំពុងប្រើ កម្មវិធីចាក់មេឌៀ 71
Live Plus 75
ការជូនដំណឹង 76

ការកំណត់

ការកំណត់រហ័ស 77
រូបភាព 78
សំឡេង 89
លទ្ធភាពប្រើប្រាស់ 99
សេវាកម្ម AI 104
កម្មវិធីកែលម្អហ្គេម 106
ការថែទាំ OLED 110
ការកំណត់សម្រាប់ផ្ទៃកត្រួសារ 112
ប៉ុស្តិ៍ 113
បណ្តាញ 118
ឧបករណ៍ខាងក្រៅ 119
ប្រព័ន្ធ 123
ការសន្សំសំចៃថាមពល 130
ជំនួយ 130

ការដោះស្រាយបញ្ហា

ធ្វើការត្រួតពិនិត្យដោយប្រើ Quick Help 134
ការដោះស្រាយបញ្ហាតេឡេបញ្ជា/ថាមពល 135
ការដោះស្រាយបញ្ហាអេក្រង់ 137
ការដោះស្រាយបញ្ហាសំឡេង 140
ការដោះស្រាយបញ្ហានៃការតភ្ជាប់ឧបករណ៍ 142
ការដោះស្រាយបញ្ហានៃការចាក់ភាពយន្ត 143
ការដោះស្រាយបញ្ហានៃការថត 145
ការដោះស្រាយបញ្ហានៃការតភ្ជាប់បណ្តាញ 146
ការដោះស្រាយបញ្ហាគណនី LG 148
ការដោះស្រាយបញ្ហាខ្លឹមសារ 149
ការដោះស្រាយបញ្ហាកម្មវិធីរុករកនៅលើអ៊ីនធឺណិត 150

ការទទួលបានព័ត៌មាន

ទម្រង់ឯកសាររូបថតដែលស្គាល់ 151
ទម្រង់ឯកសារវីដេអូដែលស្គាល់ 152
ទម្រង់ឯកសារតន្ត្រីដែលស្គាល់ 154
គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-DTV 156
គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-PC 160
ព័ត៌មានអំពីអាជ្ញាប័ណ្ណ 164

ចាប់ផ្តើម webOS

កម្មវិធីបង្រៀនលើអេក្រង់ដើម

ការប្រើមុខងារ Home របស់ LG webOS

អ្នកអាចបើកអេក្រង់ដើម ដោយចុចប៊ូតុង លើតេឡេរបស់អ្នក។
រំកិលប៊ូតុង **រង្វង់មូល (OK)** នៅលើ Magic Remote ដើម្បីរំកិលតាមរយៈម៉ឺនុយ។
អ្នកអាចបើកកម្មវិធី និងខ្លឹមសារ ឬប្រើមុខងារផ្សេងៗនៃមុខងារឆ្លាតវៃ។
ចុចប៊ូតុង លើតេឡេ។ អ្នកអាចប្រើ ឬបិទកម្មវិធីដែលទើបបានប្រើថ្មីៗ
ដែលបានរក្សាទុកសម្រាប់គណនី គណនី LG នីមួយៗបាន។

- តេឡេបញ្ជាស្តង់ដារអនុញ្ញាតឱ្យអ្នករំកិលតាមរយៈម៉ឺនុយដោយប្រើ ▼/▲។



1. ចាប់ផ្តើម **គណនី LG**។
   ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ចាប់ផ្តើម webOS** → **ការគ្រប់គ្រងគណនី LG របស់អ្នក** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
2. ចាប់ផ្តើម **ការជូនដំណឹង**។
   ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីមុខងារឆ្លាតវៃ** → **ការជូនដំណឹង** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
3. ចាប់ផ្តើម **ការកំណត់រហ័ស**។
   ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **ការកំណត់រហ័ស** → **ដើម្បីប្រើមុខងារកំណត់បានរហ័ស** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
4. ចាប់ផ្តើម **ស្វែងរក**។
   ដើម្បីមើលព័ត៌មានលម្អិត សូមចុច **កម្មវិធី និងមាតិកា** → **ការស្វែងរកមាតិកា** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❺ ការផ្សាយពាណិជ្ជកម្មត្រូវបានបង្ហាញ។
អ្នកអាចបើក ឬបិទការផ្សាយពាណិជ្ជកម្មនៅក្នុង ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ការកំណត់ទំព័រដើម** → **ការផ្តល់ជូនពិសេសនៅទំព័រដើម**។

❻ អ្នកអាចប្រើមុខងារ ឬសេវាកម្មផ្សេងៗបាន។

❼ អ្នកអាចដំណើរការ ផ្លាស់ទី និងលុបកម្មវិធីដែលបានដំឡើងនៅលើឧបករណ៍របស់អ្នក។

❽ ត្រឡប់ទៅធាតុបញ្ជូលខាងក្រៅដែលប្រើថ្មីៗនេះបំផុត។

- អេក្រង់ដើមត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ នៅពេលណាដែលអ្នកបើកថាមពល។
ដើម្បីបិទលក្ខណៈពិសេសនេះ សូមចូលទៅកាន់ ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ការកំណត់ទំព័រដើម** រួចកំណត់ **បើកថាមពលអេក្រង់** ទៅ **ការបញ្ជូលថ្មីៗ**។
- លទ្ធភាពផ្តល់ជូន និងការចូលប្រើប្រាស់មាតិកា និងសេវាកម្មក្នុងឧបករណ៍
អាចនឹងមានការផ្លាស់ប្តូរគ្រប់ពេល ដោយគ្មានការជូនដំណឹងជាមុន។
- មុខងារដែលអាចប្រើបានមានភាពខុសគ្នាទៅតាមតំបន់ ឬសេវាកម្ម។

គ្រប់គ្រងអេក្រង់ដើម

គ្រប់គ្រង LG webOS Home

អ្នកអាចប្តូរលំដាប់នៃបញ្ជីខ្លឹមសារ ឬកម្មវិធីដែលបានបង្ហាញដោយចុចប៊ូតុង 🏠
នៅលើឧបករណ៍បញ្ជាពីចម្ងាយ។

- សម្រាប់ គណនី LG នីមួយៗ បញ្ជីដែលអ្នកកែត្រូវបានរក្សាទុកតែនៅលើឧបករណ៍នោះប៉ុណ្ណោះ។

កែសម្រួលបញ្ជីកាត

01 ជ្រើសរើសកាតដែលអ្នកចង់កែ បន្ទាប់មកចុចប៊ូតុង **រង្វង់មូល (OK)**
នៅលើតេឡេបញ្ជាឱ្យដាប់។
ឬអ្នកអាចចុចប៊ូតុង **កែសម្រួល** ដែលស្ថិតនៅផ្នែកខាងចុងនៃបញ្ជីកាត។

02 ផ្លាស់ទីទៅទីតាំងដែលចង់បាន រួចចុចប៊ូតុង **រង្វង់មូល (OK)** ដើម្បីប្តូរទីតាំងកម្មវិធី។
អ្នកក៏អាចប្តូរទីតាំងកាតដោយប្រើប៊ូតុង ◀/▶ នៅលើតេឡេបញ្ជារបស់អ្នកបានផងដែរ។
ជ្រើសរើសកាតដែលអ្នកចង់បាន រួចបញ្ចូលកាតទាំងនោះទៅក្នុងបញ្ជី។
ដើម្បីលុបកាតណាមួយ សូមជ្រើសរើសរូប ^ នៅផ្នែកខាងលើកាត។

- ចុចប៊ូតុង ••• លើតេឡេ។
ការកំណត់ទំព័រដើម : នៅពេលបើកថាមពល
សូមចូលទៅកាន់អេក្រង់ដែលកំណត់សកម្មភាពទំព័រដើម ឬការបង្ហាញការផ្សាយពាណិជ្ជកម្ម។
ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

03 បន្ទាប់ពីបញ្ចប់ការកែសម្រួលសូមចុចប៊ូតុង ↩ នៅលើតេឡេបញ្ជា

ដើម្បីចាកចេញពីមុខងារកែសម្រួលភាគ។

កែសម្រួលបញ្ជីកម្មវិធី

01 ជ្រើសរើសកម្មវិធីដែលអ្នកចង់កែសម្រួល បន្ទាប់មកចុចប៊ូតុង **រង្វង់មូល (OK)** នៅលើតេឡេបញ្ជាឱ្យដាប់ ដើម្បីចូលរបៀប **កែសម្រួលបញ្ជីកម្មវិធី**។
ឬអ្នកអាចចុចប៊ូតុង **កែសម្រួលបញ្ជីកម្មវិធី** នៅខាងចុងនៃ បញ្ជីកម្មវិធី។

02 ផ្លាស់ទីទៅទីតាំងដែលចង់បាន រួចចុចប៊ូតុង **រង្វង់មូល (OK)** ដើម្បីប្តូរទីតាំងកម្មវិធី។
ដើម្បីលុបកម្មវិធី សូមជ្រើសរើសអាយខុន 🗑 ខាងលើកម្មវិធី។
អ្នកអាចកំណត់លំដាប់បញ្ជីកម្មវិធីឡើងវិញបានដោយចុច **កំណត់លំដាប់កម្មវិធីឡើងវិញ**។

- អ្នកក៏អាចប្តូរកម្មវិធីដោយប្រើប៊ូតុង ◀/▶ លើតេឡេរបស់អ្នកផងដែរ។
- ចុចប៊ូតុង ••• លើតេឡេ។
  ការកំណត់ទំព័រដើម : នៅពេលបើកថាមពល
  សូមចូលទៅកាន់អេក្រង់ដែលកំណត់សកម្មភាពទំព័រដើម ឬការបង្ហាញការផ្សាយពាណិជ្ជកម្ម។
  ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

03 បន្ទាប់ពីបញ្ចប់ការកែសម្រួល សូមចុច **បិទ** នៅផ្នែកខាងក្រោមនៃអេក្រង់
ដើម្បីចាកចេញពីរបៀប “កម្មវិធីកែសម្រួល”។

- មិនអាចលុបកម្មវិធីលំនាំដើមបានទេ។

កែសម្រួលបញ្ជីមាតិកា

01 រំកិលទៅផ្នែកខាងក្រោមនៃអេក្រង់ដើមដោយរំកិលប៊ូតុង **រង្វង់មូល (OK)** ហើយជ្រើសរើស ✎ ដើម្បីចូលរបៀប កែសម្រួលបញ្ជីមាតិកា។

02 ជ្រើសរើសបញ្ជីដែលអ្នកចង់ផ្លាស់ទីដោយប្រើប៊ូតុង **រង្វង់មូល (OK)**
ដើម្បីផ្លាស់ទីវាទៅទីតាំងដែលចង់បាន រួចចុច **រង្វង់មូល (OK)**
ដើម្បីប្តូរទីតាំងរបស់បញ្ជីនោះ។ អ្នកក៏អាចផ្លាស់ទីបញ្ជីដោយប្រើប៊ូតុង ▲/▼/◀/▶
លើតេឡេបញ្ជាបានផងដែរ។

- ចុចប៊ូតុង ••• លើតេឡេ។
  ការកំណត់ទំព័រដើម : នៅពេលបើកថាមពល
  សូមចូលទៅកាន់អេក្រង់ដែលកំណត់សកម្មភាពទំព័រដើម ឬការបង្ហាញការផ្សាយពាណិជ្ជកម្ម។
  ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

03 បន្ទាប់ពីបញ្ចប់ការកែសម្រួល ចុច **បិទ** នៅផ្នែកខាងក្រោមនៃអេក្រង់
ដើម្បីចាកចេញពីរបៀប “កែសម្រួលបញ្ជីមាតិកា”។

- បញ្ជីមួយចំនួនមិនអាចផ្លាស់ទីបានទេ។

ការមើលការផ្សាយ

ការមើលការផ្សាយ

01 ភ្ជាប់ខ្សែ/អង់តែនផ្សាយជាមួយឧបករណ៍។
ប្រសិនបើមានរន្ធដោតលើសពីពីរ អ្នកត្រូវតែពិនិត្យមើលសញ្ញាសម្គាល់នៅលើរន្ធអង់តែន ហើយដោតវាទៅ រន្ធណាមួយដែលសមស្របសម្រាប់ប្រទេសរបស់អ្នក។

02 បើកដំណើរការ → → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**។
អ្នកអាចស្វែងរកប៉ុស្តិ៍ផ្សាយបច្ចុប្បន្ន ហើយរក្សាទុកវាទៅក្នុងឧបករណ៍បាន។


- អ្នកក៏អាចតភ្ជាប់ឧបករណ៍មួយដែលអាចទទួលការផ្សាយ ដូចជាឧបករណ៍ចាប់រលកសញ្ញាដំនួសអង់តែនបានដែរ។
បើកដំណើរការ → → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់អង្គបញ្ជាសកល**។
- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងមុខងារនេះ សូមមើល **ការដោះស្រាយបញ្ហា** ផ្នែករបស់ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការភ្ជាប់ទៅបណ្តាញ

ការភ្ជាប់ទៅបណ្តាញ

ប្រសិនបើអ្នកកែប្រែការកំណត់របស់បណ្តាញ អ្នកអាចប្រើសេវាជាច្រើន ដូចជាមាតិកា និងកម្មវិធីលើប្រព័ន្ធអ៊ីនធឺណិត។

ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)



01 ភ្ជាប់រន្ធ LAN របស់ឧបករណ៍ និងរ៉ោតទ័រដោយប្រើខ្សែ LAN។
អ្នកគួរតភ្ជាប់រ៉ោតទ័រជាមួយអ៊ីនធឺណិតជាមុន។

- នៅពេលអ្នកភ្ជាប់ឧបករណ៍ទៅបណ្តាញតាមរយៈខ្សែ LAN
ឧបករណ៍នោះនឹងត្រូវបានភ្ជាប់ទៅបណ្តាញដោយស្វ័យប្រវត្តិ ប្រសិនបើរ៉ោតទ័រនោះស្គាល់ DHCP។

ប្រសិនបើបណ្តាញមិនត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិទេ

02 ចុចប៊ូតុង ⚙ លើតេឡេ។

03 ជ្រើសរើស ⚙ → **ទូទៅ** → **បណ្តាញ** → **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)**។
ដើម្បីមើលព័ត៌មានលម្អិត សូមមើល **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)** ក្នុង **ការកំណត់** → **បណ្តាញ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការតភ្ជាប់ Wi-Fi



01 បើករ៉ោតទ័រដែលតភ្ជាប់អ៊ីនធឺណិត។

02 ចុចប៊ូតុង ⚙ លើតេឡេ។

03 ជ្រើសរើស ⚙ → **ទូទៅ** → **បណ្តាញ** → **ការតភ្ជាប់ Wi-Fi**។

04 នៅពេលការស្វែងរកបណ្តាញបានបញ្ចប់ បញ្ជីបណ្តាញដែលមានដើម្បីតភ្ជាប់នឹងបង្ហាញ។

05 ជ្រើសរើសបណ្តាញដែលត្រូវតភ្ជាប់។
ប្រសិនបើរ៉ោតទ័រតតខ្សែ ការពារដោយពាក្យសម្ងាត់ សូមបញ្ចូលពាក្យសម្ងាត់របស់រ៉ោតទ័រ ។
ដើម្បីមើលព័ត៌មានលម្អិត សូមមើល **ការតភ្ជាប់ Wi-Fi** ក្នុង **ការកំណត់** → **បណ្តាញ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការព្រមានស្តីពីការកំណត់បណ្តាញ

- ប្រើខ្សែ LAN ស្តង់ដារ (តភ្ជាប់ជាមួយ Cat7 ឬខ្ពស់ជាងនេះជាមួយឧបករណ៍តភ្ជាប់ RJ45 10 Base-T, ឬរន្ធ 100 Base TX LAN)។
- ការកំណត់រ៉ោតទ័រឡើងវិញអាចបណ្តាលឱ្យមានបញ្ហាក្នុងការតភ្ជាប់បណ្តាញ។ រ៉ោតទ័រនឹងដំណើរការធម្មតាប្រសិនបើអ្នកបិទវាហើយផ្តាច់ឧបករណ៍ចេញ ហើយបន្ទាប់មកភ្ជាប់វានឹងបើកវាឡើងវិញ។
- ក្រុមហ៊ុនផលិតមិនទទួលខុសត្រូវចំពោះការតភ្ជាប់បណ្តាញ ឬប្រតិបត្តិការមិនដំណើរការដោយសារតែបញ្ហាដូចជា ឧបករណ៍មិនដំណើរការ ឬដាច់ខ្សែនោះទេ។
- ការតភ្ជាប់បណ្តាញអាចដំណើរការមិនប្រក្រតី ដោយសារការកំណត់បណ្តាញ ឬអ្នកផ្តល់សេវាអ៊ីនធឺណិត។
- សេវាកម្ម DSL ត្រូវតែប្រើម៉ូឌឹម DSL ហើយសេវាកម្មខ្សែកាបត្រូវតែប្រើម៉ូឌឹមខ្សែកាប។ ការកំណត់បណ្តាញរបស់ឧបករណ៍អាចមិនត្រូវបានប្រើដោយផ្អែកលើកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតនោះទេ ដោយសារអាចប្រើការតភ្ជាប់បណ្តាញមួយចំនួនតែប៉ុណ្ណោះ។ (ប្រសិនបើកិច្ចសន្យាមិនអនុញ្ញាតឱ្យប្រើឧបករណ៍ច្រើនជាងក្នុងមួយបណ្តាញទេ មានតែកុំព្យូទ័រដែលបានភ្ជាប់រួចហើយប៉ុណ្ណោះទើបអាចប្រើបាន។)
- បណ្តាញឥតខ្សែអាចមានការរំខានពីឧបករណ៍ផ្សេងទៀតដែលប្រើហ្វ្រេកង់ 2.4 GHz (ទូរសព្ទឥតខ្សែ ឧបករណ៍ Bluetooth ឬម៉ាស៊ីនអាំងសាច់)។ ទោះបីជាការរំខានអាចកើតឡើងនៅពេលប្រើហ្វ្រេកង់ 5 GHz វាហាក់ដូចជាមិនអាចកើតឡើងទេ។
- បរិយាកាសឥតខ្សែអាចបណ្តាលឲ្យសេវាបណ្តាញឥតខ្សែដំណើរការយឺត។
- ការប្រើឧបករណ៍ឥតខ្សែច្រើនក្នុងពេលតែមួយអាចធ្វើឱ្យបណ្តាញរបស់អ្នកដំណើរការយឺត។
- ឧបករណ៍ចំណុចចូលប្រើត្រូវគាំទ្រការតភ្ជាប់ដោយឥតខ្សែ ហើយមុខងារតភ្ជាប់ដោយឥតខ្សែត្រូវតែបើកលើឧបករណ៍ដើម្បីតភ្ជាប់ (ចំណុចចូលប្រើ) AP។ ទាក់ទងអ្នកផ្តល់សេវាសម្រាប់ការតភ្ជាប់ដោយឥតគិតខ្សែលើចំណុចចូលប្រើ។
- ពិនិត្យ SSID និងការកំណត់សុវត្ថិភាពរបស់ AP ។ សូមមើលឯកសារត្រឹមត្រូវសម្រាប់ SSID និងការកំណត់សុវត្ថិភាពរបស់ AP ។
- ប្រសិនបើបណ្តាញត្រូវបានប្តូរដោយផ្លាស់ទីឧបករណ៍ ឬប្តូររ៉ោតទ័រ អ្នកត្រូវរៀបចំបណ្តាញឥតខ្សែម្តងទៀត។ ការតភ្ជាប់បណ្តាញឥតខ្សែដែលមានស្រាប់នឹងមិនត្រូវបានរក្សាទុកទេ។
- ការកំណត់ឧបករណ៍បណ្តាញមិនត្រឹមត្រូវ (មណ្ឌលអង្គចែករំលែកបណ្តាញមានខ្សែ/ឥតខ្សែ) អាចបណ្តាលឱ្យឧបករណ៍ដំណើរការយឺត ឬមិនដំណើរការតាមប្រក្រតី។ ដំឡើងឧបករណ៍ឱ្យបានត្រឹមត្រូវដោយផ្អែកតាមឯកសារណែនាំ និងបណ្តាញដែលសមស្រប។
- វិធីសាស្ត្រតភ្ជាប់អាចខុសគ្នាអាស្រ័យលើក្រុមហ៊ុនផលិត AP។
- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងមុខងារនេះ សូមមើល **ការដោះស្រាយបញ្ហា** ផ្នែករបស់ **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការគ្រប់គ្រងគណនី LG របស់អ្នក

សមាជិកភាព LG

ការចូលដោយប្រើ **គណនី LG** អាចឱ្យអ្នកប្រើមាតិកាដែលបានណែនាំស្របតាមបុគ្គល
និងសេវាកម្មកម្មវិធីផ្សេងៗ។
អ្នកអាចចុះឈ្មោះប្រើសមាជិកភាព LG និងចូលដោយប្រើអាសយដ្ឋានអ៊ីមែលរបស់អ្នកនៅក្នុង
គណនី LG។
ឬអ្នកអាចចុះឈ្មោះប្រើសមាជិកភាព LG ដោយប្រើលេខសម្ងាត់
និងពាក្យសម្ងាត់គណនីសម្រាប់សេវាកម្មខាងក្រៅ។

01 ចុចប៊ូតុង ⌂ នៅលើតេឡេបញ្ជា រួចជ្រើសរើស 👤។

02 ចាប់ផ្តើមចុះឈ្មោះសម្រាប់សមាជិកភាព LG
ដោយជ្រើសរើសវិធីចុះឈ្មោះចូលមួយដែលបានណែនាំ។

03 យល់ព្រមតាម កិច្ចព្រមព្រៀងអ្នកប្រើប្រាស់ និងបញ្ចូលព័ត៌មានតម្រូវសម្រាប់ចុះឈ្មោះ។

- ព័ត៌មានដែលចាំបាច់អាចប្រែប្រួលតាមប្រទេស។

04 តំណភ្ជាប់សម្រាប់ផ្ទៀងផ្ទាត់នឹងផ្ញើទៅអាសយដ្ឋានអ៊ីមែល
ដែលអ្នកបានបញ្ចូលនៅពេលអ្នកចុះឈ្មោះ។ សូមបញ្ចប់ការផ្ទៀតផ្ទាត់តាមអ៊ីមែល
ក្នុងរយៈដែលមានសុពលភាព។

05 នៅពេលផ្ទៀងផ្ទាត់អាសយដ្ឋានអ៊ីមែលរបស់អ្នករួច
អ្នកអាចចូលដោយប្រើព័ត៌មានផ្ទៀងផ្ទាត់របស់អ្នក។

- លក្ខណៈពិសេសនេះប្រហែលជាមិនអាចប្រើបាននៅប្រទេសមួយចំនួនទេ។
- ការដាក់កំហិតអាយុអាចអនុវត្តសម្រាប់ការចុះឈ្មោះ។
- ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងមុខងារនេះ សូមមើល **ការដោះស្រាយបញ្ហា** ផ្នែករបស់
ការណែនាំសម្រាប់អ្នកប្រើប្រាស់។

ការប្តូរគណនីចូល

អ្នកអាចប្តូររវាងគណនីដែលបានចូលពីមុនបានយ៉ាងងាយស្រួល។

01 សូមជ្រើសរើស ⌂ → **គណនី LG**។

02 បញ្ជីគណនីដែលបានចូលពីមុនបង្ហាញឡើង។ ជ្រើសរើសគណនីដែលអ្នកចង់ប្តូរ។
ដើម្បីចូលដោយប្រើគណនីថ្មី សូមជ្រើសរើស **បញ្ចូលគណនី**។

- អ្នកអាចរក្សាទុកគណនីបានរហូតដល់ 10។ ប្រសិនបើចំនួនគណនីលើស 10
គណនីដែលបានចូលមុនគេបំផុតត្រូវបានលុប។

ការគ្រប់គ្រងគណនី LG របស់អ្នក

អ្នកអាចកែបញ្ជីគណនីដែលបានចូលបាន។

01 សូមជ្រើសរើស ⌂ → **គណនី LG**។

02 ចុច ⋮ ដើម្បីជ្រើសរើស **ព័ត៌មានបន្ថែមអំពីគណនី**។

- អាចមើលព័ត៌មានគោលៗអំពីគណនីដោយជ្រើសរើស **ការគ្រប់គ្រងគណនី** នៅក្រោមគណនីដែលបានចូល។ អ្នកក៏អាចប្តូរពាក្យសម្ងាត់របស់អ្នក ឬកែសម្រួលព័ត៌មានអំពីគណនីរបស់អ្នកបានផងដែរ។
  ការចុច អាចឱ្យអ្នកលុបគណនីដែលបានរក្សាទុក។

ការប្រើប្រាស់ពាក្យសម្ងាត់ធម្មតា

អ្នកអាចកំណត់ពាក្យសម្ងាត់ធម្មតាសម្រាប់បញ្ចូល នៅពេលប្តូរគណនីបាន។

01 សូមជ្រើសរើស ⌂ → **គណនី LG**។

02 ចុច ⋮ ដើម្បីជ្រើសរើស **ព័ត៌មានបន្ថែមអំពីគណនី**។

03 ជ្រើសរើស **ការគ្រប់គ្រងគណនី**។
អ្នកអាចត្រឹមតែជ្រើសរើសគណនីដែលអ្នកបានចូលសម្រាប់ **ការគ្រប់គ្រងគណនី** ប៉ុណ្ណោះ។

04 ជ្រើសរើស**ការកំណត់សុវត្ថិភាព** → **កែការកំណត់សុវត្ថិភាព**
រួចបញ្ចូលពាក្យសម្ងាត់សម្រាប់គណនីនោះ។

05 ជ្រើសរើស**ពាក្យសម្ងាត់សាមញ្ញ**សម្រាប់**វិធីប្តូរគណនី**។

06 បញ្ចូលលេខបួនខ្ទង់ដែលចង់ប្រើ រួចចុច **OK**។

- អ្នកអាចប្រើ **ពាក្យសម្ងាត់សាមញ្ញ** បានតែនៅពេលប្តូរគណនីនៅក្នុងឧបករណ៍នេះប៉ុណ្ណោះ។

អំពី ការណែនាំសម្រាប់អ្នកប្រើប្រាស់

អំពី **ការណែនាំសម្រាប់អ្នកប្រើប្រាស់**

សម្រាប់ព័ត៌មាននៅលើមុខងារ webOS នីមួយៗ សូមមើល **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ដែលមាននៅលើឧបករណ៍។
អ្នកអាចពិនិត្យមើលការពណ៌នា **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ដែលពាក់ព័ន្ធ ដោយចុច ⋮ → **ការណែនាំសម្រាប់អ្នកប្រើប្រាស់** នៅជ្រុងខាងស្តាំផ្នែកខាងលើ ខណៈពេលកំពុងប្រើកម្មវិធី ឬដោយចុច ? អំឡុងពេលរៀបចំនៅក្នុង **ការកំណត់**។
ប្រសិនបើអ្នកចុចលើ **សាកល្បងឥឡូវ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** អ្នកអាចរុករកទៅការកំណត់ ឬមុខងារនោះបាន។
ពណ៌អក្សរនៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** នេះត្រូវបានប្រើដើម្បីបង្ហាញចំណុចខាងក្រោម៖

- ■ ក្រហម : ឈ្មោះប៊ូតុងតែឡើយ។

· ■ លឿង : ប៊ូតុង និងអក្សរដែលត្រូវបង្ហាញនៅលើអេក្រង់។

- រូបភាព និងព័ត៌មាន នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** អាចខុសគ្នា អាស្រ័យលើម៉ូដែល និងបរិយាកាសប្រតិបត្តិការ។
- ព័ត៌មានស្តីពីផលិតផលអាចត្រូវបានផ្លាស់ប្តូរដោយមិនជូនដំណឹងជាមុន ដោយសារការធ្វើមុខងារ របស់ផលិតផលឱ្យកាន់តែប្រសើរឡើង។

ការប្រើប្រាស់ឧបករណ៍យ៉ាងងាយស្រួល

ការប្រើប្រាស់ឧបករណ៍យ៉ាងងាយស្រួល

ប្រសិនបើអ្នកមានការលំបាកក្នុងការមើល ឬស្តាប់ សូមសាកល្បងប្រើមុខងារជំនួយរូបភាព-សំឡេង។ អ្នកក៏អាចរកឃើញរបៀបប្រើតេឡេបញ្ជា និងឧបករណ៍ ហើយដោះស្រាយបញ្ហាបានផងដែរ។
ចុចប៊ូតុង 🏠 នៅលើតេឡេបញ្ជា រួចជ្រើសរើស **លទ្ធភាពប្រើប្រាស់**។
ដើម្បីបើកដំណើរការ **លទ្ធភាពប្រើប្រាស់** ពីអេក្រង់ណាមួយ សូមចុចប៊ូតុង 🔇 នៅលើតេឡេបញ្ជាឱ្យជាប់។

មុខងារចក្ខុ

មានការកំណត់ដែលអាចប្រើបានសម្រាប់ការកែលម្អការមើលអេក្រង់។

មុខងារស្តាប់

មានការកំណត់ដែលអាចប្រើបានសម្រាប់ការកែលម្អគុណភាពសំឡេង។

ស្វែងយល់អំពីតេឡេបញ្ជា

ចុចប៊ូតុងនៅលើតេឡេបញ្ជា ដោយអនុវត្តតាមការណែនាំនៅលើអេក្រង់ ដើម្បីទទួលបានព័ត៌មានអំពីប៊ូតុង។

គន្លឹះ

អ្នកអាចស្វែងរកគន្លឹះអំពីមុខងារនានាបាន។

Quick Help

អ្នកអាចទទួលបានជំនួយសម្រាប់ការវិភាគ និងដោះស្រាយបញ្ហាជាមួយឧបករណ៍។
អ្នកក៏អាចចុចប៊ូតុងលេខ **9** របស់តេឡេបញ្ជាឱ្យជាប់ ដើម្បីដំណើរការ **Quick Help** ផងដែរ។

Chatbot

អ្នកអាចដោះស្រាយបញ្ហាទាក់ទងនឹងឧបករណ៍នេះដោយជជែកជាមួយ Chatbot។

របៀបបើកដំណើរការឧបករណ៍

ផ្គូផ្គង Magic Remote

ស្វែងយល់បន្ថែមអំពី Magic Remote

អ្នកអាចជ្រើសរើសមុខងារដែលអ្នកចង់ប្រើបានយ៉ាងងាយស្រួលដោយរំកិល
ហើយចុចទស្សន៍ទ្រនិចលើអេក្រង់ គឺដូចដែលអ្នកប្រើកណ្តុរនៅលើអេក្រង់កុំព្យូទ័រដូច្នេះដែរ។

- អ្នកអាចទិញ Magic Remote ដាច់ដោយឡែកបាន ប្រសិនបើមិនមានផ្តល់ជូន។

ផ្គូផ្គង Magic Remote

អ្នកត្រូវតែផ្គូផ្គង Magic Remote ជាមួយឧបករណ៍ដើម្បីប្រើវា។
ផ្គូផ្គង Magic Remote មុនពេលប្រើដូចខាងក្រោម៖

01 បើកឧបករណ៍។ បន្ទាប់ពីរយៈពេល 20 វិនាទី សូមតម្រង់តេឡេទៅឧបករណ៍ បន្ទាប់មកចុច **រង្វង់មូល (OK)**។

02 តេឡេបញ្ជានឹងត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិ
ហើយសារអំពីការបញ្ចប់ការផ្គូផ្គងនឹងបង្ហាញនៅលើអេក្រង់។

- ប្រសិនបើចុះឈ្មោះ Magic Remote មិនបានសម្រេចទេ សូមបិទឧបករណ៍ បន្ទាប់មកបើកវិញ
រួចព្យាយាមចុះឈ្មោះម្តងទៀត។

ចុះឈ្មោះ Magic Remote ឡើងវិញ

ប្រសិនបើសញ្ញាព្រួញរបស់ Magic Remote មិនបង្ហាញនៅលើអេក្រង់ទេ
អ្នកត្រូវតែចុះឈ្មោះវាឡើងវិញ។

01 តម្រង់តេឡេបញ្ជាឱ្យចំឧបករណ៍ រួចចុចប៊ូតុង ⌂ និង ⚙ ដំណាលគ្នាឱ្យបានលើសពី 5 វិនាទី
រហូតដល់បង្ហាញការណែនាំ។

02 តេឡេដែលបានចុះឈ្មោះពីមុនត្រូវបានលុបចោល ហើយចុះឈ្មោះម្តងទៀត។

ការលុបការចុះឈ្មោះ Magic Remote

ប្រសិនបើអ្នកមានឧបករណ៍ LG ច្រើន ហើយចង់ចុះឈ្មោះ Magic Remote ដែលកំពុងប្រើជាមួឧបករណ៍ផ្សេងទៀត អ្នកត្រូវតែលុបការចុះឈ្មោះពីមុនជាមុនសិន។

01 ប្រសិនបើអ្នកចុចប៊ូតុង ↩ និងប៊ូតុង ⌂ ក្នុងពេលតែមួយរយៈពេលលើស 5 វិនាទី អំពូលនៅលើ Magic Remote នឹងលោតភ្លឺបត់ភ្លែត ហើយការចុះឈ្មោះនឹងត្រូវបោះបង់។

02 ប្រសិនបើអ្នកចង់លុបការចុះឈ្មោះ ហើយចុះឈ្មោះឧបករណ៍ LG ផ្សេងទៀត សូមអនុវត្តតាមវិធីចុះឈ្មោះខាងលើ។

ការប្រើ Magic Remote

ការប្រើប្រាស់ប៊ូតុងលើតេឡេ

ចុចដោយរហ័ស ឬចុច ហើយសង្កត់ ប៊ូតុងលើតេឡេ ដើម្បីចូលប្រើប្រាស់មុខងារផ្សេងៗទៀត។
សូមជ្រើសរើស ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ស្វែងយល់អំពីតេឡេបញ្ជា**។
ចុចប៊ូតុងនៅលើតេឡេបញ្ជា ដោយអនុវត្តតាមការណែនាំនៅលើអេក្រង់ ដើម្បីទទួលបានព័ត៌មានអំពីប៊ូតុង។

- ចំណុចសម្គាល់ និងទីតាំងរបស់ប៊ូតុងនៅលើតេឡេបញ្ជាអាចនឹងខុសគ្នាទៅតាមប្រភេទម៉ូដែល។
- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។



សម្រាប់ប៊ូតុងដែលមាន ◎ សូមចុចឱ្យជាប់
(ចុចឱ្យជាប់ឱ្យយូរជាងមួយវិនាទី)។

- **9** ◎ : ចាប់ផ្តើម **Quick Help**។
- **GUIDE** : ចាប់ផ្តើម **ការណែនាំ**។
  GUIDE ◎ : បង្ហាញ **ប៉ុស្តិ៍**។
- **0** ◎ : អេក្រង់កែសម្រួល **មុខងារចូលប្រើរហ័ស** លេចចេញមក។
- ••• : បង្ហាញប៊ូតុងបន្ថែមនៅលើតេឡេបញ្ជា។
  ••• ◎ : វាអានមាតិកានៃអេក្រង់ទៅក្រៅឮៗ ឬកំណត់សំឡេងច្រើន។
- +− : កែតម្រូវកម្រិតសំឡេង។
- : ជ្រើសរើស ដើម្បីបិទសំឡេងពីឧបករណ៍។
  ◎ : ចូលម៉ឺនុយ **លទ្ធភាពប្រើប្រាស់**។
- ∧∨ : អ្នកអាចប្តូរប៉ុស្តិ៍បាន។
- : បង្ហាញពាក្យបញ្ជាដោយប្រើសំឡេងដែលបានណែនាំ។
  អ្នកអាចប្រើមុខងារសម្គាល់សំឡេង ដោយចុចប៊ូតុងនេះឱ្យជាប់
  ហើយនិយាយទៅកាន់តេឡេបញ្ជា។
- : បង្ហាញម៉ឺនុយដើមទំព័រដើម។
  ◎ : ចាប់ផ្តើមកម្មវិធីដែលបានប្រើប្រាស់ចុងក្រោយ។
- : ជ្រើសរើសប្រភពចូល។
  ◎ : ការចូលទៅក្នុង **មណ្ឌលទំព័រដើម**។
- : ផ្លាស់ទីទៅជំហានពីមុន។
  ◎ : បិទម៉ឺនុយ។
- : ចូលម៉ឺនុយការកំណត់រហ័ស។
  ◎ : ចូលម៉ឺនុយការកំណត់ទាំងអស់។
- ◎ : ចាប់ផ្តើម **ថត**។

ការប្រើ Magic Remote

01 ប្រសិនបើអ្នករលាក់ Magic Remote ឆ្វេងស្តាំ ឬបង្វិលកង់របស់វា
នៅពេលតម្រង់វាទៅឧបករណ៍ សញ្ញាព្រួញនឹងបង្ហាញនៅលើអេក្រង់។
បើអ្នកចល័តតេឡេបញ្ជាពីចម្ងាយតាមទិសដៅដែលអ្នកចង់បាន សញ្ញាព្រួញនឹងទៅតាម
ចលនានោះ។

02 ចល័តសញ្ញាព្រួញទៅកាន់ទៅទីតាំងដែលអ្នកចង់បាន ហើយចុចប៊ូតុង **រង្វង់មូល (OK)**
ដើម្បីប្រតិបត្តិមុខងារ។

03 ប្រសិនបើមិនប្រើសញ្ញាព្រួញក្នុងរយៈពេលជាក់លាក់មួយ វានឹងបាត់។
នៅពេលបាត់សញ្ញាព្រួញពីអេក្រង់ សូមរលាក់ Magic Remote ទៅខាងស្តាំ និងខាងឆ្វេង។

បន្ទាប់មក វានឹងបង្ហាញឡើងវិញ។
ទស្សន៍ទ្រនិចនឹងបាត់ ប្រសិនបើអ្នកចុចប៊ូតុង ▲/▼/◀/▶
ហើយឧបករណ៍បញ្ជាពីចម្ងាយនឹងដំណើរការជាឧបករណ៍បញ្ជាពីចម្ងាយស្តង់ដារ។

04 អ្នកអាចបញ្ជាឧបករណ៍បានដោយរំកិល ឬចុចប៊ូតុង **រង្វង់មូល (OK)** នៅចំកណ្តាលប៊ូតុង ▲/▼/◀/▶។ នៅពេលមើលអេក្រង់ដែលតម្រូវឱ្យរំកិល អ្នកអាចផ្លាស់ទីឡើងលើ និងចុះក្រោមបានយ៉ាងងាយស្រួល ដោយរំកិលប៊ូតុង **រង្វង់មូល (OK)**។ នៅពេលមើលវីដេអូ អ្នកអាចចុចប៊ូតុង **រង្វង់មូល (OK)** ដើម្បីផ្អាក/ចាក់។

- ប្រសិនបើទស្សន៍ទ្រនិចមិនដំណើរការរលូនទេ
  អ្នកអាចកំណត់ទស្សន៍ទ្រនិចឡើងវិញដោយផ្លាស់ទីវាទៅគែមអេក្រង់។
- ប្រើឧបករណ៍បញ្ជាពីចម្ងាយនៅក្នុងចម្ងាយដែលអាចដំណើរការបាន (ក្នុងចម្ងាយ 10 ម៉ែត្រ)។
  ប្រសិនបើមានឧបសគ្គរវាងឧបករណ៍ និងតេឡេបញ្ជា វាអាចនឹងមិនដំណើរការត្រឹមត្រូវទេ។
- អាស្រ័យទៅតាមឧបករណ៍ភ្ជាប់ខាងក្រៅ (រ៉ោតទ័រឥតខ្សែ ម៉ាស៊ីនមីក្រូវ៉ែវ ។ល។)
  បញ្ហាក្នុងការទំនាក់ទំនងអាចនឹងកើតមានឡើង។
- ផលប៉ះពាល់អាចបណ្តាលឱ្យ Magic Remote ដំណើរការខុសប្រក្រតី។
- ពេលប្រើប្រាស់ Magic Remote សូមប្រុងប្រយ័ត្នកុំយកអោយប៉ះគ្រឿងសង្ហារឹម
  គ្រឿងអេឡិចត្រូនិក ឬប៉ះមនុស្សនៅជិតហ្នឹង។
- ដើម្បីទទួលបានព័ត៌មានលម្អិតអំពីការកំណត់រចនាសម្ព័ន្ធសញ្ញាព្រួញរបស់ Magic Remote
  សូមមើល **ការណែនាំសម្រាប់អ្នកប្រើប្រាស់** → **ការកំណត់** → **ប្រព័ន្ធ** → **ជម្រើសទ្រនិច**។


ការប្រើប្រាស់មុខងារឧបករណ៍តាមរយៈការនិយាយ

ការប្រើប្រាស់មុខងារឧបករណ៍តាមរយៈការនិយាយ

អ្នកអាចចូលប្រើមុខងារផ្សេងៗរបស់ឧបករណ៍បានយ៉ាងរហ័ស
និងងាយស្រួលតាមរយៈការស្គាល់ការនិយាយ។

01 ចុច ហើយសង្កត់ប៊ូតុង 🎙 នៅលើតេឡេ ហើយនិយាយមុខងារដែលអ្នកចង់ចាប់ផ្តើម ឬ
ពាក្យគន្លឹះដែលអ្នកចង់ប្រើប្រាស់សម្រាប់ការស្វែងរករបស់អ្នក។

02 នៅពេលអ្នកលែងប៊ូតុង 🎙 បន្ទាប់ពីបញ្ចូលការនិយាយរបស់អ្នក មុខងារដែលទាក់ទងត្រូវ
បានចាប់ផ្តើម។



- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- **ភាសាក្នុងម៉ឺនុយ (Menu Language)** ត្រូវតែកំណត់ជាភាសាផ្លូវការនៃប្រទេសនៅក្នុង **ទីតាំង** ដើម្បីមើលលទ្ធផលស្វែងរកដែលត្រឹមត្រូវ។ ប្រសិនបើ **ភាសាក្នុងម៉ឺនុយ (Menu Language)** មិនត្រូវបានកំណត់ជាភាសាផ្លូវការទេ មុខងារមួយចំនួនអាចនឹងត្រូវបានដាក់កំហិត។
- អ្នកអាចប្តូរភាសានៅក្នុង ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ភាសា (Language)** → **ភាសាក្នុងម៉ឺនុយ (Menu Language)**។
- ភាសាដែលអាចប្រើបានសម្រាប់លក្ខណៈពិសេសនៃការសម្គាល់សំឡេងអាចនឹងមានការផ្លាស់ប្តូរទៅតាមគោលការណ៍ប្រតិបត្តិការនៃសេវាកម្ម។
- សេចក្តីលម្អិតអំពីសេវាកម្មអាចនឹងខុសគ្នាទៅតាមម៉ូដែល។
- សូមចំណាំថា សេវាកម្មដែលបើកការបញ្ជាតាមសំឡេង ការសម្គាល់សំឡេង និងមុខងារឆ្លាតវៃផ្សេងទៀតអាចផ្លាស់ប្តូរ លុបចេញ ឬបញ្ឈប់ដោយក្រុមហ៊ុនផលិត ឬក្រុមហ៊ុនផ្តល់សេវាជាភាគីទីបីរបស់ខ្លួនដោយគ្មានការជូនដំណឹង។
- អ្នកអាចប្តូរការកំណត់ពាក់ព័ន្ធនឹងសំឡេង ឬមើលថាតើលក្ខណៈពិសេសណាខ្លះដែលអាចប្រើបានជាមួយសំឡេងនៅក្នុង ⚙ → ⚙ → **ទូទៅ** → **សេវាកម្ម AI** → **ការកំណត់ការសម្គាល់សំឡេង/ជំនួយសម្រាប់ការសម្គាល់សំឡេង**។

ការប្រើប្រាស់សំឡេងរបស់អ្នកជា **លេខសម្គាល់សំឡេង** របស់អ្នក

ចុះឈ្មោះសំឡេងរបស់អ្នកក្នុង **គណនី LG** របស់អ្នក។
យើងអាចស្គាល់អ្នកបានតាមរយៈសំឡេងដែលអ្នកបានចុះឈ្មោះ ដើម្បីផ្តល់ខ្លឹមសារ និងសេវាកម្មដែលមានលក្ខណៈផ្ទាល់ខ្លួន។

01 ចូល គណនី LG របស់អ្នក ដើម្បីចុះឈ្មោះសំឡេងរបស់អ្នក។

02 ជ្រើសរើស ⚙ → ⚙ → **ទូទៅ** → **សេវាកម្ម AI** → **ការកំណត់ការសម្គាល់សំឡេង**។

03 ជ្រើសរើស **លេខសម្គាល់សំឡេង** → **គ្រប់គ្រងលេខសម្គាល់សំឡេង**។

04 ចុច **ចុះឈ្មោះលេខសម្គាល់សំឡេង** រួចអនុវត្តតាមការណែនាំនៅលើអេក្រង់ ដើម្បីចុះឈ្មោះសំឡេងរបស់អ្នក។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ភាសាដែលអាចប្រើបានសម្រាប់មុខងារ **លេខសម្គាល់សំឡេង**

អាចមានការផ្លាស់ប្តូរទៅតាមគោលការណ៍ប្រតិបត្តិការនៃសេវាកម្ម។

- បន្ទាប់ពីចុះឈ្មោះសំឡេងរបស់អ្នកតាមរយៈ **គណនី LG** របស់អ្នកហើយ អ្នកត្រូវតែកំណត់ **ប្រើលេខសម្គាល់សំឡេងនៅលើទូរទស្សន៍នេះ** ទៅ **បើក** ដើម្បីប្រើវា។
- អ្នកអាចចុះឈ្មោះ ចុះឈ្មោះឡើងវិញ ឬលុបសំឡេងរបស់អ្នកចេញពី **លេខសម្គាល់សំឡេង** បាននៅក្នុង ⚙ → ⚙ → **ទូទៅ** → **សេវាកម្ម AI** → **ការកំណត់ការសម្គាល់សំឡេង**។
- តាមរយៈ **លេខសម្គាល់សំឡេង** អ្នកមិនចាំបាច់បញ្ចូលពាក្យសម្ងាត់របស់អ្នកនៅពេលដែលអ្នកប្តូរគណនីនោះទេ។
- អ្នកដែលមានសំឡេងស្រដៀងអ្នកអាចដោះសោឧបករណ៍បានហើយប្រសិនបើសំឡេងរបស់អ្នកប្លែកដោយសារតែបញ្ហាសុខភាពនោះប្រហែលជាមិនស្គាល់សំឡេងរបស់អ្នកទេ។

ការប្រើមុខងារសម្គាល់ការនិយាយដោយប្រើកម្មវិធី LG ThinQ

អ្នកអាចប្រើមុខងារសម្គាល់ការនិយាយដោយចុចប៊ូតុង 🎙 នៅលើកម្មវិធី LG ThinQ ដែលបានដំឡើងនៅលើឧបករណ៍ឆ្លាតវៃរបស់អ្នក។
ដើម្បីភ្ជាប់ឧបករណ៍ឆ្លាតវៃរបស់អ្នកទៅឧបករណ៍ដោយប្រើកម្មវិធី LG ThinQ សូមមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយប្រើ LG ThinQ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- នៅពេលប្រើមុខងារសម្គាល់ការនិយាយតាមរយៈកម្មវិធី LG ThinQ មុខងារឬឧបករណ៍មួយចំនួនអាចនឹងមិនដំណើរការទេ។

ការប្រុងប្រយ័ត្នចំពោះការស្គាល់សម្តី

- ដើម្បីប្រើមុខងារសម្គាល់សំឡេងអ្នកត្រូវតែប្រើ Magic Remote។
អ្នកត្រូវតែកំណត់ប៉ុស្តិ៍ តំបន់ ។ល។ ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
អ្នកត្រូវតែភ្ជាប់ទៅបណ្តាញ។ អ្នកត្រូវតែយល់ព្រមតាមលក្ខខណ្ឌប្រើប្រាស់មុខងារសម្គាល់សំឡេងនៅពេលដែលអ្នកភ្ជាប់ទៅបណ្តាញ។
- ដើម្បីគ្រប់គ្រងប្រអប់ចាប់ប៉ុស្តិ៍ដែលបានភ្ជាប់ជាមួយឧបករណ៍តាមរយៈមុខងារសម្គាល់សំឡេងអ្នកត្រូវតែកំណត់តេឡេបញ្ជាដែលបានរួមបញ្ចូលនៅក្នុង ⚙ → ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់អង្គបញ្ជាសកល**។
យើងសូមណែនាំឱ្យតម្រង់សញ្ញាព្រួញរបស់ Magic Remote ទៅកាន់ប្រអប់ចាប់ប៉ុស្តិ៍បន្ទាប់ពីបញ្ចូលសំឡេងហើយ។
- អត្រានៃការសម្គាល់ការនិយាយអាចខុសគ្នាទៅតាមលក្ខណៈរបស់អ្នកប្រើប្រាស់ (កម្រិតសំឡេង ការបញ្ចេញសំឡេង តុងសំឡេង និងល្បឿននិយាយ) និងមជ្ឈដ្ឋានជុំវិញ (សំឡេងរំខាន និងកម្រិតសំឡេងឧបករណ៍)។
ដើម្បីទទួលបានការសម្គាល់ការនិយាយរបស់អ្នកបានត្រឹមត្រូវ
អ្នកត្រូវតែបញ្ចេញសំឡេងរបស់ពាក្យងឺតៗ
និងត្រឹមត្រូវតាមកម្រិតសំឡេងសមរម្យនៅចម្ងាយប្រហែល 10 cm ពីមីក្រូហ្វូនរបស់ Magic Remote។
- បើគ្មានការនិយាយរបស់អ្នកឲ្យបានត្រឹមត្រូវទេនោះ មុខងារស្គាល់សម្តីនិយាយអាចដំណើរការខុសគ្នាពីអ្វីដែលអ្នកចង់បានខាងដើម។


ការបម្លែងពីការនិយាយទៅជាអត្ថបទ

ការប្រើសម្តីទៅអត្ថបទ

អ្នកអាចបញ្ចូលអត្ថបទក្នុងវាលអត្ថបទ ដោយប្រើប្រាស់មុខងារស្គាល់ការនិយាយ។
ជ្រើសរើសប៊ូតុង 🎙 នៅលើក្តារចុចលើអេក្រង់ ដើម្បីប្តូរទៅទម្រង់បញ្ចូលការនិយាយ។


- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

01 សូមរំកិលសញ្ញាព្រួញរបស់ Magic Remote ទៅក្នុងប្រអប់អត្ថបទដើម្បីបើកក្តារចុចនិម្មិត។




02 ចុចប៊ូតុង 🎙 លើក្តារចុចជាក់ស្តែង។

03 បន្ទាប់ពីបើកផ្ទាំងព័ត៌មានចំណាំសំឡេង ដូចបង្ហាញនៅខាងក្រោម និយាយដាក់ មីក្រូហ្វូន លើឧបរណ៍បញ្ជា យឺតៗ និងច្បាស់ៗ។





04 ប្រសិនបើមានពាក្យស្រដៀងគ្នាដែលអ្នកបាននិយាយឮៗ អ្នកអាចឃើញបញ្ជីលទ្ធផលជាច្រើនដូចបានបង្ហាញខាងក្រោម។
ប្រសិនបើអ្នកមិនទទួលបានលទ្ធផលដែលអ្នកចង់បាន ចុច **ព្យាយាមម្តងទៀត**។
ជ្រើសរើសលទ្ធផល ហើយវានឹងបង្ហាញលើប្រអប់អត្ថបទ។



ការប្រុងប្រយត្នពេលប្រើប្រាស់សម្តីទៅជាអត្ថបទ

- ពិនិត្យការផ្ទាប់បណ្តាញ មុនពេលប្រើប្រាស់មុខងារសម្តីទៅជាអត្ថបទ។
- អ្នកអាចប្តូរភាសានៅក្នុង ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ភាសា (Language)** → **ភាសាក្នុងម៉ឺនុយ (Menu Language)**។ ដើម្បីប្តូរទៅជាភាសាចំណាំពាក្យសម្តីមួយផ្សេងទៀតជាអចិន្ត្រៃយ៍ ចុចប៊ូតុងក្រហម នៅក្នុងផ្ទាំងបង្ហាញព័ត៌មានចំណាំសំឡេងដែល។
- អ្នកអាចប្រើប្រាស់មុខងារនេះ នៅពេលអ្នកយល់ព្រមនឹងលក្ខខណ្ឌការសម្គាល់សំឡេង។
- អត្រានៃការសម្គាល់ការនិយាយអាចខុសគ្នាទៅតាមលក្ខណៈរបស់អ្នកប្រើប្រាស់ (កម្រិតសំឡេង ការបញ្ចេញសំឡេង តុងសំឡេង និងល្បឿននិយាយ) និងមជ្ឈដ្ឋានជុំវិញ (សំឡេងរំខាន និងកម្រិតសំឡេងឧបករណ៍)។
- ដើម្បីកែលម្អកម្រិតត្រឹមត្រូវនៃការបំប្លែងការនិយាយទៅជាអត្ថបទ អ្នកត្រូវតែនិយាយឱ្យច្បាស់ និងឮៗនៅចម្ងាយប្រហែល 10 cm (4 អ៊ីញ) ពីមីក្រូហ្វូន Magic Remote។
- ការចំណាំសំឡេងមិនអាចប្រើបាននៅក្នុងចន្លោះដាក់លេខសម្ងាត់ និងរបាអាសយដ្ឋាននៃ **កម្មវិធីរុករកលើអ៊ីនធឺណិត** របស់អ្នកទេ (លើកលែងតែការស្វែងរកទូទៅ)។

របៀបប្រើ Alexa នៅលើឧបករណ៍

របៀបប្រើ Alexa នៅលើឧបករណ៍

ជាដំបូង ត្រូវធានាថា Alexa ត្រូវបានរៀបចំនៅលើឧបករណ៍របស់អ្នក។ ដើម្បីចាប់ផ្តើម សូមចុចប៊ូតុង alexa (Alexa) នៅលើ Magic Remote របស់អ្នក។ អំឡុងពេលរៀបចំ អ្នកនឹងចូលគណនី Alexa របស់អ្នក ធ្វើការបញ្ជាសាកល្បងរហ័ស ដើម្បីប្រាកដថា Alexa ដំណើរការ ហើយអ្នកអាចចាប់ផ្តើមបាន។

ដើម្បីប្រើ Alexa សូមចុចប៊ូតុង alexa (Alexa) ឱ្យជាប់នៅលើ Magic Remote របស់អ្នក។ នៅពេលរូបមានចលនាពណ៌ខៀវបង្ហាញនៅខាងក្រោមអេក្រង់របស់អ្នក សូមនិយាយពាក្យបញ្ជាដូចជា “Alexa បើក Prime Video។”

ចុចប៊ូតុង alexa (Alexa) នៅលើ Magic Remote របស់អ្នកម្តង (មិនចាំបាច់ចុចឱ្យជាប់) ដើម្បីចូលប្រើកម្មវិធី Alexa នៅលើឧបករណ៍របស់អ្នក។ នៅទីនេះ អ្នកនឹងរកឃើញវិធីច្រើនទៀតក្នុងការប្រើ Alexa ក៏ដូចជាការកំណត់មុខងារដូចជា ការបើកជម្រើសដោយមិនប្រើដៃ (ប្រសិនបើមាន)។

- Alexa មិនមានជាភាសា និងក្នុងប្រទេសទាំងអស់ទេ។
- លក្ខណៈពិសេស និងមុខងារ Alexa អាចខុសគ្នាទៅតាមទីតាំង។

ការប្រើ សកម្មភាពច្រើនទៀត

ការប្រើ សកម្មភាពច្រើនទៀត

អ្នកអាចគ្រប់គ្រងមុខងារច្រើនទៀត ឬឧបករណ៍ខាងក្រៅដែលបានភ្ជាប់ជាមួយផលិតផលរបស់អ្នកដោយប្រើប៊ូតុងដែលបង្ហាញនៅលើអេក្រង់។

01 ចុចប៊ូតុង ••• លើតេឡេ។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

02 ដោយប្រើតេឡេបញ្ជា សូមជ្រើសរើសប៊ូតុងដែលអ្នកពេញចិត្តនៅលើ **សកម្មភាពច្រើនទៀត** ដែលបង្ហាញនៅលើអេក្រង់។

- ប្រភេទប៊ូតុងដែលលេចឡើងនៅលើ **សកម្មភាពច្រើនទៀត** មានលក្ខណៈខុសគ្នា អាស្រ័យទៅតាមតំបន់ និងប្រភេទឧបករណ៍ដែលបានភ្ជាប់។

ការកំណត់ការបញ្ចាសកល

ការកំណត់ការបញ្ចាសកល

នៅពេលអ្នករៀបចំតេឡេបញ្ចាជាសកល អ្នកអាចគ្រប់គ្រងឧបករណ៍ភ្ជាប់ខាងក្រៅ (ម៉ាស៊ីនចាក់ Blu-ray/ DVD, ភាពយន្តនៅផ្ទះ ប្រអប់ចាប់ប៉ុស្តិ៍ ។ល។) ដោយប្រើ Magic Remote ជាជាងប្រើតេឡេបញ្ចាដែលពួកគេបានកំណត់។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- មុខងារនេះអាចប្រើតែជាមួយ Magic Remote ប៉ុណ្ណោះ។
  អ្នកអាចទិញ Magic Remote ដាច់ដោយឡែកបាន ប្រសិនបើមិនមានផ្តល់ជូន។
  ម៉ូដែលមួយចំនួនអាចឱ្យអ្នកភ្ជាប់ជាមួយឧបករណ៍បញ្ជា IR ដែលបានផ្តល់ជូន
  ដែលអាចឱ្យប្រើតេឡេបញ្ចាទូទៅបានដោយកំណត់តេឡេបញ្ចាដែលបានរួមបញ្ចូល។
- នៅពេលប្តូរការកំណត់នៅលើឧបករណ៍ណាមួយ ត្រូវប្រាកដថាបើកឧបករណ៍នោះជាមុនសិន។
- ដើម្បីរៀបចំតេឡេបញ្ចាសកលដោយប្រើព័ត៌មានចុងក្រោយបំផុត សូមភ្ជាប់បណ្តាញ រួចទទួលយក
  កិច្ចព្រមព្រៀងអ្នកប្រើប្រាស់។
- សម្រាប់ម៉ាស៊ីនលេងហ្គេម
  វាមិនស្គាល់លក្ខណៈពិសេសនៃការកំណត់ដោយផ្ទាល់សម្រាប់តេឡេបញ្ចាសកលទេ។
- ប៊ូតុងមួយចំនួនអាចមិនដំណើរការ អាស្រ័យលើម៉ូដែលនៃឧបករណ៍ខាងក្រៅនោះ។
- តម្រង់ Magic Remote ឱ្យចំឧបករណ៍ដែលអ្នកចង់បញ្ជា។ ត្រូវប្រាកដថា
  មិនមានវត្ថុនៅពីមុខឧបករណ៍ទេ ដើម្បីធានាថាអាចទទួលរលកសញ្ញាតេឡេបញ្ចាបានល្អ។

ការកំណត់តេឡេបញ្ចាសកលដោយស្វ័យប្រវត្តិ

ភ្ជាប់ឧបករណ៍ដែលត្រូវកំណត់ទៅ HDMI របស់ឧបករណ៍ រួចបើកថាមពលឧបករណ៍។
ឧបករណ៍នេះនឹងស្គាល់ឧបករណ៍ដែលបានភ្ជាប់ ដើម្បីកំណត់តេឡេបញ្ចាសកលដោយស្វ័យប្រវត្តិ
ដោយមិនចាំបាច់កំណត់ដោយផ្ទាល់។

- បន្ទាប់ពីកំណត់តេឡេបញ្ចាសកលរួចហើយ
  នោះអ្នកអាចនឹងត្រូវធ្វើការកំណត់អ្នកប្រើប្រាស់បន្ថែមមួយចំនួនទៀត។
- វាអាចចំណាយពេលពីរបីវិនាទី ដើម្បីបញ្ចប់ការកំណត់សម្រាប់តេឡេបញ្ចាសកល។
- ក្នុងម៉ូឌែលមួយចំនួន អ្នកអាចកំណត់តេឡេបញ្ចាសកលបាន
  បន្ទាប់ពីបានប្តូរវាទៅជាធាតុបញ្ចូលនៃឧបករណ៍ដែលបានភ្ជាប់ប៉ុណ្ណោះ។
- អាស្រ័យលើឧបករណ៍ដែលបានភ្ជាប់
  វាអាចនឹងមិនស្គាល់លក្ខណៈពិសេសនៃការកំណត់ដោយស្វ័យប្រវត្តិសម្រាប់តេឡេបញ្ចាសកល
  (ការភ្ជាប់ឧបករណ៍ដោយស្វ័យប្រវត្តិ) ទេ។

ការកំណត់តេឡេបញ្ចាសកលដោយផ្ទាល់

នៅពេលយើង ប្រើ mouse អត់ខ្សែ ការតភ្ជាប់អាចដាច់ឬយឺត

វាអាស្រ័យទៅលើចម្ងាយរវាងទូរទស្សន៍និង mouse របស់អ្នក។

01 ជ្រើសរើស ⚙ → ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់អង្គបញ្ជាសកល**។

02 ជ្រើសរើស HDMI ដែលបានភ្ជាប់ជាមួយឧបករណ៍ដែលអ្នកចង់កំណត់ រួចជ្រើសរើស **គ្រប់គ្រងការកំណត់**។

03 ចុចប៊ូតុង**ចាប់ផ្តើមការកំណត់**
ដើម្បីកំណត់តេឡេបញ្ជាដែលបានរួមបញ្ចូលថ្មីដោយអនុវត្តតាមការណែនាំនៅលើអេក្រង់។
អ្នកអាចទាញយកតេឡេបញ្ជាដែលបានរួមបញ្ចូលដែលបានកំណត់ពីមុនបានពី **មើលប្រវត្តិការកំណត់**។

- ដើម្បីលុបការកំណត់តេឡេបញ្ជាដែលបានរួមបញ្ចូល សូមជ្រើសរើស **លុបការកំណត់** ពី **គ្រប់គ្រងការកំណត់** នៃ HDMI ដែលចង់ប្រើ។

ការប្រើ មុខងារចូលប្រើរហ័ស

ការប្រើកម្មវិធីនានាបានយ៉ាងលឿន និងងាយស្រួលជាមួយនឹង មុខងារចូលប្រើរហ័ស។

ចុច ហើយសង្កត់ប៊ូតុងលេខមួយលើតេឡេបញ្ជាដើម្បីបើកកូនកម្មវិធីមួយ ឬដើម្បីដាក់ឲ្យសកម្មនូវទិន្នន័យបញ្ចូលខាងក្រៅដែលបានចុះបញ្ជីចំពោះប៊ូតុង។

Magic Link

01 ចាប់ផ្តើមកម្មវិធី ឬជ្រើសរើសប៉ុស្តិ៍ ឬបញ្ចូលអ្វីដែលអ្នកចង់ផ្តល់។

- ធាតុដែលអាចចុះឈ្មោះទៅប៊ូតុងផ្លូវកាត់មានភាពខុសគ្នាទៅតាមម៉ូដែល។

02 ចុច ហើយសង្កត់ប៊ូតុងលេខ (1~8) ដែលអ្នកចង់ចុះឈ្មោះ។
លេខ 9 ត្រូវបានកំណត់ទៅ **Quick Help**។

03 នៅពេលដែលវីនដូផុសឡើងសម្រាប់ការចុះឈ្មោះលេចចេញមក ជ្រើសរើសចុច **បាទ/ចាស**។

- បើអ្នកចុច ហើយសង្កត់លើប៊ូតុងលេខមួយដែលមានចុះឈ្មោះរួចហើយ នឹងមានការបំពេញមុខងារដែលបានចុះបញ្ជី។
- ដើម្បីពិនិត្យមើលធាតុដែលអាចមានការចុះឈ្មោះបាន ជ្រើសរើសលេខតួលេខមួយដែលមិនទាន់មានការចុះបញ្ជីនៅក្នុងម៉ូដកែសម្រួល **មុខងារចូលប្រើរហ័ស**។
- បើអ្នកកំពុងស្ថិតក្នុងម៉ូដមួយដែល **មុខងារចូលប្រើរហ័ស** មិនអាចដំណើរការបាន នឹងមិនមានការបំពេញសកម្មភាពអ្វីឡើយ។
- បើអ្នកលុបកូនកម្មវិធីដែលបានចុះឈ្មោះ **មុខងារចូលប្រើរហ័ស** នឹងមានការលុបចេញពីបញ្ជីវិញយ៉ាងដូច្នោះដែរ។

ការពិនិត្យមើល និងការកែសម្រួល **មុខងារចូលប្រើរហ័ស**។

ចុច ហើយសង្កត់ឲ្យយូរលើប៊ូតុងលេខ **0** ដែលលើតេឡេបញ្ជាពីចម្ងាយរបស់អ្នក។
អេក្រង់កែសម្រួល **មុខងារចូលប្រើរហ័ស** លេចចេញមក។



❶ ការជ្រើសរើសតួលេខមួយដែលមានការចុះឈ្មោះរួចហើយ នឹងបើកឲ្យមានការលុបវាចេញពីបញ្ជីវិញ។

❷ នៅពេលដែលអ្នកជ្រើសរើសតួលេខមួយដែលមិនទាន់មានការចុះឈ្មោះធាតុនានាដែលអាចមានការចុះបញ្ជីបាន នឹងមានការបង្ហាញឲ្យឃើញ។

- ធាតុមួយដែលមានការចុះឈ្មោះហើយទៅនឹងតួលេខមួយផ្សេងទៀត មានការបញ្ជាក់ប្រាប់ដោយសញ្ញាគូសធីក។

❸ អ្នកអាចមើលសេចក្តីណែនាំសង្ខេបសម្រាប់មុខងារនេះបាន។

ការភ្ជាប់ទៅ SIMPLINK (HDMI-CEC)

កំពុងប្រើ SIMPLINK

អ្នកអាចគ្រប់គ្រងឧបករណ៍បានយ៉ាងងាយស្រួលដូចជា របារសំឡេង
ប្រអប់ចាប់ប៉ុស្តិ៍ដែលបានភ្ជាប់តាមរយៈ HDMI ដែលមានតេឡេបញ្ជាតែមួយ។

- អាចភ្ជាប់ឧបករណ៍បានរហូតដល់បី និងអាចប្រើដំណាលគ្នាបាន។

01 ភ្ជាប់រន្ធបញ្ចេញ SIMPLINK HDMI ជាមួយរន្ធ HDMI ដោយប្រើខ្សែ HDMI។
02 ចុចប៊ូតុង ⚙ លើតេឡេ។
03 ជ្រើសរើស ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់ HDMI**។
04 កំណត់ **SIMPLINK (HDMI-CEC)** ទៅ **បើក**។

05 បើកថាមពលឧបករណ៍ដែលបានភ្ជាប់។
នៅពេលវាត្រូវបានភ្ជាប់ជាមួយឧបករណ៍ដោយស្វ័យប្រវត្តិ
ធាតុបញ្ចូលខាងក្រៅត្រូវបានផ្លាស់ប្តូរ។
ប្រសិនបើមិនបានភ្ជាប់ឧបករណ៍ដោយស្វ័យប្រវត្តិទេ សូមចុចប៊ូតុង
រួចជ្រើសរើសឧបករណ៍ដែលអ្នកចង់ភ្ជាប់។

- មុខងារនេះដំណើរការជាមួយតែឧបករណ៍ដែលមានឡូហ្គោ SIMPLINK ប៉ុណ្ណោះ។ សូមពិនិត្យឡូហ្គោ SIMPLINK លើឧបករណ៍ភ្ជាប់ខាងក្រៅ។
ការប្រើប្រាស់ផលិតផលក្រៅពីផលិតផលដែលបានបញ្ជាក់អាចបណ្តាលឱ្យមានបញ្ហាអំឡុងពេលប្រតិបត្តិការ។
- ដើម្បីប្រើ SIMPLINK អ្នកចាំបាច់ត្រូវប្រើខ្សែ HDMI® ដែលមានល្បឿនលឿនជាមួយមុខងារ CEC (Consumer Electronics Control)។ ខ្សែ HDMI® ដែលមានល្បឿនលឿនមានកន្លែងភ្ជាប់ទី 13 សម្រាប់អនុញ្ញាតឱ្យផ្លាស់ប្តូរព័ត៌មានរវាងឧបករណ៍នានា។
- ដើម្បីបញ្ចេញសំឡេងពីឧបករណ៍សំឡេងខាងក្រៅ សូមភ្ជាប់ឧបករណ៍សំឡេងជាមួយរន្ធ HDMI របស់ឧបករណ៍ដោយប្រើខ្សែ HDMI។ កំណត់ **សំឡេងចេញ** ទៅ **ឧបករណ៍ HDMI(ARC)**និងកំណត់ **SIMPLINK (HDMI-CEC)** ទៅ **បើក**។

មុខងារ SIMPLINK ដែលអាចប្រើបាន

លេងភ្លាមៗ

នៅពេលអ្នកចាប់ផ្តើមឧបករណ៍ចាក់មេឌៀបានច្រើន អ្នកអាចមើលមាតិកាភ្លាមៗពីឧបករណ៍នៅលើអេក្រង់ដោយមិនចាំបាច់បញ្ជាអ្វីទាំងអស់។

ការបញ្ជាឧបករណ៍ដោយប្រើតេឡេបញ្ជា

អនុញ្ញាតឱ្យអ្នកប្រើប្រាស់បញ្ជាឧបករណ៍ពហុមេឌៀដោយប្រើតេឡេបញ្ជាដែលបានផ្តល់ជូនដើម្បីទស្សនាខ្លឹមសារ។

- ម៉ឺនុយឧបករណ៍ពហុមេឌៀអាចដំណើរការជាមួយគ្រាប់ចុចព្រួញនៅលើតេឡេបញ្ជា។

បិទថាមពលមេ

ការបិទឧបករណ៍ក៏នឹងបិទឧបករណ៍ដែលភ្ជាប់តាមរយៈ SIMPLINK ផងដែរ។

- មុខងារនេះមាននៅក្នុងឧបករណ៍ជាក់លាក់ប៉ុណ្ណោះ។

បើកថាមពលមេ

ការបើកឧបករណ៍ SIMPLINK ក៏នឹងបើកឧបករណ៍នេះផងដែរ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការប្រើប្រាស់ក្តារចុច ម៉ៅស៍ និងដែហ្គេម

ការភ្ជាប់ជាមួយក្តារចុច ម៉ៅស៍ និងដៃហ្គេម

អ្នកអាចបញ្ចូលអក្សរ ឬផ្លាស់ទីទស្សន៍ទ្រនិចសម្រាប់ប្រតិបត្តិការដោយភ្ជាប់ជាមួយក្តារចុច ឬម៉ៅស៍។
អ្នកអាចលេងហ្គេមសម្រាប់លេងតែជាមួយដៃហ្គេមបានដោយភ្ជាប់ជាមួយដៃហ្គេម។

ការភ្ជាប់ជាមួយរន្ធ USB ដោយប្រើខ្សែ ឬមិនប្រើខ្សែ

ភ្ជាប់ម៉ៅស៍ ក្តារចុច ឬដៃហ្គេមរបស់អ្នកជាមួយរន្ធ USB។

- សូមណែនាំអ្នកឱ្យប្រើផលិតផលដែលបានធ្វើតេស្តលើភាពត្រូវគ្នាជាមួយឧបករណ៍នេះ។
  ក្តារចុច : Logitech K360, Logitech K400, Logitech K750
  ដៃហ្គេម : Sony DualShock 4, Sony DualShock 3, Sony DualSense Controller, Sony DualSense Edge Controller, Microsoft Xbox 360 Controller, Microsoft Xbox Adaptive Controller, NVIDIA SHIELD Controller, Logitech F310, Logitech F710, Amazon Luna Controller, Shaks S3b, Shaks S2b, Nintendo Switch Pro Controller, MOGA XP5-X Plus Controller
- ការតភ្ជាប់អាចនឹងដាច់ ឬដើរយឺតដោយផ្អែកលើចម្ងាយ និងមជ្ឈដ្ឋានឥតខ្សែ។
- ប៊ូតុងម៉ៅស៍ខាងស្តាំ និងប៊ូតុងម៉ៅស៍ពិសេសប្រហែលជាមិនដំណើរការទេ។
- ការបញ្ចូលក្តារចុចអាចមានកំណត់នៅលើអេក្រង់មួយចំនួន។
- អ្នកអាចប្តូរភាសាបញ្ចូលដោយចុចលើគ្រាប់ចុចប្តូរភាសា ឬគ្រាប់ចុច Alt ខាងស្តាំ ហើយក៏អាចប្តូរបានផងដែរដោយចុចគ្រាប់ចុច Ctrl និងគ្រាប់ចុចដកឃ្លាក្នុងពេលតែមួយ។
- ដើម្បីបញ្ចូលអក្សរនៅក្នុងកន្លែងបញ្ចូលអក្សរ សូមប្រើក្តារចុចនៅលើអេក្រង់ ឬក្តារចុច USB។
- អ្នកអាចប្រើប៊ូតុងដៃហ្គេមដែលបានភ្ជាប់ ជាប៊ូតុងគេឡេបញ្ជា។ ប្រតិបត្តិការ ឬឈ្មោះរបស់ប៊ូតុងអាចខុសគ្នាទៅតាមម៉ូដែលដៃហ្គេម។
  ប៊ូតុងនិមិត្តសញ្ញា : ចាប់ផ្តើម **ហ្គេម**។
  ដងកាន់ខាងឆ្វេង : អ្នកអាចផ្លាស់ទីបានទាំងបួនទិសដៅ។
  ដងកាន់ខាងស្តាំ : អ្នកអាចប្តូរប៉ុស្តិ៍ ឬកម្រិតសំឡេងបាន។
  ប៊ូតុង A : ជ្រើសរើសធាតុដែលត្រូវគ្នា។
  ប៊ូតុង B : ត្រឡប់ទៅអេក្រង់មុន។

ការភ្ជាប់តាមរយៈ Bluetooth

អ្នកអាចភ្ជាប់ និងប្រើឧបករណ៍បញ្ចូលដូចជា ដៃហ្គេម កណ្តុរ ឬក្តារចុចដែលអាចប្រើ Bluetooth។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **ឧបករណ៍ខាងក្រៅ** → **ភ្ជាប់ឧបករណ៍បញ្ជាតាម Bluetooth** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការប្រើប្រាស់មីក្រូហ្វូនបញ្ចូល USB

ការប្រើប្រាស់មីក្រូហ្វូនបញ្ចូល USB


ភ្ជាប់មីក្រូហ្វូនរបស់អ្នកជាមួយរន្ធ USB។
អ្នកអាចរីករាយនឹងខ្លឹមសារផ្តាច់មុខសម្រាប់មីក្រូហ្វូន។

រីករាយនឹង Live Channel

ការប្រើ មុឺនុយផ្សាយផ្ទាល់

ការប្រើ មុឺនុយផ្សាយផ្ទាល់

អ្នកអាចប្រើមុខងារដែលពាក់ព័ន្ធយ៉ាងងាយស្រួល នៅពេលកំពុងទស្សនាការផ្សាយ។
ចុចប៊ូតុង **GUIDE** នៅលើ Magic Remote ឱ្យជាប់។
ឬចុចប៊ូតុង **LIST** នៅលើតេឡេបញ្ជាស្តង់ដារ។



❶ **ការណែនាំ** : អ្នកអាចមើលកម្មវិធី និងពេលវេលារបស់កម្មវិធីនីមួយៗ។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយនឹង Live Channel** → **ការមើល ការណែនាំ** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❷ **ប៉ុស្តិ៍** : មើលតារាងមាតិកាផ្សព្វផ្សាយដែលកំពុងតែចាក់ផ្សាយ។

❸ **កម្មវិធីកាលវិភាគទូរទស្សន៍** : អ្នកអាចបញ្ចូលម៉ោង និងកាលបរិច្ឆេទនៃកម្មវិធី ដើម្បីកំណត់កាលវិភាគសម្រាប់មើល ឬថតវា នៅក្នុងពេលកំណត់ណាមួយ។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយនឹង Live Channel** → **ការប្រើកម្មវិធីកាលវិភាគទូរទស្សន៍** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❹ **ការថត** : អ្នកអាចពិនិត្យមើលការថតដែលផ្ទុកនៅក្នុងឧបករណ៍ផ្ទុក និងចាក់ការថតបាន។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយនឹង Live Channel** → **ការបើកស្តាប់ការថត** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- ម៉ឺនុយលេចឡើង ក្នុងករណីដែលបានភ្ជាប់ឧបករណ៍ផ្ទុកខាងក្រៅ និងអាចមើលវីដេអូដែលបានថតតែប៉ុណ្ណោះ។

- ប៉ុស្តិ៍ដែលបង្ហាញនៅក្នុងបញ្ជីប៉ុស្តិ៍ត្រូវបានផ្តល់ជូនដោយក្រុមហ៊ុនផ្សាយ ដូច្នេះប្រសិនបើក្រុមហ៊ុនផ្សាយនោះប្តូរការកំណត់រចនាសម្ព័ន្ធប៉ុស្តិ៍ដោយគ្មានការជូនដំណឹងជាមុន ប៉ុស្តិ៍មួយចំនួននៅក្នុងបញ្ជីនោះអាចខុសគ្នាពីប៉ុស្តិ៍របស់ឧបករណ៍ជាក់ស្តែង។
- ដោយសារព័ត៌មានរបស់ប៉ុស្តិ៍ដែលបង្ហាញនៅក្នុងបញ្ជីប៉ុស្តិ៍មានព័ត៌មានដែលផ្តល់ដោយអ្នកផ្តល់ Electronic Program Guide (EPG) ខាងក្រៅ វាអាចខុសពីប៉ុស្តិ៍ទូរទស្សន៍ជាក់ស្តែង។
- អ្នកត្រូវបញ្ចប់ការកំណត់បណ្តាញ ការកំណត់តំបន់ និងការកំណត់ប៉ុស្តិ៍ស្វ័យប្រវត្តិ ទើបអាចទទួលសេវានៃការផ្សាយផ្ទាល់ធម្មតាបាន។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការមើល ការណែនាំ


ការមើល ការណែនាំ

អ្នកអាចមើលកម្មវិធី និងពេលវេលារបស់កម្មវិធីនីមួយៗ។

01 ដំណើរការ **Live TV** ដោយចុច ⏎។

02 ចុចប៊ូតុង ••• លើតេឡេបញ្ជា រួចជ្រើសរើស **ការណែនាំ** លើអេក្រង់។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។



❶ ជ្រើសរើសផ្នែកនីមួយៗ ដើម្បីចូលប្រើលក្ខណៈពិសេសដែលត្រូវគ្នា។

❷ អ្នកមើលព័ត៌មាននៅលើប៉ុស្តិ៍ និងកម្មវិធីផ្សាយបាន។

❸ អ្នកអាចមើលត្រួសៗលើទំព័រផ្សេងៗដោយចុចប៊ូតុង (**ប៉ុស្តិ៍**) ∧/∨ លើតែឡេបញ្ជាបានផងដែរ។ ជ្រើសរើសប៊ូតុង ⓘ ឬចំណងជើងរបស់កម្មវិធីដែលត្រូវការ។ អ្នកអាចមើលព័ត៌មានអំពីកម្មវិធី និងប្រតិបត្តិការ **ទស្សនា**/**ថត** (មានសម្រាប់តែម៉ូឌែលជាក់លាក់ប៉ុណ្ណោះ) ឬ **ការរំលឹក**/**ការថតដែលបានកំណត់ពេល** (មានសម្រាប់តែម៉ូឌែលជាក់លាក់ប៉ុណ្ណោះ) ។ល។

❹ ផ្លាស់ទីទៅផ្នែកខាងលើនៃបញ្ជីកម្មវិធី។

❺ អ្នកនឹងត្រូវបាននាំទៅបញ្ជីកម្មវិធីសម្រាប់ពេលវេលា និងកាលបរិច្ឆេទបច្ចុប្បន្ន។

❻ អាចកំណត់ប្រភេទប៉ុស្តិ៍ដែលបានបង្ហាញនៅលើអេក្រង់បាន។

❼ បង្ហាញប្រភេទដែលបានជ្រើសរើសនៅក្នុង**ការណែនាំ** ជាមួយពណ៌។

❽ អ្នកអាចមើលព័ត៌មានអំពីកម្មវិធីដែលអ្នកកំពុងមើលក៏ដូចជាព័ត៌មានរបស់កម្មវិធីដែលចង់មើល។

❾ **កម្មវិធីគ្រប់គ្រងប៉ុស្តិ៍** : ចាប់ផ្តើម **កម្មវិធីគ្រប់គ្រងប៉ុស្តិ៍**។
ជួរប៉ុស្តិ៍ : អ្នកអាចប្តូរទំហំបញ្ជីកម្មវិធី ដើម្បីកែតម្រូវចំនួនប៉ុស្តិ៍បានបង្ហាញនៅលើអេក្រង់។
តម្រង : អាចកំណត់ប្រភេទប៉ុស្តិ៍ដែលបានបង្ហាញនៅលើអេក្រង់បាន។
ទូរទស្សន៍តូច : អាចបិទ ឬបើកអេក្រង់ ដើម្បីមើលប៉ុស្តិ៍ដែលបានជ្រើសរើសបាន។
ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

❿ បិទកម្មវិធី។

- ព័ត៌មានកម្មវិធីមិនត្រូវបានបង្ហាញសម្រាប់ប៉ុស្តិ៍ដែលគ្មានព័ត៌មានប្រកាសដែលបានផ្តល់ឲ្យនោះទេ។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល ឬប្រទេស។

ការណែនាំអំពីការមើលប្រអប់ចាប់ប៉ុស្តិ៍

បន្ទាប់ពីភ្ជាប់ប្រអប់ចាប់ប៉ុស្តិ៍ អ្នកអាចមើលកម្មវិធី និងកំណត់កាលវិភាគប្រអប់ចាប់ប៉ុស្តិ៍ ព្រមទាំងប្រើ Magic Remote។


- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការពិនិត្យមើលព័ត៌មានអំពីប៉ុស្តិ៍

ការមើលព័ត៌មានអំពីកម្មវិធី

នៅពេលកំពុងមើលការផ្សាយផ្ទាល់ សូមចុចប៊ូតុង **រង្វង់មូល (OK)**។ បដាប៉ុស្តិ៍នឹងបង្ហាញ។ អ្នកអាចប្តូរទីតាំងរបស់ផ្ទាំងផ្សព្វផ្សាយដោយចុចប៊ូតុង ••• នៅលើតេឡេបញ្ជា រួចជ្រើសរើស **ប្តូរទីតាំងផ្ទាំងផ្សព្វផ្សាយ**។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។



❶ វាបង្ហាញព័ត៌មានអំពីកម្មវិធីដែលអ្នកកំពុងមើល។
ជ្រើសរើសផ្ទាំងប៉ុស្តិ៍សម្រាប់បញ្ចូលផ្ទាំងលោតឡើងព័ត៌មានលម្អិត
ដើម្បីឃើញព័ត៌មានលម្អិតអំពីកម្មវិធី
ឬដំណើរការលក្ខណៈពិសេសបន្ថែមដែលពាក់ព័ន្ធនឹងផ្ទាំងនេះ។

អ្នកអាចមើលព័ត៌មានការផ្សព្វផ្សាយអំពីប៉ុស្តិ៍ផ្សេងៗទៀតដោយការប្រើប៊ូតុង ▲/▼។

អ្នកអាចមើលព័ត៌មានការផ្សព្វផ្សាយអំពីប៉ុស្តិ៍ដែលអ្នកកំពុងមើលដោយប្រើប៊ូតុង ◀/▶។

- លក្ខណៈពិសេសនេះអាចត្រូវបានគ្រប់គ្រងនៅក្នុងផ្ទាំងលោតឡើងព័ត៌មានលម្អិតតែប៉ុណ្ណោះ។

❷ ចាប់ផ្តើម **សកម្មភាពច្រើនទៀត**។
សម្រាប់ព័ត៌មានបន្ថែម សូមមើល **របៀបបើកដំណើរការឧបករណ៍** → **ការប្រើសកម្មភាពច្រើនទៀត** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❸ ចាប់ផ្តើម **ការណែនាំ**។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយនឹង Live Channel** → **ការមើល ការណែនាំ** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- មុខងារដែលមាន ប្រហែលជាមានភាពខុសគ្នាអាស្រ័យលើរលកសញ្ញាផ្សព្វផ្សាយ។
- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។

Live Playback

ការប្រើការលេងឡើងវិញផ្ទាល់ (លេងឡើងវិញតាមពេលវេលាជាក់ស្តែង)

មុខងារនេះអនុញ្ញាតឱ្យអ្នកក្សាទុកជាបណ្តោះអាសន្ននូវកម្មវិធីដែលកំពុងមើលនាពេលបច្ចុប្បន្ននៅលើថាសរឹង USB និងចាក់ឡើងវិញនូវឈុតដែលខកខានមិនបានមើលនៅពេលកំពុងមើលការផ្សាយ ដោយធានាបាននូវការបន្តភាពប្រសិនបើអ្នកចាកចេញមួយភ្លែត។

01 បញ្ចូល USB HDD នៅក្នុងរន្ធ USB។


02 ចុចប៊ូតុង ••• នៅលើតេឡេបញ្ជា រួចជ្រើសរើស **Live Playback**។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

03 អេក្រង់បញ្ជាក់ការកំណត់ **Live Playback** បង្ហាញ។
បញ្ចប់ការកំណត់ រួចចុចប៊ូតុង **OK**។

- ប្រសិនបើភ្ជាប់ឧបករណ៍ផ្ទុក USB មួយ នោះអេក្រង់ការកំណត់អាចនឹងមិនបង្ហាញទេ ហើយ **Live Playback** អាចនឹងដំណើរការ។

04 នៅពេលមើលការផ្សព្វផ្សាយបន្តផ្ទាល់ ប្រើទស្សន៍ទ្រនិចដើម្បីជ្រើសរើសចំណុចមួយលើរបាដំណើរការដែលអ្នកចង់បន្តការមើល។ អ្នកក៏អាចចុចប៊ូតុង ◀/▶ លើតេឡេរបស់អ្នក ដើម្បីប្រើប្រាស់មុខងារនេះ។
ជ្រើសរើសចំណុចមួយ មុនចំណុចបច្ចុប្បន្នលើរបាដំណើរការ។



- អ្នកអាចប្រើមុខងារ Live Playback សម្រាប់តែប៉ុស្តិ៍ផ្សាយតាមរលកធាតុអាកាសឌីជីថលដែលអ្នកមើល ដោយប្រើរន្ធដោតអង់តែនប៉ុណ្ណោះ។ ប៉ុន្តែអ្នកមិនអាចប្រើប្រាស់ជម្រើសនេះបានទេ នៅពេលកំពុងស្តាប់ប៉ុស្តិ៍វិទ្យុ។
- នៅពេលដែលថាសរឹង USB ច្រើនជាងមួយត្រូវបានភ្ជាប់ទៅឧបករណ៍

សូមជ្រើសរើសឧបករណ៍ដែលត្រូវប្រើសម្រាប់ការផ្លាស់ប្តូរពេលវេលា។

- អ្នកមិនអាចប្រើប្រាស់ផ្លាសយូអេសប៊ីបានទេ។ ភាjប់ថាសរឹងយូអេសប៊ីមួយដែលមានទំហំ 80 ជីកាបៃឬលើសពីនេះ។
- ប្រសិនបើមិនមានទំហំទំនេរនៅសល់គ្រប់គ្រាន់នៅក្នុង HDD USB ទេ នោះLive Playback អាចដំណើរការមិនបានល្អ។ ដើម្បីប្រើមុខងារ Live Playback អ្នកត្រូវការ HDD USB ដែលមានទំហំយ៉ាងតិច 2.3 ជីកាបៃ។
- តាមរយៈមុខងារ **Live Playback** អ្នកអាចចាក់កម្មវិធីវិញបានរហូតដល់ពីរម៉ោង អាស្រ័យលើសមត្ថភាព USB HDD ដែលនៅសល់។
  ពេលនេះប្រហែលជាមានភាពខុសគ្នាអាស្រ័យទៅលើតំបន់របស់អ្នក។
- ខ្លឹមសារដែលបានរក្សាទុកក្នុងការផ្លាស់ប្តូរពេលវេលាត្រូវបានលុប ប្រសិនបើអ្នកបិទឧបករណ៍ដោយមិនថតទុក។
- ការប្តូរពីប៉ុស្តិ៍មួយទៅប៉ុស្តិ៍មួយទៀតអំឡុងពេល Live Playback នឹងលុបទិន្នន័យរបស់ប៉ុស្តិ៍ពីមុន។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការថត


ការប្រើប្រាស់ការថតភ្លាមៗ

01 ភ្ជាប់ USB HDD ឬបន្ទះ USB ទៅរន្ធ USB។
ជាការល្អ អ្នកគួរថតទុកក្នុងថាសរឹងយូអេសប៊ី។

02 ចុចប៊ូតុង ••• នៅលើតេឡេបញ្ជា រួចជ្រើសរើស **ថត**។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

- ដើម្បីបញ្ចប់ការថត សូមចុចប៉ូតុង ••• នៅលើតេឡេបញ្ជា អំឡុងពេលថត រួចជ្រើសរើស **ថត**។



បញ្ហាដែលត្រូវយកចិត្តទុកដាក់នៅពេលថត

- នៅពេលថត សូមចុចប៊ូតុង **រង្វង់មូល (OK)** ដើម្បីបង្ហាញព័ត៌មានអំពីការថត។
- អ្នកអាចកំណត់រយៈពេលថត មុនពេលការថតចាប់ផ្តើម ហើយអំឡុងពេលថត
  អ្នកអាចផ្លាស់ប្តូរម៉ោងបានដោយជ្រើសរើសប៊ូតុងថត។
- វីដេអូដែលបានថតមានបច្ចេកវិទ្យាការពារខ្លឹមសារ ហើយមិនអាចចាក់នៅលើកុំព្យូទ័រ
  ឬឧបករណ៍ផ្សេងទៀតបានទេ។ វីដេអូនោះក៏នឹងមិនលេងដែរ
  ប្រសិនបើសៀគ្វីវីដេអូរបស់ឧបករណ៍ត្រូវបានប្តូរជំនួស។
- មិនត្រូវដកខ្សែយូអេសប៊ីចេញនៅពេលកំពុងថតឡើយ។
- ប្រសិនបើអ្នកបង្ខំឱ្យឧបករណ៍របស់អ្នកបិទថាមពល នៅពេលកំពុងថត
  ខ្លឹមសារដែលបានថតប្រហែលជាមិនត្រូវបានរក្សាទុកទេ។ ល្អបំផុតនោះអ្នកគួរតែឈប់ថត
  ហើយពិនិត្យមើលថាប៉ុស្តិ៍នោះត្រូវបានថតឬអត់ មុនពេលបិទថាមពល។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- មុខងារមួយចំនួនប្រហែលមិនអាចប្រើបានទេ នៅពេលការថតកំពុងដំណើរការ។
- អ្នកអាចត្រឹមតែថតប៉ុស្តិ៍ផ្សាយតាមរលកធាតុអាកាសឌីជីថលដែលអ្នកមើល
  ដោយប្រើរន្ធដោតអង់តែនប៉ុណ្ណោះ។
- Bluetooth និងរន្ធយូអេសប៊ីអាចមិនដំណើរការបានត្រឹមត្រូវនៅពេលកំពុងថតជាមួយឧបករណ៍
  យូអេសប៊ីឡើយ។
- ការថតដែលមានរយៈពេលតិចជាង 10 វិនាទីនឹងមិនត្រូវបានរក្សាទុកទេ។
- អ្នកអាចរក្សាទុកមាតិការហូតដល់ចំនួន 600 នៅលើឧបករណ៍ផ្ទុកមួយ។

អំពីឧបករណ៍ផ្ទុក USB សម្រាប់ការថត

- រយៈពេលដែលអាចថតបានអាចខុសគ្នា អាស្រ័យលើសមត្ថភាពផ្ទុករបស់ឧបករណ៍ផ្ទុកយូអេសប៊ី
  របស់អ្នក។
- ឧបករណ៍ធ្វើការត្រួតពិនិត្យដំណើរការ នៅពេលព្យាយាមថតដោយប្រើអង្គចងចាំ USB
  ជាលើកដំបូង។ ការត្រួតពិនិត្យនេះត្រូវតែបញ្ចប់ដោយជោគជ័យ ទើបការថតអាចចាប់ផ្តើមបាន។
- មានតែប្រព័ន្ធឯកសារ NTFS, FAT32 ឬ exFAT ដែលប្រើក្នុងប្រព័ន្ធប្រតិបត្តិការ Windows
  ប៉ុណ្ណោះដែលអាចឈូសឧបករណ៍ផ្ទុក USB បាន។ ឧបករណ៍ផ្ទុក USB
  ដែលឈូសដោយកម្មវិធីបំពេញមុខងារដែលមិនអាចប្រើដោយ Windows ប្រហែលជាមិនស្គាល់ទេ។
- ការឈូសឧបករណ៍ផ្ទុក USB
  លើឧបករណ៍នឹងឈូសឧបករណ៍ផ្ទុកជាប្រព័ន្ធឯកសារមុនរបស់ឧបករណ៍ផ្ទុក USB នោះ, NTFS,
  FAT32 ឬ exFAT។
- សមត្ថភាពផ្ទុកដែលបានណែនាំសម្រាប់អង្គចងចាំ USB គឺ 32 GB
  រីឯសមត្ថភាពផ្ទុកដែលបានណែនាំសម្រាប់ថាសរឹង USB គឺ 4 TB ចុះក្រោម។
  ឧបករណ៍លើសសមត្ថភាពផ្ទុកដែលបានណែនាំមិនអាចដំណើរការបានត្រឹមត្រូវទេ។
- ទំហំទំនេររបស់ថាសរឹងយូអេសប៊ីត្រូវតែមានទំហំយ៉ាងតិចណាស់ 1 ជាកាបៃ។
- ត្រូវតែមានទំហំភាគថាសយ៉ាងហោចណាស់ 4 ជីកាបៃនៅលើដ្រាយយូអេសប៊ី។
- ការថតអាចនឹងត្រូវបានរំខាន ប្រសិនបើទំហំផ្ទុកដែលនៅសល់មានមិនគ្រប់គ្រាន់។ ការប្រើប្រាស់
  ឧបករណ៍ផ្ទុកដែលមានទំហំគ្រប់គ្រាន់សម្រាប់ថត ត្រូវបានណែនាំ។
- ប្រសិនបើឧបករណ៍ផ្ទុកយូអេសប៊ីជាច្រើនត្រូវបានភ្ជាប់
  នោះឧបករណ៍ផ្ទុកដែលបានថតទុកចុងក្រោយគេ នឹងត្រូវបានជ្រើសរើសដោយស្វ័យប្រវត្តិ។
- ល្បឿនផ្ទេររបស់អង្គចងចាំ USB មានភាពខុសគ្នាសម្រាប់ឧបករណ៍អង្គចងចាំនីមួយៗ។

- គុណភាពនៃការថតគឺអាស្រ័យលើដំណើរការរបស់ឧបករណ៍ផ្ទុក USB។
- ប្រសិនបើឧបករណ៍ផ្ទុកយូអេសប៊ីមានបញ្ហា ការថតអាចមិនបញ្ចប់ត្រឹមត្រូវទេ។
- ឧបករណ៍ផ្ទុក USB ដែលប្រើសម្រាប់ការថតមិនដំណើរការទេ នៅពេលភ្ជាប់ទៅដុំបំបែក USB។ ដូចគ្នានេះដែរ ដោយសារការថតមិនអាចបញ្ចប់បានត្រឹមត្រូវ នៅពេលភ្ជាប់ទៅខ្សែ USB តបន្តែម សូមភ្ជាប់វាទៅរន្ធ USB ដោយផ្ទាល់។
- យើងសូមណែនាំឱ្យប្រើឧបករណ៍ផ្ទុក USB ដែលដំណើរការដោយអាដាប់ទ័រ AC ដោតជាប់ព្រីភ្លើង។


ការចាប់យកតន្ត្រី

ការប្រើការទទួលយកតន្ត្រី

អ្នកអាចថតតន្ត្រីពីឧបករណ៍បានគ្រប់ពេល។

01 នៅពេលកំពុងមើលការផ្សាយផ្ទាល់ សូមចុចប៊ូតុង •••។

02 សូមជ្រើសរើស **ថតតន្ត្រី**។



- នៅពេលដែលថាសរឹង USB ត្រូវបានភ្ជាប់ទៅឧបករណ៍ សូមជ្រើសរើសឧបករណ៍ដែលអ្នកចង់ប្រើដើម្បីថត។
- ប្រសិនបើមិនមានទំហំទំនេរគ្រប់គ្រាន់ក្នុងឧបករណ៍ ថាសរឹងយូអេសប៊ីទេ ការទទួលយកតន្ត្រីអាចមិនដំណើរការបានពេញលេញឡើយ។ ដើម្បីប្រើប្រាស់មុខងារការទទួលយកតន្ត្រីអ្នកត្រូវមានថាសរឹងយូអេសប៊ីដែលមានទំហំយ៉ាងតិច 100MB។
- អាចមើលឯកសារដែលបានរក្សាទុកនៅក្នុងកម្មវិធី **កម្មវិធីចាក់មេឌៀ** ហើយអ្នកអាចបើកឯកសារទាំងនោះនៅលើកុំព្យូទ័រ ឬឧបករណ៍ចល័តរបស់អ្នក។
- ឯកសារដែលបានថតត្រូវបានរក្សាទុកជាទម្រង់ aac ឬ mp3។ (ទម្រង់ដែលបានរក្សាទុកខុសគ្នាទៅតាមម៉ូដែលឧបករណ៍។)
- ប្រសិនបើអ្នកប្តូរកម្មវិធី ឬបញ្ចូលពេលកំពុងថត នោះការថតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ និងឯកសារដែលបានថតនឹងត្រូវបានរក្សាទុក។
- ប្រើបានតែជាមួយការផ្សព្វផ្សាយតាមបែបអាណាឡុកប៉ុណ្ណោះ។

- ជាមួយមុខងារការទទួលយកតន្ត្រី អ្នកអាចបើកតន្ត្រីបានរហូតដល់ទៅពីរម៉ោង។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការប្រើ កម្មវិធីកាលវិភាគទូរទស្សន៍


ការប្រើ **កម្មវិធីកាលវិភាគទូរទស្សន៍**

អ្នកអាចបញ្ចូលម៉ោង និងកាលបរិច្ឆេទនៃកម្មវិធី ដើម្បីកំណត់កាលវិភាគសម្រាប់មើល ឬថតវានៅក្នុងពេលកំណត់ណាមួយ។

01 ចុច នៅលើតេឡេបញ្ជា ដើម្បីជ្រើសរើស **Live TV** និងមើលការផ្សាយបន្តផ្ទាល់។

02 ចុចប៊ូតុង ••• លើតេឡេបញ្ជា រួចជ្រើសរើស **កម្មវិធីកាលវិភាគទូរទស្សន៍** លើអេក្រង់។
អេក្រង់ **កម្មវិធីកាលវិភាគទូរទស្សន៍** នឹងត្រូវបានបង្ហាញ។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។



❶ អ្នកអាចកំណត់ការថតដែលបានកំណត់កាលវិភាគថ្មី។

❷ អ្នកអាចកំណត់ការរំលឹកថ្មី។

❸ **តម្រៀប** : អ្នកអាចតម្រៀបបញ្ជីនេះបាន។
តម្រង : កំណត់តម្រង។
លុប : អ្នកអាចកំណត់ទម្រង់លុប។
ការណែនាំ : ចាប់ផ្តើម **ការណែនាំ**។
ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ចាប់ផ្តើម **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
ចាកចេញពីកម្មវិធី : បិទកម្មវិធីពីការដំណើរការនៅផ្នែកខាងក្រោយ។

❹ បិទកម្មវិធី។

កំពុងកំណត់កាលវិភាគការផ្សាយដែលបានជ្រើសរើសពី **ការណែនាំ**

អ្នកអាចជ្រើសរើសកម្មវិធីប៉ុស្តិ៍ទូរទស្សន៍មួយដើម្បីកំណត់ពេលមើល ឬថតទុក។

01 ដំណើរការ **Live TV** ដោយចុច ⏎។

02 ចុចប៊ូតុង ••• លើតេឡេប៊ញ្ចា រួចជ្រើសរើស **ការណែនាំ** លើអេក្រង់។

- ប្រសិនបើតេឡេប៊ញ្ចារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

03 ជ្រើសរើសកម្មវិធីដែលអ្នកចង់ថត។
ប្រសិនបើអ្នកចង់ថតការផ្សាយផ្តាល់ សូមចុចប៊ូតុង **ថត** ឬ **ទស្សនា**។
ក្នុងករណីមានកម្មវិធីដែលជិតមកដល់ សូមចុចប៊ូតុង **ការថតដែលបានកំណត់ពេល** ឬ **ការរំលឹក**។

- ការថតដែលបានកំណត់ពេលមិនធានាពេលវេលាថតទុកត្រឹមត្រូវរបស់កម្មវិធីទេ ពីព្រោះកម្មវិធីនឹងត្រូវថតទុកផ្អែកលើព័ត៌មានដែលផ្តល់ដោយអ្នកផ្សព្វផ្សាយ។
- អនុវត្តចំពោះការផ្សាយឌីជីថល។

ការកំណត់កាលវិភាគដោយផ្តាល់ដៃ

អ្នកអាចជ្រើសរើសកាលបរិច្ឆេទ ម៉ោង និងប៉ុស្តិ៍ដើម្បីមើល ឬថតប៉ុស្តិ៍ទុក។

01 ដំណើរការ **Live TV** ដោយចុច ⏎។

02 ចុចប៊ូតុង ••• លើតេឡេប៊ញ្ចា រួចជ្រើសរើស **កម្មវិធីកាលវិភាគទូរទស្សន៍** លើអេក្រង់។

- ប្រសិនបើតេឡេប៊ញ្ចារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

03 ជ្រើសរើស ◔ ឬ ◔។

04 ជ្រើសរើស **បង្កើតដោយផ្តាល់**។

05 ចូរកំណត់កាលបរិច្ឆេទ ម៉ោង និងប៉ុស្តិ៍ដែលត្រូវថត ឬមើល។

- រយៈពេលការថតដែលបានកំណត់ពេលត្រូវមានយ៉ាងតិច 1 នាទី។

ការបើកស្តាប់ការថត


ការគ្រប់គ្រងការថត

អ្នកអាចមើល និងចាក់ការថតដែលផ្ទុកក្នុងឧបករណ៍ផ្ទុកដោយប្រើកម្មវិធី **ការថត**។

01 ដំណើរការ **Live TV** ដោយចុច ⏎។

02 ចុចប៊ូតុង ••• លើតេឡេប៊ញ្ចា ហើយចាប់ផ្តើម **ការថត** លើអេក្រង់។

- ប្រសិនបើតេឡេប៊ញ្ចារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។



1. អ្នកអាចមើលត្រួសៗលើទំព័រផ្សេងៗដោយចុចប៊ូតុង (ប៉ុស្តិ៍) ∧/∨ លើតេឡេបញ្ជាបានផងដែរ។
   ចុចប៊ូតុង **រង្វង់មូល (OK)** លើតេឡេបញ្ជា ដើម្បីចាក់មាតិកា។
   ចុចប៊ូតុង **រង្វង់មូល (OK)** ឱ្យយូរលើតេឡេបញ្ជា ដើម្បីធ្វើសកម្មភាពខាងក្រោម៖
   - **លុប** : អ្នកអាចលុបមាតិកាដែលបានថត។
   - **ព័ត៌មានបន្ថែម** : អ្នកអាចមើលព័ត៌មានអំពីមាតិកាដែលបានថត **ចាក់** ឬ **កែសម្រួលចំណងជើង** បាន។
2. ចាប់ផ្តើម **ស្វែងរក**។
3. អ្នកអាចប្រើការកំណត់ដូចជា ឧបករណ៍ផ្ទុក និងជម្រើសក្នុងការតម្រៀបជាដើម សម្រាប់បញ្ជីមាតិកាបាន។
4. បិទកម្មវិធី។


- មានតែខ្លឹមសារថតដែលបានថតនៅលើឧបករណ៍នេះប៉ុណ្ណោះ ទើបអាចចាក់ឡើងវិញពី **ការថត** បាន។

ការបើកស្តាប់ការថត

អ្នកអាចចូលប្រើ និងដំណើរការមុខងារងាយៗដូចជា ការចាក់ និងផ្អាកលើអេក្រង់ដែលកំពុងចាក់។

01 ជ្រើសរើសការថតដែលអ្នកចង់បានពីកម្មវិធី **ការថត**។

02 ការចុចប៊ូតុង ◀/▶ នៅលើតេឡេបញ្ជាអាចឱ្យអ្នករំលងថយក្រោយ/ទៅមុខ 10 វិនាទី។
   អ្នកអាចគ្រប់គ្រងការចាក់ការថតរបស់អ្នកដោយចុចប៊ូតុង **រង្វង់មូល (OK)** នៅពេលកំពុងចាក់។
   អ្នកអាចចូលប្រើលក្ខណៈពិសេសច្រើនទៀតដោយចុច ∨ លើអេក្រង់ ខណៈពេលកំពុងប្រើការគ្រប់គ្រងការចាក់។



1. បង្ហាញការថតមុន។
2. ចាក់ ឬផ្អាកការថត។
3. បង្ហាញការថតបន្ទាប់។
4. បិទ ឬបើកអក្សររត់ពីក្រោម។
5. អ្នកអាចកំណត់ការលេងឡើងវិញបន្ត។
6. ខារីដេអូលឿនទៅក្រោយក្នុងល្បឿនលឿនជាងមុន។
7. ខារីដេអូលឿនទៅមុខក្នុងល្បឿនលឿនជាងមុន។
8. អ្នកអាចកំណត់លក្ខណៈពិសេសដូចជា “បន្ត” និងភាសាសំឡេងដែលអាចបញ្ចេញបាន។
9. បញ្ជីសំឡេងថតត្រូវបានបង្ហាញខាងក្រោម។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

កំពុងមើល LG Channels

កំពុងមើល LG Channels

អ្នកអាចមើលការផ្សាយក្នុងពេលជាក់ស្តែង តាមរយៈសេវាកម្មនេះនៅលើអ៊ីនធឺណិតបាន។
អ្នកអាចមើលព័ត៌មាននៅលើប៉ុស្តិ៍អ៊ីនធឺណិតថ្មី ឬគ្រប់គ្រងប៉ុស្តិ៍ដែលអ្នកពេញចិត្តនៅក្នុង **LG Channels**។

ចុចប៊ូតុង លើតេឡេបញ្ជា រួចជ្រើសរើស **LG Channels** លើអេក្រង់។
អ្នកក៏អាចមើល **LG Channels** ដោយចុចប៊ូតុង **(ប៉ុស្តិ៍)** ∧/∨
នៅលើតេឡេបញ្ជាបានផងដែរ។

អ្នកអាចប្រើសេវាកម្ម 'ប៉ុស្តិ៍អន្តរកម្ម'
ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចរីករាយនឹងមាតិកាដែលពាក់ព័ន្ធនឹងប៉ុស្តិ៍បច្ចុប្បន្នបានយ៉ា

ងងាយស្រួលផងដែរ ដោយមិនចាំបាច់ប្តូរកម្មវិធីឡើយ។
អ្នកអាចប្រើ 'ប៉ុស្តិ៍អន្តរកម្ម' ដោយចុចប៊ូតុងនៅលើតេឡេបញ្ជារបស់អ្នក
ឬចុចអេក្រង់របស់អ្នក
ផ្អែកតាមការណែនាំដែលលេចឡើងនៅលើអេក្រង់ប៉ុស្តិ៍អ៊ីនធឺណិតផងដែរ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- អ្នកត្រូវតែភ្ជាប់បណ្តាញ និងយល់ព្រមតាម **កិច្ចព្រមព្រៀងអ្នកប្រើប្រាស់** មុននឹងប្រើវា។
- នៅក្នុង ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ទីតាំង**, **ប្រទេសផ្សព្វផ្សាយ** និង **ប្រទេសផ្តល់សេវាកម្ម LG** ត្រូវតែដូចគ្នា។ ប្រសិនបើអ្នកប្តូរចំណុចណាមួយ អ្នកនឹងមិនអាចប្រើសេវាកម្មនេះបានទេ។
- ខណៈពេលកំពុងមើលប៉ុស្តិ៍អ៊ីនធឺណិត សូមចុចប៊ូតុង ពណ៌បៃតង នៅលើតេឡេបញ្ជា។ អ្នកអាចចាប់ផ្តើម **LG Channels**។
- ការជ្រើសរើស **LG Channels** នឹងប្តូរម៉ូដបញ្ចូលទៅ **LG Channels**។
  ខ្លឹមសារមួយចំនួនអាចត្រូវបានជំនួសដោយកម្មវិធីផ្សេងទៀត។
- ប៉ុស្តិ៍អ៊ីនធឺណិតមួយចំនួនប្រហែលជាមិនស្គាល់ឧបករណ៍នេះទេ។
- មិនអាចប្រើ Live Playback និងការថតសម្រាប់ប៉ុស្តិ៍អ៊ីនធឺណិតបានទេ។
- សេវាកម្មប៉ុស្តិ៍អ៊ីនធឺណិតអាចនឹងត្រូវបានបញ្ឈប់
  ឬផ្លាស់ប្តូរដោយគ្មានការជូនដំណឹងទុកជាមុនពីក្រុមហ៊ុនផ្សាយ។

អក្សរសន្ទស្សន៍

ដើម្បីប្រើអត្ថបទបង្ហាញលើទូរទស្សន៍

អត្ថបទបង្ហាញលើទូរទស្សន៍ជាសេវាឥតគិតថ្លៃមួយដែលផ្តល់ដោយស្ថានីយទូរទស្សន៍ដែល
ផ្តល់ព័ត៌មានជាអក្សរអំពីកម្មវិធីទូរទស្សន៍ ព័ត៌មាន និងអាកាសធាតុ។
ឧបករណ៍ឌិកូដតេឡេតិកបស់ឧបករណ៍ស្គាល់ប្រព័ន្ធ SIMPLE, TOP និង FASTEXT។

01 ចុចប៊ូតុង ••• លើតេឡេ។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

02 ជ្រើសរើស **អក្សរសន្ទស្សន៍** នៅលើអេក្រង់។

03 បង្ហួចអត្ថបទបង្ហាញលើទូរទស្សន៍លេចឡើង។

04 ដើម្បីមើលការផ្សាយ និងតេឡេតិកព្រមគ្នា សូមចុចប៊ូតុង ••• នៅលើតេឡេបញ្ជា
រួចជ្រើសរើស **អក្សរសន្ទស្សន៍**។

ប៊ូតុងពណ៌

ជ្រើសរើសទំព័របន្ទាប់ ឬខាងក្រោម។

ប៊ូតុងលេខ

បញ្ចូលលេខទំព័រដើម្បីផ្លាស់ប្តូរ។

ប៊ូតុង (ប៉ុស្តិ៍) ∧/∨

ជ្រើសរើសទំព័របន្ទាប់ ឬខាងក្រោម។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

មុខងារអត្ថបទបង្ហាញលើទូរទស្សន៍ពិសេស

01 ចុចប៊ូតុង ••• លើតេឡេ។

- ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

02 ជ្រើសរើស **ជម្រើសអក្សរសន្ធសុរន៍** នៅលើអេក្រង់។

03 ជ្រើសរើសមីនុយ **អក្សរសន្ធសុរន៍**។

Index

ជ្រើសរើសទំព័រលិបិក្រមនីមួយៗ។

ម៉ោង

នៅពេលមើលការផ្សាយ សូមជ្រើសរើសមីនុយដែលពាក់ព័ន្ធ
ដើម្បីមើលរយៈពេលនៅខាងលើផ្នែកខាងស្តាំនៃអេក្រង់។ នៅក្នុងទម្រង់អត្ថបទបង្ហាញលើទូរទស្សន៍ ចុចប៊ូតុងនេះ ដើម្បីជ្រើសរើសលេខទំព័ររង។ លេខទំព័ររងត្រូវបានបង្ហាញនៅផ្នែកខាងក្រោមនៃអេក្រង់។ ដើម្បីបន្ត ឬប្តូរទំព័ររង សូមចុច /, / ឬប៊ូតុង Number។

រង់ចាំ

បញ្ឈប់ទំព័រមិនឲ្យប្តូរដោយស្វ័យប្រវត្តិដែលនឹងដើតឡើង ប្រសិនបើទំព័រអត្ថបទបង្ហាញលើទូរទស្សន៍មានទំព័ររង 2 ឬច្រើនជាងនេះ។ ចំនួនទំព័ររងនិងទំព័ររងតាមធម្មតាត្រូវបានបង្ហាញលើអេក្រង់ខាងក្រោមម៉ោង។ នៅពេលមីនុយនេះត្រូវបានជ្រើសរើស និមិត្តសញ្ញាបញ្ឈប់ត្រូវបានបង្ហាញនៅជ្រុងខាងលើផ្នែកខាងឆ្វេងនៃអេក្រង់ ហើយការប្តូរលេខទំព័រស្វ័យប្រវត្តិមិនអាចប្រើបានទេ។

បង្ហាញ

ជ្រើសរើសមីនុយនេះដើម្បីបង្ហាញព័ត៌មានលាក់ ដូចជាចម្លើយប្រស្នា ឬល្បែងប្រាជ្ញា។

អាប់ដេត

បង្ហាញរូបភាពទូរទស្សន៍លើកញ្ចក់ នៅពេលកំពុងរង់ចាំទំព័រអត្ថបទបង្ហាញលើទូរទស្សន៍។

ការបង្ហាញលេងលេចឡើងនៅជ្រុងខាងឆ្វេងដៃផ្នែកខាងលើនៃអេក្រង់។ នៅពេលមានទំព័រ
បានធ្វើបច្ចុប្បន្នភាព បន្ទាប់មកការបង្ហាញនឹងប្តូរទៅលេខទំព័រ។ ជ្រើសរើសម៉ឺនុយនេះម្តង
ទៀត ដើម្បីមើលទំព័រអត្ថបទបង្ហាញលើទូរទស្សន៍បានធ្វើបច្ចុប្បន្នភាព។

ភាសា

កំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍។

- ក្នុងរបៀបឌីជីថលតែប៉ុណ្ណោះ

ដើម្បីកំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍

ប្រើមុខងារភាសាអត្ថបទបង្ហាញលើទូរទស្សន៍នៅពេលភាសាអត្ថបទបង្ហាញលើទូរទស្សន៍ពីរ
ឬច្រើនកំពុងត្រូវបានផ្សាយ។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 ជ្រើសរើស ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ភាសា (Language)** →
ភាសាអក្សរសន្ទស្សន៍ចម្បង/ភាសាអក្សរសន្ទស្សន៍ទីពីរ។

- ក្នុងរបៀបឌីជីថលតែប៉ុណ្ណោះ
- ប្រសិនបើទិន្នន័យអត្ថបទបង្ហាញលើទូរទស្សន៍មិនត្រូវផ្សាយជាភាសាដែលបានជ្រើសរើសទេ
ភាសាលំនាំដើមនឹងបង្ហាញ។
- ប្រសិនបើអ្នកជ្រើសរើសប្រទេសក្នុងតំបន់ខុសអត្ថបទបង្ហាញលើទូរទស្សន៍
នឹងបង្ហាញមិនបានត្រឹមត្រូវលើកញ្ចក់ទូរទស្សន៍ទេ ហើយបញ្ហាមួយចំនួន
អាចកើតឡើងនៅក្នុងប្រតិបត្តិការអត្ថបទបង្ហាញលើទូរទស្សន៍។

HbbTV

ស្វែងយល់បន្ថែមអំពី HbbTV

HbbTV (Hybrid Broadcast Broadband TV)
គឺជាស្តង់ដារផ្សាយថ្មីដែលនាំមកនូវសេវាកម្មប្រភេទតេឡេតិកកំពូល។
វាធ្វើឱ្យកម្មវិធីដែលបានបញ្ជូនអាចរួមបញ្ចូលជាមួយឧបករណ៍ឆ្លាតវៃនៅពេលប្រើប្រាស់
ឬភ្ជាប់ទៅសេវាកម្មលើអ៊ីនធឺណិតដែលបានបញ្ជូនតាមរយៈប្រតបេន។ ដូច្នេះ
អ្នកប្រើប្រាស់អាចរីករាយនឹងមុខងារនានា ដូចជាការចាក់នៅលើទូរទស្សន៍ឡើងវិញ
(ការទស្សនាកម្មវិធីលើទូរទស្សន៍ឡើងវិញ, វីដេអូតាមតម្រូវការ)
និងអាចចូលប្រើសេវាកម្មលើអ៊ីនធឺណិតជាច្រើន ដែលបានភ្ជាប់ជាមួយកម្មវិធី
បន្ថែមពីលើសេវាកម្មព័ត៌មានដ៏សម្បូរបែបរបស់តេឡេតិកឌីជីថលដែលមានស្រាប់។
អាចបើកដំណើរការសេវាកម្ម HbbTV បានតាមវិធីជាច្រើន

ដែលវិធីទូទៅបំផុតនោះគឺការចុចប៊ូតុង 🔴 នៅលើតេឡេបញ្ជា។ ជាទូទៅ
អាចដំណើរការសេវាកម្មនេះបានដោយប្រើប៊ូតុងរុករកដែលមានស្រាប់។ (រួមទាំងប៊ូតុង 'OK',
🔴, 🟢, 🟡, 🔵) ព័ត៌មានលម្អិតអំពី HbbTV ចុងក្រោយបំផុតស្គាល់
“ការផ្សាយដែលមានភាពបត់បែន” នៅលើវីដេអូ តាមរយៈការតភ្ជាប់ប្រតបេន
ដែលធ្វើឱ្យអ្នកមើលអាចរីករាយទស្សនាវីដេអូដែលមានគុណភាពខ្ពស់បំផុត។
សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពី HbbTV សូមចូលទៅកាន់ www.hbbtv.org។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ដើម្បីប្រើទូរទស្សន៍ HbbTV

⚙ → ⚙ → **ទូទៅ** → **ប៉ុស្តិ៍** → **HbbTV**

កំណត់ទូរទស្សន៍ HbbTV ទៅបើក។
រីករាយជាមួយមាតិកាជាច្រើនពីសេវារបស់ទូរទស្សន៍ Hbb TV។

- ប្រសិនបើគ្មានការតភ្ជាប់អ៊ីនធឺណិតទេ សេវាកម្មអាចនឹងមានកម្រិត។
- មុខងារ និងគុណភាពរបស់សេវាទូរទស្សន៍ HbbTV អាចខុសៗគ្នាអាស្រ័យ
លើគុណភាពនៃការភ្ជាប់រលកអាកាសរបស់អ្នក។
- សេវាទូរទស្សន៍ HbbTV មិនធានាថាអាចប្រើកម្មវិធីទាំងអស់ទេ -
បានតែកម្មវិធីដែលអ្នកផ្សព្វផ្សាយរបស់អ្នកជ្រើសរើសដើម្បីគាំទ្រប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- នៅពេល Live Playback កំពុងដំណើរការ HbbTV នឹងត្រូវបានបិទ។
- នៅពេលប្រើសេវាកម្ម HbbTV គ្រាប់ចុចរុករក និងប៊ូតុង **រង្វង់មូល (OK)** អាចត្រូវបានបិទ
ប្រសិនបើសញ្ញាព្រួញរបស់ Magic Remote ត្រូវបានបើកដំណើរការនៅលើអេក្រង់។ ក្នុងករណីនេះ
សូមចុចគ្រាប់ចុចឆ្វេង ស្តាំ និងចុះក្រោម ដើម្បីបិទដំណើរការសញ្ញាព្រួញ។
(ការកំណត់នេះអនុវត្តចំពោះម៉ូដែលដែលអាចប្រើជាមួយ Magic Remote។)

កម្មវិធី និងមាតិកា

ការដំឡើងកម្មវិធី

ការដំឡើងកម្មវិធី

អ្នកអាចដំឡើងកម្មវិធីតាមប្រភេទដ៏សម្បូរបែបដូចជា ហ្គេម ការអប់រំ និងព័ត៌មាន

ហើយប្រើកម្មវិធីទាំងនោះបានយ៉ាងងាយស្រួលនៅលើផលិតផលរបស់អ្នក។

01 ចុចប៊ូតុង ⌂ លើតេឡេ។


02 បើកដំណើរការ **Apps**។

03 ជ្រើសរើសប្រភេទ ឬចុចប៊ូតុង 🔍 ដើម្បីស្វែងរកកម្មវិធី។

04 ជ្រើសរើសកម្មវិធីសម្រាប់ដំឡើង។

05 អានព័ត៌មានលម្អិតអំពីកម្មវិធី រួចចុច **ដំឡើង**។

06 នៅពេលការដំឡើងបានបញ្ចប់ អ្នកអាចដំណើរការកម្មវិធីបានភ្លាមៗ។



❶ ស្វែងរកមាតិកា។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **កម្មវិធី និងមាតិកា** → **ការស្វែងរកមាតិកា** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❷ អ្នកអាចចូលគណនី LG របស់អ្នកបាន។
សម្រាប់ព័ត៌មានបន្ថែម ចូលទៅ **ចាប់ផ្តើម webOS** → **ការគ្រប់គ្រងគណនី LG របស់អ្នក** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❸ អ្នកអាចគ្រប់គ្រងកម្មវិធីដូចជា អាប់ដេត ឬលុបកម្មវិធីដែលបានដំឡើងជាដើម។

❹ បិទកម្មវិធី។

- ដើម្បីបិទកម្មវិធីពីការដំណើរការនៅផ្នែកខាងក្រោយ សូមចុចប៊ូតុង ••• នៅលើតេឡេបញ្ជា រួចចុច **ចាកចេញពីកម្មវិធី**។
  ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។

- ដើម្បីដំឡើងកម្មវិធី អ្នកត្រូវតែចូលគណនី។
- ប្រភេទដែលមាននឹងប្រែប្រួលតាមប្រទេស ឬស្ថានភាពសេវាកម្ម។
- ប្រសិនបើទំហំផ្ទុកនៅលើឧបករណ៍របស់អ្នកមិនគ្រប់គ្រាន់ទេ
  អ្នកអាចដំឡើងកម្មវិធីដោយភ្ជាប់ឧបករណ៍ផ្ទុកខាងក្រៅ។
- ឧបករណ៍ផ្ទុកយូអេសប៊ីមួយចំនួន អាចមិនស្គាល់ ឬមានដំណើរការមិនស្រួល។
- បន្ទះ USB ដែលមានកម្មវិធីពីឧបករណ៍ផ្សេងទៀតអាចមិនត្រូវបានប្រើ។
- ត្រូវចេះប្រុងប្រយ័ត្ននៅពេលកំពុងមានការប្រើដោយកុមារ។ កុមារអាចនឹងមានលទ្ធភាពមើលមេឌៀ ឬមាតិកាមិនត្រឹមត្រូវនៅអនឡាញតាមរយៈផលិតផលនេះបាន។ អ្នកអាចទប់ស្កាត់

មាតិកាលើអ៊ីនធឺណិតដែលមិនសមរម្យ ដោយកម្រិតការចូលប្រើប្រាស់កម្មវិធីមួយចំនួន។
កំណត់រចនាសម្ព័ន្ធឲ្យសំណុំកំណត់នេះនៅ ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **សុវត្ថិភាព** → **ការចាក់សោកម្មវិធី**។

ដើម្បីប្រើ កម្មវិធីរុករកវេទមន្ត

ដើម្បីប្រើ កម្មវិធីរុករកវេទមន្ត

អ្នកអាចដំណើរការការស្វែងរកបានយ៉ាងងាយស្រួល តាមរយៈកម្មវិធីផ្សេងៗ
ផ្តែកលើព័ត៌មានអំពីវីដេអូ ឬអក្សរលើអេក្រង់។

01 កម្មវិធីរុករកវេទមន្ត អាចត្រូវបានប្រើ ប្រសិនបើពណ៌សញ្ញាព្រួញរបស់ Magic Remote ប្រែប្រួល (ឧ. ទៅជា 🔵)។


02 ចុចប៊ូតុង **រង្វង់មូល (OK)** នៅលើរូបភាពឱ្យជាប់ ប្រសិនបើអ្នកកំពុងមើលការផ្សាយ ឬនៅលើអត្ថបទ ប្រសិនបើអ្នកកំពុងប្រើសេវាកម្ម **កីឡា** ឬ **ការណែនាំ** ឬកម្មវិធី **ការកំណត់**។


03 នៅលើអេក្រង់ផ្សាយ ពាក្យគន្លឹះដែលពាក់ព័ន្ធនឹងកម្មវិធីនឹងបង្ហាញ។
នៅលើអត្ថបទក្នុងកម្មវិធី រូបតំណាងមួយនឹងបង្ហាញ
ដែលអនុញ្ញាតឱ្យអ្នកចូលទៅកាន់ធាតុដូចជា កម្មវិធីរុករកលើអ៊ីនធឺណិត ឬ
ស្វែងរកជាដើម។

04 ជ្រើសរើសធាតុដែលត្រូវប្រើ។

- អ្នកអាចផ្លាស់ទីធាតុដោយចុចប៊ូតុង ▲/▼/◀/▶ នៅលើតេឡេបញ្ជា។

05 អ្នកអាចចាកចេញពី កម្មវិធីរុករកវេទមន្ត ដោយចុចប៊ូតុង ↩ នៅលើតេឡេបញ្ជា។





- អ្នកក៏អាចប្រើលមុខងារនេះបានផងដែរ ដោយចុចប៊ូតុង OK ឱ្យជាប់នៅលើតេឡេបញ្ជាស្តង់ដារ។
- មុខងារដែលអាចប្រើបានមានភាពខុសគ្នាទៅតាមតំបន់ ឬសេវាកម្ម។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការស្វែងរកមាតិកា


ការស្វែងរកមាតិកា

ស្វែងរកមាតិកាតាមចំណងជើង តួសម្តែងប្រុស/ស្រី និងប្រភេទ។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 បើកដំណើរការ 🔍។

03 ស្វែងរកមើលមេឌៀ ឬមាតិកា និងព័ត៌មាននានាដែលប្រើពាក្យស្វែងរកដែលចង់បាន។



❶ វាយបញ្ចូលពាក្យស្វែងរក។

❷ បង្ហាញការស្វែងរកថ្មីៗ។

❸ អ្នកអាចជ្រើសរើសមួយពីពាក្យគន្លឹះដែលបានណែនាំ រួចបន្តស្វែងរក។

❹ អ្នកអាចរុករកមាតិកាតាមប្រភេទ។

- អ្នកត្រូវភ្ជាប់ទៅបណ្តាញ ដើម្បីប្រើលក្ខណៈពិសេសនៃការស្វែងរក។
- លទ្ធផលស្វែងរកអាចប្រែប្រួលដោយអាស្រ័យលើប៉ុស្តិ៍ តំបន់ កំណត់បណ្តាញ និងលក្ខខណ្ឌទូទៅដែលបានយល់ព្រមទទួលយករួចមកហើយ។
  ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការប្រើ ការិយាល័យនៅផ្ទះ

ការប្រើ ការិយាល័យនៅផ្ទះ

ចុចប៊ូតុង ⌂ លើតេឡេបញ្ជា ហើយចាប់ផ្តើម **ការិយាល័យនៅផ្ទះ** លើអេក្រង់។
កុំព្យូទ័រអាចដំណើរការពីចម្ងាយពីឧបករណ៍។

01 បើកថាមពលកុំព្យូទ័រដែលអ្នកចង់ភ្ជាប់។

02 ចុចប៊ូតុង ⌂ លើតេឡេបញ្ជា ហើយចាប់ផ្តើម **ការិយាល័យនៅផ្ទះ** លើអេក្រង់។

03 ជ្រើសរើស **បញ្ចូលកុំព្យូទ័រពីចម្ងាយ**។ អាចភ្ជាប់កុំព្យូទ័រថ្មីបាន។

- ត្រូវបើកកុំព្យូទ័រដែលត្រូវភ្ជាប់ ហើយត្រូវបើក ‘បើកដំណើរការកុំព្យូទ័រលើតុពីចម្ងាយ’ នៅក្នុងការកំណត់កុំព្យូទ័រ។
- អាចភ្ជាប់ឧបករណ៍ជាមួយ **បញ្ចូលកុំព្យូទ័រពីចម្ងាយ** បានរហូតដល់បួនគ្រឿង។ ដើម្បីបញ្ចូលកុំព្យូទ័រផ្សេងទៀត សូមលុបកុំព្យូទ័រដែលបានចុះឈ្មោះកាលពីមុន។
- អ្នកអាចភ្ជាប់បានតែប្រព័ន្ធប្រតិបត្តិការ Windows 10 Professional ឬកំណែក្រោយនេះ ឬ Mac ប៉ុណ្ណោះ។
  ត្រូវតែកំណត់ពាក្យសម្ងាត់ និងឈ្មោះអ្នកប្រើប្រាស់ Windows។
  ការចុះឈ្មោះចូលតាមរយៈការបញ្ចូលកូដ PIN មិនអាចប្រើបានទេ។
- មុនពេលភ្ជាប់ សូមបើក Mac របស់អ្នក ហើយត្រូវប្រាកដថាការចែករំលែកអេក្រង់ត្រូវបានបើកនៅក្នុងការកំណត់របស់ Mac → ការចែករំលែក។



❶ អ្នកអាចប្រើសេវាកម្មក្លោងលើកុំព្យូទ័រដែលបានជ្រើសរើសបាន។

❷ អ្នកអាចប្រើវាបានដោយប្តូរទៅកុំព្យូទ័រដែលបានភ្ជាប់។
: អ្នកអាចកែព័ត៌មាននៃការតភ្ជាប់បាន។
: អ្នកអាចលុបកុំព្យូទ័រដែលបានភ្ជាប់។

❸ អាចភ្ជាប់កុំព្យូទ័រថ្មីបាន។

❹ អ្នកអាចប្រើសេវាកម្មអ៊ីនធឺណិតដែលផ្តល់ដោយកុំព្យូទ័រនៅលើឧបករណ៍បាន។
ការជ្រើសរើស អាចឱ្យអ្នកកែបញ្ជីបាន។

- លក្ខណៈពិសេសដែលអាចប្រើបានអាចនឹងខុសគ្នាទៅតាមប្រទេស។

❺ ចាប់ផ្តើម **គណនី LG**។
សម្រាប់រាល់គណនីដែលបានចូល អ្នកអាចកំណត់រចនាសម្ព័ន្ធបញ្ជីកុំព្យូទ័រពីចម្ងាយ និងសេវាកម្មអ៊ីនធឺណិត ដើម្បីភ្ជាប់បាន។

❻ អ្នកអាចភ្ជាប់ mouse ឬក្តារចុច Bluetooth ហើយកំណត់ថាប្រើឧបករណ៍ដែលបានភ្ជាប់ឬអត់។

- សម្រាប់ការតភ្ជាប់ mouse ឬក្តារចុច Bluetooth សូមមើល **ការកំណត់** → **ឧបករណ៍ខាងក្រៅ** → **ភ្ជាប់ឧបករណ៍បញ្ចូតាម Bluetooth** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

❼ បិទកម្មវិធី។

- ការភ្ជាប់ក្តារចុច និង mouse ជាមួយឧបករណ៍ធ្វើឱ្យដំណើរការមានភាពរលូន។
  ប្រសិនបើប្តូរក្តារចុចភ្ជាប់ទៅកុំព្យូទ័រ ហើយនិងក្តារចុចដែលភ្ជាប់ទៅឧបករណ៍វាខុសគ្នា
  ចឹងគ្រាប់ចុចប្រហែលជាមិនដំណើរការទេ។
- កំណត់ការតភ្ជាប់បណ្តាញ និងការកំណត់រួចទើបអាចភ្ជាប់ទាំងឧបករណ៍ និងកុំព្យូទ័របាន។
- ប្រសិនបើឧបករណ៍ និងកុំព្យូទ័រមិនបានភ្ជាប់ជាមួយបណ្តាញតែមួយទេ
  នោះចាំបាច់ត្រូវតែមានព័ត៌មាន IP សាធារណៈ
  ហើយអាចនឹងតម្រូវឱ្យមានការកំណត់ការបញ្ជូនរន្ធបន្ត។
- ប្រសិនបើការតភ្ជាប់ត្រូវបានរឹតបន្តឹងដោយគោលការណ៍សុវត្ថិភាពកុំព្យូទ័រ
  សូមទាក់ទងអ្នកគ្រប់គ្រងសុវត្ថិភាពបណ្តាញ។
- មុខងារ ឬកម្មវិធីមួយចំនួនរបស់កុំព្យូទ័រមិនអាចប្រើបានទេ។
- នៅពេលបើកដំណើរការមុខងារសន្សំសំចៃថាមពលរបស់កុំព្យូទ័រ ការតភ្ជាប់នឹងដាច់
  ហើយមិនអាចភ្ជាប់ឡើងវិញបានទេ។
  យើងសូមណែនាំឱ្យបិទមុខងារសន្សំសំចៃថាមពលរបស់កុំព្យូទ័រ មុនពេលប្រើប្រាស់។


ការរីករាយប្រើប្រាស់ ហ្គេម

ការរីករាយប្រើប្រាស់ ហ្គេម

អ្នកអាចជ្រើសរើសកម្មវិធីដែលពាក់ព័ន្ធនឹងហ្គេម ឧបករណ៍ហ្គេមដែលបានភ្ជាប់ ឬកុំព្យូទ័រ។

ចុចប៊ូតុង ⌂ នៅលើតេឡេបញ្ជាដើម្បីបើកដំណើរការ **ហ្គេម**។

- ចាប់ផ្តើមភ្លាមៗ ទោះបីជានៅពេលដែលអ្នកភ្ជាប់ជាមួយដៃហ្គេមក៏ដោយ។
  សូមណែនាំអ្នកឱ្យប្រើដៃហ្គេមដែលបានធ្វើតេស្តលើភាពត្រូវគ្នាជាមួយឧបករណ៍នេះ។
  សម្រាប់ដៃហ្គេម Bluetooth ដែលត្រូវគ្នា សូមមើល**ការកំណត់** → **ឧបករណ៍ខាងក្រៅ** →
  ភ្ជាប់ឧបករណ៍បញ្ជាតាម Bluetoothនៅក្នុង**ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
  សម្រាប់ដៃហ្គេម USB ដែលត្រូវគ្នា សូមមើល**របៀបបើកដំណើរការឧបករណ៍** →
  ការប្រើប្រាស់ក្តារចុច ម៉ៅស៍ និងដៃហ្គេមនៅក្នុង**ការណែនាំសម្រាប់អ្នកប្រើប្រាស់**។



❶ ជ្រើសរើសសេវាកម្មហ្គេមពពកដែលចង់ប្រើ។

បង្ហាញហ្គេមដែលបានណែនាំដោយសេវាកម្មដែលបានជ្រើសរើស។
ជ្រើសរើស**បានលេងថ្មីៗនេះ** ដើម្បីបង្ហាញហ្គេមដែលបានលេងពីមុន។

❷ អ្នកអាចជ្រើសរើសឧបករណ៍ហ្គេមដែលបានភ្ជាប់ ឬកុំព្យូទ័រ។
ឧបករណ៍ដែលមិនបានភ្ជាប់មិនបង្ហាញទេ។

❸ អ្នកអាចដំណើរការកម្មវិធីដែលពាក់ព័ន្ធនឹងហ្គេម។

❹ ចូលមុខងារ **កែសម្រួលបញ្ជីកម្មវិធី**។

❺ ចាប់ផ្តើម **គណនី LG**។

❻ បង្ហាញថាតើបានភ្ជាប់ឧបករណ៍បញ្ជូល Bluetooth ឬអត់។ បញ្ជូនបន្ត
ដើម្បី**ភ្ជាប់ឧបករណ៍បញ្ជាតាម Bluetooth** នៅពេលជ្រើសរើស។

❼ បិទកម្មវិធី។

- មុខងារនេះប្រហែលជាមិនអាចប្រើនៅក្នុងម៉ូដែល ឬប្រទេសមួយចំនួនបានទេ។
- ឧបករណ៍ហ្គេម និងកុំព្យូទ័រដែលបានភ្ជាប់ទៅ HDMI ត្រូវបានបញ្ជូលទៅ **ហ្គេម** ដោយស្វ័យប្រវត្តិ។


ការប្រើសេវាកម្ម ការស្វែងយល់

ការប្រើសេវាកម្ម ការស្វែងយល់

អ្នកអាចជ្រើសរើសសេវាកម្មដែលបានបង្ហាញ ឬខ្លឹមសារពាក់ព័ន្ធដែលទាក់ទងនឹងការអប់រំ។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ជ្រើសរើសកាត **ការស្វែងយល់**។



❶ ជ្រើសរើសសេវាកម្មដែលអ្នកចង់ប្រើ។ ខ្លឹមសារដែលផ្តល់ដោយសេវាកម្មនេះបង្ហាញនៅខាងក្រោម។

❷ ធាតុដែលត្រូវបានជ្រើសរើសពីមុនមានរាយក្នុងបញ្ជី។ ប្រសិនបើចំនួនធាតុលើស 16
នោះធាតុដែលចាស់ជាងគេត្រូវបានលុបតាមលំដាប់ដោយស្វ័យប្រវត្តិ។

❸ អ្នកអាចដំណើរការកម្មវិធីដែលពាក់ព័ន្ធនឹងការអប់រំ។

❹ ចូលមុខងារ **កែសម្រួលបញ្ជីកម្មវិធី**។

❺ ចាប់ផ្តើម **គណនី LG**។

❻ បិទកម្មវិធី។

- អ្នកត្រូវតែភ្ជាប់ទៅបណ្តាញ ទើបអាចប្រើសេវាកម្ម **ការស្វែងយល់** បាន។
- មុខងារនេះប្រហែលជាមិនអាចប្រើនៅក្នុងម៉ូដែល ឬប្រទេសមួយចំនួនបានទេ។
- មុខងារដែលអាចប្រើបានមានភាពខុសគ្នាទៅតាមតំបន់ ឬសេវាកម្ម។
- លទ្ធផលនៃការស្វែងរក ឬការណែនាំអាចខុសគ្នាពីលទ្ធផល ឬការណែនាំនៅលើកុំព្យូទ័រ ឬឧបករណ៍ឆ្លាតវៃ។


ការរីករាយប្រើប្រាស់ តន្ត្រី

ការរីករាយប្រើប្រាស់ តន្ត្រី

អ្នកអាចស្វែងរកតន្ត្រីដែលអ្នកចូលចិត្តបាននៅកន្លែងតែមួយ
និងទទួលបានការណែនាំអំពីបទចម្រៀងពេញនិយម ឬបទចម្រៀងថ្មីៗបំផុត។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ជ្រើសរើសកាត **តន្ត្រី**។



❶ ជ្រើសរើសសេវាកម្មដែលអ្នកចង់ប្រើ។ ខ្លឹមសារដែលផ្តល់ដោយសេវាកម្មនេះបង្ហាញនៅខាងក្រោម។

❷ តន្ត្រីដែលបានជ្រើសរើសពីមុនបង្ហាញនៅក្នុងបញ្ជី។ ប្រសិនបើចំនួនធាតុលើស 16
នោះធាតុដែលចាស់ជាងគេត្រូវបានលុបតាមលំដាប់ដោយស្វ័យប្រវត្តិ។

❸ អ្នកអាចស្តាប់តន្ត្រីពីឧបករណ៍ឆ្លាតវៃ ឬ USB ដែលបានភ្ជាប់។
ការជ្រើសរើសមុខងារដែលចង់បាន វានឹងភ្ជាប់ទៅកម្មវិធីដែលត្រូវគ្នា។

❹ បង្ហាញកម្មវិធីតន្ត្រីដែលមាននៅលើឧបករណ៍។ ការជ្រើសរើសមុខងារដែលចង់បាន វានឹងភ្ជាប់ទៅកម្មវិធីដែលត្រូវគ្នា។

❺ អ្នកអាចកែបញ្ជីកម្មវិធីបាន។

❻ ចាប់ផ្តើម **គណនី LG**។

❼ បិទកម្មវិធី។

- លក្ខណៈពិសេសនេះប្រហែលជាមិនអាចប្រើបាននៅប្រទេសមួយចំនួនទេ។
- អ្នកត្រូវតែភ្ជាប់ទៅបណ្តាញ ទើបអាចប្រើមុខងារ **តន្ត្រី** បាន។
- មុខងារដែលអាចប្រើបានមានភាពខុសគ្នាទៅតាមតំបន់ ឬសេវាកម្ម។
- លទ្ធផលនៃការស្វែងរក ឬការណែនាំអាចខុសគ្នាពីលទ្ធផល ឬការណែនាំនៅលើកុំព្យូទ័រ ឬឧបករណ៍ឆ្លាតវៃ។

ការប្រើសេវាកម្ម កីឡា

ការប្រើសេវាកម្ម **កីឡា**

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ជ្រើសរើសកាត **កីឡា**។

03 អ្នកអាចមើលបញ្ជីក្រុមតាមលីគ និងព័ត៌មានលម្អិត។
ការជ្រើសរើសលីគកីឡាដែលចង់មើលអាចឱ្យអ្នកពិនិត្យមើលព័ត៌មានអំពីលីគនោះបាន។

04 សូមចុច **ក្រុមរបស់ខ្ញុំ** ដើម្បីចុះឈ្មោះក្រុម ឬកីឡាករដែលអ្នកចូលចិត្ត។
ការចុះឈ្មោះក្រុម
ឬកីឡាករអាចឱ្យអ្នកពិនិត្យមើលព័ត៌មានថ្មីៗអំពីការប្រកួតផ្សាយបន្តផ្ទាល់ និងកាលវិភាគការប្រកួតនាពេលខាងមុខនៅក្នុង **ក្រុមរបស់ខ្ញុំ**។

- អ្នកត្រូវតែចុះឈ្មោះចូលគណនី LG របស់អ្នក ដើម្បីចុះឈ្មោះក្រុម ឬកីឡាករដែលអ្នកពេញចិត្ត។
- ស្ថានភាព ឬកាលវិភាគនៃការប្រកួតអាចខុសគ្នាពីស្ថានភាព ឬកាលវិភាគជាក់ស្តែង ផ្អែកលើស្ថានភាពរបស់ក្រុមហ៊ុនផ្តល់ទិន្នន័យ។
- ប្រហែលជាមិនអាចប្រើម៉ោងរោទ៍ក្នុងពេលជាក់ស្តែងបានទេ នៅពេលប្រើកម្មវិធីមួយចំនួន។
- អាចប្រើលក្ខណៈពិសេសនេះបាន តែនៅពេលដែលភ្ជាប់បណ្តាញប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការប្តូរការកំណត់ការជូនដំណឹងសម្រាប់កីឡាករ ឬក្រុមនីមួយៗ

អ្នកអាចទទួលបានការជូនដំណឹងអំពីការប្រកួតរបស់ក្រុម
ឬកីឡាករដែលអ្នកបានចុះឈ្មោះនៅក្នុង **ក្រុមរបស់ខ្ញុំ**
ទោះបីជានៅពេលកំពុងទស្សនាការប្រកួតក៏ដោយ។

01 នៅក្នុង **ក្រុមរបស់ខ្ញុំ** សូមជ្រើសរើសក្រុម ឬកីឡាករដែលអ្នកចង់ប្តូរ។

02 នៅក្នុងទំព័រលម្អិត សូមជ្រើសរើស **កំណត់ម៉ោងរោទ៍**។

ម៉ោងរោទ៍សម្រាប់ចាប់ផ្តើមការប្រកួត

ជូនដំណឹងអំពីការចាប់ផ្តើមការប្រកួតរបស់ក្រុម ឬកីឡាករដែលបានចុះឈ្មោះ។

ម៉ោងរោទ៍សម្រាប់ពិន្ទុក្នុងពេលជាក់ស្តែង

ជូនដំណឹងអំពីការប្រែប្រួលពិន្ទុនៅក្នុងការប្រកួត ដែលក្រុម
ឬកីឡាករដែលបានចុះឈ្មោះបានចូលរួម។

- ភាពញឹកញាប់នៃការជូនដំណឹងអាចមានភាពខុសគ្នាទៅតាមកីឡា។

ម៉ោងរោទ៍សម្រាប់លទ្ធផលនៃការប្រកួត

ជូនដំណឹងអំពីលទ្ធផលនៃការប្រកួតរបស់ក្រុម ឬកីឡាករដែលបានចុះឈ្មោះ។


- ដើម្បីបិទការជូនដំណឹងអំពី**កីឡា** សូមចុចប៊ូតុង••• នៅលើតេឡេបញ្ជាពីទំព័រដើម**កីឡា**
រួចកំណត់**មុខងារម៉ោងរោទ៍** ទៅ**បិទ**។

ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ

ការប្រើ មណ្ឌលទំព័រដើម

ការប្រើ **មណ្ឌលទំព័រដើម**

អ្នកអាចជ្រើសរើស ឬបញ្ជាឧបករណ៍ដែលបានភ្ជាប់ (ឧបករណ៍ចល័ត ឧបករណ៍ខាងក្រៅ
ឧបករណ៍ IoT នៅក្នុងផ្ទះ។ល។)។
ដំណើរការ **មណ្ឌលទំព័រដើម** ដោយចុចប៊ូតុង ⏎ នៅលើតេឡេបញ្ជា។
អ្នកក៏អាចចុចប៊ូតុង ⏎ ឱ្យជាប់នៅលើ Magic Remote បានផងដែរ។



1. អ្នកអាចជ្រើសរើសឧបករណ៍ខាងក្រៅ ឬការផ្សាយដែលភ្ជាប់ជាមួយរន្ធបញ្ចូលខាងក្រៅ។
2. ប្រើ Apple Home, AirPlay ដើម្បីបញ្ជាឧបករណ៍របស់អ្នក ហើយទស្សនាខ្លឹមសារពី iPad ឬ Mac របស់អ្នកនៅលើអេក្រង់។
   - ខ្លឹមសារ និងសេវាកម្មដែលមានផ្តល់ជូនតាមរយៈការភ្ជាប់ទៅ Apple Home និង AirPlay អាចមានការផ្លាស់ប្តូរដោយគ្មានការជូនដំណឹង។
3. អ្នកអាចទទួលបាន និងមើលខ្លឹមសារដូចជា ភាពយន្ត កម្មវិធីផ្សាយ រូបថត និងគេហទំព័រនៅលើគ្រប់ឧបករណ៍ដែលអាចផ្ទេរបានតាមរយៈ Chromecast ដូចជាទូរសព្ទឆ្លាតវៃ ឬកុំព្យូទ័រថេប្លេតជាដើម។
   - លក្ខណៈពិសេសនេះប្រហែលជាមិនអាចប្រើបាននៅប្រទេសមួយចំនួនទេ។
   - ឧបករណ៍ទាំងអស់ដែលអ្នកចង់ភ្ជាប់ជាមួយ Chromecast ត្រូវតែភ្ជាប់ជាមួយបណ្តាញតែមួយ។
4. អ្នកអាចចែករំលែកអេក្រង់ឧបករណ៍ឆ្លាតវៃរបស់អ្នក ឬរីករាយជាមួយខ្លឹមសាររបស់វាបានដោយភ្ជាប់ជាមួយឧបករណ៍ឆ្លាតវៃនោះ។
5. ឧបករណ៍បំពងសំឡេងដែលបានជ្រើសរើសបច្ចុប្បន្នត្រូវបានបង្ហាញ ហើយអ្នកអាចទៅកាន់អេក្រង់ការកំណត់របស់ឧបករណ៍បំពងសំឡេងបាន។
6. អ្នកអាចជ្រើសរើសឧបករណ៍ Bluetooth, ឧបករណ៍ផ្តុក USB, ឧបករណ៍ម៉ាស៊ីនមេបណ្តាញ និងកាមេរ៉ាដែលបានភ្ជាប់។
7. ផ្ទាំងត្រូវបានចាត់ប្រភេទដោយសេវាកម្មឧបករណ៍ IoT ដែលបានភ្ជាប់។ តាមរយៈការជ្រើសរើសផ្ទាំងនីមួយៗ អ្នកអាចមើលព័ត៌មានអំពីស្ថានភាពនៃឧបករណ៍ IoT ដែលបានភ្ជាប់ និងធ្វើប្រតិបត្តិការដែលពាក់ព័ន្ធ។
8. អ្នកអាចពិនិត្យមើលការណែនាំអំពីការតភ្ជាប់ សម្រាប់ប្រភេទនីមួយៗនៃ **ឧបករណ៍ IoT នៅក្នុងផ្ទះ**បាន។ អ្នកអាចភ្ជាប់ និងមើលឧបករណ៍ដែលចុះឈ្មោះដោយប្រើគណនី LG ThinQ ឬឧបករណ៍ IoT របស់អ្នក។

- ប្រសិនបើអ្នកនៅតំបន់ដែលមិនអាចប្រើកម្មវិធី LG ThinQ បាន ការតភ្ជាប់ឧបករណ៍ LG ThinQ នឹងមិនអាចប្រើបានទេ។
- ដើម្បីចុះឈ្មោះឧបករណ៍ IoT របស់អ្នក សូមជ្រើសរើស **ភ្ជាប់ឧបករណ៍ IoT** រួចអនុវត្តតាមការណែនាំ ដើម្បីប្រើការកំណត់។
- ប្រសិនបើអ្នកកំពុងគ្រប់គ្រងឧបករណ៍ខាងក្រៅ ពីកម្មវិធីទូរស័ព្ទរបស់អ្នក អ្នកប្រហែលជាមិនអាចគ្រប់គ្រងឧបករណ៍នោះពីឧបករណ៍នេះបានទេ។ សូមបិទកម្មវិធីទូរស័ព្ទដើម្បីគ្រប់គ្រងវាពីឧបករណ៍នេះ។
- ឧបករណ៍ IoT ដែលអាចភ្ជាប់ជាមួយឧបករណ៍នេះអាចនឹងមានការផ្លាស់ប្តូរដោយគ្មានការជូនដំណឹង។
- ឧបករណ៍ LG ThinQ ដែលអាចភ្ជាប់បាន និងមុខងារដែលអាចប្រើបានអាចខុសគ្នាពីឧបករណ៍ចល័តទាំងនោះ។

❾ អ្នកអាចស្វែងយល់អំពីរបៀបរៀបចំ **មណ្ឌល LG** សម្រាប់ការបញ្ជាឧបករណ៍ Matter។ តាមរយៈការកំណត់ឧបករណ៍នេះជា **មណ្ឌល LG** អាចឱ្យអ្នកគ្រប់គ្រងឧបករណ៍ Matter ដោយប្រើកម្មវិធី LG ThinQ សូម្បីនៅពេលអ្នកនៅក្រៅ។

- Matter
  គឺជាស្តង់ដារភ្ជាប់ទំនាក់ទំនងសកលដែលអាចឱ្យឧបករណ៍ឆ្លាតវៃក្នុងផ្ទះពីក្រុមហ៊ុនផលិតផ្សេងគ្នាដំណើរការជាមួយគ្នាក្នុងកម្មវិធីតែមួយ។

❿ ចាប់ផ្តើម **គណនី LG**។

⓫ **កែសម្រួលធាតុបញ្ចូល** : អ្នកអាចកែសម្រួលឈ្មោះឧបករណ៍ដែលបានភ្ជាប់ ឬអនុវត្តការកំណត់ដែលពាក់ព័ន្ធ។
ការកំណត់អង្គបញ្ជាសកល : ទៅកាន់កម្មវិធី **ការកំណត់អង្គបញ្ជាសកល** ។
បញ្ជីកែសម្រួល : អ្នកអាចលាក់ ឬបង្ហាញ ឧបករណ៍ IoT នៅក្នុងផ្ទះដែលបានភ្ជាប់ និងរៀបចំបញ្ជីឡើងវិញ។
លុបឧបករណ៍ : អ្នកអាចលុបឧបករណ៍ដែលបានភ្ជាប់។
អ្នកអាចលុបឧបករណ៍មួយចំនួនពីឧបករណ៍នេះតែប៉ុណ្ណោះ។
ការជូនដំណឹង : អ្នកអាចបើក ឬបិទការជូនដំណឹងនៅលើឧបករណ៍ដែលបានភ្ជាប់។
បង្ហាញឧបករណ៍ IoT ដែលអាចភ្ជាប់បាន : បង្ហាញឧបករណ៍ដែលអាចភ្ជាប់នៅលើអេក្រង់បាន។
ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។
ចាកចេញពីកម្មវិធី : បិទកម្មវិធីពីការដំណើរការនៅផ្នែកខាងក្រោយ។

⓬ បិទកម្មវិធី។

- ធាតុដែលអាចកំណត់បានមានភាពខុសគ្នា ទៅតាមម៉ូដែល ឬតំបន់។

ការភ្ជាប់ ឧបករណ៍ IoT នៅក្នុងផ្ទះ

អ្នកអាចពិនិត្យមើល និងគ្រប់គ្រងស្ថានភាពនៃ ឧបករណ៍ IoT នៅក្នុងផ្ទះ ដែលបានភ្ជាប់។

01 ដំឡើងកម្មវិធី LG ThinQ នៅលើស្មាតហ្វូនរបស់អ្នក។

02 ចូលគណនី LG ThinQ របស់អ្នក រួចចុះឈ្មោះឧបករណ៍ LG ThinQ របស់អ្នក។

03 ដំណើរការ **មណ្ឌលទំព័រដើម** ដោយចុចប៊ូតុង នៅលើតេឡេបញ្ជា។

04 ជ្រើសរើស នៅជ្រុងផ្នែកខាងលើ។

05 ចូលគណនី LG ThinQ របស់អ្នក។ បញ្ជីឧបករណ៍ LG ThinQ ដែលបានចុះឈ្មោះរួចហើយនឹងលេចឡើង។

- ធាតុដែលអាចកំណត់បានមានភាពខុសគ្នា ទៅតាមម៉ូដែល ឬតំបន់។
- ប្រសិនបើអ្នកនៅតំបន់ដែលមិនអាចប្រើកម្មវិធី LG ThinQ បាន ការតភ្ជាប់ឧបករណ៍ LG ThinQ នឹងមិនអាចប្រើបានទេ។
- ដើម្បីចុះឈ្មោះឧបករណ៍ IoT របស់អ្នក សូមជ្រើសរើស **ភ្ជាប់ឧបករណ៍ IoT** រួចអនុវត្តតាមការណែនាំដើម្បីប្រើការកំណត់។
- ប្រសិនបើអ្នកកំពុងគ្រប់គ្រងឧបករណ៍ខាងក្រៅ ពីកម្មវិធីទូរស័ព្ទរបស់អ្នក អ្នកប្រហែលជាមិនអាចគ្រប់គ្រងឧបករណ៍នោះពីឧបករណ៍នេះបានទេ។ សូមបិទកម្មវិធីទូរស័ព្ទដើម្បីគ្រប់គ្រងវាពីឧបករណ៍នេះ។
- ឧបករណ៍ IoT ដែលអាចភ្ជាប់ជាមួយឧបករណ៍នេះអាចនឹងមានការផ្លាស់ប្តូរដោយគ្មានការជូនដំណឹង។
- ឧបករណ៍ LG ThinQ ដែលអាចភ្ជាប់បាន និងមុខងារដែលអាចប្រើបានអាចខុសគ្នាពីឧបករណ៍ចល័តទាំងនោះ។

ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយប្រើ LG ThinQ

ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយប្រើ LG ThinQ

អ្នកអាចប្រើមុខងារផ្សេងៗជាច្រើនដោយភ្ជាប់ឧបករណ៍ជាមួយឧបករណ៍ឆ្លាតវៃ។

ការភ្ជាប់ឧបករណ៍ឆ្លាតវៃរបស់អ្នកជាមួយផលិតផលដោយប្រើកម្មវិធី LG ThinQ

01 ទាញយកកម្មវិធី LG ThinQ ពីស្តូរនៃកម្មវិធីក្នុងឧបករណ៍ឆ្លាតវៃរបស់អ្នក។

02 ភ្ជាប់ឧបករណ៍ និងឧបករណ៍ឆ្លាតវៃទៅបណ្តាញតែមួយ។

03 បើកដំណើរការកូនកម្មវិធី LG ThinQ ដែលបានបញ្ចូលក្នុងឧបករណ៍ទំនើបរបស់អ្នក។

04 អនុវត្តតាមការណែនាំនៅលើកម្មវិធី LG ThinQ ដើម្បីភ្ជាប់ឧបករណ៍ឆ្លាតវៃរបស់អ្នក។

- នៅពេលព័ត៌មានគណនី LG ThinQ របស់អ្នកត្រូវបានភ្ជាប់ជាមួយឧបករណ៍ អ្នកអាចគ្រប់គ្រងឧបករណ៍ IoT ដែលបានភ្ជាប់ជាមួយគណនីរបស់អ្នកដោយប្រើ **មណ្ឌលទំព័រដើម**។
- ការបញ្ជាតាមសំឡេងក៏អាចធ្វើឡើងតាមរយៈ ឧបករណ៍បំពងសំឡេងឆ្លាតវៃ ដែលភ្ជាប់គណនីនៅក្នុងការកំណត់របស់កម្មវិធី LG ThinQ ។
- សេវាកម្មនេះប្រហែលជាមិនមានផ្តល់ជូនទេ អាស្រ័យលើប្រទេស។

ការគ្រប់គ្រងឧបករណ៍របស់អ្នកជាមួយកម្មវិធី LG ThinQ

អ្នកអាចចុចប៊ូតុងនៅលើអេក្រង់របស់ឧបករណ៍ឆ្លាតវៃអ្នក ដើម្បីបញ្ជាឧបករណ៍នេះ។

- ការបញ្ជាខ្លះអាចត្រូវបានកម្រិតនៅត្រឹមម៉ូដធាតុចូលពីខាងក្រៅ។
- អេក្រង់ និងលទ្ធភាពបំពេញមុខងារនៃកម្មវិធី ស្ថិតនៅក្រោមការកែប្រែដោយគ្មានការជូនដំណឹងជ្រាប់ជាមុន។
- មុខងារពិសេសៗដែលអាចរកបានអាចនឹងប្រែប្រួលតាមប្រទេស និងប្រព័ន្ធប្រតិ (OS)។

ការប្រើកាមេរ៉ារបស់ឧបករណ៍ឆ្លាតវៃដែលបានភ្ជាប់នៅលើឧបករណ៍

អ្នកអាចប្រើកាមេរ៉ារបស់ឧបករណ៍ឆ្លាតវៃដែលបានភ្ជាប់ជាមួយ LG ThinQ នៅលើឧបករណ៍។

- ដើម្បីទទួលបានការតភ្ជាប់ដែលទុកចិត្តបាន
  សូមដំឡើងកំណែឧបករណ៍ដែលបានភ្ជាប់ជាមួយឧបករណ៍នេះទៅកំណែ OS ចុងក្រោយបំផុតជានិច្ច។
- អាស្រ័យលើម៉ូដែល ឬក្រុមហ៊ុនផលិតឧបករណ៍ឆ្លាតវៃ កាមេរ៉ាប្រហែលជាមិនអាចភ្ជាប់បានទេ។
- តភ្ជាប់ឧបករណ៍ជាមួយរ៉ោតទ័រ 5 Ghz ពីព្រោះការប្រើអាចមានការរំខានដោយបរិយាកាសឥតខ្សែ។
- កម្រិតឆ្លើយតបអាចខុសគ្នា អាស្រ័យលើបរិយាកាសអ្នកប្រើប្រាស់។
- ប្រសិនបើនៅតែមិនអាចភ្ជាប់បាន សូមបិទផលិតផល
  និងឧបករណ៍ដែលអ្នកកំពុងព្យាយាមភ្ជាប់។ បន្ទាប់មកបើកវិញ រួចព្យាយាមម្តងទៀត។


ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយដាក់ស្លាក NFC

ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយដាក់ស្លាក NFC

ទំនាក់ទំនងនៅជិត (NFC) គឺជាបច្ចេកវិទ្យាដែលអាចឱ្យអ្នកផ្ទេរ
និងទទួលព័ត៌មានបានយ៉ាងងាយស្រួល ដោយមិនចាំបាច់មានការកំណត់ដាច់ដោយឡែក។
តាមរយៈការយកឧបករណ៍ឆ្លាតវៃមកដាក់ជិតតេឡេបញ្ជាដែលបានបង្កប់ NFC
អ្នកអាចដំឡើងកម្មវិធី LG ThinQ រួចភ្ជាប់ឧបករណ៍នោះជាមួយឧបករណ៍។

01 បើក NFC នៅក្នុងការកំណត់របស់ឧបករណ៍ឆ្លាតវៃ។
ដើម្បីប្រើ NFC ជាមួយឧបករណ៍ Android សូមកំណត់ជម្រើស NFC
ដើម្បីបើកស្លាកអាន/សរសេរនៅក្នុងការកំណត់របស់ឧបករណ៍ឆ្លាតវៃ។
ការកំណត់ NFC អាចមានភាពខុសគ្នា អាស្រ័យលើឧបករណ៍។

02 បើកអេក្រង់ឧបករណ៍ឆ្លាតវៃ រួចដាក់វានៅជិត N នៅលើតេឡេបញ្ជា។
ចម្ងាយអតិបរមាសម្រាប់ការភ្ជាប់ NFC គឺ 1 cm។



03 អនុវត្តតាមការណែនាំ ដើម្បីដំឡើងកម្មវិធី LG ThinQ នៅលើឧបករណ៍ឆ្លាតរបស់អ្នក។

04 ដាក់ស្លាកឧបករណ៍ឆ្លាតរបស់អ្នកជាមួយតេឡេបញ្ជាម្តងទៀត។
អ្នកអាចរីករាយជាមួយខ្លឹមសាររបស់ឧបករណ៍ឆ្លាតរ៉ែ ឬភ្ជាប់វាទៅអេក្រង់តាមរយៈកម្មវិធី LG ThinQ។

- ប្រទេសមួយចំនួនមិនអាចដំឡើងកម្មវិធី LG ThinQ ដែលមានស្លាក NFC បានទេ។ ក្នុងករណីនេះ សូមទាញយកកម្មវិធី LG ThinQ ពីហាងកម្មវិធីនីមួយៗ។
- ឧបករណ៍ឆ្លាតរ៉ែដែលអាចប្រើ NFC ទើបអាចប្រើលក្ខណៈពិសេសនេះបាន។
- អាស្រ័យទៅតាមឧបករណ៍ឆ្លាតរ៉ែ ទីតាំង NFC អាចមានភាពខុសគ្នា។ សម្រាប់ព័ត៌មានបន្ថែម សូមមើលការណែនាំសម្រាប់អ្នកប្រើប្រាស់របស់ឧបករណ៍។
- មុខងារដែលបានភ្ជាប់តាមរយៈ NFC អាចនឹងខុសគ្នា អាស្រ័យលើឧបករណ៍ឆ្លាតរ៉ែ។
- អាចប្រើលក្ខណៈពិសេសនេះបាន លុះត្រាតែតេឡេបញ្ជាមាននិមិត្តសញ្ញា NFC។
- តេឡេបញ្ជាមួយចំនួនមាន N នៅខាងក្រោយនៃតេឡេបញ្ជា។

ការបញ្ចាំងអេក្រង់របស់ឧបករណ៍ឆ្លាតរ៉ែ

ការបញ្ចាំងអេក្រង់របស់ឧបករណ៍ឆ្លាតរ៉ែ

01 បើកមុខងារ Screen Share នៅលើឧបករណ៍ឆ្លាតរ៉ែ។

02 ឧបករណ៍របស់អ្នកនឹងត្រូវបានបង្ហាញនៅក្នុងបញ្ជីឧបករណ៍ដែលមាន។

03 ជ្រើសរើសឧបករណ៍របស់អ្នក និងស្នើសុំការតភ្ជាប់។

04 ជ្រើសរើស **ទទួលយក** ក្នុងបង្អួចលេចឡើងស្នើការតភ្ជាប់។

05 នៅពេលការតភ្ជាប់ត្រូវបានបញ្ចប់ អេក្រង់នៃឧបករណ៍ដែលបានភ្ជាប់នឹងបង្ហាញ។

- នៅពេលអ្នកភ្ជាប់ **Screen Share** ជាលើកដំបូង ផ្ទាំងលោតឡើងនឹងបង្ហាញ ដែលអនុញ្ញាតឱ្យអ្នកជ្រើសរើស **ទទួលយក**, **បដិសេធ** ឬ **ទប់ស្កាត់**។

- **ទទួលយក** : អ្នកអាចភ្ជាប់ឧបករណ៍បាន។
  ផ្ទាំងលោតឡើងបង្ហាញពីការតភ្ជាប់នឹងមិនបង្ហាញជាលើកទីពីរទេ។
- **បដិសេធ** : កុំភ្ជាប់ឧបករណ៍។ ប្រសិនបើអ្នកព្យាយាមភ្ជាប់ម្តងទៀត ផ្ទាំងលោតឡើងនឹងបង្ហាញ។
- **ទប់ស្កាត់** : កុំភ្ជាប់ឧបករណ៍។ ទោះបីជាអ្នកព្យាយាមភ្ជាប់ម្តងទៀត
  ក៏ផ្ទាំងលោតឡើងមិនបង្ហាញដែរ ហើយការតភ្ជាប់នឹងមិនដំណើរការទេ។
  ដើម្បីបិទ **ទប់ស្កាត់** សូមចូលទៅកាន់ → → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** រួចជ្រើសរើស
  លុបប្រវត្តិនៃការតភ្ជាប់។

- ដើម្បីទទួលបានការតភ្ជាប់ដែលទុកចិត្តបាន
  សូមដំឡើងកំណែឧបករណ៍ដែលបានភ្ជាប់ជាមួយឧបករណ៍នេះទៅកំណែ OS
  ចុងក្រោយបំផុតជានិច្ច។
- អាស្រ័យលើម៉ូដែល ឬក្រុមហ៊ុនផលិតឧបករណ៍ឆ្លាតវៃ មុខងារ Screen Share
  ប្រហែលជាមិនអាចប្រើបានទេ។
- អាចភ្ជាប់ iPad, iPhone, Mac ។ល។ បានតាមរយៈ AirPlay។ សម្រាប់ព័ត៌មានបន្ថែម សូមមើល
  ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ → **ការប្រើ មណ្ឌលទំព័រដើម** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
- តភ្ជាប់ឧបករណ៍ជាមួយរ៉ោតទ័រ 5 Ghz ពីព្រោះការប្រើអាចមានការរំខានដោយបរិយាកាស
  ឥតខ្សែ។
- កម្រិតឆ្លើយតបអាចខុសគ្នា អាស្រ័យលើបរិយាកាសអ្នកប្រើប្រាស់។
- វាខុសគ្នាទៅតាមឧបករណ៍។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ដែលអ្នកចង់តភ្ជាប់
  សូមអានការណែនាំពីរបៀបប្រើប្រាស់របស់វា។
- ប្រសិនបើនៅតែមិនអាចភ្ជាប់បាន សូមបិទផលិតផល
  និងឧបករណ៍ដែលអ្នកកំពុងព្យាយាមភ្ជាប់។ បន្ទាប់មកបើកវិញ រួចព្យាយាមម្តងទៀត។

ការចាក់សំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈឧបករណ៍បំពងសំឡេងខាងក្នុង

ការចាក់សំឡេងពីឧបករណ៍ឆ្លាតវៃតាមរយៈឧបករណ៍បំពងសំឡេងខាងក្នុង

ភ្ជាប់ឧបករណ៍ឆ្លាតវៃតាមរយៈ Bluetooth
ដើម្បីចាក់សំឡេងពីឧបករណ៍ឆ្លាតវៃតាមឧបករណ៍បំពងសំឡេងខាងក្នុង។

01 បើក Bluetooth របស់ឧបករណ៍ឆ្លាតវៃ បន្ទាប់មកជ្រើសរើសឧបករណ៍នេះពីបញ្ជីឧបករណ៍។

02 ឧបករណ៍នេះនឹងត្រូវបានភ្ជាប់ជាមួយឧបករណ៍ឆ្លាតវៃ។


- ប្រហែលជារកមិនឃើញឧបករណ៍នៅក្នុងបញ្ជីឧបករណ៍ឆ្លាតវៃទេ នៅពេលធ្វើប្រតិបត្តិការ
  ដូចជានៅពេលកំពុងស្វែងរកប៉ុស្តិ៍ផ្សាយ ឬកំពុងរៀបចំឧបករណ៍បំពងសំឡេង Bluetooth។
  ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

- ប្រសិនបើអ្នកភ្ជាប់ឧបករណ៍ឆ្លាតវៃជាមួយឧបករណ៍តាមរយៈ Bluetooth និងស្តាប់សំឡេងរបស់ឧបករណ៍ឆ្លាតវៃតាមរយៈឧបករណ៍បំពងសំឡេងខាងក្រៅ នោះឧបករណ៍អាចនឹងមិនភ្ជាប់ជាមួយឧបករណ៍ឆ្លាតវៃផ្សេងទៀតទេ។

ការតភ្ជាប់កាមេរ៉ា

ការតភ្ជាប់កាមេរ៉ា

តាមរយៈការតភ្ជាប់កាមេរ៉ាជាមួយឧបករណ៍ អ្នកអាចប្រើវាសម្រាប់ការប្រជុំតាមវីដេអូ និងធ្វើអ្វីៗផ្សេងទៀត។
ចុចប៊ូតុង ⌂ នៅលើតេឡេបញ្ជាដើម្បីបើកដំណើរការ **កាមេរ៉ា**។



❶ ជ្រើសរើសប្រភេទកាមេរ៉ាសម្រាប់ប្រើ។ អេក្រង់ការកំណត់កាមេរ៉ាខាងក្រោមត្រូវបានប្តូរ។

- អ្នកអាចភ្ជាប់កាមេរ៉ា USB ទៅរន្ធបញ្ចូល USB ហើយប្រើកាមេរ៉ាទាំងនោះបានភ្លាមៗដោយជ្រើសរើស **បើកកាមេរ៉ា**។
- អ្នកអាចប្រើកាមេរ៉ារបស់ឧបករណ៍ឆ្លាតវៃដែលបានភ្ជាប់ជាមួយ LG ThinQ នៅលើឧបករណ៍។ សូមពិនិត្យមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការភ្ជាប់ឧបករណ៍ឆ្លាតវៃដោយប្រើ LG ThinQ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានបន្ថែមអំពីសកម្មភាពនេះ។

❷ ជ្រើសរើសកម្មវិធី ដើម្បីប្រើជាកាមេរ៉ា។

- កម្មវិធី និងសេវាកម្មដែលអាចប្រើបានអាចខុសគ្នាទៅតាមប្រទេស។

❸ អ្នកអាចពិនិត្យមើលកាមេរ៉ាដែលបានភ្ជាប់។ ប្រសិនបើអ្នកបានភ្ជាប់ជាមួយកាមេរ៉ា USB ច្រើន អ្នកអាចជ្រើសរើសកាមេរ៉ាមួយដែលអ្នកចង់ប្រើបាន។

❹ កំណត់ទៅជា **បើក**។ តែតម្រូវកាមេរ៉ា ដើម្បីផ្តោតមនុស្ស ឬវត្ថុឱ្យចំកណ្តាលដោយស្វ័យប្រវត្តិ ដែលត្រូវបានសម្គាល់ជាមុខនៅលើអេក្រង់។

- សម្គាល់មនុស្សបានរហូតដល់ប្រាំមួយនាក់។

- វាអាចត្រូវបានសម្គាល់ជាមុខ ទោះបីជាវាមិនមែនជាមនុស្សក៏ដោយ។
- ប្រសិនបើចម្ងាយរវាងកាមេរ៉ា និងវត្ថុស្ថិតនៅឆ្ងាយពេក
  ការសម្គាល់មុខអាចនឹងមិនដំណើរការទេ។

❺ អ្នកអាចកំណត់ទីតាំងរបស់កាមេរ៉ា និងពង្រីក ឬបង្រួមនៅលើអេក្រង់បាន។

❻ **ការណែនាំសម្រាប់អ្នកប្រើប្រាស់** : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។
ចាកចេញពីកម្មវិធី : បិទកម្មវិធីពីការដំណើរការនៅផ្ទៃខាងក្រោយ។

❼ បិទកម្មវិធី។

- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។
- សម្រាប់ការពណ៌នាលម្អិតអំពីមុខងាររបស់កាមេរ៉ា សូមមើលសៀវភៅណែនាំរបស់ឧបករណ៍។
- ត្រូវទិញកាមេរ៉ាដាច់ដោយឡែក។
  សូមណែនាំអ្នកឱ្យប្រើផលិតផលដែលបានធ្វើតេស្តលើភាពត្រូវគ្នាជាមួយឧបករណ៍នេះ។
  កាមេរ៉ាដែលត្រូវគ្នាអាចប្រែប្រួលដោយគ្មានការជូនដំណឹងជាមុន។
  Amcrest : AWC496, AWC195-B
  Logitech : BRIO, C920, C920c, C920e, C920s, C920x, C922 Pro, C922x, C925e, C930c, C930e
  LG Smart Cam
- កាមេរ៉ាប្រហែលជាមិនអាចភ្ជាប់នៅលើឧបករណ៍បានទេ
  ដោយអាស្រ័យលើស្ថានភាពដំឡើងឧបករណ៍។
- ឧបករណ៍ផ្ទុកយូអេសប៊ីអាចមិនដំណើរការ ឬដំណើរការមិនពេញលេញទេ នៅពេលហាប់យូអេសប៊ី
  ឬខ្សែត្រូវបានប្រើ។

ការប្រជុំតាមវីដេអូ

អ្នកអាចធ្វើការប្រជុំតាមវីដេអូដោយប្រើគេហទំព័រអ៊ីនធឺណិត
ឬកម្មវិធីដែលអាចប្រើការប្រជុំតាមវីដេអូបាន។

- មុខងារនេះប្រហែលជាមិនអាចប្រើនៅក្នុងម៉ូដែល ឬប្រទេសមួយចំនួនបានទេ។
- ចាំបាច់ត្រូវមានការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ដើម្បីប្រើមុខងារនេះបាន។
- គុណភាពរូបភាពប្រហែលជាមិនច្បាស់ទេ ដោយអាស្រ័យលើមជ្ឈដ្ឋានបណ្តាញ
  ឬប្រតិបត្តិការរបស់កាមេរ៉ា។
- អ្នកអាចពិនិត្យមើលកម្មវិធី
  ឬគេហទំព័រប្រជុំតាមវីដេអូនៅក្នុងបញ្ជីសេវាកម្មអ៊ីនធឺណិតរបស់**ការិយាល័យនៅផ្ទះ**បាន។
  ការប្រើប្រាស់កម្មវិធី ឬគេហទំព័រប្រជុំតាមវីដេអូអាចអនុលោមតាមការផ្អាក ឬការផ្លាស់ប្តូរ
  អាស្រ័យលើកាល:ទេស:របស់ក្រុមហ៊ុនផ្តល់សេវាកម្ម។

ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី **មុខងារមើលច្រើន**

តាមរយៈការចុច **មុខងារមើលច្រើន** អ្នកអាចដំណើរការអេក្រង់វីដេអូ ឬអេក្រង់ផ្សាយ
និងកាមេរ៉ាក្នុងពេលដំណាលគ្នា។ សម្រាប់ព័ត៌មានបន្ថែម សូមមើល
ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីមុខងារឆ្លាតវៃ → **ការប្រើ មុខងារមើលច្រើន** ក្នុង
ការណែនាំសម្រាប់អ្នកប្រើប្រាស់។

- មុខងារនេះអាចប្រើបាននៅលើម៉ូដែល ដែលអាចប្រើមុខងារ **មុខងារមើលច្រើន** តែប៉ុណ្ណោះ។
- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។

ការភ្ជាប់ឧបករណ៍ផ្ទុក USB

ការភ្ជាប់ឧបករណ៍ផ្ទុក USB

ភ្ជាប់ឧបករណ៍ផ្ទុក USB (USB HDD, បន្ទះ USB) ជាមួយរន្ធ USB នៅលើឧបករណ៍នេះ ដើម្បីរីករាយនឹងឯកសារឌីមសារដែលរក្សាទុកនៅលើឧបករណ៍ទំហំផ្ទុក USB នៅលើឧបករណ៍នេះ។

ជំនួយសម្រាប់ប្រើប្រាស់ឧបករណ៍ផ្ទុកយូអេសប៊ី

- ឧបករណ៍ផ្ទុកយូអេសប៊ីដែលមានកម្មវិធីស្គាល់ដែលភ្ជាប់មកជាមួយដោយស្វ័យប្រវត្តិ ឬប្រើកម្មវិធីបញ្ជាផ្ទាល់របស់អ្នកមិនអាចស្គាល់។
- ឧបករណ៍ផ្ទុកយូអេសប៊ីមួយចំនួន អាចមិនស្គាល់ ឬមានដំណើរការមិនស្រួល។
- បើអ្នកប្រើខ្សែយូអេសប៊ី ឧបករណ៍ផ្ទុកយូអេសប៊ីអាចមិនស្គាល់ឬមិនដំណើរការត្រឹមត្រូវ។
- សូមប្រើតែឧបករណ៍ផ្ទុកយូអេសប៊ីដែលបានហ្វ័រម៉ាតជាមួយប្រព័ន្ធឯកសារ FAT32, exFAT ឬ NTFS ដែលបានផ្តល់ដោយប្រព័ន្ធប្រតិបត្តិការ Windows។
- វាត្រូវបានផ្តល់យោបល់ឲ្យអ្នកប្រើថាសរឹងយូអេសប៊ីខាងក្រៅដែលមានតង់ស្យុង5V ឬតិចជាងនេះ ហើយតង់ស្យុងបច្ចុប្បន្នគឺ 500 mA ឬតិចជាងនេះ។ ប្រសិនបើអ្នកប្រើឧបករណ៍ដែលប្រើរ៉ុល/ចរន្តភ្លើង ច្រើនជាង់រ៉ុល/ចរន្តភ្លើងដែលបានកំណត់ ឧបករណ៍នោះអាចនឹងដំណើរការមិនបានត្រឹមត្រូវទេ ដោយសារតែកង្វះចរន្តភ្លើង។
- យើងសូមណែនាំឱ្យអ្នកប្រើប្រាស់ឧបករណ៍ផ្ទុក USB ឬហាប់ USB ដែលមានឧបករណ៍ផ្គត់ផ្គង់ថាមពល។
- យើងសូមណែនាំឱ្យប្រើឧបករណ៍ផ្ទុកដែលមានទំហំ 32GB សម្រាប់ USB ហើយសម្រាប់ Hard disk ត្រូវមានទំហំត្រឹម 2TB ចុះ។
- បើថាសរឹងយូអេសប៊ីមានមុខងារសន្សំថាមពលមិនដំណើរការ បិទថាសរឹង ហើយបើកឡើងវិញ ដើម្បីឲ្យវាដំណើរការត្រឹមត្រូវ។ សូមមើលសៀវភៅរបស់ម្ចាស់សម្រាប់ព័ត៌មានបន្ថែមអំពីថាសរឹងយូអេសប៊ី។
- ទិន្នន័យក្នុងឧបករណ៍ផ្ទុកយូអេសប៊ីអាចខូច ដូច្នេះវាត្រូវបានផ្តល់យោបល់ឲ្យអ្នកបម្រុងទុកឯកសារដែលសំខាន់។ អ្នកប្រើទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងឯកសារ។ ក្រុមហ៊ុនផលិតមិនទទួលខុសត្រូវ។
- ចុចប៊ូតុង ⏏ លើតេឡេ។ ដើម្បីលុបឧបករណ៍ផ្ទុក USB សូមចុចប៊ូតុង **ដកចេញ** ដែលលេចឡើងនៅផ្នែកខាងលើ នៅពេលដែលអ្នកផ្តោតលើឧបករណ៍ផ្ទុកដែលអ្នកចង់លុប។ ប្រសិនបើអ្នកផ្តាច់ឧបករណ៍ផ្ទុក USB ដោយមិនជ្រើសរើស **ដកចេញ** នោះបញ្ហាអាចកើតឡើងនៅក្នុងឧបករណ៍ ឬឧបករណ៍ផ្ទុកនេះ។

- នៅពេលដែលអ្នកភ្ជាប់ឧបករណ៍ផ្ទុក USB នៃប្រព័ន្ធឯកសារដែលឧបករណ៍នេះមិនស្គាល់ ជាមួយនឹងរន្ធ USB សារទម្រង់នេះនឹងលេចឡើង។ ដើម្បីប្រើឧបករណ៍ផ្ទុក USB ដែលបានភ្ជាប់ អ្នកគួរតែលុបឧបករណ៍ជាមុនសិន។
  ការឈូសនឹងលុបទិន្នន័យដែលរក្សាទុកនៅលើឧបករណ៍ផ្ទុក USB ទាំងអស់ ហើយឧបករណ៍នេះត្រូវបានឈូសដោយប្រើប្រព័ន្ធឯកសារ FAT32, exFAT ឬ NTFS។
- ដំណើរការ **មណ្ឌលទំព័រដើម** ដោយចុចប៊ូតុង នៅលើតេឡេបញ្ជា។ ជ្រើសរើសយូអេសប៊ីដែល បានតភ្ជាប់ពី **មណ្ឌលទំព័រដើម** ហើយជ្រើសរើសប៊ូតុង **សម្អាត** ដើម្បីហ្វ័រម៉ាតឧបករណ៍ផ្ទុក យូអេសប៊ី។
- នៅពេលភ្ជាប់ឧបករណ៍ផ្ទុក USB ឯកសារ/សីមីចែដន្យអាចត្រូវបានបង្កើត ដើម្បីផ្តល់សេវាកម្មដូចជា ការរក្សាទុក និងទាញយករូបភាពតូចៗជាដើម។

ការចែករំលែកខ្លឹមសារនៅលើកុំព្យូទ័រ

មើលខ្លឹមសារដែលរក្សាទុកក្នុងកុំព្យូទ័ររបស់អ្នកនៅលើផលិតផល

អ្នកអាចរីករាយជាមួយវីដេអូ/តន្ត្រី/រូបថត ដែលរក្សាទុកនៅក្នុងកុំព្យូទ័ររបស់អ្នកនៅលើអេក្រង់ នៅពេលឧបករណ៍ទាំងនេះភ្ជាប់ជាមួយបណ្តាញតែមួយ។

រុករកខ្លឹមសារនៅក្នុងកុំព្យូទ័ររបស់អ្នក ដើម្បីមើលនៅលើអេក្រង់ (Windows 10/Windows 11)។

01 ភ្ជាប់ឧបករណ៍ និងកុំព្យូទ័ររបស់អ្នកជាមួយបណ្តាញតែមួយ។

02 ចុចកណ្តុរខាងស្តាំលើឯកសារដែលអ្នកចង់ចាក់ រួចជ្រើសរើស “ដោតចូលឧបករណ៍”។

03 ជ្រើសរើសឈ្មោះឧបករណ៍ដែលអ្នកចង់មើលពីបញ្ជីដែលបង្ហាញ នោះការចាក់នឹងចាប់ផ្តើមនៅលើឧបករណ៍នោះ។

- ទោះបីជានៅពេលភ្ជាប់ឧបករណ៍ច្រើនក៏ដោយ ក៏ឯកសារដែលបានជ្រើសរើសត្រូវបានចាក់តាមរយៈឧបករណ៍មួយតែប៉ុណ្ណោះ។ អត្រាចាក់អាចខុសគ្នាទៅតាមការតភ្ជាប់បណ្តាញ។
- ដើម្បីចាក់តាមឧបករណ៍ ឬប្រព័ន្ធប្រតិបត្តិការផ្សេងទៀត សូមមើលការណែនាំអំពីឧបករណ៍/ប្រព័ន្ធប្រតិបត្តិការដោយផ្ទាល់។

រុករក និងមើលខ្លឹមសារដែលរក្សាទុកនៅក្នុងកុំព្យូទ័រដោយប្រើឧបករណ៍ (Windows 10/Windows 11)

01 ភ្ជាប់ឧបករណ៍ និងកុំព្យូទ័ររបស់អ្នកជាមួយបណ្តាញតែមួយ។

02 បើកម៉ឺនុយ “ចាប់ផ្តើម” នៅលើអេក្រង់កុំព្យូទ័ររបស់អ្នក ស្វែងរក “ជម្រើសស្រ្តីមមេឌៀ”

បន្ទាប់មកជ្រើសរើសលទ្ធផលដែលបង្ហាញ។

03 ជ្រើសរើសប៊ូតុង “បើកមេឌៀកំពុងស្ទ្រីម” នៅក្នុងវិនដូដែលបើក។

04 អនុញ្ញាត “ជម្រើសស្ទ្រីមមេឌៀ” ទាំងអស់។

05 ជ្រើសរើស “យល់ព្រម” ដើម្បីរក្សាទុកការកំណត់នោះ។

06 ជ្រើសរើសកុំព្យូទ័រដែលបានភ្ជាប់នៅក្នុងកម្មវិធី **មណ្ឌលទំព័រដើម** នៅលើឧបករណ៍ បន្ទាប់មកជ្រើសរើស ហើយចាក់ឯកសារតាមដែលអ្នកចង់បាន។

- ដើម្បីចាក់តាមឧបករណ៍ ឬប្រព័ន្ធប្រតិបត្តិការផ្សេងទៀត សូមមើលការណែនាំអំពីឧបករណ៍/ប្រព័ន្ធប្រតិបត្តិការដោយផ្ទាល់។

បញ្ហាគឺថាវាទាមទារការយកចិត្តទុកដាក់ពិសេសកំឡុងពេលចែករំលែកមាតិកា

- ពិនិត្យមើលការកំណត់បណ្តាញរបស់អ្នក បើជម្រើសចែករំលែកមាតិកាមិនដំណើរការត្រឹមត្រូវ។
- តភ្ជាប់ឧបករណ៍ជាមួយរ៉ោតទ័រ 5 Ghz ពីព្រោះការប្រើអាចមានការរំខានដោយបរិយាកាសឥតខ្សែ។
- មិនអាចដំណើរការត្រឹមត្រូវ អាស្រ័យលើបរិស្ថានបណ្តាញ។
- ប្រសិនបើភ្ជាប់ឧបករណ៍ច្រើនជាមួយឧបករណ៍មួយ ខ្លឹមសារអាចមិនចាក់បានត្រឹមត្រូវទេ នៅពេលមានប្រតិបត្តិការម៉ាស៊ីនមេ។
- តម្រូវឱ្យមានរូតទ័រដែលប្រើហ្វ្រេកង់កម្រិត 5 GHz ដើម្បីមើលវីដេអូកម្រិត 1080p តាមរយៈមុខងារចែករំលែកខ្លឹមសារ។ ប្រសិនបើអ្នកប្រើរូតទ័រកម្រិត 2.4 GHz ដែលមានស្រាប់វីដេអូអាចនឹងមានភាពយឺតយ៉ាវ ឬបញ្ចាំងមិនបានត្រឹមត្រូវ។
- មុខងារចែករំលែកមាតិកាមិនអាចត្រូវបានគាំទ្រសម្រាប់រ៉ោតទ័រដែលមិនគាំទ្រការបញ្ជូនច្រើន។ សម្រាប់ព័ត៌មានបន្ថែម សូមយោងតាមមគ្គុទ្ទេសក៍អ្នកប្រើ ដែលភ្ជាប់មកជាមួយរ៉ោតទ័ររបស់អ្នក ឬទាក់ទងក្រុមហ៊ុនផលិត។
- ចំណងជើងត្រូវបានគាំទ្រតែលើឧបករណ៍បានតភ្ជាប់មួយចំនួនតែប៉ុណ្ណោះ។
- ប្រសិនបើអ្នកបានបន្ថែមឯកសារអក្សររត់បន្ទាប់ពីនោះ សូមបិទថតរួមនៅលើកុំព្យូទ័រ រួចបើកវាម្តងទៀត។
- ឯកសារ DRM ក្នុងឧបករណ៍បានតភ្ជាប់មិននឹងលេងទេ។
- ទោះបីជាទម្រង់ឯកសារដែលអាចប្រើបានដោយឧបករណ៍នេះក៏ដោយ ក៏ទម្រង់ឯកសារដែលអាចប្រើបានអាចខុសគ្នា ដោយផ្អែកលើមជ្ឈដ្ឋានឧបករណ៍ដែលបានភ្ជាប់។
- បើមានថតឯកសារ ឬឯកសារច្រើនពេកក្នុងថតឯកសារ វាមិនអាចដំណើរការត្រឹមត្រូវទេ។
- ព័ត៌មានលើឯកសារដែលបាននាំចូលពីឧបករណ៍ដែលបានតភ្ជាប់មិនអាចលេងបានត្រឹមត្រូវទេ។
- ដោយអាស្រ័យលើការអ៊ីនកូដ ការផ្សាយមួយចំនួនមិនអាចលេងក្នុងទម្រង់ចែករំលែកមាតិកា។

ការបញ្ចាំងអេក្រង់កុំព្យូទ័រ

ការបញ្ចាំងអេក្រង់កុំព្យូទ័រ

តភ្ជាប់ដោយឥតខ្សែ (Windows 10/Windows 11)

01 សូមចុចរូបមជ្ឈមណ្ឌលនៃការជូនដំណឹងនៅលើរបារកិច្ចការលើអេក្រង់កុំព្យូទ័រ រួចជ្រើសរើសភ្ជាប់។

02 ជ្រើសរើសឧបករណ៍ដែលអ្នកចង់ភ្ជាប់ និងស្នើសុំការតភ្ជាប់។

03 បន្ទាប់ពីធ្វើការតភ្ជាប់រួច ឧបករណ៍នេះនឹងបង្ហាញអេក្រង់របស់កុំព្យូទ័រដែលបានភ្ជាប់។

- ដើម្បីទទួលបានការតភ្ជាប់ដែលទុកចិត្តបាន សូមដំឡើងកំណែឧបករណ៍ដែលបានភ្ជាប់ជាមួយឧបករណ៍នេះទៅកំណែ OS ចុងក្រោយបំផុតជានិច្ច។
- អ្នកគួរប្រើមុខងារនេះនៅចម្ងាយជិតៗ។
- ចាប់ផ្តើម Screen Share រហ័សជាងមុនដោយភ្ជាប់ឧបករណ៍ឆ្លាតវៃ ឬកុំព្យូទ័ររបស់អ្នកទៅបណ្តាញតែមួយជាមួយឧបករណ៍នេះ។
- ទោះបីជាវាអាចភ្ជាប់ដោយគ្មានរ៉ោតទ័រឥតខ្សែក៏ដោយ ការភ្ជាប់ឧបករណ៍របស់អ្នកជាមួយរ៉ោតទ័រ 5 GHz ត្រូវបានណែនាំពីព្រោះវាអាចប៉ះពាល់ដំណើរការដោយបរិស្ថានឥតខ្សែនៅជុំវិញ។
- កម្រិតឆ្លើយតបអាចខុសគ្នា អាស្រ័យលើបរិយាកាសអ្នកប្រើប្រាស់។
- វាខុសពីកំណែរបស់ Windows ។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ដែលអ្នកចង់តភ្ជាប់ សូមអានការណែនាំពីរបៀបប្រើប្រាស់របស់វា។
- ប្រសិនបើនៅតែមិនអាចភ្ជាប់បាន សូមបិទផលិតផល និងឧបករណ៍ដែលអ្នកកំពុងព្យាយាមភ្ជាប់។ បន្ទាប់មកបើកវិញ រួចព្យាយាមម្តងទៀត។

តតភ្ជាប់ដោយប្រើខ្សែ

01 ភ្ជាប់កុំព្យូទ័ររបស់អ្នកជាមួយឧបករណ៍ដោយប្រើខ្សែ HDMI។

02 សូមប្តូរប្រភពបញ្ចូលទិន្នន័យ ទៅរន្ធដែលបានភ្ជាប់ខ្សែរ HMDI នៅក្នុង ⌂ → **មណ្ឌលទំព័រដើម**។

03 បន្ទាប់ពីធ្វើការតភ្ជាប់រួច ឧបករណ៍នេះនឹងបង្ហាញអេក្រង់របស់កុំព្យូទ័រដែលបានភ្ជាប់។

- ប្រសិនបើការតភ្ជាប់របស់អ្នកមានបញ្ហា សូមមើល **ការដោះស្រាយបញ្ហា** → **ការដោះស្រាយបញ្ហានៃការតភ្ជាប់ឧបករណ៍** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីមុខងារឆ្លាតវៃ

ការប្រើ មុខងារមើលច្រើន

ការប្រើ **មុខងារមើលច្រើន**


អ្នកអាចបំបែកអេក្រង់ និងប្រើកម្មវិធីក្នុងពេលដំណាលគ្នាបាន។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 ជ្រើសរើស **មុខងារមើលច្រើន**។

03 ជ្រើសរើសធាតុដែលត្រូវប្រើ។
អេក្រង់ពីរ / **អេក្រង់ច្រើន** : អ្នកអាចជ្រើសរើសកម្មវិធីច្រើន និងមើលកម្មវិធីទាំងនោះនៅលើអេក្រង់តែមួយបាន។
ម៉ូនីទ័រកុំព្យូទ័រទ្វេ : អ្នកអាចមើលធាតុបញ្ចូលនៅលើអេក្រង់តាមរយៈ HDMI ក្នុងពេលដំណាលគ្នាបាន។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។



❶ នៅពេលអ្នកជ្រើសរើសកម្មវិធីពីរ អ្នកអាចប្តូររវាងទិដ្ឋភាព **ពីម្ខាងទៅម្ខាង** និង **រូបភាពក្នុងរូបភាព**។

❷ អ្នកអាចជ្រើសរើសកម្មវិធី ឬធាតុបញ្ចូលដែលអ្នកអាចដំណើរការបាននៅក្នុង **មុខងារមើលច្រើន**។

- ធាតុបញ្ចូល HDMI អាចនឹងមិនត្រូវបានបង្ហាញទេ នៅពេលថាមពលរបស់ឧបករណ៍ដែលបានភ្ជាប់ទៅ HDMI ត្រូវបានបិទ។

❸ អ្នកអាចជ្រើសរើសការរួមបញ្ចូលកម្មវិធីដែលបានប្រើថ្មីៗបំផុតបាន។

- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។
- អាចមានការរឹតបន្តឹងលើការដំណើរការ **មុខងារមើលច្រើន** ក្នុងមាតិកាមួយចំនួន។

- ប្រសិនបើកម្មវិធីដែលកំពុងដំណើរការមិនស្គាល់ **មុខងារមើលច្រើន** ទេ វានឹងណែនាំការរួមបញ្ចូលកម្មវិធីដែលអាចដំណើរការបាន។

ការប្រើប្រាស់មុខងារ មុខងារមើលច្រើន

ជ្រើសរើស 🔇/🔊 នៅលើអេក្រង់។
ប្តូរដើម្បីស្តាប់សំឡេងនៅលើអេក្រង់ដែលមិនមែនជាសំឡេងបញ្ចេញនាពេលបច្ចុប្បន្ន។
ជ្រើសរើស ⋯ នៅលើអេក្រង់។ អ្នកអាចកំណត់ជម្រើសបន្ថែម។

ផ្លាស់ប្តូរប្រភេទទិដ្ឋភាព

ប្តូរមុខងារ **មុខងារមើលច្រើន**។

បញ្ចូលកម្មវិធី

អ្នកអាចបញ្ចូល/លុបកម្មវិធី ដើម្បីប្រើនៅក្នុង **មុខងារមើលច្រើន**។

ប្តូរកម្មវិធី

អ្នកអាចប្តូរកម្មវិធី ដើម្បីប្រើនៅក្នុង **មុខងារមើលច្រើន**។

គ្រប់គ្រងនៅអេក្រង់ពេញ

អ្នកអាចដំណើរការកម្មវិធីនេះបានដោយប្តូរទៅអេក្រង់ពេញ។

ផ្លាស់ទី

អ្នកអាចផ្លាស់ទីទីតាំងនៃអេក្រង់រងបាន។

ទំហំ

អ្នកអាចប្តូរទំហំអេក្រង់រងបាន។

ចាកចេញពីកម្មវិធី

បិទកម្មវិធី។

ប្តូរធាតុបញ្ចូល

អ្នកអាចប្តូរធាតុបញ្ចូល ដើម្បីប្រើនៅក្នុង **ម៉ូនីទ័រកុំព្យូទ័រទ្វេ**។

ចាកចេញពីម៉ូនីទ័រកុំព្យូទ័រទ្វេ

បិទ **ម៉ូនីទ័រកុំព្យូទ័រទ្វេ**។

- មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។

- ជម្រើសដែលមានអាចមានភាពខុសគ្នា អាស្រ័យលើរបៀប **មុខងារមើលច្រើន** ដែលអ្នកកំពុងដំណើរការ។

គុណភាពបង្ហាញដែលបានគាំទ្រ៖ ម៉ូនីទ័រកុំព្យូទ័រទ្វេ

កម្រិតគុណភាព	ហ្វ្រេកង់បញ្ឈរ
1024 × 768	60
1360 × 768	60
1280 × 720	60
	50
1280 × 1024	60
1920 × 1080	60
	50

ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី វិចិត្រសាល

ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពី **វិចិត្រសាល**

អ្នកអាចរីករាយនឹងរូបភាពកម្រិតគុណភាពខ្ពស់ដែលផ្តល់ដោយធីមនីមួយៗ។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 ដំណើរការកម្មវិធី **វិចិត្រសាល**។
អ្នកអាចមើលព័ត៌មាន និងរូបភាពនៃធីមសំខាន់ជាមុនបាន។
ជ្រើសរើសមាតិកាដែលត្រូវចាក់។

- **ធីមរបស់ខ្ញុំ**

អ្នកអាចលុបធីមដែលបានដោនឡូត ឬជ្រើសរើសធីមដែលអ្នកពេញចិត្តដើម្បីចាក់បាន។

- ✕
  បិទកម្មវិធី។
  ដើម្បីបិទកម្មវិធីពីការដំណើរការនៅផ្ទៃខាងក្រោយ សូមចុចប៊ូតុង ••• លើតេឡេបញ្ជា រួចចុច **ចាកចេញពីកម្មវិធី** លើអេក្រង់។

ការប្រើ កម្មវិធីរុករកលើអ៊ីនធឺណិត

ការប្រើ កម្មវិធីរុករកលើអ៊ីនធឺណិត

អ្នកអាចចូលវេបសាយបាននៅពេលដែលអ្នកវាយបញ្ចូលអាសយដ្ឋានវេបសាយទៅក្នុងរបារ URL។
បើអ្នកវាយបញ្ចូលពាក្យស្វែងរក វានឹងរកមើលព័ត៌មានអំពីមូលដ្ឋាននៃពាក្យស្វែងរកលើកម្មវិធីស្វែងរក។

01 ចុចប៊ូតុង ⌂ លើតេឡេ។

02 បើកដំណើរការកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត**។



❶ អ្នកអាចរីហ្វ្រេសគេហទំព័រ ដែលអ្នកកំពុងមើលបាន។

❷ អ្នកអាចវាយបញ្ចូលអាសយដ្ឋានគេហទំព័រ ដើម្បីទៅកាន់គេហទំព័រជាក់លាក់ណាមួយ ឬបញ្ចូលពាក្យស្វែងរកដោយផ្ទាល់។

❸ អ្នកអាចមើលផ្ទាំង ដែលកំពុងតែបើកបច្ចុប្បន្ននេះ។

❹ អ្នកអាចពង្រីក ឬបង្រួម នៅពេលរុករកនៅលើគេហទំព័រ។
រារាំងការផ្សាយពាណិជ្ជកម្ម : អ្នកអាចទប់ស្កាត់ការផ្សាយពាណិជ្ជកម្មនៅក្នុងគេហទំព័រដែលអ្នកកំពុងមើល។
ប៉ុន្តែ ប៊ូតុងនេះបង្ហាញឡើង ក្នុងករណីដែលលក្ខណៈពិសេសនៃ ⋮ → **ការកំណត់** → **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ត្រូវបានកំណត់ទៅ **បើក** ប៉ុណ្ណោះ។
ការទស្សនាទូរទស្សន៍ : បំបែកអេក្រង់ឧបករណ៍ ដើម្បីបង្ហាញ។ អ្នកអាចរុករកនៅលើទំព័របណ្តាញនៅពេលកំពុងមើលឧបករណ៍នេះបាន។
ប្រវត្តិ : អ្នកអាចមើល និងលុបប្រវត្តិចូលមើលគេហទំព័របាន។
បន្ថែមទៅចំណាំ : អ្នកអាចបញ្ចូលគេហទំព័រ ដែលអ្នកកំពុងទស្សនាទៅក្នុងសំណព្វរបស់អ្នកបាន។
បញ្ចូលផ្លូវកាត់ទៅក្នុងអេក្រង់ដើម :
អ្នកអាចបញ្ចូលគេហទំព័រដែលអ្នកកំពុងទស្សនាជាផ្លូវកាត់ទៅក្នុងអេក្រង់ដើមរបស់អ្នក។
បញ្ចូលទៅផ្លូវកាត់ការិយាល័យនៅផ្ទះ :
អ្នកអាចបញ្ចូលគេហទំព័រដែលអ្នកកំពុងមើលជាផ្លូវកាត់ទៅកាន់**ការិយាល័យនៅផ្ទះ**បាន។
ចំណាំ : អ្នកអាចមើល និងលុបបញ្ជីគេហទំព័រដែលអ្នកបានបញ្ចូលទៅក្នុងសំណព្វរបស់អ្នកបាន។
ការកំណត់ : អ្នកអាចប្តូរការកំណត់កម្មវិធីរុករកលើអ៊ីនធឺណិតបាន។

ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ចាប់ផ្តើម **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
ចាកចេញពីកម្មវិធី : បិទកម្មវិធីពីការដំណើរការនៅផ្នែកខាងក្រោយ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

❺ បិទកម្មវិធី។

- កម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** គឺជាកម្មវិធីរុករកអ៊ីនធឺណិតសម្រាប់ឧបករណ៍នេះ ដូច្នេះវាអាចដំណើរការខុសពីកម្មវិធីរុករកតាមអ៊ីនធឺណិតសម្រាប់កុំព្យូទ័ររបស់អ្នក។

  · មាតិកាខ្លះអាចនឹងចាក់មិនបានត្រឹមត្រូវទេ។
  · មិនស្គាល់កម្មវិធីជំនួយ Flash ទេ ស្គាល់តែមេឌៀ HTML5 ប៉ុណ្ណោះ។
  · មិនស្គាល់ការដំឡើងកម្មវិធីជំនួយទេ។
  · មេឌៀដែលមានទម្រង់ខុសពី JPEG/PNG/GIF ប្រហែលជាមិនអាចចាក់បានទេ។
  · កម្មវិធីអាចនឹងត្រូវបានបង្ខំឱ្យបិទ ប្រសិនបើឧបករណ៍អស់មេម៉ូរី។
  · ពុម្ពអក្សរដែលបានផ្តល់នៅលើឧបករណ៍នេះត្រូវបានប្រើ។ ផ្អែកលើខ្លឹមសារ តួអក្សរអាចនឹងបង្ហាញខុសពីកម្មវិធីរុករកតាមអ៊ីនធឺណិតរបស់ឧបករណ៍ចល័ត ឬកុំព្យូទ័រ។
  · តម្រូវឱ្យមានការប្រុងប្រយ័ត្ន ដោយសារតែគេហទំព័របោកបញ្ឆោត ឬមានគ្រោះថ្នាក់មិនត្រូវបានទប់ស្កាត់ដោយស្វ័យប្រវត្តិនោះទេ។
  · មុខងារមួយចំនួនរបស់កម្មវិធីរុករកតាមអ៊ីនធឺណិតប្រហែលជាមិនអាចប្រើបានជាបណ្តោះអាសន្ន ដោយសារកត្តាខាងក្រៅ។

- គេអាចចូលប្រើគេហទំព័របានតាមរយៈកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** ដូច្នេះសូមមានការប្រុងប្រយ័ត្នចំពោះការចូលប្រើខ្លឹមសារនៅលើអ៊ីនធឺណិតដែលមានគ្រោះថ្នាក់របស់កូនៗ។
  អ្នកអាចចាក់សោកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** ដើម្បីការពារមិនឱ្យចូលប្រើមាតិកានៅលើអ៊ីនធឺណិតដែលមានគ្រោះថ្នាក់។
  កំណត់រចនាសម្ព័ន្ធឲ្យសំណុំកំណត់នេះនៅ → → **ទូទៅ** → **ប្រព័ន្ធ** → **សុវត្ថិភាព** → **ការចាក់សោកម្មវិធី**។
- ប្រសិនបើអ្នកជួបនឹងបញ្ហា នៅពេលប្រើប្រាស់ **កម្មវិធីរុករកលើអ៊ីនធឺណិត** សូមពិនិត្យមើល **ការដោះស្រាយបញ្ហា** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការផ្លាស់ប្តូរការកំណត់ **កម្មវិធីរុករកលើអ៊ីនធឺណិត**

ជ្រើសរើស → **ការកំណត់** នៅផ្នែកខាងលើនៃកម្មវិធី **កម្មវិធីរុករកលើអ៊ីនធឺណិត** ។

នៅពេលចាប់ផ្តើម

អ្នកអាចជ្រើសរើសទំព័រដែលបង្ហាញ
នៅពេលអ្នកចាប់ផ្តើមកម្មវិធី**កម្មវិធីរុករកលើអ៊ីនធឺណិត**។

ម៉ាស៊ីនស្វែងរក

អ្នកអាចជ្រើសរើសម៉ាស៊ីនស្វែងរក
សម្រាប់ស្វែងរកនៅពេលបញ្ចូលពាក្យគន្លឹះនៅក្នុងរបារអាសយដ្ឋាន។

- ការកំណត់ម៉ាស៊ីនស្វែងរកអាចជាកម្មវត្ថុចំពោះការផ្លាស់ប្តូរដោយមិនជូនដំណឹងផ្អែកតាមកាល:ទេស:របស់អ្នកផ្គត់ផ្គង់។

បង្ហាញគេហទំព័រដែលបានណែនាំ

អ្នកអាចកំណត់ថាត្រូវបង្ហាញបញ្ជី **គេហទំព័រដែលបានណែនាំ** នៅលើអេក្រង់ផ្ទាំងថ្មីបានឬអត់។

បង្ហាញរបារអាសយដ្ឋានជានិច្ច

នៅពេលកំណត់ទៅ **បើក** របារអាសយដ្ឋាន និងរបារម៉ឺនុយនៅខាងលើនឹងបង្ហាញជានិច្ច។

របាយការណ៍ស្ថិយប្រវត្តិអំពីបញ្ហាកម្មវិធីរុករកលើអ៊ីនធឺណិត

នៅពេលកំណត់វាទៅ **បើក** ប្រសិនបើមានបញ្ហាមិនដំណើរការ (ដំណើរការខុសប្រក្រតី មិនអាចចាក់មេឌៀ មិនអាចផ្ទុកទំព័រ ការបិទខុសពីធម្មតា ការពន្យារពេលឆ្លើយតបដោយសារអង្គចងចាំមិនគ្រប់គ្រាន់។ល។) ខណៈពេលកំពុងប្រើប្រាស់កម្មវិធីរុករកលើអ៊ីនធឺណិត នោះព័ត៌មានត្រូវបានផ្ញើទៅក្រុមការងារអភិវឌ្ឍកម្មវិធីរុករកលើអ៊ីនធឺណិតដោយស្ថិយប្រវត្តិនៅទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនផលិត (កូរ៉េ)។ ព័ត៌មានដែលផ្ញើនឹងត្រូវបានប្រើសម្រាប់តែកែលម្អដំណើរការរបស់កម្មវិធីរុករកលើអ៊ីនធឺណិតប៉ុណ្ណោះ។

ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម

នៅពេលកំណត់វាទៅ **បើក** ប្រសិនបើអ្នកចុច ⋮ នៅផ្នែកខាងលើនៃ **កម្មវិធីរុករកលើអ៊ីនធឺណិត** នោះប៊ូតុងសម្រាប់បើក ឬបិទ **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** នឹងបង្ហាញនៅលើអេក្រង់។ ការបើកលក្ខណៈពិសេសនៃ **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ជួយបង្កើនល្បឿនក្នុងការផ្ទុកទំព័រ តាមរយៈការទប់ស្កាត់ការផ្សាយពាណិជ្ជកម្មដែលមាននៅក្នុងគេហទំព័រ។

ការគ្រងគេហទំព័រ

អ្នកអាចចុះឈ្មោះគេហទំព័រដែលត្រូវទប់ស្កាត់ ឬអនុញ្ញាតបាន។
គេហទំព័រដែលបានយល់ព្រម : អ្នកអាចកំណត់រចនាសម្ព័ន្ធសំណុំកំណត់ដើម្បីបើកតែទំព័រវេបសាយដែលមានចុះបញ្ជីបាន។
គេហទំព័រដែលបានរារាំង : អ្នកអាចកំណត់រចនាសម្ព័ន្ធសំណុំកំណត់ដើម្បីដើម្បីខ្ទប់វេបសាយជាក់លាក់នានាបាន។

- ដើម្បីប្រើមុខងារ **ការគ្រងគេហទំព័រ** អ្នកគួរតែបញ្ជូលពាក្យសម្ងាត់ឧបករណ៍។

កម្មវិធីទប់ស្កាត់សារលោតឡើង

វាទប់ស្កាត់ផ្ទាំងលោតឡើង ដែលគេហទំព័របង្ហាញដោយស្ថិយប្រវត្តិ។

ការរុករកឯកជន

ប្រសិនបើកំណត់ទៅ **បើក** នោះវានឹងមិនរក្សាទុកប្រវត្តិនៃការចូលមើលគេហទំព័រទេ។

កុំតាមដាន

អ្នកអាចស្នើកុំឱ្យគេហទំព័ររក្សាទុកប្រវត្តិនៃការចូលមើលរបស់អ្នកបាន។
ប្រតិបត្តិការនេះអាចមានភាពខុសគ្នា ទៅតាមគោលការណ៍របស់គេហទំព័រ។

បច្ចេកវិទ្យាស្ទ្រីមមានភាពប្រែប្រួលដែលប្រើ JavaScript

បច្ចេកវិទ្យាចាក់មេឌៀតាមរយៈ JavaScript
ជួយឱ្យអ្នកអាចមើលវីដេអូដែលមានគុណភាពបង្ហាញខ្ពស់។
ប្រសិនបើវាត្រូវបានកំណត់ជា **បិទ**គុណភាពបង្ហាញរបស់វីដេអូបានលេងនៅក្នុង
កម្មវិធីរុករកលើអ៊ីនធឺណិត ត្រូវបានកម្រិតត្រឹម 720p ។

ការកំណត់ខូគី

វាផ្តល់លទ្ធភាពឱ្យគេហទំព័រអាចរក្សាទុក និងប្រើទិន្នន័យខូគី។

សម្អាតទិន្នន័យរុករក


សម្អាតខូគី : លុបទិន្នន័យខូគី។ នៅពេលលុបហើយ អ្នកនឹងត្រូវចេញពីគេហទំព័រភាគច្រើន។
សម្អាតទិន្នន័យរុករកទាំងអស់ : លុបប្រវត្តិរុករកទាំងអស់ រួមទាំងខូគីផងដែរ។

កំពុងប្រើ កម្មវិធីចាក់មេឌៀ

កំពុងប្រើ **កម្មវិធីចាក់មេឌៀ**

អ្នកអាចស្វែងរក និងមើលរូបថត ឬចាក់វីដេអូ និងចម្រៀងដោយប្រើកម្មវិធី
កម្មវិធីចាក់មេឌៀ។

01 ចុចប៊ូតុង ⌂ លើតេឡេ។
02 ដំណើរការកម្មវិធី **កម្មវិធីចាក់មេឌៀ**។
03 ជ្រើសរើសឧបករណ៍ដែលត្រូវប្រើពីបញ្ជីឧបករណ៍។
04 ជ្រើសរើសមាតិកាដែលត្រូវចាក់។



❶ អ្នកអាចជ្រើសរើសឧបករណ៍ដែលភ្ជាប់ជាមួយឧបករណ៍នេះ។

❷ បង្ហាញតែនៅពេលតន្ត្រីកំពុងលេងប៉ុណ្ណោះ។ ចុចលើ ដើម្បីចូលប្រើអេក្រង់ចាក់តន្ត្រី។

❸ ចាប់ផ្តើម **ស្វែងរក**។


❹ **ប្រភេទទិដ្ឋភាព** : ជ្រើសរើសរបៀបបង្ហាញមាតិកា។
តម្រៀប : ជ្រើសរើសជម្រើសដែលត្រូវតម្រៀបមាតិកា។
ក្រុម : ប្រសិនបើអ្នកត្រងតាម **តន្ត្រី** អ្នកអាចផ្គុំមាតិកាទៅតាមប្រភេទដូចជា **អ្នកចម្រៀង** និង **អាល់ប៊ុម** ជាដើម។
ចាក់ការជ្រើសរើស : អ្នកអាចជ្រើសរើស និងចាក់មាតិកាក្នុងចំនួនច្រើន។
ចម្លង : អ្នកអាចចម្លងមាតិកាទៅឧបករណ៍ផ្ទុកយូអេសប៊ីបាន។
លុប : អ្នកអាចជ្រើសរើស និងលុបមាតិកាក្នុងចំនួនច្រើន។
ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។
ចាកចេញពីកម្មវិធី : បិទកម្មវិធី។

❺ បិទកម្មវិធី។

- អ្នកមិនអាចលុបឯកសារដែលត្រូវបានចែករំលែកពីឧបករណ៍ផ្សេងបានទេ។
- អាចប្រើធាតុផ្សេងៗនៃការកំណត់ អាស្រ័យលើការត្រង ឬម៉ូដែលដែលអ្នកបានជ្រើសរើស។
- មានមាតិកាដែលមិនអាចត្រូវបានបង្ហាញលើបញ្ជីនបើចំនួនមាតិកាលើសពី 40,000។

ការមើលរូបថត


អ្នកអាចជ្រើសរើសរូបថតពីកម្មវិធី **កម្មវិធីចាក់មេឌៀ** រួចមើលរូបថត។
ដើម្បីប្រើលក្ខណៈពិសេសច្រើនទៀត ចុចប៊ូតុង **រង្វង់មូល (OK)** លើតេឡេប៊ញ្ជា រួចជ្រើសរើស លើអេក្រង់។



1. បង្ហាញមាតិកាមុន។
2. ចាប់ផ្តើមការបញ្ចាំងស្លាយ។
3. បង្ហាញមាតិកាបន្ទាប់។
4. បង្វិលរូបថត។
5. ពង្រីក ឬបង្រួមរូបថត។
6. រូបថត 360 ដឺក្រអាចត្រូវបានមើលក្នុងទិដ្ឋភាព 360 ដឺក្រ។
   - 360° VR Playលើរូបថតធម្មតាអាចធ្វើឲ្យរូបភាពខូចទ្រង់ទ្រាយ។
   - អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
7. ចាក់ឯកសារតន្ត្រីដែលជ្រើសរើសពីឧបករណ៍ផ្ទុក ជាតន្ត្រីនៅផ្ទៃខាងក្រោយ។
8. កំណត់ទំហំរូបថត ឬប្តូរល្បឿន ឬបែបផែនសម្រាប់ការបញ្ចាំងស្លាយ។
   - អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការចាក់វីដេអូ

អ្នកអាចជ្រើសរើសវីដេអូពីកម្មវិធី **កម្មវិធីចាក់មេឌៀ** រួចចាក់វីដេអូ។
ការចុចប៊ូតុង ◀/▶ នៅលើតេឡេបញ្ជាអាចឱ្យអ្នករំលងថយក្រោយ/ទៅមុខ 10 វិនាទី។
ដើម្បីប្រើលក្ខណៈពិសេសច្រើនទៀត ចុចប៊ូតុង **រង្វង់មូល (OK)** លើតេឡេបញ្ជា រួចជ្រើសរើស ⌄ លើអេក្រង់។



❶ បង្ហាញវីដេអូមុន។

❷ ចាក់ ឬផ្អាកវីដេអូ។

❸ បង្ហាញវីដេអូបន្ទាប់។

❹ អ្នកអាចប្តូរការកំណត់អក្សររត់។

❺ ការបង្វិលវីដេអូ។

❻ ខាវីដេអូលើនទៅក្រោយក្នុងល្បឿនលើនជាងមុន។

❼ អ្នកអាចរៀបចំការកំណត់ដែលទាក់ទងនឹងការចាក់វីដេអូឡើងវិញ។

❽ ខាវីដេអូលើនទៅមុខក្នុងល្បឿនលើនជាងមុន។


❾ វីដេអូ 360 ដឺក្រអាចត្រូវបានមើលក្នុងទិដ្ឋភាព 360 ដឺក្រ។

- 360° VR Playលើវីដេអូធម្មតាអាចធ្វើឲ្យរូបភាពខូចទ្រង់ទ្រាយ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

❿ **បន្តចាក់** : អ្នកអាចកំណត់ការមើលបន្ត ដើម្បីបន្តលេងពីឈុតដែលមានមើលចុងក្រោយ។
ល្បឿនចាក់ : កំណត់ល្បឿនការចាក់ឡើងវិញ។
ឯកសារសំឡេង : អ្នកអាចកំណត់បទចម្រៀងបាន។
បង្ហាញរបារដំណើរការ នៅពេលវីដេអូចាប់ផ្តើម : អ្នកអាចកំណត់ឱ្យលាក់របារចាក់នៅពេលអ្នកចាប់ផ្តើមចាក់វីដេអូ។

ការស្តាប់តន្ត្រី

អ្នកអាចជ្រើសរើសចម្រៀងពីកម្មវិធី **កម្មវិធីចាក់មេឌៀ** រួចចាក់ចម្រៀងនោះ។
ដើម្បីប្រើលក្ខណៈពិសេសច្រើនទៀត ចុចប៊ូតុង **រង្វង់មូល (OK)** លើតេឡេបញ្ជា រួចជ្រើសរើស ⌄ លើអេក្រង់។



❶ អ្នកអាចកំណត់របៀបចាក់តាមលំដាប់ចៃដន្យបាន។

❷ អ្នកអាចកំណត់របៀបចាក់សាឡើងវិញ។

❸ មានទំនុកបទចម្រៀងសម្រាប់ឯកសារតន្ត្រីដែលផ្តល់ពួកវា។
នៅក្នុងឯកសារតន្ត្រីមួយចំនួន អ្នកអាចជ្រើសរើសផ្នែកទំនុកបទចម្រៀងហើយផ្លាស់ទីទៅទីតាំងលេងឡើងវិញ។

- គ្រាន់តែមានការស្គាល់មុខងារពិសេសសម្រាប់អត្ថបទចម្រៀងនៅលើឧបករណ៍មួយចំនួនប៉ុណ្ណោះ។
- ទំនុកភ្លេងអាចមិនត្រូវបានបង្ហាញក្នុងពេលធ្វើសមកាលកម្ម អាស្រ័យលើទិន្នន័យទំនុកភ្លេងក្នុងឯកសារតន្ត្រី។

❹ អ្នកអាចស្តាប់តន្ត្រីនៅពេលបិទអេក្រង់ក៏បាន។

❺ **សមកាលកម្មទំនុកច្រៀង** : អ្នកអាចកំណត់ល្បឿនទំនុកច្រៀងបាន។

- លក្ខណៈពិសេសនេះប្រហែលជាមិនអាចប្រើបានទេ ដោយអាស្រ័យលើតន្ត្រី។

Live Plus

ការប្រើប្រាស់មុខងារ Live Plus

Live Plus

ផ្តល់ជូនបទពិសោធន៍ទស្សនាប្រសើរជាងមុនទាក់ទងនឹងមាតិកាដែលអ្នកកំពុងទស្សនា រួមទាំងការពិនិត្យមើលព័ត៌មានបន្ថែម ការចូលរួមក្នុងព្រឹត្តិការណ៍ ការធ្វើអន្តរកម្មជាមួយការផ្សាយពាណិជ្ជកម្ម ។ល។

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម**។

03 កំណត់ Live Plus ទៅជា **បើក**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ដើម្បីបិទមុខងារនេះនៅក្នុង Live Plus សូមចូលទៅកាន់ ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** ហើយកំណត់ **ប្រូម៉ូសិនពេលផ្សាយបន្តផ្ទាល់** ទៅ **បិទ**។
  អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- អ្នកនៅតែអាចចូលប្រើលក្ខណៈពិសេសមួយចំនួនរបស់ **Live Plus** នៅពេលប្រើឧបករណ៍ខាងក្រៅដូចជា ប្រអប់ចាប់ប៉ុស្តិ៍បានដដែល។
- ប្រសិនបើអ្នករៀបចំតេឡេបញ្ជាសកល អ្នកអាចប្រើ **Live Plus** ទោះបីជានៅពេលប្រើឧបករណ៍ខាងក្រៅក៏ដោយ។
- សេវាកម្មនេះត្រូវបានផ្តល់ជូនសម្រាប់មាតិកាដែលបានជ្រើសរើសជាមួយដៃគូក្នុងត្រាប៉ុណ្ណោះ។

ការជូនដំណឹង

ការប្រើ ការជូនដំណឹង

អ្នកអាចពិនិត្យមើល ឬលុបការជូនដំណឹងដែលបានទទួលពីសេវាកម្ម ឬកម្មវិធី webOS។
សម្រាប់ការជូនដំណឹងដែលស្គាល់ផ្លូវកាត់ អ្នកអាចចូលទៅកាន់កម្មវិធី
ឬគេហទំព័រនោះដោយផ្ទាល់បាន។

01 ចុចប៊ូតុង 🏠 លើតេឡេ។

02 ជ្រើសរើស 🔔 នៅលើអេក្រង់។

03 អ្នកអាចពិនិត្យមើលព័ត៌មានលម្អិតបាន ដោយជ្រើសរើសធាតុដែលអ្នកចង់ពិនិត្យ។
អ្នកអាចចាប់ផ្តើមកម្មវិធីបាន ប្រសិនបើវាស្គាល់ផ្លូវកាត់។


- ចុចប៊ូតុង ••• លើតេឡេ។
  សម្គាល់ទាំងអស់ថាបានអាន : ប្តូរការជូនដំណឹងទាំងអស់ទៅ ‘អាន’។
  លុប : អ្នកអាចលុបការជូនដំណឹងនានាចោលបាន។
  ការកំណត់ការជូនដំណឹង :
  អ្នកអាចកំណត់ថាតើត្រូវទទួលការជូនដំណឹងសម្រាប់កម្មវិធីនីមួយៗឬអត់។
  ប្រសិនបើវាត្រូវបានកំណត់ទៅ **បិទ**
  ការជូនដំណឹងទាំងឡាយដែលបានទទួលពីមុនពីកម្មវិធីក៏នឹងត្រូវបានលុបផងដែរ។
  សម្រាប់កម្មវិធីសេវាកម្មខាងក្រៅ
  អ្នកអាចពិនិត្យមើលការជូនដំណឹងនៅក្នុង**ការកំណត់ការជូនដំណឹង**
  បន្ទាប់ពីយល់ព្រមទទួលការជូនដំណឹងពីកម្មវិធី។
  ការណែនាំសម្រាប់អ្នកប្រើប្រាស់ : ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

ការកំណត់

ការកំណត់រហ័ស

ដើម្បីប្រើមុខងារកំណត់បានរហ័ស

អ្នកអាចប្រើការកំណត់មុខងារដែលបានប្រើញឹកញាប់បានយ៉ាងងាយស្រួល និងរហ័ស។
ចុចប៊ូតុង ⚙ លើតេឡេ។



❶ អ្នកអាចកំណត់ជម្រើសច្រើនទៀតបាន។

- អ្នកក៏អាចចុចប៊ូតុង⚙នៅលើតេឡេបញ្ជាឱ្យដាប់ដើម្បីដំណើរការការកំណត់ទាំងអស់ដោយផ្ទាល់បានផងដែរ។

❷ អ្នកអាចដោះស្រាយបញ្ហាទាក់ទងនឹងឧបករណ៍នេះដោយជជែកជាមួយ Chatbot។

❸ ចូលត្រង់ទៅការកំណត់ **លទ្ធភាពប្រើប្រាស់** តែម្តង។

❹ ចូលត្រង់ទៅការកំណត់ **សុវត្ថិភាព** តែម្តង។

❺ ចូលត្រង់ទៅការកំណត់ **បណ្តាញ** តែម្តង។

❻ អ្នកអាចបញ្ចូល/លុបធាតុនៅក្នុង **ការកំណត់រហ័ស** និងផ្លាស់ប្តូរលំដាប់បាន។

❼ ធាតុដែលបានជ្រើសរើសថ្មីៗបំផុតនៅក្នុង **ការកំណត់រហ័ស** ត្រូវបានបង្ហាញ។

❽ អ្នកអាចប្តូរការកំណត់សម្រាប់អេក្រង់ សំឡេង។ល។ ឬដំណើរការមុខងារបាន។

- អ្នកអាចកែវាទៅធាតុណាមួយតាមដែលអ្នកចង់។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ផ្ទាំងគ្រប់គ្រងហ្គេម

អំឡុងពេលលេងហ្គេម អ្នកអាចផ្លាស់ប្តូរ ប្រភេទហ្គេម បានយ៉ាងរហ័ស
និងពិនិត្យមើលស្ថានភាពការកំណត់នៅក្នុងពេលជាក់ស្តែង។

ចុចប៊ូតុង ⚙ លើតេឡេ។

- នៅពេលអ្នកភ្ជាប់កុងសូលហ្គេម និងដំណើរការហ្គេម **ទូទៅ** → **កម្មវិធីកែលម្អហ្គេម** ត្រូវបានប្តូរទៅ **បើក** ហើយ **រូបភាព** / **សំឡេង** → **របៀបជ្រើសរើស** ត្រូវបានប្តូរទៅ **កម្មវិធីកែលម្អហ្គេម**។ ប្រសិនបើ

ផ្ទាំងគ្រប់គ្រងហ្គេម មិនបង្ហាញទេ សូមពិនិត្យមើលការកំណត់នីមួយៗ។



1. អ្នកអាចបង្កើនប្រសិទ្ធភាពអេក្រង់ អាស្រ័យលើប្រភេទហ្គេម។
2. រលកសញ្ញាក្នុងពេលជាក់ស្តែង
   និងតម្លៃនៃការកំណត់របស់ប្រភេទដែលបានជ្រើសរើសត្រូវបានបង្ហាញ។
   - ធាតុដែលបានបង្ហាញអាចខុសគ្នាតាមម៉ូដែល។
3. ចាប់ផ្តើម **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
4. **របៀបបន្ទប់ងងឹត** : អ្នកអាចកែតម្រូវពន្លឺអេក្រង់ទាំងមូល
   ដើម្បីកាត់បន្ថយការចុកភ្នែកនៅក្នុងមជ្ឈដ្ឋានងងឹត ឬនៅពេលមើលរយៈពេលយូរ
   ដើម្បីធ្វើឱ្យកាន់តែងាយស្រួលមើលអេក្រង់។
   មុខងារមើលច្រើន : អ្នកអាចបំបែកអេក្រង់ និងប្រើកម្មវិធីពីរក្នុងពេលដំណាលគ្នាបាន។
   ពណ៌ម៉ឺនុយ : អ្នកអាចប្តូរពណ៌ម៉ឺនុយបាន។
   កម្មវិធីកែលម្អហ្គេម : ចូលត្រង់ទៅការកំណត់ **កម្មវិធីកែលម្អហ្គេម** តែម្តង។
   ដើម្បីមើលព័ត៌មានលម្អិត សូមចុច **ការកំណត់** → **កម្មវិធីកែលម្អហ្គេម** ក្នុង
   ការណែនាំសម្រាប់អ្នកប្រើប្រាស់។
   ការកំណត់ទាំងអស់ : អ្នកអាចកំណត់ជម្រើសច្រើនទៀតបាន។ អ្នកក៏អាចចុចប៊ូតុង⚙
   នៅលើតេឡេបញ្ជាឱ្យជាប់ ដើម្បីដំណើរការការកំណត់ទាំងអស់ដោយផ្ទាល់បានផងដែរ។
   - អាចមានការរឹតបន្តឹងលើការដំណើរការ **មុខងារមើលច្រើន** ក្នុងមាតិកាមួយចំនួន។
5. លំដាប់នៃធាតុដែលបង្ហាញនៅលើ **ផ្ទាំងគ្រប់គ្រងហ្គេម** អាចត្រូវបានប្តូរ
   ឬជំនួសដោយធាតុផ្សេងទៀត។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

រូបភាព

ការជ្រើសរើសទម្រង់រូបភាព

⚙ → ⚙ → **រូបភាព** → **របៀបជ្រើសរើស**

ជ្រើសរើសទម្រង់រូបភាពដែលត្រូវគ្នាល្អបំផុតទៅនឹងប្រព័ន្ធកម្មវិធីមើលរូបភាព ចំណូលចិត្ត ឬ
ប្រភេទវីដេអូសម្រាប់ការមើលរបស់អ្នក។
ជ្រើសរើសរបៀបរូបភាព។ តាមរយៈការកែសម្រួល
និងកំណត់ធាតុនីមួយៗដោយលម្អិតជាងមុនទៅតាមម៉ូដែល
វីដេអូរបស់អ្នកត្រូវបានបង្កើនប្រសិទ្ធភាពឱ្យប្រសើរជាងមុនសម្រាប់លក្ខណៈរបស់វា។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- ដោយអាស្រ័យសញ្ញាចូល ទម្រង់រូបភាពដែលមានអាចនឹងមានលក្ខណៈខុសគ្នា។
- នៅពេលកំពុងមើលមេឌៀ ឬមាតិកានៃសេវាកម្មនេះនៅអនឡាញ គេអាចប្តូរទម្រង់រូបភាព ឲ្យត្រូវ
គ្នានឹងមេឌៀ ឬមាតិកាដែលកំពុងមានការបង្ហាញឲ្យឃើញបាន។
- **របៀបជ្រើសរើស** ការផ្លាស់ប្តូរអាចកែប្រែ **ការសន្សំសំចៃថាមពល** និងការកំណត់
ការថែរក្សាចលនាភ្នែក ហើយវាអាចប៉ះពាល់ដល់ការប្រើប្រាស់ថាមពល។
អ្នកអាចប្តូរការកំណត់នៅក្នុង **ទូទៅ** → **ការសន្សំសំចៃថាមពល** និង **រូបភាព** →
ការកំណត់កម្រិតខ្ពស់ → **កម្រិតពន្លឺ** → **ការថែរក្សាចលនាភ្នែក**។

រូបភាពផ្ទាល់ខ្លួន

វាត្រូវបានកំណត់ទៅគុណភាពរូបភាពដែលបានវិភាគ
ដោយប្រើបច្ចេកវិទ្យារៀនដ៏ស៊ីជម្រៅនៃបញ្ញាសិប្បនិម្មិត។

ពណ៌ដិត

ការបង្កើនកម្រិតច្បាស់នៃរូបភាពដោយការបង្កើនកម្រិតពណ៌ ភាពភ្លឺច្បាស់ និងកម្រិត
ពណ៌។

ស្តង់ដារ

បង្ហាញរូបភាពដែលមានកម្រិតដិតបែបធម្មជាតិ ពន្លឺ និងដិតខ្លាំង។
ប្រសិនបើអ្នកជ្រើសរើសវាអំឡុងពេលរលកសញ្ញា HDR
នោះអេក្រង់ដែលអាចបង្ហាញការខ្ចីមសារ និងកម្រិតពន្លឺរបស់រូបភាព HDR បានគ្រប់គ្រាន់
បង្ហាញឡើងនៅក្នុងមជ្ឈដ្ឋានមើលធម្មតា។

អេកូ / ការសន្សំសំចៃថាមពលដោយស្វ័យប្រវត្តិ

មុខងារសន្សំសំចៃថាមពលប្តូរការកំណត់នៅលើឧបករណ៍
ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

របៀបកុននៅផ្ទះ

អេក្រង់លេចចេញមកជាអេក្រង់ដែលពន្លឺភ្លឺថ្លាជាង **រោងកុន**។

រោងកុន

រូបភាពសមស្របសម្រាប់ភាពយន្ត។

ប្រសិនបើអ្នកជ្រើសរើសវាអំឡុងពេលរលកសញ្ញា HDR
នោះអេក្រង់ដែលបានបង្កើនប្រសិទ្ធភាពសម្រាប់រលកសញ្ញាវីដេអូ HDR បង្ហាញឡើង។

កីឡា / ជាល់ទាត់ / Cricket

រូបភាពសមស្របសម្រាប់ហ្គេមកីឡា។ បង្កើនភាពច្បាស់នៃរូបភាពមានចល័តរហ័សដែលមានប្រភេទដូចជាការទាត់ ឬគប់បាល់។

- ឈ្មោះកីឡាអាចខុសៗគ្នាទៅតាមតំបន់។

កម្មវិធីកែលម្អហ្គេម

រូបភាពសមស្របសម្រាប់ការលេងហ្គេម។

FILMMAKER MODE

វាផ្តល់នូវគុណភាពរូបភាពបែបរោងភាពយន្តកម្រិតខ្ពស់ ដែលទទួលស្គាល់ដោយ UHD Alliance ដែលជាផ្នែកនៃការកំណត់ស្តង់ដារ សម្រាប់បច្ចេកវិទ្យាដែលពាក់ព័ន្ធនឹង UHD ។

- ដើម្បីប្តូរទៅ **FILMMAKER MODE** ដោយស្វ័យប្រវត្តិ នៅពេលមានការបញ្ចូលរលកសញ្ញាដែលអាចដំណើរការជាមួយរបៀបនេះបាន សូមកំណត់ **FILMMAKER MODE** **ចាប់ផ្តើមស្វ័យប្រវត្តិ** ទៅ **បើក**។

isf អ្នកជំនាញ (កន្លែងភ្លឺ ពេលថ្ងៃ) / isf អ្នកជំនាញ (កន្លែងងងឹត ពេលយប់)

របៀបនេះគឺស័ក្តិសមសម្រាប់ភាពយន្ត ។ល។ សម្រាប់ទស្សនានៅក្នុងមជ្ឈដ្ឋានងងឹត។
អ្នកជំនាញ (កន្លែងងងឹត ពេលយប់) មានកម្រិតពណ៌ពីព្រឿងៗមកស្រទន់ទាបជាង **អ្នកជំនាញ (កន្លែងភ្លឺ ពេលថ្ងៃ)**។
ជ្រើសរើសរបៀបដែលស័ក្តិសមសម្រាប់ភាពយន្ត ដែលអ្នកកំពុងទស្សនា។

- ISFccc : ការត្រួតពិនិត្យរៀបចំដែលមានបញ្ជាក់ដោយមូលនិធិវិទ្យាសាស្ត្របង្កើតរូបភាព។ isf ជំនាញ គឺជាជម្រើសមួយដែលអនុញ្ញាតឱ្យអ្នកជំនាញខាងគុណភាពរូបភាពធ្វើការលៃតម្រូវគុណភាពនៃរូបភាពដែលមានបទដ្ឋានត្រឹមត្រូវបាន។ ដូច្នេះ វាអាចនឹងមិនមានប្រសិទ្ធភាពសម្រាប់រូបភាពធម្មតាមួយបាន។

ជំនួយរូបភាពផ្ទាល់ខ្លួន

⚙ → ⚙ → **រូបភាព** → **ជំនួយរូបភាពផ្ទាល់ខ្លួន**

ធ្វើការវិភាគរូបភាពដែលបានជ្រើសរើសដោយអ្នកប្រើប្រាស់ដែលមានបច្ចេកវិទ្យារៀនដ៏ស៊ីជម្រៅនៃបញ្ញាសិប្បនិម្មិត
និងកំណត់វាទៅគុណភាពរូបភាពល្អបំផុតដែលចង់ប្រើដោយអ្នកប្រើប្រាស់។ ចុចប៊ូតុង **ចាប់ផ្តើម** នៅលើអេក្រង់ និងជ្រើសរើសរូបភាពដែលអ្នកចូលចិត្តសម្រាប់ជំហាននីមួយៗ។

- បន្ទាប់ពីចូលដោយប្រើ គណនី LG របស់អ្នក និងដំណើរការ **ជំនួយរូបភាពផ្ទាល់ខ្លួន** ហើយការកំណត់ត្រូវបានរក្សាទុកសម្រាប់គណនីនីមួយៗ។
- នៅពេលអ្នកបញ្ចប់ការរៀបចំការកំណត់ **ជំនួយរូបភាពផ្ទាល់ខ្លួន**, របៀបរូបភាព

សម្រាប់ការបញ្ចូលទាំងអស់ប្តូរទៅ **រូបភាពផ្ទាល់ខ្លួន**។
ដើម្បីដំឡើងមុខងារ របៀបរូបភាព ខុសគ្នាសម្រាប់ការបញ្ចូលនីមួយៗ សូមចុចប៊ូតុង
ដើម្បីជ្រើសរើសធាតុបញ្ចូលដែលអ្នកចង់ផ្លាស់ប្តូរ រួចប្តូរទៅ របៀបរូបភាព ដែលចង់បាននៅក្នុង
→ → **រូបភាព** → **របៀបជ្រើសរើស**។

- អាស្រ័យលើគុណភាពរូបភាពដែលបានកំណត់ **ជំហាននៃការសន្សំសំចៃថាមពល** អាចផ្លាស់ប្តូរ និងប៉ះពាល់ដល់ការប្រើប្រាស់ថាមពល។

ការកំណត់ទំហំអេក្រង់

→ → **រូបភាព** → **អត្រាទ្រង់ទ្រាយ** → **ការជ្រើសរើសដោយអ្នកប្រើប្រាស់**

អ្នកអាចប្តូរទំហំអេក្រង់ ទៅតាមប្រភេទមាតិកាដែលអ្នកកំពុងទស្សនា។

16:9

បង្ហាញសមាមាត្រ16:9។

ដើម

សមាមាត្រអេក្រង់គុណភាពខ្ពស់បំផុតប្រែប្រួល អាស្រ័យលើរលកសញ្ញារូបភាពបញ្ចូល។

4:3

បង្ហាញសមាមាត្រ4:3។

ពង្រីកបញ្ឈរ

អ្នកអាចកែតម្រូវវិមាត្រអេក្រង់បញ្ឈររបស់អេក្រង់ និងតម្រឹមអេក្រង់បញ្ឈរដោយប្រើ **សម្រួលអត្រាពង្រីក** និង **កែសម្រួលទីតាំងអេក្រង់**។

ការពង្រីកបង្រួមដោយប្រើប៊ូតុង 4 ទិស

អ្នកអាចកែតម្រូវវិមាត្រអង្កត់ទ្រូងផ្តេក/បញ្ឈររបស់អេក្រង់ និងតម្រឹមអេក្រង់ផ្តេក/បញ្ឈរដោយប្រើ **សម្រួលអត្រាពង្រីក** និង **កែសម្រួលទីតាំងអេក្រង់**។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- រូបភាពអាចនឹងបែក នៅពេលពង្រីក ឬបង្រួម។
- ការជ្រើសរើសទំហំអេក្រង់ខុសពីទំហំដើមអាចនឹងបណ្តាលឱ្យរូបភាពមានលក្ខណៈខុសប្លែក។
- អាស្រ័យលើការរួមបញ្ចូលគ្នារវាងទម្រង់រូបភាព និងទំហំអេក្រង់ គែមអាចនឹងត្រូវបានលាក់ ឬបង្ហាញជាពណ៌ខ្មៅ ឬផ្នែកទាំងសងខាងរបស់រូបភាពអាចនឹងភ្លឺភ្លឹបភ្លែតៗ។ ដូចគ្នានេះដែរ នៅពេលជ្រើសរើសធាតុណាមួយនៅលើអេក្រង់ផ្សាយ
បន្ទាត់អាចនឹងមិនស្របគ្នាបានត្រឹមត្រូវនោះទេ។
- ដោយអាស្រ័យលើសញ្ញាចូល ទំហំអេក្រង់ដែលអាចប្រើបានអាចខុសគ្នា។

ដើម្បីមើលអេក្រង់ការប្រើ ទើបស្មែន

→ → **រូបភាព** → **អត្រាទ្រង់ទ្រាយ** → **ទើបស្មែន**

បើអ្នកដាក់កំណត់បើកមុខងារពិសេសនេះទៅ**បើក**នោះអ្នកនឹងអាចមើលមេឌៀ ឬមាតិកានៅក្នុងទំហំសមាមាត្រដែលស្ថិតនៅក្នុងសញ្ញាផ្សាយ និងប្រភពមេឌៀ / មាតិកាបាន។ បើជ្រុងនៃអេក្រង់មិនច្បាស់ សូមកំណត់បិទវាទៅ**បិទ**។
ប្រសិនបើជ្រើសរើសទៅជា **ស្វ័យប្រវត្តិ** លក្ខណៈពិសេសនឹងប្តូរគ្នារវាងស្ថានភាព **បើក** ឬ **បិទ** អាស្រ័យលើព័ត៌មាននៅក្នុងសញ្ញាវីដេអូ។

- ធាតុដែលអាចជ្រើសរើសបាន អាចប្រែប្រួលទៅតាមធាតុចូលបច្ចុប្បន្ន។

ការកែតម្រូវពន្លឺរូបភាព

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កម្រិតពន្លឺ**

អ្នកអាចកែតម្រូវពន្លឺអេក្រង់ទាំងមូល។

ពន្លឺផ្ទាំង

គ្រប់គ្រងកម្រិតនៃភាពភ្លឺច្បាស់របស់អេក្រង់ដោយការលៃតម្រូវពន្លឺផ្នែខាងក្រោយ។ កាន់តែរំកិលខិតជិតលេខ 100 រូបភាពក៏កាន់តែឡើងពន្លឺកាលនោះដែរ។

- បន្ថយ **ពន្លឺផ្ទាំង** ដើម្បីកុំឲ្យស៊ីថាមពលខ្លាំង។
- ដោយអាស្រ័យលើ **ការសន្សំសំចៃថាមពល** (**ស្វ័យប្រវត្តិ**/**អតិបរមា**) អ្នកមិនអាចនឹងកែតម្រូវ **ពន្លឺផ្ទាំង** បានឡើយ។
  ស្ថិតក្នុងករណីនេះ រុករកទៅកាន់អេក្រង់ → → **ទូទៅ** → **ការសន្សំសំចៃថាមពល** → **ជំហាននៃការសន្សំសំចៃថាមពល** ហើយដាក់កំណត់ទៅជា **បិទ** ឬ **អប្បបរមា**។
- អាស្រ័យលើម៉ូដែល ប្រហែលជាមិនមានជម្រើសនៃការកំណត់ **ពន្លឺផ្ទាំង** ទេ។

ពន្លឺភិចសែល OLED

កែតម្រូវពន្លឺបង្ហាញដោយធ្វើឲ្យពន្លឺបន្ទះOLED ខុសគ្នា។

- ដោយអាស្រ័យលើ **ការសន្សំសំចៃថាមពល** (**ស្វ័យប្រវត្តិ**/**អតិបរមា**) អ្នកមិនអាចនឹងកែតម្រូវ **ពន្លឺភិចសែល OLED** បានឡើយ។
  ស្ថិតក្នុងករណីនេះ រុករកទៅកាន់អេក្រង់ → → **ទូទៅ** → **ការសន្សំសំចៃថាមពល** → **ជំហាននៃការសន្សំសំចៃថាមពល** ហើយដាក់កំណត់ទៅជា **បិទ** ឬ **អប្បបរមា**។
- អាស្រ័យលើម៉ូដែល ប្រហែលជាមិនមានជម្រើសនៃការកំណត់ **ពន្លឺភិចសែល OLED** ទេ។

កែសម្រួលពណ៌ពន្លឺ

កែតម្រូវកម្រិតពន្លឺនៃផ្នែដែលភ្លឺ និងងងឹតរបស់រូបភាព។ កាន់តែជិត 100 នោះកម្រិតពន្លឺកាន់តែខ្ពស់។

កម្រិតពណ៌ខ្មៅ

កែតម្រូវពន្លឺនៃផ្នែកងងឹតរបស់អេក្រង់។ ពន្លឺជិតដល់ 100 នោះអេក្រង់កាន់តែភ្លឺ។

ពណ៌ដិតឌីណាមិកស្វ័យប្រវត្តិ

កែភាពខុសគ្នារវាងពន្លឺ និងផ្នែងងឹតរបស់អេក្រង់សម្រាប់លទ្ធផលល្អបំផុតដោយអាស្រ័យលើពន្លឺរបស់រូបភាព។

ការធ្វើឲ្យចេញជាពណ៌តែមួយ

កំណត់ទៅជា **បើក**។ ធ្វើឲ្យការកំណត់កម្រិតពន្លឺសមស្របផ្នែកតាមពន្លឺរូបភាពរបស់មាតិកា HDR ។
កំណត់ទៅជា **បិទ**។ ការកំណត់ **អ្នកជំនាញ** ទៅ**បើក**អាចឱ្យអ្នកកែសម្រួលការបង្ហាញខ្លឹមសារ HDR បាន។

មុខងារកែលម្អទឹកមុខ

វាគឺជាបច្ចេកវិទ្យាក្នុងការកែលម្អភាពជិត និងការបញ្ចេញផ្ទៃខាងមុខ ផ្ទៃខាងក្រោយ និងវត្ថុដោយធ្វើការវិភាគព័ត៌មានរបស់រូបភាព HDR។

កម្រិតពន្លឺខ្ពស់បំផុត

កែតម្រូវកម្រិតពណ៌អតិបរមារបស់អេក្រង់។

អក្សរហ្គាម៉ា (កែសម្រួលពន្លឺ)

កែតម្រូវពន្លឺមធ្យមរបស់រូបភាព។

- **BT.1886** បង្ហាញពីកម្រិតនៅក្នុង ITU-R BT.1886 ដែលជាស្តង់ដារអន្តរជាតិ។

កម្រិតវីដេអូ

កែតម្រូវភាពងងឹតនៃអេក្រង់ ដើម្បីបង្ហាញពណ៌ខ្មៅដ៏ស័ក្តិសមបំផុត។ ជ្រើសរើស **កម្រិតវីដេអូ** ដើម្បីផ្លុងចន្លោះពណ៌នៃឧបករណ៍បញ្ចូលខាងក្រៅ។

- អាចប្រើលក្ខណៈពិសេសនេះបាន នៅពេលកំពុងទស្សនាមាតិកាតាមរយៈធាតុបញ្ចូលខាងក្រៅ។

ការចុះស្រេអាប់ LED ខាងក្នុង

បង្កើតកម្រិតពណ៌អតិបរមាដោយធ្វើឲ្យផ្ទៃដែលភ្លឺច្បាស់នៃអេក្រង់កាន់តែមានពន្លឺ និងផ្នែកងងឹតនៃអេក្រង់កាន់តែឡើងខ្មៅ។

- **បិទ** : បិទមុខងារ **ការចុះស្រេអាប់ LED ខាងក្នុង** ។
- **ទាប** / **មធ្យម** / **ខ្ពស់** : ផ្លាស់ប្តូរផលធៀបកម្រិតពណ៌។

- ការដាក់ជម្រើសនេះទៅជា **បិទ** អាចនឹងបង្កើនការស៊ីថាមពលកាន់តែច្រើន។

ការថែរក្សាចលនាភ្នែក

ស្ងួយលៃតម្រូវភាពភ្លឺច្បាស់ និងបន្ថយភាពព្រិលៗនៃរូបភាពដោយអាស្រ័យលើទិន្នន័យរូបភាពដែលនឹងបន្ថយការរោយភ្នែក។

- ការដាក់ជម្រើសនេះទៅជា **បិទ** អាចនឹងបង្កើនការស៊ីថាមពលកាន់តែច្រើន។

- ដោយអាស្រ័យសញ្ញាទិន្នន័យចូលរទម្រង់នៃរូបភាពដែលបានជ្រើសរើស ជម្រើសដែលអាចរកបាននឹងប្រែខុសគ្នា។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការកែតម្រូវពណ៌រូបភាព

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **ពណ៌**

ជម្រៅពណ៌

ដំឡើង ឬបន្ថយកម្រិតពណ៌ដែលមានបង្ហាញលើអេក្រង់។ កាន់តែរំកិលខិតជិតលេខ 100 ពណ៌ក៏កាន់តែឡើងជិតកាលនោះដែរ។

គុណពណ៌

កែតម្រូវតុល្យភាពពណ៌រវាងពណ៌ក្រហម និងបៃតង ដែលបានបង្ហាញលើអេក្រង់។ កាន់តែជិតពណ៌ក្រហម 50 នោះពណ៌កាន់តែក្រហម។ កាន់តែជិតពណ៌បៃតង 50 នោះពណ៌កាន់តែបៃតង។

ដែននៃពណ៌

ជ្រើសរើសចន្លោះពណ៌ដើម្បីបង្ហាញ។

ដើម

បង្ហាញពណ៌ជិត និងច្បាស់ជាងមុន។

ស្វែងរកដោយស្ងួយប្រវត្តិ

រាកំណត់ **ដែននៃពណ៌** ដោយស្ងួយប្រវត្តិ ដើម្បីឱ្យត្រូវគ្នានឹងរលកសញ្ញា។

ឌីណាមិក

រាពង្រីក **ដែននៃពណ៌** ឱ្យត្រូវគ្នានឹងទិដ្ឋភាព។

Adobe RGB

កំណត់ **ដែននៃពណ៌** ទៅស្តង់ដារ Adobe RGB។

កែសម្រួលឱ្យស័ក្តិសមបំផុត

វាត្រូវបានប្រើប្រាស់ នៅពេលអ្នកជំនាញគ្រប់គ្រងវាដោយប្រើលំនាំសាកល្បង។
អ្នកអាចគ្រប់គ្រងវាបានដោយជ្រើសរើសផ្នែកទាំងប្រាំមួយពណ៌
(**ក្រហម/បៃតង/ខៀវ/បៃតងលាយខៀវ/ស្វាយលាយក្រហម/លឿង**)។
សម្រាប់រូបភាពធម្មតា ការកែតម្រូវមិនអាចបង្ហាញលទ្ធផលក្នុងការប្តូរពណ៌គួរឱ្យកត់សម្គាល់ទេ។

ការកែសម្រួលពណ៌

កែតម្រូវពណ៌ និងតិត្ថិភាពរបស់រូបភាពដើម្បីធ្វើឱ្យរូបភាពកាន់តែមានពណ៌ និងរស់រវើក។

ជ្រើសរើសពណ៌

ចាប់ពីពណ៌ **ក្រហម/បៃតង/ខៀវ/បៃតងលាយខៀវ/ស្វាយលាយក្រហម/លឿង**
សូមជ្រើសរើសពណ៌ សម្រាប់កែសម្រួល។

កែសម្រួលភាពដិតនៃពណ៌ / កែសម្រួលពណ៌ព្រឿងៗ / កែសម្រួលពន្លឺចាំងផ្លាត

កែសម្រួលពណ៌ដិត/ពណ៌ព្រឿងៗ/ពណ៌ពន្លឺចាំងនៃកម្រិតពណ៌ក្នុងកម្រិត -30 ដល់ +30។

កម្រិតពណ៌ស

មុខងារសម្រាប់កែសម្រួលពណ៌នីមួយៗ
ដែលត្រូវបានបង្កើតឡើងវិញឱ្យកាន់តែត្រឹមត្រូវជាងមុនដោយផ្អែកលើពណ៌សអនុញ្ញាតឱ្យអ្នកកែសម្រួលកម្រិតពណ៌ទូទៅរបស់អេក្រង់ទៅតាមការចង់បានរបស់អ្នក។

កម្រិតពណ៌ពីព្រឿងៗមកស្រទន់

អ្នកអាចកំណត់ពណ៌ ដើម្បីធ្វើឱ្យអេក្រង់មានលក្ខណៈត្រជាក់ភ្នែក ឬក្តៅភ្នែកជាងមុន។

វិធីសាស្ត្រ

វិធីនេះគឺប្រើសម្រាប់កែសម្រួលការកំណត់កម្រិតពណ៌។
អ្នកអាចគ្រប់គ្រងកម្រិតពណ៌ពីព្រឿងៗមកស្រទន់នៅកម្រិតពីរនៃចំណុចភ្លឺ
និងចំណុចងងឹតរបស់វីដេអូ ប្រសិនបើអ្នកជ្រើសរើស **2 ចំណុច** នៅគ្រប់ចំណុចនៃកម្រិត
10 ប្រសិនបើអ្នកជ្រើសរើស **កម្រិតរលកសញ្ញា 10 ពិន្ទុ (%)** និងនៅគ្រប់ចំណុចនៃកម្រិត
22 របស់វីដេអូ ប្រសិនបើអ្នកជ្រើសរើស **កម្រិតរលកសញ្ញា 22 ពិន្ទុ (%)**។

ចំណុច

ជ្រើសរើសកម្រិតពន្លឺពណ៌សម្រាប់ការកែសម្រួលកម្រិតពណ៌។
ប្រសិនបើ **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **2 ចំណុច** សូមប្រើ Low ដើម្បីជ្រើសរើសស្រមោល
និង High ដើម្បីជ្រើសរើសហាយឡាយ។
ប្រសិនបើ **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **កម្រិតរលកសញ្ញា 10 ពិន្ទុ (%)**
អ្នកអាចជ្រើសរើសពន្លឺ ដោយប្រើលេខដែលបង្ហាញ 10 កម្រិត។
នៅពេល **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **កម្រិតរលកសញ្ញា 22 ពិន្ទុ (%)**

នោះអ្នកអាចជ្រើសរើសពន្លឺក្នុងកម្រិតភ្លឺ 22។

កម្រិតរលកសញ្ញា (%)

ជ្រើសរើសកម្រិតពន្លឺពណ៌សម្រាប់ការកែសម្រួលកម្រិតពណ៌។
ប្រសិនបើ **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **កម្រិតរលកសញ្ញា 10 ពិន្ទុ (%)**
អ្នកអាចជ្រើសរើសពន្លឺ ដោយប្រើលេខដែលបង្ហាញ 10 កម្រិត។
នៅពេល **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **កម្រិតរលកសញ្ញា 22 ពិន្ទុ (%)**
នោះអ្នកអាចជ្រើសរើសពន្លឺក្នុងកម្រិតភ្លឺ 22។

- ឈ្មោះ **កម្រិតរលកសញ្ញា (%)** អាចមានភាពខុសគ្នាទៅតាមរលកសញ្ញា។

បង្ហាញកម្រិតពន្លឺនៅកម្រិតរលកសញ្ញាអតិបរមា (%)

កែសម្រួលពន្លឺចាំងនៃកម្រិតរលកសញ្ញាខ្ពស់បំផុត 100%។

កែសម្រួលកម្រិតពន្លឺនៅកម្រិតរលកសញ្ញាដែលបានជ្រើសរើស (%)

អាចកែសម្រួលពន្លឺនៃកម្រិតរលកសញ្ញាដែលបានជ្រើសរើសបាន។

- អ្នកអាចធ្វើការកំណត់ទាំងនេះបាននៅពេល **រូបភាព** → **របៀបជ្រើសរើស** គឺជា **រោងកុន**, **អ្នកជំនាញ (កន្លែងភ្លឺ ពេលថ្ងៃ)** ឬ **អ្នកជំនាញ (កន្លែងងងឹត ពេលយប់)** និងនៅពេល **វិធីសាស្ត្រ** ត្រូវបានកំណត់ទៅ **កម្រិតរលកសញ្ញា 10 ពិន្ទុ (%)** ឬ **កម្រិតរលកសញ្ញា 22 ពិន្ទុ (%)** តែប៉ុណ្ណោះ។

ក្រហម / បៃតង / ខៀវ

កែសម្រួលកម្រិតពណ៌នៃចំណុចដែលបានជ្រើសរើស។
កែសម្រួលតង់ស៊ីតេនៃពណ៌ **ក្រហម**/**បៃតង**/**ខៀវ** ក្នុងកម្រិត -50 ដល់ 50។
អ្នកអាចកែសម្រួលតម្លៃខាងលើ សម្រាប់ពន្លឺដែលបានជ្រើសរើសនៅក្នុង **ចំណុច**។

- ដោយអាស្រ័យសញ្ញាទិន្នន័យចូលរទម្រង់នៃរូបភាពដែលបានជ្រើសរើស ជម្រើសដែលអាចរកបាន និងប្រែខុសគ្នា។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការកែតម្រូវភាពជិតរបស់រូបភាព

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **ភាពច្បាស់**

អ្នកអាចកែតម្រូវភាពជិតរបស់រូបភាព ដើម្បីបង្ហាញវាឱ្យកាន់តែច្បាស់។

កែសម្រួលភាពច្បាស់នៃរូប

លៃតម្រូវភាពច្បាស់នៃរូបភាព។ កាន់តែរំកិលខិតជិតលេខ 50 កាលណា រូបភាពក៏កាន់តែមានភាពច្បាស់និងឡើងថ្លាកាលនោះដែរ។

គុណភាពបង្ហាញច្បាស់អស្ចារ្យ

កែតម្រូវគុណភាពបង្ហាញដើម្បីធ្វើឲ្យរូបភាពព្រិលៗ និងស្រអាប់ច្បាស់។

ការកាត់បន្ថយសំឡេងរំខាន

លុបចេញនូវចំណុចតូចៗដែលលេចចេញមកដើម្បីធ្វើឲ្យរូបភាពច្បាស់។

ការកាត់បន្ថយសំឡេងរំខានក្នុង MPEG

បន្ថយសំឡេងរំខានដែលកើតឡើងក្នុងពេលបង្កើតសញ្ញាវីដេអូឌីជីថល។

ការប្តូរពណ៌យ៉ាងរលូន

វាជួយកាត់បន្ថយគុណភាពនៃរូបភាពមានលក្ខណៈរដិបរដុបនិងមិនច្បាស់ដោយបង្ហាញអោយរូបភាពច្បាស់ល្អ។

ដូចរោងកុនពិតៗ

បង្កើនគុណភាពការបញ្ចាំងភាពយន្ត

TruMotion

ធ្វើឲ្យគុណភាពរូបភាពសមស្របសម្រាប់រូបភាពដែលមានចលនាលឿន។

- **បិទ** : បិទ **TruMotion**។
- **ចលនាដូចក្នុងរោងកុន** : កែសម្រួលចលនាញ័រនៅលើអេក្រង់ ដើម្បីធ្វើឱ្យមានអារម្មណ៍ថាអ្នកកំពុងស្ថិតនៅក្នុងរោងភាពកុន។
- **ធម្មជាតិ** : កំណត់រូបភាព ដោយប្រើចលនាជាច្រើន ដើម្បីធ្វើឱ្យរូបភាពមានភាពរស់រវើកបែបធម្មជាតិ និងភ្លឺច្បាស់។
- **ចលនារលូន** : ធ្វើឲ្យរូបភាពដែលកំពុងមានចលនាលឿនមើលទៅស្រទន់។
- **ការជ្រើសរើសដោយអ្នកប្រើប្រាស់** : កំណត់ **TruMotion** ដោយផ្ទាល់ដៃ។
  - **De-Judder** : លៃតម្រូវរូបភាពញ័រព្រិលៗលើអេក្រង់។
  - **De-Blur** : បន្ថយភាពព្រិលៗនៃចលនា។
  - **OLED Motion** / **Motion Pro** : អ្នកអាចធ្វើឱ្យវីដេអូរបស់អ្នកច្បាស់ជាងមុន ដោយកម្ចាត់ស្នាមដានចេញ។

- សំណុំកំណត់កម្រិតខ្ពស់ អាចមានការផ្លាស់ប្តូរតែនៅក្នុងទម្រង់ **ការជ្រើសរើសដោយអ្នកប្រើប្រាស់** ប៉ុណ្ណោះ។

- ដោយអាស្រ័យសញ្ញាទិន្នន័យចូលរទម្រង់នៃរូបភាពដែលបានជ្រើសរើស ជម្រើសដែលអាចរកបាននឹងប្រែខុសគ្នា។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការប្រើការកំណត់រូបភាពបច្ចុប្បន្នសម្រាប់ធាតុបញ្ចូលទាំងអស់

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **អនុវត្តចំពោះធាតុបញ្ចូលទាំងអស់**

សំណុំកំណត់ដែលអ្នកបញ្ជាក់ គ្រាន់តែប្រើចំពោះទម្រង់ទិន្នន័យបញ្ចូលដែលបានជ្រើសរើសប៉ុណ្ណោះ។
ដើម្បីប្រើសំណុំកំណត់នៃរូបភាពបច្ចុប្បន្នរបស់អ្នកទៅនឹងទម្រង់បញ្ចូលទិន្នន័យទាំងអស់បានជ្រើសរើសចុចលើ **អនុវត្តចំពោះធាតុបញ្ចូលទាំងអស់**។

ការកំណត់ទម្រង់រូបភាព

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កំណត់ឡើងវិញ**

ប្រសិនបើអ្នកចង់កំណត់ការកំណត់រូបភាពទៅលំនាំដើមឡើងវិញបន្ទាប់ពីប្រើការកំណត់សូមកំណត់ឡើងវិញសម្រាប់របៀបរូបភាពនីមួយៗ។

FILMMAKER MODE ចាប់ផ្តើមស្វ័យប្រវត្តិ

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **FILMMAKER MODE ចាប់ផ្តើមស្វ័យប្រវត្តិ**

ប្រសិនបើកំណត់ទៅ **បើក** **របៀបរូបភាព** នឹងត្រូវបានប្តូរទៅ **FILMMAKER MODE** ដោយស្វ័យប្រវត្តិ នៅពេលមានការបញ្ចូលរលកសញ្ញា ដែលអាចដំណើរការជាមួយ **FILMMAKER MODE** បាន។

- ថ្វីបើរបៀបនេះបង្ហាញពីបំណងរបស់អ្នកបង្កើតយ៉ាងមានប្រសិទ្ធភាពក៏ពិតមែន ប៉ុន្តែវាអាចមានភាពងងឹតជាង របៀបរូបភាព ផ្សេងទៀត។

ដើម្បីប្រើមុខងារ **កាត់បន្ថយពន្លឺពណ៌ខៀវ**

→ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កាត់បន្ថយពន្លឺពណ៌ខៀវ**

សីតុណ្ហភាពពណ៌នឹងត្រូវបានកែតម្រូវ ដើម្បីកាត់បន្ថយការឈឺភ្នែក។

បើក

សីតុណ្ហភាពពណ៌នៅលើអេក្រង់របស់អ្នកត្រូវបានកែតម្រូវ។

បិទ

បិទ **កាត់បន្ថយពន្លឺពណ៌ខៀវ**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

សំឡេង

របៀបជ្រើសរើស

→ → **សំឡេង** → **របៀបជ្រើសរើស**

អ្នកអាចជ្រើសរើសទម្រង់សំឡេងដែលសមស្របបំផុតសម្រាប់ប្រភេទនីមួយៗបាន។

សំឡេង AI / សំឡេង AI Pro

ផ្អែកលើខ្លឹមសារដែលអ្នកមើល អ្នកអាចរីករាយជាមួយសំឡេង
និងមជ្ឈដ្ឋានជុំវិញបែបនិម្មិតដែលប្រសើរជាងមុនក្នុងពេលជាក់ស្តែង។

ស្តង់ដារ

បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ប្រភេទមេឌៀ ឬមាតិកាទាំងអស់។

ភាពយន្ត

បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ភាពយន្ត។

សំឡេងច្បាស់ / សំឡេងច្បាស់ Pro

បង្កើនភាពច្បាស់នៃសំឡេង។

កីឡា / បាល់ទាត់ / Cricket

បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ល្បែង ឬហ្គេមកីឡា។

- ឈ្មោះកីឡាអាចខុសៗគ្នាទៅតាមតំបន់។

តន្ត្រី

បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់តន្ត្រី។

កម្មវិធីកែលម្អហ្គេម

បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ការលេងហ្គេម។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- ប្រសិនបើអ្នកភ្ជាប់របារសំឡេង LG ដែលអាចប្រើ **ចែករំលែករបៀបសំឡេងតាមទូរទស្សន៍** ទៅរន្ធ HDMI អ្នកអាចជ្រើសរើស របៀបសំឡេង ដែលផ្តល់ដោយរបារសំឡេង LG នៅលើឧបករណ៍។
ប្រសិនបើ → → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ចែករំលែករបៀបសំឡេងតាមទូរទស្សន៍**
ត្រូវបានកំណត់ទៅ **បើក** នោះ របៀបសំឡេង របស់ឧបករណ៍ត្រូវបានបញ្ជូនទៅរបារសំឡេង LG។

ប្រើឧបករណ៍បំពងសំឡេងទូរទស្សន៍

→ → **សំឡេង** → **សំឡេងចេញ** → **ប្រើឧបករណ៍បំពងសំឡេងទូរទស្សន៍**

សំឡេងត្រូវបានចាក់តាមរយៈឧបករណ៍បំពងសំឡេងខាងក្នុងរបស់ឧបករណ៍។

ប្រើឧបករណ៍បំពងសំឡេងឥតខ្សែ

→ → **សំឡេង** → **សំឡេងចេញ** → **ប្រើឧបករណ៍បំពងសំឡេងឥតខ្សែ**

ឧបករណ៍ Bluetooth

ភ្ជាប់ឧបករណ៍សំឡេង Bluetooth ឥតខ្សែ ដើម្បីរីករាយជាមួយសំឡេងបានកាន់តែងាយស្រួល។ សូមពិនិត្យមើលសៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់ដែលនិយាយអំពីឧបករណ៍សំឡេង Bluetooth ដើម្បីទទួលបានព័ត៌មានលម្អិតអំពីរបៀបភ្ជាប់ និងប្រើប្រាស់ឧបករណ៍។

- ចុច ⋮ ដើម្បីមើលបណ្តាឧបករណ៍ដែលបានតភ្ជាប់ ឬឧបករណ៍ដែលគេអាចតភ្ជាប់ទៅឧបករណ៍ណាមួយក្នុងចំណោមឧបករណ៍ទាំងនេះបាន។
- សម្រាប់ឧបករណ៍ប៊ូធូសមួយចំនួន កម្រិតសំឡេងរបស់ឧបករណ៍អាចបញ្ហាដោយជ្រើសរើសពីបញ្ជីនៃការតភ្ជាប់។
- ប្រសិនបើឧបករណ៍ LG Sound Sync ត្រូវបានភ្ជាប់ថ្មីៗបំផុត វានឹងព្យាយាមភ្ជាប់ដោយស្វ័យប្រវត្តិ នៅពេលបើកឧបករណ៍នោះ។
- យើងខ្ញុំសូមណែនាំឲ្យអ្នកប្រើឧបករណ៍អូឌីយោ LG ដែលស្គាល់ LG Sound Syncដោយការប្រើទម្រង់ LG TV ឬទម្រង់ LG Sound Sync លើឧបករណ៍។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- កូឌិកសំឡេងដែលអាចបញ្ចេញតាមរយៈប៊ូធូសគឺ SBC/aptX™។
- បើការតភ្ជាប់ឧបករណ៍មិនបានសម្រេច ពិនិត្យមើលថាមពលនៃឧបករណ៍ដែលតភ្ជាប់ និងពិនិត្យមើលថាតើឧបករណ៍អូឌីយោកំពុងដើរស្រួលឬក៏អត់។
- សូមណែនាំឱ្យប្រើកាស Bluetooth នៅពេលអ្នកភ្ជាប់ឧបករណ៍ Bluetooth ពីរ។
- ដោយអាស្រ័យលើប្រភេទឧបករណ៍ Bluetooth ឧបករណ៍នេះអាចនឹងមិនតភ្ជាប់បានត្រឹមត្រូវ បើមិនដូច្នេះទេ ដំណើរការមិនប្រក្រតីអាចនឹងកើតមានឡើងដែលមានប្រភេទដូចជាវីដេអូ និងអូឌីយោដែលបានធ្វើសមកាលកម្ម។
  - កាសប្រើសម្រាប់តែឧបករណ៍ចល័តប្រហែលជាមិនដំណើរការទេ។
  - ប្រសិនបើឧបករណ៍ Bluetooth ពីរផ្សេងគ្នាត្រូវបានភ្ជាប់ និងប្រើក្នុងពេលតែមួយ នោះសំឡេងអាចនឹងមិនត្រូវគ្នា។
- សំឡេងអាចត្រដិត ឬគុណភាពសំឡេងអាចមានការធ្លាក់ចុះ បើ:
  - ឧបករណ៍ Bluetooth នៅឆ្ងាយពីឧបករណ៍នេះពេក
  - មានរបាំងរវាងឧបករណ៍ Bluetooth និងឧបករណ៍នេះ ឬ

- បានប្រើរួមគ្នាជាមួយនឹងគ្រឿងបរិក្ខារវិទ្យុដែលមានប្រភេទដូចជា ដើងក្រាន់មីក្រូវ៉ែ ឬ LAN ឥតខ្សែ

- ប្រសិនបើ **រូបភាព** → **របៀបជ្រើសរើស** ត្រូវបានកំណត់ជា **កម្មវិធីកែលម្អហ្គេម** និង **សំឡេងចេញ** ត្រូវបានកំណត់ជា **ឧបករណ៍ Bluetooth**ការផ្លាស់ប្តូរ **រូបភាព** → **របៀបជ្រើសរើស** ទៅ **ស្តង់ដារ**។
- ប្រសិនបើអ្នកនៅតែជួបនឹងបញ្ហាទៀត យើងសូមណែនាំឱ្យប្រើការតភ្ជាប់ដោយប្រើខ្សែ។ (ឌីជីថលអុបទិក, រន្ធ HDMI)

ឧបករណ៍ LG WOWCAST

អ្នកអាចរីករាយជាមួយនឹងសំឡេងដ៏សម្បូរបែបដោយគ្មានបញ្ហាសំឡេង
ទោះបីជាអ្នកភ្ជាប់របារសំឡេងដែលស្គាល់ LG WOWCAST ដោយឥតប្រើខ្សែក៏ដោយ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- សូមណែនាំឱ្យភ្ជាប់ទៅបណ្តាញឥតខ្សែដោយប្រើ 5 GHz។ បណ្តាញនេះមិនដំណើរការនៅលើបណ្តាញ 6 GHz ឬ DFS ទេ។ ប្រសិនបើអ្នកចែករំលែកអេក្រង់របស់អ្នកជាមួយឧបករណ៍ឆ្លាតវៃ ឬភ្ជាប់ Wi-Fi ផ្ទាល់ នៅពេលភ្ជាប់ជាមួយបណ្តាញ 2.4 GHz, LG WOWCAST នឹងផ្តាច់។
- ប្រសិនបើអ្នកភ្ជាប់ជាមួយដុំភ្ជាប់ LG WOWCAST នោះដុំភ្ជាប់នោះត្រូវបានភ្ជាប់ជាមុន។

ឧបករណ៍បំពងសំឡេង WiSA

អ្នកអាចភ្ជាប់ឧបករណ៍ជាមួយ **ឧបករណ៍បំពងសំឡេង WiSA** ដោយឥតប្រើខ្សែបាន
ដើម្បីរីករាយនឹងសំឡេងដែលមានគុណភាពខ្ពស់។
ជ្រើសរើស ⋮ ដើម្បីកែសម្រួលការកំណត់លម្អិតសម្រាប់ **ឧបករណ៍បំពងសំឡេង WiSA**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ដើម្បីប្រើឧបករណ៍បំពងសំឡេង WiSA អ្នកត្រូវភ្ជាប់ឧបករណ៍របស់វាជាមុនសិន។
- បញ្ហាក្នុងការភ្ជាប់រវាងឧបករណ៍ WiSA ជាមួយនឹងឧបករណ៍បំពងសំឡេង WiSA អាចនឹងកើតមានឡើង នៅក្នុងមជ្ឈដ្ឋានដែលមានការរំខានលើរលកសញ្ញា។ ក្នុងករណីនេះ សូមទាក់ទងទៅក្រុមហ៊ុនផលិតឧបករណ៍បំពងសំឡេង។
- សម្រាប់ព័ត៌មានបន្ថែមអំពីការទិញផលិតផលដែលមានការទទួលស្គាល់ពី WiSA សូមពិនិត្យមើលនៅលើ www.wisaassociation.org ។

ឧបករណ៍ចល័ត

ប្រសិនបើអ្នកដំឡើងកម្មវិធី LG ThinQ នៅលើឧបករណ៍ឆ្លាតវៃ រួចភ្ជាប់វាជាមួយឧបករណ៍នេះ
អ្នកអាចប្រើឧបករណ៍នោះជាឧបករណ៍បំពងសំឡេងសម្រាប់ឧបករណ៍នេះបាន។

ប្រើឧបករណ៍បំពងសំឡេងមានខ្សែ

⚙ → ⚙ → **សំឡេង** → **សំឡេងចេញ** → **ប្រើឧបករណ៍បំពងសំឡេងមានខ្សែ**

ឧបករណ៍អុបទិកចេញ

អ្នកអាចភ្ជាប់ឧបករណ៍សំឡេងដែលស្គាល់ អុបទិក ទៅរន្ធបញ្ចេញសំឡេងឌីជីថលបែបអុបទិច ដើម្បីរីករាយជាមួយសំឡេងរបស់ឧបករណ៍អ្នក ដែលមានគុណភាពកាន់តែសម្បូរបែប និងកាន់តែងាយស្រួល។

- គ្រាន់តែមានស្រាប់ម៉ូដែលមានរន្ធដោតខ្សែអុបទិកឌីជីថលប៉ុណ្ណោះ។
- ដើម្បីកែសម្រួលកម្រិតសំឡេងរបស់របារសំឡេងដែលស្គាល់ LG Sound Sync ជាមួយតេឡេបញ្ជារបស់ឧបករណ៍នេះ សូមកំណត់ ⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **LG Sound Sync** ទៅ**បើក**

ឧបករណ៍ HDMI(ARC)

អាចបញ្ចេញសំឡេងបានតាមរយៈឧបករណ៍សំឡេងខាងក្រៅដែលបានភ្ជាប់តាមរយៈរន្ធ HDMI (eARC/ARC)។

- ជ្រើសរើស **ឧបករណ៍ HDMI(ARC)**ដើម្បីបើក SIMPLINK ដោយស្វ័យប្រវត្តិ។ នៅពេល SIMPLINK ត្រូវបានបិទ ការកំណត់អូប៉ាល័រចេញត្រឡប់ទៅការកំណត់លំនាំដើមដោយស្វ័យប្រវត្តិ សម្រាប់ការបញ្ចេញសំឡេងដែលមិនរំខាន។

ឧបករណ៍សំឡេងចេញ / កាសមានខ្សែ

ជ្រើសរើស **កាសមានខ្សែ** ឬ **ឧបករណ៍សំឡេងចេញ** ដើម្បីបង្កើនប្រសិទ្ធភាពទិន្នន័យចេញនៃអូឌីយោដោយអាស្រ័យលើឧបករណ៍ដែលបានតភ្ជាប់។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ប្រសិនបើអ្នកភ្ជាប់កាសមានខ្សែ នៅពេលបើកឧបករណ៍ វានឹងរកឃើញកាសមានខ្សែដោយស្វ័យប្រវត្តិ ហើយបញ្ជូនសំឡេងបន្តតាមរយៈកាសនោះ។

ប្រើឧបករណ៍បំពងសំឡេងខាងក្រៅជាមួយឧបករណ៍បំពងសំឡេងក្នុងទូរទស្សន៍

⚙ → ⚙ → **សំឡេង** → **សំឡេងចេញ** → **ប្រើឧបករណ៍បំពងសំឡេងខាងក្រៅជាមួយឧបករណ៍បំពងសំឡេងក្នុងទូរទស្សន៍**

អូឌីយោអាចមានការចាក់លេងបានតាមរយៈឧបករណ៍ចម្រុះដំណាលៗគ្នា។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ឧបករណ៍ Bluetooth + ឧបករណ៍បំពងសំឡេងទូរទស្សន៍

ទាំងឧបករណ៍បំពងសំឡេងខាងក្នុងនៃឧបករណ៍នេះ និងឧបករណ៍បំពងសំឡេង Bluetooth អាចត្រូវបានប្រើ ដើម្បីបញ្ចេញសំឡេងក្នុងពេលតែមួយ ឬសំឡេងរងអាចត្រូវបានប្រើ។ អាចភ្ជាប់ឧបករណ៍ Bluetooth ដែលមានម៉ូដែលដូចគ្នាបានរហូតដល់ពីរ។

01 ជ្រើសរើស ⋮ ដើម្បីភ្ជាប់ឧបករណ៍ Bluetooth ។

02 ដំណើរការ **ការពន្យារសំឡេង**

ដើម្បីធ្វើសមកាលកម្មឧបករណ៍បំពងសំឡេងខាងក្នុងរបស់ឧបករណ៍នេះជាមួយឧបករណ៍បំពងសំឡេង Bluetooth។ អ្នកអាចកែសម្រួលវាបានដោយផ្ទាល់ ឬដោយស្វ័យប្រវត្តិ។

- នៅពេលអ្នកកំណត់ **សំឡេងចេញ** ជា **ឧបករណ៍ Bluetooth + ឧបករណ៍បំពងសំឡេងទូរទស្សន៍** ប្រសិនបើ **រូបភាព** → **របៀបជ្រើសរើស** គឺ **កម្មវិធីកែលម្អហ្គេម** វានឹងត្រូវបានផ្លាស់ប្តូរទៅ **ស្តង់ដារ** ហើយ **Dolby Atmos** នឹងត្រូវបានបិទ។
- នៅពេលប្រើប្រាស់មុខងារ Screen Share វីដេអូ និងសំឡេងអាចនឹងមិនធ្វើសមកាលកម្មឡើយ។ យើងសូមណែនាំឱ្យប្រើ **ប្រើឧបករណ៍បំពងសំឡេងទូរទស្សន៍** នៅក្នុង **សំឡេងចេញ**។
- ដើម្បីកែតម្រូវកម្រិតសំឡេងដោយប្រើប៊ូតុងកម្រិតសំឡេងនៅលើឧបករណ៍ប្តូរសរបស់អ្នក សូមកំណត់ ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់** ទៅ **ឧបករណ៍ Bluetooth**។ សម្រាប់ឧបករណ៍ប្តូរដែលមិនមានប៊ូតុងតម្លើងសម្លេង អ្នកក៏អាចតម្លើងសម្លេងនៅលើអេក្រង់ការកំណត់លម្អិត **ឧបករណ៍ Bluetooth + ឧបករណ៍បំពងសំឡេងទូរទស្សន៍**។
- ប្រសិនបើ ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់** ត្រូវបានកំណត់ទៅ **ឧបករណ៍ Bluetooth** មានតែឧបករណ៍ប្តូរសមួយប៉ុណ្ណោះដែលអាចភ្ជាប់បាន។
- ឧបករណ៍ពីរប្រហែលជាមិនអាចភ្ជាប់ជាមួយគ្នាក្នុងពេលតែមួយបានទេ អាស្រ័យលើប្រភេទឧបករណ៍ Bluetooth របស់អ្នក។
- ដោយអាស្រ័យលើប្រភេទឧបករណ៍ Bluetooth ឧបករណ៍នេះអាចនឹងមិនតភ្ជាប់បានត្រឹមត្រូវ បើមិនដូច្នេះទេ ដំណើរការមិនប្រក្រតីអាចនឹងកើតមានឡើងដែលមានប្រភេទដូចជាវីដេអូ និងអូឌីយោដែលបានធ្វើសមកាលកម្ម។

ឧបករណ៍ LG WOWCAST + ឧបករណ៍បំពងសំឡេងទូរទស្សន៍

បញ្ចេញសំឡេងដំណាលគ្នាតាមរយៈឧបករណ៍បំពងសំឡេងខាងក្នុងរបស់ឧបករណ៍ និងរបារសំឡេងដែលស្គាល់ LG WOWCAST។
អ្នកអាចជ្រើសរើសជម្រើសនេះបាន ប្រសិនបើអ្នកភ្ជាប់ជាមួយរបារសំឡេងដែលស្គាល់ LG WOWCAST។

ឧបករណ៍អុបទិកចេញ + ឧបករណ៍បំពងសំឡេងទូរទស្សន៍

សំឡេងត្រូវបានចាក់តាមរយៈឧបករណ៍បំពងសំឡេងខាងក្នុងរបស់ឧបករណ៍ និងឧបករណ៍សំឡេងដែលបានភ្ជាប់ទៅរន្ធបញ្ចេញសំឡេងឌីជីថលបែបអុបទិចក្នុងពេលដំណាលគ្នា។

ឧបករណ៍ HDMI(ARC) + ឧបករណ៍បំពងសំឡេងទូរទស្សន៍

ការភ្ជាប់របារសំឡេង LG ដែលមានមុខងារ WOW Orchestra

ឧបករណ៍បំពងសំឡេងខាងក្នុង និងរបារសំឡេងអាចបញ្ចេញសំឡេងក្នុងពេលដំណាលគ្នា សម្រាប់បទពិសោធសំឡេងកាន់តែសម្បូរបែប។
ប្រសិនបើអ្នកភ្ជាប់របារសំឡេង LG ទៅរន្ធ HDMI (eARC/ARC) វានឹងត្រូវបានភ្ជាប់ដោយស្វ័យប្រវត្តិ។

- កំណត់ **សំឡេងចេញ** ទៅ **ប្រើឧបករណ៍បំពងសំឡេងទូរទស្សន៍** ឬ **ប្រើឧបករណ៍បំពងសំឡេងមានខ្សែ** ដើម្បីផ្តាច់។
- លទ្ធផលកូឌិកតាមរយៈឧបករណ៍អាចខុសគ្នាពីរលកសញ្ញាបញ្ចូល។

ការភ្ជាប់ឧបករណ៍ជំនួយការស្តាប់

អ្នកអាចកែតម្រូវកម្រិតសំឡេងរបស់ឧបករណ៍បំពងសំឡេងខាងក្នុង
និងឧបករណ៍ជំនួយការស្តាប់ផ្សេងៗពីគ្នាបាន។
ភ្ជាប់ឧបករណ៍បញ្ជូនរបស់ឧបករណ៍ជំនួយការស្តាប់ទៅរន្ធ HDMI (eARC/ARC)។
ចូលទៅ ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** →
ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់ ហើយជ្រើសរើស **ឧបករណ៍ HDMI(ARC)**។

- ដើម្បីកែតម្រូវកម្រិតសំឡេងរបស់ឧបករណ៍ជំនួយការស្តាប់ដែលបានភ្ជាប់នៅលើឧបករណ៍
  សូមចុច 🔊 នៅជាប់ **ឧបករណ៍ HDMI(ARC) + ឧបករណ៍បំពងសំឡេងទូរទស្សន៍**។

កាសមានខ្សែ + ឧបករណ៍បំពងសំឡេងទូរទស្សន៍

សំឡេងត្រូវបានចាក់តាមរយៈឧបករណ៍បំពងសំឡេងខាងក្នុង និង **កាសមានខ្សែ**
ក្នុងពេលដំណាលគ្នា។

- ប្រសិនបើអ្នកភ្ជាប់កាសមានខ្សែ នៅពេលបើកឧបករណ៍
  វានឹងរកឃើញកាសមានខ្សែដោយស្វ័យប្រវត្តិ ហើយបញ្ជូនសំឡេងបន្តតាមរយៈកាសនោះ។

Dolby Atmos

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **Dolby Atmos**

Dolby Atmos ផ្អែកលើការយល់ឃើញរបស់វត្ថុបំណងសំឡេង។ សំឡេងណាមួយអាចត្រូវត្រូវបាន
បញ្ចូលគ្នាជាសំឡេងតែមួយ, វត្ថុតែមួយ ដែលដាក់នៅកន្លែងឯករាជ្យក្នុងកន្លែងបីវិមាត្រ។
Dolby Atmos
បង្កើតបទពិសោធសំឡេងដែលហាក់ដូចជាបន្លឺឡើងជុំវិញអ្នកដោយប្រើឧបករណ៍បំពងសំឡេង
ខាងក្នុង។

ម៉ឺនុយដែលដើរតួជា **បើក/បិទ** តម្លៃលំនាំដើមគឺ **បើក**។ ឲ្យតែឥទ្ធិពលរបស់ **Dolby Atmos**,
អនុវត្តមាតិកា Dolby Atmos។ (ម៉ឺនុយពេលបើក **បើក**)

- មាតិកា Dolby Atmos មិនអាចត្រូវបានលេង។

លំនឹង

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **លំនឹង**

អ្នកអាចលៃតម្រូវកម្រិតសំឡេងនៃប្រដាប់បំពងសំឡេងខាងឆ្វេង និងខាងស្តាំបាន។

- ការកំណត់នេះមានតែសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ប៉ុណ្ណោះ។

អ៊ុំហ្គុយ

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **អ៊ុំហ្គុយ**

អ្នកអាចកែតម្រូវសំឡេងដោយបង្កើន
ឬបន្ថយសំឡេងចេញក្នុងកម្រិតហ្វ្រេកង់ជាក់លាក់នៃរលកសញ្ញាសំឡេង។

- ជម្រើសនេះអាចបើកបានប្រសិនបើ **សំឡេង** → **របៀបជ្រើសរើស**ត្រូវបានកំនត់ជា**ស្តង់ដារ**។
- ការកំណត់នេះប្រើបានសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ ឬបារសំឡេង LG ដែលអាចប្រើ **ចែករំលែកបៀបសំឡេងតាមទូរទស្សន៍** ប៉ុណ្ណោះ។

ការប្រើការកំណត់សំឡេងបច្ចុប្បន្នសម្រាប់ធាតុបញ្ចូលទាំងអស់

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **អនុវត្តចំពោះធាតុបញ្ចូលទាំងអស់**

សំណុំកំណត់ដែលអ្នកបញ្ជាក់ គ្រាន់តែប្រើចំពោះទម្រង់ទិន្នន័យបញ្ចូលដែលបានជ្រើសរើស ប៉ុណ្ណោះ។
ដើម្បីប្រើការកំណត់សំឡេងបច្ចុប្បន្នរបស់អ្នកសម្រាប់មុខងារធាតុបញ្ចូលទាំងអស់
សូមជ្រើសរើស **អនុវត្តចំពោះធាតុបញ្ចូលទាំងអស់**។

ការចាប់ផ្តើមការកំណត់សំឡេង

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **កំណត់ឡើងវិញ**

ទាញត្រលប់មកវិញរាល់ការកំណត់លម្អិតដែលប៉ះពាល់ សម្រាប់ការកំណត់ទៅសម្លេង **ស្តង់ដារ**។

- ការកំណត់នេះប្រើបានសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ ឬបារសំឡេង LG ដែលអាចប្រើ **ចែករំលែកបៀបសំឡេងតាមទូរទស្សន៍** ប៉ុណ្ណោះ។

ប្រភេទនៃការដំឡើង

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ប្រភេទនៃការដំឡើង**

មុខងារនេះបង្កើនប្រសិទ្ធភាពសំឡេង ដោយផ្អែកលើការរៀបចំឧបករណ៍។

ជើងបញ្ឈរ

ជ្រើសរើសវា ប្រសិនបើដំឡើងឧបករណ៍ដោយដាក់បញ្ឈរ។

ចាប់ភ្ជាប់ជញ្ជាំង

ជ្រើសរើសវា ប្រសិនបើដំឡើងឧបករណ៍ជាប់នឹងជញ្ជាំង។

- ការកំណត់នេះមានតែសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ប៉ុណ្ណោះ។

ការកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ

→ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ការកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ**

ប្រសិនបើកំណត់វាទៅ **បើក**
កម្រិតសំឡេងនឹងត្រូវបានកែតម្រូវដោយស្វ័យប្រវត្តិទៅកម្រិតសមស្របសម្រាប់មាតិកានីមួយៗ ដែលអ្នកទស្សនា ដើម្បីជួយឱ្យអ្នករីករាយទស្សនាច្រើនទៀតប្រកបដោយផាសុកភាព។

- ការកំណត់នេះប្រើបានសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ ឬបារសំឡេង LG ដែលអាចប្រើ **ចែករំលែកការបៀបសំឡេងតាមទូរទស្សន៍** ប៉ុណ្ណោះ។

ការកំណត់សំឡេងទូរទស្សន៍ឌីជីថល

→ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ការកំណត់សំឡេងទូរទស្សន៍ឌីជីថល**

នៅពេលដែលមានប្រភេទអូឌីយោផ្សេងក្នុងសញ្ញាទិន្នន័យចូល មុខងារនេះនឹងអនុញ្ញាតឲ្យអ្នកជ្រើសរើសប្រភេទអូឌីយោដែលអ្នកចង់បាន។

បើមានកំណត់ទៅជា **ស្វ័យប្រវត្តិ** លំដាប់លំដោយស្វែងរក គឺ AC4 → HE-AAC → Dolby Digital Plus → Dolby Digital → MPEG ហើយទិន្នន័យចេញត្រូវបានបង្កើតឡើងតាមទម្រង់ឯកសារអូឌីយោទីមួយដែលបានរកឃើញ។

- លំដាប់លំដោយស្វែងរកអាចប្រែប្រួលទៅតាមប្រទេស។ : AC4 → HE-AAC → Dolby Digital Plus → Dolby Digital → MPEG។
- បើទម្រង់ឯកសារអូឌីយោដែលបានជ្រើសរើសគ្មានការស្គាល់ទេនោះ ទម្រង់ឯកសារអូឌីយោមួយទៀតអាចនឹងមានការប្រើសម្រាប់ទិន្នន័យចេញ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការលៃតម្រូវសមកាលកម្ម AV

→ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ផ្គូផ្គងអេក្រង់ជាមួយសំឡេង**

ការលៃតម្រូវសមកាលកម្មនៃសំឡេងដែលចេញពីប្រដាប់បំពងសំឡេងដែលកំពុងដំណើរការ។ ដោយសារតម្លៃនៃការកំណត់កើនឡើង ការបញ្ចូលសំឡេងប្រែជាយឺតជាងលំនាំដើម។

ប្រសិនបើអ្នកជ្រើសរើស **Bypass** នោះរលកសញ្ញាផ្សាយនៃធាតុចេញ ឬសំឡេងពីឧបករណ៍ខាងក្រៅនឹងពន្យារពេល។ សំឡេងអាចបញ្ចេញ មុនវីដេអូ ដោយសារយ:ពេលឧបករណ៍នេះចំណាយលើការដំណើរការធាតុបញ្ចូលវីដេអូ។

- ជម្រើសដែលមានខុសគ្នាទៅតាមការកំណត់ **សំឡេងចេញ**។

ជ្រើសរើសទម្រង់សំឡេងធាតុបញ្ចូល HDMI

→ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ជ្រើសរើសទម្រង់សំឡេងធាតុបញ្ចូល HDMI**

អ្នកអាចកំណត់ទម្រង់សំឡេងសម្រាប់ធាតុបញ្ចូល HDMI នីមួយៗបាន។
នៅពេលភ្ជាប់ជាមួយឧបករណ៍ ឬខ្លឹមសារដែលអាចប្រើបច្ចេកវិទ្យាសំឡេងរង់ចុងក្រោយបំផុត ការកំណត់ទៅ **Bitstream** នឹងអាចឱ្យអ្នកស្តាប់គុណភាពសំឡេងដែលចង់បាន។
នៅពេលសំឡេងដែលផ្តល់ជូនតាមរយៈរន្ធ HDMI មិនបានធ្វើសមកាលកម្មទេ សូមកំណត់វាទៅ **PCM**។

ចែករំលែកវគ្គសិក្សាតាមទូរទស្សន៍

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ចែករំលែកវគ្គសិក្សាតាមទូរទស្សន៍**

កំណត់ទៅជា **បើក**។
ចាក់មុខងារសំឡេងដែលបានប្រើសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងរបស់ឧបករណ៍នៅលើរបារសំឡេង LG។

- របារសំឡេង LG ដែលអាចប្រើ **ចែករំលែកវគ្គសិក្សាតាមទូរទស្សន៍** ត្រូវតែភ្ជាប់ទៅ HDMI ដើម្បីរៀបចំវា។

LG Sound Sync

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **LG Sound Sync**

ភ្ជាប់ឧបករណ៍ LG Sound Sync ទៅរន្ធធាតុបញ្ចេញឌីជីថលអុកទិក រួចកំណត់ **សំឡេងចេញ** ទៅ **ឧបករណ៍អុបទិកចេញ**។
ប្រសិនបើកំណត់មុខងារនេះទៅ **បើក**
នោះអ្នកអាចកែតម្រូវកម្រិតសំឡេងរបស់ឧបករណ៍ដែលបានភ្ជាប់ LG Sound Sync ដោយប្រើតេឡេបញ្ជាឧបករណ៍បាន។

- ប្រសិនបើមុខងារថាមពលស្វ័យប្រវត្តិរបស់របារសំឡេងដែលស្គាល់ LG Sound Sync ត្រូវបានកំណត់ទៅ បើក នោះរបារសំឡេងនឹងបើក ឬបិទដំណាលគ្នាដែរ នៅពេលដែលបើក ឬបិទឧបករណ៍។

ការកំណត់ សំឡេងចេញឌីជីថល

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **សំឡេងចេញឌីជីថល**

អ្នកអាចកំណត់រចនាសម្ព័ន្ធសំណុំកំណត់ **សំឡេងចេញឌីជីថល** បាន។

- ការកំណត់នេះអាចប្រើតែនៅពេល ⚙ → ⚙ → **សំឡេង** → **សំឡេងចេញ** → **ប្រើឧបករណ៍បំពងសំឡេងមានខ្សែ** ត្រូវបានកំណត់ទៅ **ឧបករណ៍អុបទិកចេញ/ឧបករណ៍ HDMI(ARC)** ប៉ុណ្ណោះ។
- នៅពេលដែលបើកមុខងារ**ឆ្លងកាត់** សម្លេងនឹងមិនអាចលឺបានទេ។
- លទ្ធផលកូឌិកតាមរយៈឧបករណ៍អាចខុសគ្នាពីរលកសញ្ញាបញ្ចូល។

	ទិន្នន័យចូលនៃសំឡេង	ទិន្នន័យចេញនៃសំឡេងឌីជីថល
PCM	ទាំងអស់	PCM
ស្វ័យប្រវត្តិ / **ឆ្លងកាត់**	MPEG	PCM
	Dolby Digital	(Optical / HDMI ARC) Dolby Digital (HDMI eARC) Dolby Digital / Dolby Digital Plus / Dolby MAT
	Dolby Digital Plus / Atmos	(Optical) Dolby Digital (HDMI ARC) Dolby Digital / Dolby Digital Plus / Atmos (HDMI eARC) Dolby Digital / Dolby Digital Plus / Dolby MAT / Atmos
	Dolby TrueHD (សម្រាប់ HDMI តែប៉ុណ្ណោះ)	(Optical) Dolby Digital (HDMI ARC) Dolby Digital / Dolby Digital Plus / Atmos (HDMI eARC) Dolby Digital / Dolby Digital Plus / Dolby TrueHD / Dolby MAT / Atmos
	HE-AAC / AAC	(Optical) Dolby Digital (HDMI ARC) Dolby Digital / Dolby Digital Plus (HDMI eARC) Dolby Digital / Dolby Digital Plus / Dolby MAT
	DTS / DTS Express / DTS-HD MA	(Optical / HDMI ARC) DTS (HDMI eARC) DTS / DTS-HD MA
	DTS-HD	(Optical / HDMI ARC) DTS (HDMI eARC) DTS / DTS-HD / DTS-HD MA
	DTS:X	(Optical / HDMI ARC) DTS (HDMI eARC) DTS / DTS-HD MA / DTS:X

- Dolby TrueHD , HDMI eARC , Dolby Atmos , DTS : អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- នៅពេលភ្ជាប់ជាមួយ HDMI eARC
  ប្រភេទសំឡេងបញ្ចេញនឹងពឹងផ្អែកលើប្រភេទសំឡេងដែលឧបករណ៍ដែលបានភ្ជាប់នោះស្គាល់។
  - អាស្រ័យលើឧបករណ៍ដែលបានភ្ជាប់ និងប្រភេទសំឡេងចូល វាអាចបញ្ចេញជា PCM បញ្ជូនសំឡេងដែលអាចប្រើទិន្នន័យមេការបស់ Dolby (Dolby MAT PCM)។
  - ប្រសិនបើកំណត់ **សំឡេងចេញឌីជីថល** ទៅ **ឆ្លងកាត់** ហើយធាតុបញ្ចូល HDMI គឺជា PCM ពហុប៉ុស្តិ៍ ឬ Dolby TrueHD នោះសំឡេងអាចបញ្ចេញជា Bypass។

ការប្រើ eARC ដែលស្គាល់ឧបករណ៍សំឡេង

⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **អាចប្រើ eARC បាន**

eARC គឺជាបច្ចេកវិទ្យាដែលអាចផ្ទេ និងទទួលព័ត៌មានសំឡេងច្រើនជាងមុន
និងរហ័សជាងមុន ដោយសារតែកម្រិតបញ្ជូនរបស់វាធំជាងកម្រិតបញ្ជូនរបស់ ARC ធម្មតា។
អ្នកអាចរីករាយជាមួយសំឡេងឧបករណ៍ ដែលមានគុណភាពខ្ពស់ជាង ARC
តាមរយៈឧបករណ៍សំឡេងដែលបានភ្ជាប់។

01 ភ្ជាប់ឧបករណ៍សំឡេងដែលស្គាល់ eARC ទៅរន្ធ HDMI (eARC/ARC) ។

02 ចូលទៅ **សំឡេងចេញ** → **ប្រើឧបករណ៍បំពងសំឡេងមានខ្សែ** ហើយជ្រើសរើស **ឧបករណ៍ HDMI(ARC)**។

03 កំណត់ **អាចប្រើ eARC បាន** ទៅជា **បើក**។

លទ្ធភាពប្រើប្រាស់

ស្វែងយល់អំពីតេឡេបញ្ជា

⌂ → **លទ្ធភាពប្រើប្រាស់** → **ស្វែងយល់អំពីតេឡេបញ្ជា**

⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ស្វែងយល់អំពីតេឡេបញ្ជា**

ចុចប៊ូតុងនៅលើតេឡេបញ្ជា ដោយអនុវត្តតាមការណែនាំនៅលើអេក្រង់
ដើម្បីទទួលបានព័ត៌មានអំពីប៊ូតុង។
ការចុចប៊ូតុង ↩ ពីរដងជាប់ៗគ្នាបញ្ចប់ **ស្វែងយល់អំពីតេឡេបញ្ជា**។
ចុចប៊ូតុង ⏻ ដើម្បីបិទឧបករណ៍ បន្ទាប់មក ផលិតផលដែលមានមុខងារ
ដំណើរការភ្លាមៗជានិច្ច នឹងដំណើរការ **ដំណើរការភ្លាមៗជានិច្ច** ប្រសិនបើបើក
ដំណើរការភ្លាមៗជានិច្ច។

សំឡេងថាមពលរបស់ឧបករណ៍

→ **លទ្ធភាពប្រើប្រាស់** → **មុខងារចក្ខុ** → **សំឡេងថាមពលរបស់ឧបករណ៍**

→ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **សំឡេងថាមពលរបស់ឧបករណ៍**

មុខងារនេះអនុញ្ញាតឱ្យអ្នកបើក/ បិទបែបផែនសំឡេងដែលអ្នកឮ នៅពេលបើក ឬបិទឧបករណ៍របស់អ្នក។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ការកំណត់ **ការណែនាំជាសំឡេង** ទៅ **បើក** នឹងប្តូរ **សំឡេងថាមពលរបស់ឧបករណ៍** ទៅ **បើក** ដោយស្វ័យប្រវត្តិផងដែរ។

ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់

→ **លទ្ធភាពប្រើប្រាស់** → **មុខងារស្តាប់** → **ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់**

→ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់**

អាចភ្ជាប់ឧបករណ៍ជំនួយការស្តាប់ជាមួយ Bluetooth ឬ HDMI ដើម្បីបញ្ចេញសំឡេងដំណាលគ្នាជាមួយឧបករណ៍បំពងសំឡេងខាងក្នុង និងឧបករណ៍ជំនួយការស្តាប់។

បិទ

បិទ **ស្តាប់រួមគ្នាដោយប្រើឧបករណ៍ជំនួយការស្តាប់**។

ឧបករណ៍ Bluetooth

សំឡេងចេញ ប្តូរទៅ **ឧបករណ៍ Bluetooth + ឧបករណ៍បំពងសំឡេងទូរទស្សន៍**។ ប្រវត្តិនៃការតភ្ជាប់ប៊ូធូសដែលមានស្រាប់នឹងត្រូវបានលុប។

ឧបករណ៍ HDMI(ARC)

សំឡេងចេញ ប្តូរទៅ **ឧបករណ៍ HDMI(ARC) + ឧបករណ៍បំពងសំឡេងទូរទស្សន៍**។

- ប្រសិនបើអ្នកភ្ជាប់ឧបករណ៍ក្រៅពីឧបករណ៍ជំនួយការស្តាប់ មុខងារនេះអាចនឹងដំណើរការមិនបានត្រឹមត្រូវទេ។
- សម្រាប់ឧបករណ៍ប៊ូធូស យើងសូមណែនាំឱ្យប្រើប្រភេទកាសគ្របត្រចៀក ឬកាសមានមីក្រូហ្វូន។
- សម្រាប់ការណែនាំអំពីរបៀបភ្ជាប់ និងរៀបចំឧបករណ៍ប៊ូធូស សូមមើល **ការកំណត់** → **សំឡេង** → **ប្រើឧបករណ៍បំពងសំឡេងខាងក្រៅជាមួយឧបករណ៍បំពងសំឡេងក្នុងទូរទស្សន៍** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការពង្រីកបង្ហួមភាសាសញ្ញា

→ **លទ្ធភាពប្រើប្រាស់** → **មុខងារស្តាប់** → **ការពង្រីកបង្ហួមភាសាសញ្ញា**

→ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ការពង្រីកបង្ហួមភាសាសញ្ញា**

កំណត់ **បើកមុខងារ** ទៅ **បើក**។ អ្នកអាចពង្រីកនៅលើផ្នែកជាក់លាក់នៃអេក្រង់ដើម្បីមើលវាបាន។

ជ្រើសរើសទីតាំង

អ្នកអាចជ្រើសរើសទីតាំង ឬទំហំដែលអ្នកចង់ពង្រីកបាន។
អ្នកអាចជ្រើសរើសទីតាំង ដើម្បីពង្រីកដោយប្រើទស្សន៍ទ្រនិចនៅលើអេក្រង់ ឬប៊ូតុង ▲/▼/◀/▶ នៅលើតេឡេបញ្ជា។
អ្នកអាចជ្រើសរើសកម្រិតក្នុងការពង្រីកដោយចុចប៊ូតុង ● នៅលើតេឡេបញ្ជា។

- ដើម្បីប្រើ **ការពង្រីកបង្រួមភាសាសញ្ញា** អ្នកត្រូវតែកំណត់ **បញ្ជាសពណ៌** ទៅ **បិទ**។

បានបិទការកំណត់អត្ថបទពិពណ៌នាបិទ

⌂ → **លទ្ធភាពប្រើប្រាស់** → **មុខងារស្តាប់** → **អក្សរត់**

⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **អក្សរត់**

ប្រសិនបើក្រុមហ៊ុនផ្សាយផ្តល់ខ្លឹមសារដោយមានអក្សរត់ នោះអ្នកអាចឃើញអក្សរត់ទាំងនោះ។ ប្តូរ **អក្សរត់** ទៅ **បើក** ហើយជ្រើសរើសការកំណត់អក្សរត់។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ដើម្បីកំណត់ភាសាអក្សរត់

ប្រើមុខងារអក្សរត់ នៅពេលភាសាអក្សរត់ពីរឡើងទៅត្រូវបានផ្សាយ។

- ក្នុងរបៀបឌីជីថលតែប៉ុណ្ណោះ
- ប្រសិនបើការផ្សាយមិនស្គាល់អក្សរត់ដែលបានជ្រើសរើសនោះរកំណត់លំនាំដើមនៃអក្សរត់នឹងត្រូវប្រើជំនួស។

មីនុយសម្រាប់អ្នកខ្សោយភ្នែក

⌂ → **លទ្ធភាពប្រើប្រាស់** → **មុខងារចក្ខុ** → **ការពិពណ៌នាជាសំឡេង**

⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ការពិពណ៌នាជាសំឡេង**

មាតិកានៅលើអេក្រង់នឹងត្រូវបានពិពណ៌នាជាសំឡេងសម្រាប់អ្នកដែលមានបញ្ហាក្នុងការមើល។
អ្នកអាចប្រើប្រាស់មុខងារនេះបាន ប្រសិនក្រុមហ៊ុនផ្សព្វផ្សាយមាន **ការពិពណ៌នាជាសំឡេង** សម្រាប់អ្នកខ្សោយភ្នែក។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ប្រភេទអូឌីយ៉ូ

លទ្ធភាពប្រើប្រាស់ → មុខងារចក្ខុ → ប្រភេទអូឌីយ៉ូ

→ → ទូទៅ → លទ្ធភាពប្រើប្រាស់ → ប្រភេទអូឌីយ៉ូ

អក្សររត់ឬឯកសារជាសំឡេងត្រូវបានផ្តល់ជូនសម្រាប់អ្នកដែលពិបាកស្តាប់ ឬខ្សោយការមើលឃើញ។

ធម្មតា

ជ្រើសរើសសំឡេងលំនាំដើម។

ការពិពណ៌នាជាសំឡេង

សម្រាប់អ្នកខ្សោយការមើលឃើញ សូមជ្រើសរើសសំឡេងលំនាំដើមដែលចង់បានជាមួយនឹងសំឡេងជំនួយសម្រាប់អ្នកពិការ។

អត្ថបទពិពណ៌នាជាការនិយាយ

សម្រាប់អ្នកខ្សោយភ្នែក សូមជ្រើសរើសតែសំឡេងជំនួយសម្រាប់អ្នកពិការបានហើយ។

អូឌីយ៉ូបំពេញបន្ថែមណាមួយ

បង្ហាញសំឡេងបន្ថែមទាំងអស់។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

មុខងារសំឡេងបន្ថែម

លទ្ធភាពប្រើប្រាស់ → មុខងារចក្ខុ → ការជ្រើសរើសសំឡេងបន្ថែម

→ → ទូទៅ → លទ្ធភាពប្រើប្រាស់ → ការជ្រើសរើសសំឡេងបន្ថែម

អក្សររត់ឬឯកសារជាសំឡេងត្រូវបានផ្តល់ជូនសម្រាប់អ្នកដែលពិបាកស្តាប់ ឬខ្សោយការមើលឃើញ។

គ្មាន

ជ្រើសរើសសំឡេងលំនាំដើម។

ការពិពណ៌នាជាសំឡេង

សម្រាប់អ្នកខ្សោយការមើលឃើញ សូមជ្រើសរើសសំឡេងលំនាំដើមដែលចង់បានជាមួយនឹងសំឡេងជំនួយសម្រាប់អ្នកពិការ។

ជម្រះសំឡេង

សម្រាប់អ្នកខ្សោយក្នុងការស្តាប់ សូមជ្រើសរើសផលិតផលស្អាត និងសំឡេងជំនួយសម្រាប់អ្នកពិការដែលចង់បាន។

អត្ថបទពិពណ៌នាជាការនិយាយ

សម្រាប់អ្នកខ្សោយភ្នែក សូមជ្រើសរើសតែសំឡេងជំនួយសម្រាប់អ្នកពិការបានហើយ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ដើម្បីសម្រាប់អ្នកពិបាកស្តាប់

លទ្ធភាពប្រើប្រាស់ → **មុខងារស្តាប់** → **លំបាកក្នុងការស្តាប់**

ទូទៅ → **លទ្ធភាពប្រើប្រាស់** → **លំបាកក្នុងការស្តាប់**

01 ចុចប៊ូតុង លើតេឡេ។

02 សូមជ្រើសរើស → **ទូទៅ** → **លទ្ធភាពប្រើប្រាស់**។

03 កំណត់ **អក្សររត់** ទៅជា **បើក**។

04 កំណត់ **លំបាកក្នុងការស្តាប់** ទៅជា **បើក**។
អក្សររត់នឹងត្រូវបានផ្តល់ជូនសម្រាប់អ្នកខ្សោយការស្តាប់។

- នៅពេលបើក **លំបាកក្នុងការស្តាប់** **បើក** វានឹងទទួលបានអាទិភាពខ្ពស់ជាងអក្សររត់ទូទៅ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ប្តូរមីនុយទៅអេក្រង់មានកម្រិតខ្លាំង

លទ្ធភាពប្រើប្រាស់ → **មុខងារចក្ខុ** → **ភាពងឹតខ្លាំង**

ទូទៅ → **លទ្ធភាពប្រើប្រាស់** → **ភាពងឹតខ្លាំង**

នៅពេលមុខងារនេះត្រូវបានកំណត់ទៅជា **បើក**,
វានឹងកែផ្នែខាងក្រោយនៃមីនុយមួយចំនួនលើកញ្ចក់ទូរទស្សន៍ និងពណ៌អក្សរ ដើម្បីកំណត់

មាត្រដ្ឋានប្រផេះ

លទ្ធភាពប្រើប្រាស់ → **មុខងារចក្ខុ** → **មាត្រដ្ឋានប្រផេះ**

ទូទៅ → **លទ្ធភាពប្រើប្រាស់** → **មាត្រដ្ឋានប្រផេះ**

ប្តូរពណ៌មីនុយលើវីដេអូ និងអេក្រង់ទៅពណ៌សខ្មៅ ដើម្បីឱ្យកាន់តែច្បាស់។ កំណត់ទៅជា **បើក**។

បញ្ច្រាសពណ៌

លទ្ធភាពប្រើប្រាស់ → **មុខងារចក្ខុ** → **បញ្ច្រាសពណ៌**

⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **បញ្ជោសពណ៌**

ដើម្បីធ្វើឱ្យមុីនុយងាយស្រួលមើលជាងមុននៅលើអេក្រង់ អ្នកអាចប្តូរ និងកែសម្រួលពណ៌នានា
នៅក្នុងមុីនុយមួយចំនួនបាន។ កំណត់ទៅជា **បើក**។

សេវាកម្ម AI

រូបភាព AI Pro

⚙ → ⚙ → **ទូទៅ** → **សេវាកម្ម AI** → **រូបភាព AI Pro**

នៅពេលកំណត់ទៅ **បើក** បញ្ញាសិប្បនិម្មិត
ដែលត្រូវបានបង្វឹកដោយប្រើបច្ចេកវិទ្យាសិក្សាស៊ីជម្រៅរបស់ក្រុមហ៊ុនផលិត
ស្វែងរកកម្រិតច្បាស់ដែលសមស្របបំផុត អាស្រ័យទៅតាមប្រភេទវីដេអូ
និងបង្ហាញវាដោយប្រើពណ៌ដិតច្បាស់ និងមានលក្ខណៈដូចពិតជាក់ស្តែង។

- វាអាចប្រើសម្រាប់ការផ្សាយឌីជីថល វីដេអូក្នុងឧបករណ៍មេម៉ូរី USB និងធាតុបញ្ចូលវីដេអូ HDMI តែប៉ុណ្ណោះ។
  មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។
- ប្រសិនបើ ⚙ → ⚙ → **រូបភាព** → **របៀបជ្រើសរើស** គឺជា **កម្មវិធីកែលម្អហ្គេម**អ្នកមិនអាចរៀបចំលក្ខណៈពិសេសនេះបានទេ។
- ម៉ូដែលមួយចំនួនមិនដំណើរការជាមួយខ្លឹមសារដែលត្រូវបានរក្សាសិទ្ធិទេ។

ការកំណត់ពន្លឺ AI

⚙ → ⚙ → **ទូទៅ** → **សេវាកម្ម AI** → **ការកំណត់ពន្លឺ AI**

កំណត់ទៅជា **បើក**។ បញ្ញាសិប្បនិម្មិត (AI) បង្ហាញកន្លែងងងឹតយ៉ាងមានប្រសិទ្ធភាព
ដោយផ្អែកលើមជ្ឈដ្ឋានជុំវិញ និងលក្ខណៈខ្លឹមសារនៃឧបករណ៍។

ការជ្រើសរើសប្រភេទដោយ AI

⚙ → ⚙ → **ទូទៅ** → **សេវាកម្ម AI** → **ការជ្រើសរើសប្រភេទដោយ AI**

នៅពេលកំណត់ទៅ **បើក**
គុណភាពរូបភាពនឹងត្រូវបានកែលម្អឱ្យប្រសើរជាងមុនដោយស្វ័យប្រវត្តិ
សម្រាប់ប្រភេទខ្លឹមសារតាមរយៈភាពឆ្លាតវៃសិប្បនិម្មិត។

- វាមិនដំណើរការជាមួយខ្លឹមសារដែលបានការពារការចម្លងទេ។
- ប្រសិនបើ ⚙ → ⚙ → **រូបភាព** → **របៀបជ្រើសរើស** គឺជា **កម្មវិធីកែលម្អហ្គេម**អ្នកមិនអាចរៀបចំលក្ខណៈពិសេសនេះបានទេ។

សំឡេង AI / សំឡេង AI Pro

→ → ទូទៅ → សេវាកម្ម AI → សំឡេង AI / សំឡេង AI Pro

ផ្អែកលើបញ្ហាសប្បនិម្មិត វាធ្វើការវិភាគលក្ខណៈនៃខ្លឹមសារក្នុងពេលជាក់ស្តែង
ដើម្បីផ្តល់បែបផែនសំឡេងល្អបំផុតនិងសំឡេងច្បាស់ និងសម្គាល់សំឡេង 3D
បែបជាក់ស្តែងដោយប្រើបច្ចេកវិទ្យាសំឡេងថ្មីបំផុត។

- ការកំណត់នេះប្រើបានសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ ឬរបារសំឡេង LG ដែលអាចប្រើ **ចែករំលែករបៀបសំឡេងតាមទូរទស្សន៍** ប៉ុណ្ណោះ។
- នៅពេលកំណត់លក្ខណៈពិសេសនេះទៅ **បើក**, របៀបសំឡេង ត្រូវបានប្តូរទៅ **សំឡេង AI/សំឡេង AI Pro**។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI

→ → ទូទៅ → សេវាកម្ម AI → ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI

តាមរយៈមុខងារ **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**
អ្នកអាចរកមើលកន្លែងដែលឧបករណ៍របស់អ្នកត្រូវបានដំឡើងដោយប្រើមីក្រូហ្វូនរបស់ Magic Remote ដើម្បីបង្កើនប្រសិទ្ធភាពសំឡេងឧបករណ៍សម្រាប់មជ្ឈដ្ឋានរបស់អ្នក។
ជ្រើសរើស **ចាប់ផ្តើមការសម្រួលសំឡេងថ្មី** ដើម្បីវាស់ស្ទង់ទីកន្លែងដែលត្រូវដំឡើងឧបករណ៍។
នៅពេលដំណើរការវាស់វែងបានចប់សព្វគ្រប់ហើយ អ្នកអាចជ្រើសរើសទម្រង់អូឌីយ៉ូដែល
អ្នកចង់បាន។

- **បិទ** : ជម្រើសនេះបិទការប្រើ **ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI**-អូឌីយ៉ូដែលលៃតម្រូវ។
  ការជ្រើសរើសជម្រើសនេះបញ្ចេញសំឡេងលំនាំដើមរបស់ឧបករណ៍អ្នកដោយមិនចាំបាច់ធ្វើការកែតម្រូវលើវាឡើយ។
- **ស្តង់ដារ** : ការជ្រើសរើសជម្រើសនេះ បង្កើតបាន
  ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI-អូឌីយ៉ូដែលលៃតម្រូវក្នុងទម្រង់ស្តង់ដារ។
  ទម្រង់នេះផ្តល់នូវសំឡេងច្បាស់ និងដូចធម្មជាតិ។
- **បន្ថែមកម្លាំងបាស** : ការជ្រើសរើសជម្រើសនេះ បង្កើតបាន
  ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI-អូឌីយ៉ូដែលលៃតម្រូវដែលផ្តោតលើបាស។
- **បង្កើនកម្រិតសំឡេង** : ការជ្រើសរើសជម្រើសនេះ បង្កើតបាន
  ការកែប្រែសម្លេងដោយខ្លួនឯងដោយបច្ចេកវិទ្យា AI-អូឌីយ៉ូដែលលៃតម្រូវដែលផ្តោតលើត្រីស្រួ។

- បើមានច្រើនជាងកម្រិតសំឡេងរំខានក្នុងបណ្ណាល័យ (លើសពី 30 ~ 40 dBA) យើងខ្ញុំសូមណែនាំឲ្យអ្នកបញ្ចូលពីគម្លាត 3 ម៉ែត្រ។
- មុខងារនេះអាចមិនដំណើរការបានត្រឹមត្រូវ។

  - សំឡេងរំខានផ្ទៃខាងក្រោយ មានទំហំធំខ្លាំងរហូតដល់ជាង 40 dBA។
  - ប្រសិនបើឧបករណ៍ និង Magic Remote មានចម្ងាយលើសពី 5 ម៉ែត្រ (16.4 ហ្វីត)

ការមើល ជំនួយសម្រាប់ការសម្គាល់សំឡេង

→ → ទូទៅ → សេវាកម្ម AI → ជំនួយសម្រាប់ការសម្គាល់សំឡេង

វាបង្ហាញបញ្ជីនៃឃ្លាបញ្ជាដោយប្រើសំឡេង ដែលឧបករណ៍អាចធ្វើបាន។

ការប្រើ ការកំណត់ការសម្គាល់សំឡេង

→ → ទូទៅ → សេវាកម្ម AI → ការកំណត់ការសម្គាល់សំឡេង

អ្នកអាចប្រើការកំណត់សម្រាប់លក្ខណៈពិសេសនៃការសម្គាល់សំឡេង។

ការណែនាំ AI

→ → ទូទៅ → សេវាកម្ម AI → ការណែនាំ AI

អ្នកអាចទទួលបានសារណែនាំអំពីមាតិកា ដោយផ្អែកលើប្រវត្តិទស្សនាមាតិកា
និងប្រវត្តិប្រើប្រាស់កម្មវិធីរបស់អ្នក។

គន្លឹះផ្លាតវែ

អ្នកអាចទទួលបានការណែនាំអំពីមុខងារផ្លាតវែដែលអ្នកអាចប្រើបាន
នៅពេលមើលការផ្សាយ ឬប្រើកម្មវិធី។

គន្លឹះផ្លាតវែនៅក្នុងការកំណត់

នៅពេលកំណត់រចនាសម្ព័ន្ធការកំណត់លម្អិត
អ្នកក៏អាចទទួលបានការណែនាំអំពីមុខងារដែលពាក់ព័ន្ធផងដែរ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

កម្មវិធីកែលម្អហ្គេម

កម្មវិធីកែលម្អហ្គេម

→ → ទូទៅ → កម្មវិធីកែលម្អហ្គេម

រៀបចំលក្ខណៈពិសេសសម្រាប់បទពិសោធន៍ដ៏ជក់ចិត្ត
នៅពេលអ្នកលេងដោយប្រើដៃហ្គេមវីដេអូ។
ការជ្រើសរើស **បើក** នឹងបើកការកំណត់ដែលពាក់ព័ន្ធ។

- វាដំណើរការជាមួយធាតុបញ្ចូល HDMI តែប៉ុណ្ណោះ។

- ប្រសិនបើអ្នកកំណត់ ⚙ → ⚙ → **រូបភាព**/**សំឡេង** → **របៀបជ្រើសរើស** ទៅមុខងារក្រៅពី **កម្មវិធីកែលម្អហ្គេម** ធាតុមួយចំនួននៅក្នុង **កម្មវិធីកែលម្អហ្គេម** មិនអាចកំណត់មិនបាន។
- ប្រសិនបើអ្នក **បើក** លក្ខណៈពិសេសនេះ អ្នកមិនអាចប្តូរធាតុការកំណត់វីដេអូមួយចំនួនបានទេ។
- នៅពេល **កម្មវិធីកែលម្អហ្គេម** ត្រូវបានកំណត់ទៅ **បើក** សំឡេងអាចនឹងមានការយឺតយ៉ាវ ប្រសិនបើអ្នកកំណត់ **សំឡេងចេញ** ទៅ **ឧបករណ៍ Bluetooth**/**ឧបករណ៍បំពងសំឡេង WiSA**/**ឧបករណ៍អុបទិកចេញ**/**ឧបករណ៍ HDMI(ARC)**។ ប្តូរទៅ **ប្រើឧបករណ៍បំពងសំឡេងទូរទស្សន៍** ឬប្តូរ ⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ជ្រើសរើសទម្រង់សំឡេងធាតុបញ្ចូល HDMI** ទៅ **PCM**។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ហ្គេម

ប្រភេទហ្គេម

អ្នកអាចបង្កើនប្រសិទ្ធភាពអេក្រង់ អាស្រ័យលើប្រភេទហ្គេម។

OLED Motion / OLED Motion Pro

អ្នកអាចធ្វើឱ្យវីដេអូរបស់អ្នកច្បាស់ជាងមុន ដោយកម្ចាត់ស្នាមដានចេញ។

កាត់បន្ថយពន្លឺពណ៌ខៀវ

អ្នកអាចកែតម្រូវពន្លឺចេញពណ៌ខៀវ ដើម្បីសម្រាកភ្នែករបស់អ្នក ខណៈពេលកំពុងមើលអេក្រង់។

របៀបបន្ទប់ងងឹត

អ្នកអាចកែតម្រូវពន្លឺអេក្រង់ទាំងមូល ដើម្បីកាត់បន្ថយការចុកភ្នែកនៅក្នុងមជ្ឈដ្ឋានងងឹត ឬនៅពេលមើលរយៈពេលយូរ ដើម្បីធ្វើឱ្យកាន់តែងាយស្រួលមើលអេក្រង់។

ទប់ស្កាត់ភាពស្មុគស្មាញក្នុងការបញ្ចូល (ការបញ្ចូលស្មុគ)

កាត់បន្ថយការពន្យារធាតុបញ្ចូលក្នុងកម្រិតអប្បបរមា ទៅតាមរលកសញ្ញារូបភាព។

ផ្ទាំងគ្រប់គ្រងហ្គេម

កំណត់ទៅជា **បើក**។ ចុចប៊ូតុង ⚙ នៅលើតេឡេប៊ញ្ចា អំឡុងពេលលេងហ្គេម ដើម្បីបង្ហាញ **ផ្ទាំងគ្រប់គ្រងហ្គេម**។ កំណត់ទៅ **បិទ** ដើម្បីបង្ហាញជា **ការកំណត់រហ័ស** អំឡុងពេលលេងហ្គេម។

- សូមមើល **ការកំណត់** → **ការកំណត់រហ័ស** → **ផ្ទាំងគ្រប់គ្រងហ្គេម** នៃ **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ដើម្បីទទួលបានព័ត៌មានបន្ថែមអំពី **ផ្ទាំងគ្រប់គ្រងហ្គេម**។

VRR

សកម្មភាពនេះកាត់បន្ថយការប្រេះអេក្រង់ និងវីដេអូដើរយឺតក្នុងអំឡុងពេលលេងហ្គេម។

VRR & G-Sync

បច្ចេកវិទ្យាធ្វើសមកាលកម្មដែលចេះបត់បែននៃអេក្រង់របស់ NVIDIA ធ្វើការកែតម្រូវស៊ុម
ដើម្បីកាត់បន្ថយការប្រេះអេក្រង់ និងការជាប់អេក្រង់មកត្រឹមកម្រិតអប្បបរមា។

AMD FreeSync Premium

កំណត់ទៅជា **បើក**។ បច្ចេកវិទ្យាធ្វើសមកាលកម្មដែលចេះបត់បែននៃអេក្រង់របស់ AMD
ធ្វើការកែតម្រូវអត្រាចាក់បញ្ចូល ដើម្បីកាត់បន្ថយការបែកអេក្រង់
និងការជាប់អេក្រង់មកត្រឹមកម្រិតអប្បបរមា។

- អាចរៀបចំម៉ូដែល LED/QNED ដូចខាងក្រោម៖
  ខ្ពស់ : កម្រិតនៃអត្រាផ្ទុកឡើងវិញដែលអាចប្រើបានគឺ 90 Hz - 120 Hz។
  ធំ : កម្រិតនៃអត្រាផ្ទុកឡើងវិញដែលអាចប្រើបានគឺ 48 Hz - 120 Hz។
  ការលោតភ្លើងភ្លឹបភ្លែតលើអេក្រង់អាចកើតឡើងនៅក្នុងមជ្ឈដ្ឋានលេងហ្គេមមួយចំនួន។
  ក្នុងករណីនេះ សូមកំណត់វាទៅ **ខ្ពស់**។

មុខងារ 144Hz

អេក្រង់បង្ហាញកាន់តែរលូន នៅពេលលេងហ្គេម។

- វាដំណើរការសម្រាប់តែធាតុបញ្ចូលហ្គេម ឬកុំព្យូទ័រដែលស្គាល់ 144 Hz ប៉ុណ្ណោះ។

ALLM

ឧបករណ៍នឹងប្តូរទៅមុខងារភាពយឺតទាបដោយស្វ័យប្រវត្តិ
ប្រសិនបើមុខងារនេះត្រូវបានបើក ពេលកំពុងលេងហ្គេម។ ក្នុងករណីនេះ
ការកំណត់រូបភាពមួយចំនួននៅលើឧបករណ៍អាចនឹងមិនត្រូវបានប្រើទេ។

- ឧបករណ៍ដែលបានភ្ជាប់គួរតែស្គាល់សេវាកម្មនេះ។

កែសម្រួលផ្នែកងងឹតឱ្យស័ក្តិសមបំផុត

អ្នកអាចកែសម្រួលពន្លឺនៃកន្លែងងងឹតដែល **VRR**, **VRR & G-Sync** ឬ **AMD FreeSync Premium** ត្រូវបានកំណត់ទៅ **បើក**។

- វាប្រហែលជាមិនដំណើរការប្រក្រតីទេ អាស្រ័យលើមុខងារ
  ឬការកំណត់របស់កុំព្យូទ័រដែលបានភ្ជាប់ ឬកុងសូលហ្គេម។

ពណ៌ម៉ឺនុយ

ពណ៌ម៉ឺនុយរបស់ **កម្មវិធីកែលម្អហ្គេម** និង **ផ្ទាំងគ្រប់គ្រងហ្គេម** អាចផ្លាស់ប្តូរបាន។

ការណែនាំសម្រាប់អ្នកប្រើប្រាស់

ទៅកាន់កម្មវិធី **ការណែនាំសម្រាប់អ្នកប្រើប្រាស់** ។

រូបភាព

មុខងាររក្សាល់នឹងពណ៌ខ្មៅ

អ្នកអាចកែតម្រូវផ្នែកងងឹតបាន។

មុខងាររក្សាល់នឹងពណ៌ស

អ្នកអាចកែតម្រូវផ្នែកភ្លឺបាន។

កម្រិតដិតនៃហ្គេម

កែតម្រូវកម្រិតពន្លឺនៃផ្ទៃដែលភ្លឺ និងងងឹតរបស់រូបភាព។

កម្រិតពណ៌ខ្មៅនៃហ្គេម

កែតម្រូវពន្លឺអេក្រង់សរុប។
អ្នកអាចប្រើការកំណត់ **កម្រិតពណ៌ខ្មៅនៃហ្គេម** ជាក់លាក់
ដើម្បីកំណត់ផ្នែកងងឹតរបស់រូបភាព។

កែតម្រូវភាពដិតនៃហ្គេម

លៃតម្រូវភាពច្បាស់នៃរូបភាព។

កម្រិតពណ៌នៃហ្គេម

ដំឡើង ឬបន្ថយកម្រិតពណ៌ដែលមានបង្ហាញលើអេក្រង់។

ការធ្វើឲ្យចេញជាពណ៌តែមួយ

ធ្វើឲ្យការកំណត់កម្រិតពន្លឺសមស្របផ្អែកតាមពន្លឺរូបភាពរបស់មាតិកា HDR ។

កំណត់ឡើងវិញ

អ្នកអាចកំណត់ការកំណត់ឡើងវិញបាន។

អត្រាទ្រង់ទ្រាយធំទូលាយ

ស្គាល់កម្រិតច្បាស់ជាមួយនឹងសមាមាត្រអេក្រង់ **21:9** ឬ **32:9**។

- រាំដំណើរការ នៅពេលដែលឧបករណ៍ភ្ជាប់ហ្គេម ឬកុំព្យូទ័រស្គាល់សមាមាត្រអេក្រង់ 21:9 ឬ 32:9។
- ដើម្បីបង្ហាញអេក្រង់នៅក្នុងសមាមាត្រអេក្រង់ដែលបានជ្រើសរើស
  ត្រូវតែរៀបចំកម្រិតច្បាស់ដូចដែលបង្ហាញនៅខាងក្រោម
  ដើម្បីឱ្យត្រូវនឹងសមាមាត្រអេក្រង់ដែលចង់បាន
  ទោះបីជានៅលើកុំព្យូទ័រដែលបានភ្ជាប់ក៏ដោយ។

  - **21:9** : 3840 × 1600 (រលកសញ្ញា 60 Hz តែប៉ុណ្ណោះ), 2560 × 1080

- **32:9** : 3840 × 1080

ទីតាំងអេក្រង់

អ្នកអាចប្តូរទីតាំងអេក្រង់ នៅពេលអ្នកកំណត់វាទៅសមាមាត្រអេក្រង់ទូលាយ។

ការកំណត់រូបភាពកម្រិតខ្ពស់

ផ្លាស់ទីទៅ → → **រូបភាព** → **ការកំណត់កម្រិតខ្ពស់**។

សំឡេង

សំឡេងហ្គេម AI

បង្កើនប្រសិទ្ធភាពសំឡេងសម្រាប់ការលេងហ្គេម។

- ការកំណត់នេះប្រើបានសម្រាប់ឧបករណ៍បំពងសំឡេងខាងក្នុងឧបករណ៍ ឬរបារសំឡេង LG ដែលអាចប្រើ **ចែករំលែករបៀបសំឡេងតាមទូរទស្សន៍** ប៉ុណ្ណោះ។

អេក្គុយហ្គេម

អាចកែតម្រូវសំឡេងបានដោយបង្កើន
ឬបន្ថយកម្រិតបញ្ជូនហ្ក្រេកង់មួយចំនួននៃរលកសញ្ញាសំឡេង។

Dolby Atmos

បែបផែន Dolby Atmos ប្រើសម្រាប់ខ្លឹមសារ Dolby Atmos។
សម្រាប់ព័ត៌មានបន្ថែមអំពី **Dolby Atmos** សូមមើល **ការកំណត់** → **សំឡេង** → **Dolby Atmos** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

សំឡេងចេញ

អ្នកអាចជ្រើសរើសឧបករណ៍សំឡេងដែលបញ្ចេញសំឡេងពីឧបករណ៍។

- ប្រសិនបើអ្នកបានជ្រើសរើសឧបករណ៍ដែលមានសំឡេងប្រភេទ USB
នៅពេលលេងហ្គេមនៅលើកុំព្យូទ័រ សូមប្តូរឧបករណ៍សំឡេងទៅ **ប្រើនៅលើកុំព្យូទ័រ** នៅក្នុង **កំពុងប្តូរបណ្តុំ**។ ភាពយឺតនៃសំឡេងអាចត្រូវបានកាត់បន្ថយ។
អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការកំណត់សំឡេងកម្រិតខ្ពស់

ផ្លាស់ទីទៅ → → **សំឡេង** → **ការកំណត់កម្រិតខ្ពស់**។

ការថែទាំ OLED

ការថែទាំ OLED

→ → **ទូទៅ** → **ការថែទាំ OLED**

ផ្តល់សេវាកម្មថែទាំលំដាប់ខ្ពស់ផ្សេងៗជាច្រើនសម្រាប់អ្នកប្រើប្រាស់ម៉ូដែល OLED។

ការកំណត់រូបភាពថែទាំ

វាកំណត់របៀបអេក្រង់ដែលស័ក្តិសមនឹងទម្លាប់មើលរបស់អ្នក។

- **រូបភាព** → **របៀបជ្រើសរើស** និង **ទូទៅ** → **ការសន្សំសំចៃថាមពល**
  មិនអាចកំណត់ខណៈពេលកំពុងប្រើ **ការកំណត់រូបភាពថែទាំ** បានទេ។

បិទ

បិទ **ការកំណត់រូបភាពថែទាំ**។

មុខងារផាសុកភាព

បង្ហាញរូបភាពដែលមានកម្រិតនៃពណ៌ ភាពភ្លឺច្បាស់ និងភាពច្បាស់ធម្មតាៗ។

របៀបដូចក្នុងរោងកុន

រូបភាពសមស្របសម្រាប់ភាពយន្ត។

របៀបថែទាំកុមារ

វាកែតម្រូវពន្លឺពណ៌ខៀវ ដើម្បីឱ្យកុមារកាន់តែងាយស្រួលមើលអេក្រង់។

ការថែទាំផ្ទាំង OLED

ជាមួយនឹង **ការថែទាំផ្ទាំង OLED**, អ្នកអាចកែលម្អបញ្ហាគុណភាពរូបភាពទាក់ទងនឹងការប៉ះរូបភាព នៅពេលអេក្រង់ត្រូវបានបើកសម្រាប់រយៈពេលជាក់លាក់។

មុខងារសម្អាតភិចសែល

ក្រិតខ្នាតបញ្ហាអេក្រង់ដែលអាចកើតមាន
នៅពេលដែលឧបករណ៍បើកសម្រាប់រយៈពេលបន្ថែម។
ការក្រិតខ្នាតចំណាយពេលយ៉ាងតិច 10 នាទីរហូតដល់យូរបំផុតមួយម៉ោងកន្លះ
អាស្រ័យតាមម៉ូដែល។

- មិនត្រូវដកឧបករណ៍ភ្លើង នៅពេលដែលវាកំពុងដំណើរការទេ។
- ការបើកថាមពល អំឡុងពេលក្រិតខ្នាត **មុខងារសម្អាតភិចសែល** ជោះបង់ប្រតិបត្តិការ។

ការផ្លាស់ទីរបស់អេក្រង់

វារំកិលអេក្រង់បន្តិចម្តងៗតាមចន្លោះពេលទៀងទាត់ ដើម្បីការពារការប៉ះរូបភាពលើបន្ទះបង្ហាញ។

កែសម្រួលពន្លឺនិមិត្តសញ្ញា

កែតម្រូវភាពភ្លឺរបស់រូបភាពថេរដូចជារូបសញ្ញានៅក្នុងមាតិកា ដើម្បីកែបញ្ហាគុណភាពរូបភាពដែលមាន។

ការណែនាំការថែទាំ

វាណែនាំឱ្យប្រើការកំណត់រូបភាពដែលសមស្របសម្រាប់មជ្ឈដ្ឋាននៃការមើលឬបញ្ហាឈឺភ្នែកដោយវិភាគទម្លាប់នៃការមើល។

ការកំណត់សម្រាប់ផ្នែកគ្រួសារ

ការកំណត់ដែនកំណត់ការប្រើប្រាស់

→ → **ទូទៅ** → **ការកំណត់សម្រាប់ផ្នែកគ្រួសារ** → **ការកំណត់ដែនកំណត់ការប្រើប្រាស់**

អ្នកអាចប្រើឧបករណ៍ក្នុងរយៈពេលដែលបានកំណត់តែប៉ុណ្ណោះ។
ក្រៅពីរយៈពេលដែលបានកំណត់ អ្នកត្រូវបញ្ចូលពាក្យសម្ងាត់របស់អ្នក
ទើបអាចប្រើឧបករណ៍បាន។

01 កំណត់ **បើកមុខងារ** ទៅ **បើក**។

02 កំណត់ **ម៉ោងចាប់ផ្តើម** និង **ម៉ោងបញ្ចប់**។
ការជ្រើសរើស **សារឡើងវិញ** នឹងបើកដំណើរការមុខងារនេះរៀងរាល់ថ្ងៃ។

03 សូមជ្រើសរើស **កំណត់**។

- សម្រាប់ការណែនាំអំពីរបៀបកំណត់ពាក្យសម្ងាត់ឡើងវិញ សូមមើល **ការកំណត់** → **ប្រព័ន្ធ** → **សុវត្ថិភាព** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

របៀបថែទាំភ្នែក

→ → **ទូទៅ** → **ការកំណត់សម្រាប់ផ្នែកគ្រួសារ** → **របៀបថែទាំភ្នែក**

កំណត់ **បើកមុខងារ** ទៅ **បើក**។ ដើម្បីការពារភ្នែករបស់អ្នក
អេក្រង់ដែលមានពន្លឺពណ៌ខៀវតិចត្រូវបានបង្ហាញ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ការប្រើ **របៀបថែទាំភ្នែក** នឹងកំណត់ **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កាត់បន្ថយពន្លឺពណ៌ខៀវ** ទៅ **បើក**។

របៀបកំណត់កម្រិតសំឡេង

→ → **ទូទៅ** → **ការកំណត់សម្រាប់ផ្នែកគ្រួសារ** → **របៀបកំណត់កម្រិតសំឡេង**

កំណត់ **បើកមុខងារ** ទៅ **បើក**។ ដើម្បីការពារការស្តាប់របស់អ្នក
កម្រិតសំឡេងមិនអាចបង្កើនលើសពីកម្រិតជាក់លាក់បានទេ។

- **របៀបកំណត់កម្រិតសំឡេង**
  ប្រហែលជាមិនដំណើរការសម្រាប់ឧបករណ៍សំឡេងដែលដោតតាមរន្ធកាស/HDMI/ឌីជីថលអ៊ុបទិក
  ទេ។

របាយការណ៍អំពីរយៈពេលប្រើប្រាស់អេក្រង់

→ → **ទូទៅ** → **ការកំណត់សម្រាប់ផ្នែកគ្រួសារ** → **របាយការណ៍អំពីរយៈពេលប្រើប្រាស់អេក្រង់**

អ្នកអាចពិនិត្យមើលរយៈពេលនៃការប្រើប្រាស់ឧបករណ៍របស់អ្នកបាន។

ប៉ុស្តិ៍

កំពុងរៀបចំប៉ុស្តិ៍ដោយស្វ័យប្រវត្តិ

→ → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍ និងការកំណត់** → **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**

ចាប់ប៉ុស្តិ៍ដោយស្វ័យប្រវត្តិ។

01 ជ្រើសរើសប្រទេសដែលប្រើប្រាស់ឧបករណ៍នេះ។
ការកំណត់ប៉ុស្តិ៍ខុសគ្នាអាស្រ័យលើប្រទេសដែលបានជ្រើសរើស។

02 ចាប់ផ្តើម **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ**។

03 ជ្រើសរបៀបរាវប៉ុស្តិ៍

04 កំណត់ការប្តូរដោយស្វ័យប្រវត្តិតាមការណែនាំលើកញ្ចក់ទូរទស្សន៍។

- ប្រសិនបើគេតភ្ជាប់ប្រភពចូលមិនបានត្រឹមត្រូវទេការចុះឈ្មោះប៉ុស្តិ៍មិនដំណើរការទេ។
- **ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ** ចាប់បានតែប៉ុស្តិ៍ដែលកំពុងផ្សាយប៉ុណ្ណោះ។
- ប្រសិនបើបើក **ការចាក់សោប៉ុស្តិ៍** វិនដូលោតឡើងនឹងបង្ហាញដើម្បីសួររកពាក្យសម្ងាត់។

កំណត់ការកំណត់ខ្សែ

នៅពេលកំពុងស្វែងរកប៉ុស្តិ៍ដោយប្រើការកំណត់ពេញលេញ វាអាចចំណាយពេលយូរបន្តិច។
តម្លៃខាងក្រោមត្រូវការដើម្បីស្វែងរកប៉ុស្តិ៍ដែលមានឱ្យបានលឿន និងត្រឹមត្រូវ។
តម្លៃដែលប្រើជាធម្មតាត្រូវបានផ្តល់នៅ “លំនាំដើម” ។
ឧបករណ៍ដែលអាចកំណត់បានខុសគ្នាទៅតាម **ប្រភេទ**។

ហ្វ្រេកង់ (kHz)

បញ្ចូលហ្វ្រេកង់ដែលកំណត់អ្នកប្រើប្រាស់។

អត្រានិមិត្តសញ្ញា (kS/s)

ល្បឿនរបស់ឧបករណ៍ដូចជាម៉ូឌឹមបញ្ជូនទៅប៉ុស្តិ៍មួយ។

ការបែងចែករលកសញ្ញា

ការផ្គុំរលកសញ្ញាសំឡេង ឬវីដេអូ ទៅលើឧបករណ៍ផ្គុក។

លេខសម្គាល់បណ្តាញ

អ្នកំណត់តែមួយគត់ដែលបានលៃទុកសម្រាប់អ្នកប្រើប្រាស់នីមួយៗ។

ហ្វ្រេកង់ចាប់ផ្តើម (kHz)

បញ្ចូលលំដាប់ហ្វ្រេកង់ចាប់ផ្តើមដែលកំណត់អ្នកប្រើប្រាស់។

ហ្វ្រេកង់បញ្ចប់ (kHz)

បញ្ចូលលំដាប់ហ្វ្រេកង់ចុងក្រោយដែលកំណត់អ្នកប្រើប្រាស់។

កំណត់ការកំណត់ផ្កាយរណប

អ្នកអាចបន្ថែម/លុប/កំណត់ផ្កាយរណបដែលអ្នកចង់បាន។

- មុខងារនេះដំណើរការតែនៅពេលមុខងារប៉ុស្តិ៍គឺជាផ្កាយរណបប៉ុណ្ណោះ។

ផ្កាយរណប

ជ្រើសរើសផ្កាយរណបដែលអ្នកចង់បាន។

ហ្វ្រេកង់ LNB

ជ្រើសរើសតម្លៃមួយពី 9750/10600, 9750/10750, 9750, 10600, 10750, 11300, 5150, MDU1, MDU2, MDU3, MDU4, MDU5។ ប្រសិនបើអ្នកជ្រើសរើសយក 9750/10600, 9750/10750(MHz), **កម្រិតសំឡេង 22kHz** ត្រូវបានបិទ។
ប្រសិនបើអ្នករកមិនឃើញតម្លៃហ្វ្រេកង់ LNB ពីបញ្ជីទេ ត្រូវជ្រើសរើសអ្នកប្រើ និងបញ្ចូលហ្វ្រេកង់ដោយដៃ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ឧបករណ៍បញ្ជូនរលកសញ្ញា

ជ្រើសរើសឧបករណ៍ទទួលដែលអ្នកចង់បើក។

កម្រិតសំឡេង 22kHz

នៅពេលប្រើការប្តូរ 22kHz Tone switch ជ្រើសរើស 22kHz ឬ 0 Hz ។ ប្រសិនបើអ្នកប្រើ **កម្រិតសំឡេង 22kHz**, ប្រភេទ Unicable និងMotor ត្រូវបានបិទ។

ថាមពល LNB

ដើម្បីឲ្យឧបករណ៍ផ្គត់ផ្គង់ភ្លើងដំណើរការបានសម្រាប់ LNB ត្រូវជ្រើសរើស **បើក**។
ប្រសិនបើអ្នកជ្រើសរើស **បិទ**, **ប្រភេទម៉ូទ័រ** ត្រូវបានបិទ។

DiSEqC

នៅពេលប្រើ DiSEqC ជ្រើសរើសជម្រើសមួយពី A~D/ToneA~B។ ប្រសិនបើអ្នកប្រើ **DiSEqC**, Unicable និង Motor ត្រូវបានបិទ។

Unicable

ជ្រើសរើសបើក ដើម្បីប្រើយូនីខេបល និងកំណត់នៅក្នុងមីនុយ **ការកំណត់ Unicable**។
នៅពេលយូនីខេបល ដំណើរការ **កម្រិតសំឡេង 22kHz**, **DiSEqC**, **ប្រភេទម៉ូទ័រ** ត្រូវបានបិទ។

ប្រភេទម៉ូទ័រ

ជ្រើសរើសប្រភេទម៉ូទ័រ ដើម្បីប្រើប្រាស់ម៉ូទ័រ និងក្នុងមីនុយការកំណត់ម៉ូទ័រ។ នៅពេលម៉ូទ័រអាចប្រើបាន នោះ, **កម្រិតសំឡេង 22kHz**, **DiSEqC**, **Unicable** មិនអាចប្រើបានទេ។

- ប្រសិនបើអ្នកកំណត់ផ្កាយរណបទៅជាអ្វីផ្សេង អ្នកត្រូវបន្ថែមប្រដាប់ទទួលទូរលេខដោយប្រើការកែសម្រួលប្រដាប់ទទួលទូរលេខ។
- នៅពេលជ្រើសរើស **កម្រិតសំឡេង 22kHz** និង **DiSEqC**
អ្នកត្រូវតែភ្ជាប់ពួកវានៅទីតាំងដូចដែលបង្ហាញនៅលើ OSD។
- ប្រសិនបើអ្នកលុបផ្កាយរណប នោះប៉ុស្តិ៍ទាំងអស់ដែលរក្សាទុកនៅក្នុងផ្កាយរណបនឹងត្រូវលុបចោល ។

កំណត់ការកំណត់ម៉ូទ័រ

DiSEqC 1.2 : គ្រប់គ្រងម៉ូទ័រ ដើម្បីប្តូរទីតាំងចានផ្កាយរណប។

ទិសដៅថាស

ជ្រើសរើសទិសដៅដែលអ្នកចង់ប្តូរម៉ូទ័រ។

របៀបថាស

ម៉ូដពីរអាចប្រើបាន៖ ជំហានបន្ទាប់ និងបន្ត។

- ជំហាន : ម៉ូទ័រប្តូរបានអាស្រ័យដោយតម្លៃដែលអ្នកបញ្ចូល (ពី1 ទៅ 128) ។

- **បន្ត** : ម៉ូទ័របន្តប្តូរហូតដល់អ្នកចុចបញ្ឈប់។

សាកល្បងឧបករណ៍បញ្ជូនរលកសញ្ញា

ជ្រើសរើសសាកល្បងប្រដាប់ទទួលទូរលេខដែលអ្នកចង់បើក។

កំណត់កម្រិត

កំណត់ការប្តូរម៉ូទ័រទៅខាងកើត ឬខាងលិច ដើម្បីរំកិលទៅតាមទិសដៅដែលកំណត់។

- បើក : អ្នកអាចកំនត់ការប្តូរទៅទិសដៅបច្ចុប្បន្នដោយជ្រើសរើសខាងលិច/ខាងកើត។
- បិទ : អ្នកអាចបោះបង់ចំនួនដែលអ្នកបានកំណត់រួច។

ចូលទៅកាន់ 0

អ្នកអាចប្តូរម៉ូទ័រទៅសូន្យ។

USALS : កំណត់ទីតាំងបច្ចុប្បន្ន (រយៈបណ្តោយ/រយៈទទឹង)។

ដើម្បីប្រើការប្តូរប៉ុស្តិ៍ដោយដៃ

⚙ → ⚙ → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) → **ការរាវប៉ុស្តិ៍ដោយផ្ទាល់**

មុខងារនេះគឺសម្រាប់ការស្វែងរក និងការរក្សាទុកប៉ុស្តិ៍ដោយផ្ទាល់ដៃ។
អ្នកអាចពិនិត្យកម្លាំងរលកសញ្ញានៃការផ្សព្វផ្សាយឌីជីថល។

អាប់ដេតបញ្ជីប៉ុស្តិ៍

⚙ → ⚙ → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍ និងការកំណត់** → **អាប់ដេតបញ្ជីប៉ុស្តិ៍**

មុខងារនេះធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីបញ្ជីប៉ុស្តិ៍ដែលបានផ្លាស់ប្តូរ
អាស្រ័យលើស្ថានភាពផ្សាយ ឬមជ្ឈដ្ឋានផ្កាយរណបនៃប្រទេសដែលបានដំឡើងឧបករណ៍នេះ។
ធ្វើបច្ចុប្បន្នភាពបញ្ជីប៉ុស្តិ៍ នៅពេលបិទឧបករណ៍។
បន្ទាប់ពីធ្វើបច្ចុប្បន្នភាពរួច បញ្ជីប៉ុស្តិ៍អាចប្រែប្រួល។ ប្រសិនបើមិនចង់បាន សូមចុច **បិទ**

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ដើម្បីប្រើតេស្តិ៍សញ្ញា

⚙ → ⚙ → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) → **ការសាកល្បងរលកសញ្ញា**

បង្ហាញ MUX និងព័ត៌មានសេវា។ល។

- តេស្តរលកសញ្ញាមាននៅតែក្នុងទម្រង់អង់តែន ឬខ្សែ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

កែសម្រួលប៉ុស្តិ៍

→ → **ទូទៅ** → **ប៉ុស្តិ៍** → **កម្មវិធីគ្រប់គ្រងប៉ុស្តិ៍**

អ្នកអាចកែសម្រួលប៉ុស្តិ៍ដែលជ្រើសរើសរួចពីប៉ុស្តិ៍ដែលបានរក្សាទុក ឬបន្ថែម/លុបប៉ុស្តិ៍ទាំងនោះទៅ/ចេញពីប៉ុស្តិ៍សំណព្វ។

- ប្រសិនបើប៉ុស្តិ៍អ៊ីនធឺណិតត្រូវបានកំណត់ អ្នកក៏អាចគ្រប់គ្រងប៉ុស្តិ៍នៅក្នុង **កម្មវិធីគ្រប់គ្រងប៉ុស្តិ៍** បានផងដែរ។

កែរាវប៉ុស្តិ៍ទាំងអស់

នៅក្នុងបញ្ជីប៉ុស្តិ៍ពេញលេញ អ្នកអាចកំណត់ប៉ុស្តិ៍ដែលបានជ្រើសរើសទៅ **ចាក់សោ / ដោះសោ** ឬកំណត់ប៉ុស្តិ៍ទាំងនោះទៅរំលងបាន នៅពេលប្តូរប៉ុស្តិ៍។

- មុខងារដែលមាន ប្រហែលជាមានភាពខុសគ្នាអាស្រ័យលើរលកសញ្ញាផ្សព្វផ្សាយ។

កែសម្រួលសំណព្វ

អ្នកអាចបញ្ចូល/លុបប៉ុស្តិ៍ដែលចង់បានទៅកាន់ និងពីប៉ុស្តិ៍ដែលចូលចិត្ត ផ្លាស់ប្តូរលំដាប់របស់ប៉ុស្តិ៍ទាំងនោះ និងច្រើនទៀត។

កែសម្រួលប៉ុស្តិ៍ផ្កាយរណប (កម្រិតខ្ពស់)

នៅក្នុងបញ្ជីប៉ុស្តិ៍ផ្កាយរណប អ្នកអាចកំណត់ប៉ុស្តិ៍ដែលបានជ្រើសរើសទៅ **ចាក់សោ / ដោះសោ** ឬកំណត់ប៉ុស្តិ៍ទាំងនោះទៅរំលងបាន នៅពេលប្តូរប៉ុស្តិ៍។

- មានតែម៉ូដែលដែលស្គាល់ផ្កាយរណបប៉ុណ្ណោះ ទើបអាចប្រើបាន។

ស្វែងយល់បន្ថែមអំពី HbbTV

HbbTV (Hybrid Broadcast Broadband TV)
គឺជាស្តង់ដារផ្កាយថ្មីដែលនាំមកនូវសេវាកម្មប្រភេទតេឡេតិកកំពូល។
វាធ្វើឱ្យកម្មវិធីដែលបានបញ្ជូនអាចរួមបញ្ចូលជាមួយឧបករណ៍ឆ្លាតវៃនៅពេលប្រើប្រាស់ ឬភ្ជាប់ទៅសេវាកម្មលើអ៊ីនធឺណិតដែលបានបញ្ជូនតាមរយៈប្រតបេន។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយនឹង Live Channel** → **HbbTV** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ចម្លងប៉ុស្តិ៍

→ → **ទូទៅ** → **ប៉ុស្តិ៍** → **ចម្លងប៉ុស្តិ៍**

អ្នកអាចរក្សាទុកបញ្ជីប៉ុស្តិ៍របស់ឧបករណ៍ទៅឧបករណ៍ផ្ទុក USB ដែលបានភ្ជាប់
ឬក្សាទុកបញ្ជីប៉ុស្តិ៍របស់ USB ទៅក្នុងឧបករណ៍បាន។

- សម្រាប់ម៉ូដែលផ្កាយរណប

បណ្តាញ

ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)

→ → **ទូទៅ** → **បណ្តាញ** → **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)**

ប្រសិនបើរ៉ោតទ័រដែលបានភ្ជាប់ទៅបណ្តាញស្គាល់មុខងារ DHCP នោះការភ្ជាប់ឧបករណ៍
និងរ៉ោតទ័រតាមខ្សែនឹងភ្ជាប់ទៅបណ្តាញដោយស្វ័យប្រវត្តិ។
ប្រសិនបើវាមិនស្គាល់ការរៀបចំដោយស្វ័យប្រវត្តិទេ អ្នកអាចជ្រើសរើស **កែសម្រួល**
ដើម្បីរៀបចំការតភ្ជាប់បណ្តាញរបស់អ្នកដោយផ្ទាល់បាន។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការតភ្ជាប់ Wi-Fi

→ → **ទូទៅ** → **បណ្តាញ** → **ការតភ្ជាប់ Wi-Fi**

អ្នកអាចពិនិត្យមើល និងភ្ជាប់ទៅបណ្តាញអ៊ីនធឺណិតឥតខ្សែដែលមាន
ប្រសិនបើអ្នកបានរៀបចំឧបករណ៍សម្រាប់បណ្តាញឥតខ្សែ។
ជ្រើសរើសរ៉ោតទ័រឥតខ្សែដែលត្រូវភ្ជាប់។
សម្រាប់ការកំណត់លម្អិតជាងនេះ សូមជ្រើសរើស **ការកំណត់បណ្តាញផ្សេងទៀត**។

បន្ថែមបណ្តាញឥតខ្សែដែលបានលាក់

ប្រសិនបើអ្នកបញ្ចូលឈ្មោះបណ្តាញដោយផ្ទាល់ អ្នកអាចបន្ថែមបណ្តាញឥតខ្សែ។

ភ្ជាប់តាមរយៈ WPS PBC

ប្រសិនបើរ៉ោតទ័រឥតខ្សែដែលអ្នកចង់ភ្ជាប់មានលក្ខណៈពិសេសនៃការកំណត់រចនាសម្ព័ន្ធប៊ូតុង
ចុចសម្រាប់រៀបចំការការពារ Wi-Fi (WPS-PBC)
នោះអ្នកអាចភ្ជាប់រ៉ោតទ័រឥតខ្សែបានយ៉ាងងាយស្រួល ដោយចុចប៊ូតុង WPS-PBC
នៅលើរ៉ោតទ័រនោះ។ ចុចប៊ូតុង WPS-PBC របស់រ៉ោទ័រឥតខ្សែ រួចចុចប៊ូតុង [ភ្ជាប់]
របស់ឧបករណ៍។

ភ្ជាប់តាមរយៈ WPS PIN

នេះគឺជាវិធីក្នុងការភ្ជាប់ទៅចំណុចចូលប្រើ
ដោយប្រើលេខសម្គាល់ផ្ទាល់ខ្លួនសម្រាប់រៀបចំការការពារ Wi-Fi (WPS-PIN)។
ជ្រើសរើសចំណុចចូលប្រើ (AP) ដែលអ្នកចង់ភ្ជាប់។ បញ្ចូលកូដ PIN
ដែលបង្ហាញនៅលើឧបករណ៍ Wi-Fi របស់ចំណុចចូលប្រើ។

ការកំណត់ Wi-Fi កម្រិតខ្ពស់

បន្ទាប់ពីអ្នកភ្ជាប់ទៅបណ្តាញឥតខ្សែរួចហើយ
អ្នកអាចមើលព័ត៌មានអំពីការតភ្ជាប់បានដូចជា ព័ត៌មានលម្អិតអំពីអាសយដ្ឋាន IP
ជាដើម។ លើសពីនេះទៀត អ្នកអាចប្តូរអាសយដ្ឋាន IP និងអាសយដ្ឋានម៉ាស៊ីនមេ DNS
ដែលអ្នកចង់ភ្ជាប់បាន ដោយចុចប៊ូតុង **កែសម្រួល** ។

- សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបភ្ជាប់ទៅបណ្តាញ សូមមើល **ចាប់ផ្តើម webOS** → **ការភ្ជាប់ទៅបណ្តាញ** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ឧបករណ៍ខាងក្រៅ

ភ្ជាប់ឧបករណ៍បញ្ជាតាម Bluetooth

⚙ → ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ភ្ជាប់ឧបករណ៍បញ្ជាតាម Bluetooth**

អ្នកអាចភ្ជាប់ និងប្រើឧបករណ៍បញ្ចូលដូចជា ដៃហ្គេម កណ្តុរ ឬក្តារចុចដែលអាចប្រើ
Bluetooth។
បើកឧបករណ៍បញ្ចូលដែលអ្នកចង់ភ្ជាប់ កំណត់វាទៅមុខងារផ្គូផ្គង រួចចុច **ភ្ជាប់** នៅលើអេក្រង់។
ប្រសិនបើអ្នកបើកឧបករណ៍បញ្ចូលដែលអ្នកបានភ្ជាប់ពីមុន នោះវាភ្ជាប់ដោយស្វ័យប្រវត្តិ។
ដើម្បីផ្តាច់ការតភ្ជាប់ដែលមានស្រាប់ ចុច **ផ្តាច់**។

- សូមណែនាំអ្នកឱ្យប្រើផលិតផលដែលបានធ្វើតេស្តលើភាពត្រូវគ្នាជាមួយឧបករណ៍នេះ។
  Mouse ដែលប្រើ Bluetooth : Logitech M535, Logitech MX Master 2S, Apple Magic Mouse2
  ក្តារចុច Bluetooth : Logitech K480, Arteck HB030B, Arteck HB192, Apple Magic Keyboard
  ដៃហ្គេម Bluetooth : Sony Dualshock4, Sony DualSense Controller, Sony DualSense Edge Controller, Microsoft Xbox One S Controller, Microsoft Xbox Series X Controller, Microsoft Xbox Adaptive Controller, NVIDIA SHIELD Controller, Amazon Luna Controller, Shaks S3b, Shaks S2b, Nintendo Switch Pro Controller, Nintendo Joy-con Controller, MOGA XP5-X Plus Controller
- ម៉ូដែលដែលអាចប្រើ Bluetooth ទើបអាចប្រើលក្ខណៈពិសេសនេះបាន។
- ការភ្ជាប់ឧបករណ៍ Bluetooth ច្រើនអាចបណ្តាលឱ្យមានការតភ្ជាប់ ឬប្រតិបត្តិការខ្សោយ។
- ប្រសិនបើឧបករណ៍ Bluetooth ស្ថិតនៅឆ្ងាយពីឧបករណ៍នេះពេក ឬមានរបាំង
  ពួកវាប្រហែលជាមិនដំណើរការជាធម្មតាទេ។
- អាស្រ័យទៅតាមឧបករណ៍ភ្ជាប់ខាងក្រៅ (រ៉ោតទ័រឥតខ្សែ ម៉ាស៊ីនមីក្រូវ៉ែវ ។ល។)
  បញ្ហាក្នុងការទំនាក់ទំនងអាចនឹងកើតមានឡើង។
- ប្រសិនបើឧបករណ៍ដែលអ្នកបានជ្រើសរើសពី **ឧបករណ៍ដែលបានចុះឈ្មោះ** មិនភ្ជាប់ឡើងវិញទេ

សូម **ផ្តាច់** រួចភ្ជាប់ឧបករណ៍ឡើងវិញ។

- វាខុសគ្នាទៅតាមឧបករណ៍។ សម្រាប់ព័ត៌មានបន្ថែមអំពីឧបករណ៍ដែលអ្នកចង់តភ្ជាប់ សូមអានការណែនាំពីរបៀបប្រើប្រាស់របស់វា។

ការកំណត់អង្គបញ្ចាសកល

⚙ → ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់អង្គបញ្ចាសកល**

ប្រសិនបើអ្នករៀបចំតេឡេបញ្ជាសកល នោះអ្នកអាចបញ្ជាឧបករណ៍ភ្ជាប់ខាងក្រៅ ដែលបានភ្ជាប់ទៅឧបករណ៍ដោយប្រើ Magic Remote ជំនួសឱ្យតេឡេបញ្ជារបស់ឧបករណ៍ទាំងនោះផ្ទាល់។
សម្រាប់ព័ត៌មានបន្ថែម សូមមើល **របៀបបើកដំណើរការឧបករណ៍** → **ការកំណត់ការបញ្ជាសកល** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការកំណត់ធាតុបញ្ចូល HDMI ខាងក្រៅ

⚙ → ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់ HDMI**

អ្នកអាចប្រើការកំណត់ដើម្បីធានាបាននូវរូបភាពច្បាស់ល្អ និងការគ្រប់គ្រងឧបករណ៍ HDMI ដែលបានភ្ជាប់យ៉ាងងាយស្រួល។

4:4:4 ឆ្លងកាត់

ផ្ទេរលកសញ្ញា 4:4:4 ទៅឧបករណ៍ដែលនៅក្រៅមុខងារកុំព្យូទ័រ ប៉ុន្តែការដំណើរការមុខងារដូចជា **ការកាត់បន្ថយសំឡេងរំខាន**, **TruMotion** និងច្រើនទៀតអាចត្រូវបានរំលង។ ការកំណត់នេះត្រូវបានណែនាំសម្រាប់អ្នកបង្កើតខ្លឹមសារ ដែលចង់ផ្ទេរលកសញ្ញាដែលមិនត្រូវការការដំណើរការបន្ថែមតែប៉ុណ្ណោះ។

HDMI Deep Color

ប្រសិនបើអ្នកភ្ជាប់ឧបករណ៍ដែលស្គាល់ **HDMI Deep Color** នោះអ្នកអាចរីករាយជាមួយរូបភាពដែលកាន់តែច្បាស់ជាងមុន។
បន្ទាប់ពីភ្ជាប់ឧបករណ៍ចាក់រួចហើយ សូមកំណត់ **HDMI Deep Color** ទៅ **4K**។
ប្រសិនបើឧបករណ៍ដែលភ្ជាប់មិនស្គាល់មុខងារនេះទេ នោះវាអាចនឹងដំណើរការមិនត្រឹមត្រូវឡើយ។
នៅពេលមានបញ្ហាអេក្រង់កើតឡើង សូមប្តូរការកំណត់ **HDMI Deep Color** ទៅ **បិទ**។

គុណភាពបង្ហាញដែលបានគាំទ្រ

- 4K : អាចប្រើបាន 4K@120 Hz (4:4:4, 4:2:2, 4:2:0) (ម៉ូដែល 120 Hz តែប៉ុណ្ណោះ) 4K@60 Hz (4:4:4, 4:2:2 និង 4:2:0)
- បិទ : គាំទ្រ 4K@60 Hz (4:2:0)

ទម្រង់ដែលស្គាល់ 4K

កម្រិតគុណភាព	កម្រិតរូបភាព (Hz)	ជម្រៅពណ៌/គំរូក្រូម		
		8 bit	10 bit	12 bit
3840 × 2160p 4096 × 2160p	50 59.94 60 (ម៉ូដែល 60 Hz តែប៉ុណ្ណោះ)	YCbCr 4:2:0	YCbCr 4:2:0 [1)]	YCbCr 4:2:0 [1)]
		YCbCr 4:2:2 [1)]	YCbCr 4:2:2 [1)]	YCbCr 4:2:2 [1)]
		YCbCr 4:4:4 [1)]	-	-
		RGB 4:4:4 [1)]	-	-
	50 59.94 60 (ម៉ូដែល 120 Hz តែប៉ុណ្ណោះ)	YCbCr 4:2:0	YCbCr 4:2:0 [1)]	YCbCr 4:2:0 [1)]
		YCbCr 4:2:2 [1)]	YCbCr 4:2:2 [1)]	YCbCr 4:2:2 [1)]
		YCbCr 4:4:4 [1)]	YCbCr 4:4:4 [1)]	YCbCr 4:4:4 [1)]
		RGB 4:4:4 [1)]	RGB 4:4:4 [1)]	RGB 4:4:4 [1)]
	100 [1)] 120 [1)] (ម៉ូដែល 120 Hz តែប៉ុណ្ណោះ) 144 [2)] (ម៉ូដែល 144 Hz តែប៉ុណ្ណោះ)	YCbCr 4:2:0	YCbCr 4:2:0	YCbCr 4:2:0
		YCbCr 4:2:2	YCbCr 4:2:2	YCbCr 4:2:2
		YCbCr 4:4:4	YCbCr 4:4:4	YCbCr 4:4:4
		RGB 4:4:4	RGB 4:4:4	RGB 4:4:4

[1] ដំណើរការបាននៅពេល **HDMI Deep Color** ត្រូវកំណត់ទៅជា **4K**។
ស្គាល់នៅពេល[2] **កម្មវិធីកែលម្អហ្គេម** → **មុខងារ 144Hz** ត្រូវបានកំណត់ទៅ**បើក**។

- អ្នកអាចផ្លាស់ប្តូរតែការកំណត់នៃ HDMI ដែលអ្នកកំពុងមើល។
- អ្នកអាចបញ្ជាក់ពីការកំណត់ផ្សេងគ្នាសម្រាប់រន្ធ HDMI នីមួយៗបាន។

ការប្តូរមេឌៀរហ័ស

នៅពេលខ្លឹមសារដែលមានចំនួនហ្រ្វេមខុសគ្នាក្នុងមួយវិនាទី (FPS)
ត្រូវបានចាក់នៅលើឧបករណ៍ខាងក្រៅដែលអាចប្រើ QMS បាន
វាធ្វើឱ្យអេក្រង់ផ្លាស់ប្តូរដោយរលូនដោយមិនមានការរំខាន។

- អាចប្រើបានសម្រាប់តែម៉ូដែលមួយចំនួនប៉ុណ្ណោះ។

SIMPLINK (HDMI-CEC)

អ្នកអាចបញ្ជា និងប្រើឧបករណ៍ពហុមេឌៀដែលភ្ជាប់តាមរយៈ HDMI
ជាមួយតេឡេប្រជារបស់ឧបករណ៍នេះយ៉ាងងាយស្រួល។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **របៀបបើកដំណើរការឧបករណ៍** → **ការភ្ជាប់ទៅ SIMPLINK (HDMI-CEC)** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

កុំព្យូទ័រ Dolby Vision

អ្នកអាចរីករាយទស្សនាអេក្រង់ Dolby Vision ដោយបើក HDR
នៅក្នុងការកំណត់អេក្រង់របស់កុំព្យូទ័រដែលបានភ្ជាប់។

- អាចប្រើបានសម្រាប់តែម៉ូដែលមួយចំនួនប៉ុណ្ណោះ។

បើកទូរទស្សន៍ដោយប្រើឧបករណ៍ចល័ត

⚙ → **⚙** → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **បើកទូរទស្សន៍ដោយប្រើឧបករណ៍ចល័ត**

ប្រសិនបើ **បើកតាមរយៈ Wi-Fi/បើកតាមរយៈ Wi-Fi (របៀបផ្អាកដំណើរការដែលភ្ជាប់បណ្តាញ)**
ឬ **បើកតាមរយៈ Bluetooth/បើកតាមរយៈ Bluetooth**
(របៀបផ្អាកដំណើរការដែលភ្ជាប់បណ្តាញ) ត្រូវបានកំណត់ទៅ **បើក**
នោះអ្នកអាចបើកឧបករណ៍របស់អ្នក ដោយប្រើកម្មវិធីដែលស្គាល់
បើកទូរទស្សន៍ដោយប្រើឧបករណ៍ចល័ត បាន។

- ឧបករណ៍គួរតែត្រូវបានភ្ជាប់ជាមួយបណ្តាញ។
- ឧបករណ៍នេះ និងឧបករណ៍ដែលនឹងត្រូវប្រើគួរតែភ្ជាប់ជាមួយបណ្តាញតែមួយ។
- គេត្រូវតែប្រើមុខងារពិសេស **បើកតាមរយៈ Wi-Fi/បើកតាមរយៈ Wi-Fi (របៀបផ្អាកដំណើរការដែលភ្ជាប់បណ្តាញ)** នៅក្នុងកូនកម្មវិធីមួយក្នុងឧបករណ៍ទំនើបដែលស្គាល់មុខងារពិសេសនេះ។
- **បើកតាមរយៈ Bluetooth/បើកតាមរយៈ Bluetooth (របៀបផ្អាកដំណើរការដែលភ្ជាប់បណ្តាញ)**

អាចប្រើបាននៅលើស្មាតហ្វូនមួយចំនួនតែប៉ុណ្ណោះ។

- ត្រូវតែដោតឧយឧបករណ៍។
- ដើម្បីតភ្ជាប់លើកដំបូង សូមប្រាកដថាឧបករណ៍ដែលត្រូវប្រើរួចរាល់ដើម្បីតភ្ជាប់។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

លុបប្រវត្តិនៃការតភ្ជាប់

→ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **លុបប្រវត្តិនៃការតភ្ជាប់**

អ្នកអាចលុបប្រវត្តិនៃការតភ្ជាប់របស់ឧបករណ៍ដែលភ្ជាប់ជាមួយឧបករណ៍នេះនៅលើបណ្តាញតតែខ្សែ។

ប្រព័ន្ធ

ការកំណត់រចនាសម្ព័ន្ធការកំណត់ភាសា

→ → **ទូទៅ** → **ប្រព័ន្ធ** → **ភាសា (Language)**

អ្នកអាចជ្រើសរើសភាសាម៉ឺនុយឲ្យបង្ហាញលើអេក្រង់ និងភាសាតន្ត្រីនៃការផ្សាយឌីជីថល។

ភាសាក្នុងម៉ឺនុយ (Menu Language)

អ្នកអាចជ្រើសរើសភាសាមួយក្នុងចំណោមភាសានៅក្នុងម៉ឺនុយជាច្រើនដើម្បីឲ្យបង្ហាញលើអេក្រង់។
ភាសាសម្រាប់ការសម្គាល់ការនិយាយនឹងត្រូវបានកំណត់ទៅភាសាដែលបានជ្រើសរើសសម្រាប់ម៉ឺនុយដោយស្វ័យប្រវត្តិ។

- ការសម្គាល់ការនិយាយត្រូវបានប្រើប្រាស់សម្រាប់ម៉ូឌែលមួយចំនួនតែប៉ុណ្ណោះ។

ភាសាជាសំឡេងចម្បង / ភាសាជាសំឡេងបន្ទាប់បន្សំ

អ្នកអាចជ្រើសរើសភាសាដែលអ្នកចង់បាននៅពេលមើលកម្មវិធីផ្សាយឌីជីថល ដែលរួមមានភាសាតន្ត្រីច្រើនភាសា។
សម្រាប់កម្មវិធីដែលមិនគាំទ្រច្រើនភាសា ភាសាលំនាំដើមនឹងត្រូវបានប្រើ។

- អនុវត្តចំពោះការផ្សាយឌីជីថល។

ភាសាក្តារចុច

ជ្រើសរើសភាសា ដើម្បីប្រើនៅលើក្តារចុចលើអេក្រង់។

ដើម្បីកំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍

កំណត់ភាសារបស់អត្ថបទដែលបង្ហាញលើទូរទស្សន៍។
ដើម្បីមើលព័ត៌មានលម្អិត សូមចុច **រីករាយនឹង Live Channel** → **អក្សរសន្ទស្សន៍** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- ក្នុងរបៀបឌីជីថលតែប៉ុណ្ណោះ
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការកំណត់ទីតាំង

⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ទីតាំង**

អ្នកអាចប្តូរការកំណត់ទីតាំងឧបករណ៍។

ការកំណត់អាសយដ្ឋាន

អ្នកអាចកំណត់ **តំបន់** និង **ទីក្រុង** នៃឧបករណ៍របស់អ្នក។

ប្រទេសផ្សព្វផ្សាយ

អ្នកអាចកំណត់ប្រទេសផ្សាយនៅលើឧបករណ៍របស់អ្នក។

លេខកូដតំបន់

មុខងារនេះត្រូវបានប្រើ
ដើម្បីកំណត់ទីតាំងផ្សាយនៃឧបករណ៍ដោយបញ្ចូលកូដតំបន់របស់អ្នក។

ប្រទេសផ្តល់សេវាកម្ម LG

ប្រសិនបើអ្នកមិនកំណត់ **កំណត់ដោយស្វ័យប្រវត្តិ** ទេ
អ្នកអាចជ្រើសរើសប្រទេសដោយផ្ទាល់ដៃបាន។

ការកំណត់ទីតាំងអាកាសធាតុ

សូមកំណត់តំបន់របស់អ្នក
ដើម្បីអោយព័ត៌មានពីអាកាសធាតុអាចបង្ហាញនៅលើអេក្រង់បាន។

- អ្នកត្រូវតែកំណត់ប្រទេសដោយដៃ នៅពេលអ្នកមិនបានតភ្ជាប់បណ្តាញ។
- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ម៉ោង និងកម្មវិធីកំណត់ម៉ោង

⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ម៉ោង និងកម្មវិធីកំណត់ម៉ោង**

អ្នកអាចពិនិត្យមើលការកំណត់ដែលពាក់ព័ន្ធនឹងការកំណត់រចនាសម្ព័ន្ធ ឬម៉ោងបាន។

កំណត់ដោយស្វ័យប្រវត្តិ

ម៉ោងឧបករណ៍ត្រូវបានកំណត់ទៅម៉ោងនៃព័ត៌មានផ្សាយឌីជីថលដោយស្វ័យប្រវត្តិ
ដែលផ្ទៀពីស្ថានីយផ្សាយ ឬម៉ោងដែលផ្ទៀពីម៉ាស៊ីនមេ។

ម៉ោង / កាលបរិច្ឆេទ / ល្វែងម៉ោង

អ្នកអាចកំណត់ពេលវេលា និងកាលបរិច្ឆេទដោយដៃ ប្រសិនបើពេលវេលាបច្ចុប្បន្នបានកំណត់
ដោយស្វ័យប្រវត្តិមិនត្រឹមត្រូវ។

- ប្រសិនបើអ្នកកំណត់ម៉ោងដោយផ្ទាល់ តាមរយៈអង់តែនដែលភ្ជាប់ ព័ត៌មានអំពីកាលវិភាគ
  ការណែនាំអំពីកម្មវិធី ។ល។ ប្រហែលជាមិនដំណើរការត្រឹមត្រូវនោះទេ។

ល្វែងម៉ោងតាមបំណង

នៅពេលជ្រើសរើស **តាមបំណង** នៅក្នុង **ល្វែងម៉ោង** ម៉ឺនុយ **ល្វែងម៉ោងតាមបំណង**
ត្រូវបានបើកដំណើរការ។

កម្មវិធីកំណត់ម៉ោង

កម្មវិធីកំណត់ម៉ោងដេក

កំណត់ឧបករណ៍ ដើម្បីបិទនៅពេលដែលបានកំណត់។
ប្រសិនបើអ្នកមិនចង់ប្រើ **កម្មវិធីកំណត់ម៉ោងដេក** សូមជ្រើសរើស **បិទ**។

បើកកម្មវិធីកំណត់ម៉ោង

កំណត់ **បើកមុខងារ** ទៅ **បើក**។
ឧបករណ៍ត្រូវបានបើកនៅម៉ោងដែលបានកំណត់។

- **ម៉ោង** : កំណត់ម៉ោងដែលត្រូវបើកថាមពល។
- **ប្រើការកំណត់ម៉ោងឡើងវិញ** : កំណត់ថ្ងៃនៃសប្តាហ៍។ កំណត់ជម្រើសទៅ **គ្មាន**
  ដើម្បីដំណើរការលក្ខណៈពិសេសនេះតែម្តងប៉ុណ្ណោះ។
- **ធាតុបញ្ចូល** : កំណត់ធាតុបញ្ចូលខាងក្រៅសម្រាប់បង្ហាញ នៅពេលបើកថាមពល។
- **កំណត់ម៉ោងឲ្យប៉ុស្តិ៍** : កំណត់ប៉ុស្តិ៍សម្រាប់បង្ហាញ នៅពេលបើកថាមពល។
  ជម្រើសនេះអាចកំណត់បាន តែនៅពេលដែលកំណត់ **ធាតុបញ្ចូល** ទៅ **ទូរទស្សន៍** ប៉ុណ្ណោះ។
- **កម្រិតសំឡេង** : កំណត់កម្រិតសំឡេងសម្រាប់ប្រើ នៅពេលបើកថាមពល។

បិទកម្មវិធីកំណត់ម៉ោង

កំណត់ **បើកមុខងារ** ទៅ **បើក**។
ឧបករណ៍នេះបិទនៅម៉ោងកំណត់។

- **ម៉ោង** : កំណត់ម៉ោងដែលត្រូវបិទថាមពល។

· **ប្រើការកំណត់ម៉ោងឡើងវិញ** : កំណត់ថ្ងៃនៃសប្តាហ៍។ កំណត់ជម្រើសទៅ **គ្មាន** ដើម្បីដំណើរការលក្ខណៈពិសេសនេះតែម្តងប៉ុណ្ណោះ។

បិទថាមពលដោយស្វ័យប្រវត្តិបន្ទាប់ពីរយៈពេល 4 ម៉ោង

ប្រសិនបើអ្នកមិនចុចប៊ូតុងណាមួយរយៈពេល 4 ម៉ោង
បន្ទាប់ពីបើកឧបករណ៍ដោយមុខងារដូចជា **បើកកម្មវិធីកំណត់ម៉ោង** ទេ
ឧបករណ៍នេះនឹងបិទដោយស្វ័យប្រវត្តិ។
ដើម្បីធានាថាផលិតផលមិនបិទដោយស្វ័យប្រវត្តិសូមកំណត់
បិទថាមពលដោយស្វ័យប្រវត្តិបន្ទាប់ពីរយៈពេល 4 ម៉ោង ទៅ **បិទ**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

- ដើម្បីប្រើ **បើកកម្មវិធីកំណត់ម៉ោង**/**បិទកម្មវិធីកំណត់ម៉ោង**, កំណត់ពេលវេលាឲ្យបានត្រឹមត្រូវ។

ការកំណត់ **សុវត្ថិភាព**

→ → **ទូទៅ** → **ប្រព័ន្ធ** → **សុវត្ថិភាព**

អ្នកអាចចាក់សោលើកម្មវិធី ឬការផ្សាយបាន។
កំណត់ **បើកមុខងារ** ទៅ **បើក**។

ការចាក់សោកម្មវិធីទូរទស្សន៍

មុខងារនេះ ដំណើរការបានដោយអាស្រ័យលើព័ត៌មានដែលបានពីស្ថានីយ៍ផ្សាយ។
អាស្រ័យហេតុ បើសញ្ញាមានព័ត៌មានមិនត្រឹមត្រូវ មុខងារនេះដំណើរការទៅបានទេ។
ដាក់កំហិតលើការមើលរបស់កុមារចំពោះខ្លឹមសារផ្សាយសម្រាប់មនុស្សពេញវ័យដាក់លាក់
ដោយផ្អែកលើការកំណត់ការដាក់កំហិតការវាយតម្លៃ។ ដើម្បីមើលខ្លឹមសារដែលបានទប់ស្កាត់
សូមបញ្ចូលពាក្យសម្ងាត់។ ការវាយតម្លៃការមើលមានភាពខុសគ្នាទៅតាមប្រទេស។

- ស្គាល់តែនៅក្នុងទម្រង់ឌីជីថលប៉ុណ្ណោះ។
- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ការចាក់សោប៉ុស្តិ៍

ខ្ទប់ប៉ុស្តិ៍ដែលមានផ្ទុកមេឌៀ ឬមាតិកាដែលមិនត្រឹមត្រូវសម្រាប់កុមារ។ អាចមាន
ការជ្រើសរើសប៉ុស្តិ៍នានាបាន តែអេក្រង់នៅទទេ ហើយអូឌីយ៉ូត្រូវបានដាក់ឲ្យស្ងាត់សំឡេង។
ដើម្បីមើលប៉ុស្តិ៍ដែលចាក់សោហើយបាន វាយបញ្ចូលពាក្យសម្ងាត់។

ការចាក់សោកម្មវិធី

អ្នកអាចចាក់សោ ឬដោះសោកម្មវិធីបាន។

- មុខងារសោមិនអាចរកបានភ្លាមៗសម្រាប់កម្មវិធីដែលកំពុងដំណើរការទេ។

បានចាក់សោធាតុបញ្ចូល

អ្នកអាចចាក់សោ ឬដោះសោទិន្នន័យបញ្ចូលបាន។

កំណត់ពាក្យសម្ងាត់ឡើងវិញ

កំណត់ ឬផ្លាស់ប្តូរពាក្យសម្ងាត់សម្រាប់ឧបករណ៍។

- ពាក្យសម្ងាត់លំនាំដើមត្រូវបានកំណត់ជា “0000”។
  នៅពេលបារាំង នីរ៉ែរ ឬបែលហ្ស៊ិក ត្រូវបានរើសជាប្រទេស លេខសម្ងាត់មិនមែន “0000” ទេ ប៉ុន្តែគឺ “1234”។

ការកំណត់ពាក្យសម្ងាត់ដែលបាត់ឡើងវិញ

ប្រសិនបើអ្នកបានភ្លេចពាក្យសម្ងាត់ដែលអ្នកបានកំណត់ អ្នកអាចកំណត់វាឡើងវិញបានតាមវិធីដូចខាងក្រោម៖

01 ចុចប៊ូតុង ⚙ លើតេឡេ។

02 សូមជ្រើសរើស ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **សុវត្ថិភាព**។

03 ចុច **(ប៉ុស្តិ៍)** ∧ → **(ប៉ុស្តិ៍)** ∧ → **(ប៉ុស្តិ៍)** ∨ → **(ប៉ុស្តិ៍)** ∧ នៅលើតេឡេ។ បង្អួចបញ្ចូលពាក្យសម្ងាត់មេនឹងបង្ហាញឡើង។

04 បញ្ចូលលេខ “0313” នៅក្នុងផ្ទាំងបញ្ចូលពាក្យសម្ងាត់មេ។ ពាក្យសម្ងាត់នឹងត្រូវបានកំណត់ឡើងវិញ។

ចាប់ផ្តើមរហ័ស+

⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ចាប់ផ្តើមរហ័ស+**

ការកំណត់នេះធ្វើឱ្យឧបករណ៍របស់អ្នកស្ថិតក្នុងមុខងាររង់ចាំ នៅពេលវាត្រូវបានបិទ ដូច្នេះវានឹងជួយដល់ការប្រើប្រាស់មុខងាររបស់ឧបករណ៍បានកាន់តែរហ័ស នៅពេលអ្នកបើកឧបករណ៍វិញ។
កំណត់ **ចាប់ផ្តើមរហ័ស+** ទៅ **បើក**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។
- ការបើកជម្រើសនេះអាចបង្កើនការប្រើប្រាស់ថាមពល។

ការកំណត់ទំព័រដើម

⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ការកំណត់ទំព័រដើម**

បើកថាមពលអេក្រង់

អ្នកអាចជ្រើសរើសអេក្រង់ឱ្យបង្ហាញ នៅពេលបើកថាមពល។

ការផ្តល់ជូនពិសេសនៅទំព័រដើម

អ្នកអាចបើក ឬបិទការផ្សាយពាណិជ្ជកម្មបាននៅលើអេក្រង់ដើម។

ការណែនាំអំពីខ្លឹមសារ

អ្នកអាចទទួលការណែនាំអំពីខ្លឹមសារនៅលើអេក្រង់ដើម។

ផ្ទាំងរូបភាពអេក្រង់

ផ្ទាំងរូបភាពអេក្រង់ដើមដែលអ្នកបានជ្រើសរើសត្រូវបានបង្ហាញជារបៀបខ្មៅ។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការផ្សព្វផ្សាយធាតុរក្សាអេក្រង់

→ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ការផ្សព្វផ្សាយធាតុរក្សាអេក្រង់**

អ្នកអាចបើក ឬបិទការផ្សាយពាណិជ្ជកម្មដែលបង្ហាញនៅលើធាតុរក្សាអេក្រង់របស់កម្មវិធីជាក់លាក់។ ការកំណត់ទៅ**បិទ** អាចឱ្យអ្នកបិទការផ្សាយពាណិជ្ជកម្មដែលបង្ហាញនៅលើធាតុរក្សាអេក្រង់។

ដើម្បីកំណត់សញ្ញាបង្ហាញថាមពល

→ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ពន្លឺរង់ចាំ**

អ្នកអាចបិទ ឬបើកពន្លឺរង់ចាំ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

កំណត់សញ្ញាព្រួញរបស់ Magic Remote

→ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ជម្រើសទ្រនិច**

អ្នកអាចកំណត់ល្បឿន និងទំហំសញ្ញាព្រួញតាមការចង់បាន នៅពេលដែលវាស្ថិតនៅលើអេក្រង់។

ល្បឿនតាមដាន

កំណត់ល្បឿនទស្សន៍ទ្រនិច។

ទំហំទស្សន៍ទ្រនិច

ជ្រើសរើសទំហំទស្សន៍ទ្រនិច។

ការប្រើ Live Plus

Live Plus គឺជាសេវាកម្មដែលផ្តល់ព័ត៌មានផ្សេងៗអំពីកម្មវិធីដល់អ្នកទស្សនា។

សម្រាប់ព័ត៌មានបន្ថែម សូមមើល **ការទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីមុខងារឆ្លាតវៃ** → **Live Plus** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ដើម្បីប្រើជំនួយការកំណត់

ការកំណត់ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ជំនួយការកំណត់**

នៅពេលកំណត់ទៅ **បើក** អ្នកអាចទទួលបានជំនួយសម្រាប់ធាតុដែលបានជ្រើសរើស នៅពេលរុករកនៅក្នុងម៉ឺនុយការកំណត់។

កំណត់លេខសម្គាល់

ការកំណត់ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **កំណត់លេខសម្គាល់**

អ្នកអាចកំណត់លេខ (លេខសម្គាល់) ដើម្បីគ្រប់គ្រងឧបករណ៍ច្រើន។

- មុខងារនេះគឺសម្រាប់អ្នកគ្រប់គ្រង។
  វាមិនត្រូវបានណែនាំសម្រាប់ការប្រើប្រាស់នៅក្នុងមជ្ឈដ្ឋានក្នុងផ្ទះធម្មតាទេ។

ស្តារទៅការកំណត់លំនាំដើមឡើងវិញ

ការកំណត់ → **ទូទៅ** → **ប្រព័ន្ធ** → **កំណត់ឡើងវិញទៅជាការកំណត់ដំបូង**

ត្រឡប់ឧបករណ៍ទៅការកំណត់ដំបូងរបស់វាវិញ។ បន្ទាប់ពីកំណត់ឡើងវិញ ឧបករណ៍នឹងបិទ និងបើកដោយស្វ័យប្រវត្តិ។

កំណត់ឡើងវិញទាំងអស់

សកម្មភាពនេះនឹងត្រឡប់ការកំណត់ទាំងអស់ទៅតម្លៃដើមរបស់ពួកវាវិញ។

កំណត់ឡើងវិញទាំងអស់ លើកលែងតែការកំណត់បណ្តាញ។

ធាតុទាំងអស់លើកលែងតែការកំណត់បណ្តាញប៉ុណ្ណោះ
ដែលត្រូវបានប្តូរទៅការកំណត់លំនាំដើមរបស់វា។

- ប្រសិនបើ **សុវត្ថិភាព** ត្រូវបានកំណត់ទៅ **បើក**, អ្នកគួរតែបញ្ចូលពាក្យសម្ងាត់ដើម្បី **កំណត់ឡើងវិញទៅជាការកំណត់ដំបូង**។
- កុំបិទពេលចាប់ផ្តើម។
- យើងសូមណែនាំឱ្យអ្នកកំណត់ឧបករណ៍ឡើងវិញទៅ **កំណត់ឡើងវិញទៅជាការកំណត់ដំបូង** មុនពេលអ្នកលក់វា ឬផ្ទេរវាទៅភាគីទីបី។

ការសន្សំសំចៃថាមពល

ដើម្បីប្រើមុខងារ ការសន្សំសំចៃថាមពល

→ → **ទូទៅ** → **ការសន្សំសំចៃថាមពល**

កាត់បន្ថយការប្រើប្រាស់ថាមពល ដោយកែតម្រូវពន្លឺអេក្រង់កម្រិតខ្ពស់។

ជំហាននៃការសន្សំសំចៃថាមពល

ស្វ័យប្រវត្តិ : សេនស័ររបស់ផលិតផលចាប់ពន្លឺជុំវិញ
ហើយកែតម្រូវកម្រិតពន្លឺអេក្រង់ដោយស្វ័យប្រវត្តិ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ពន្លឺអប្បបរមា : អ្នកអាចកំណត់កម្រិតងងឹតនៃអេក្រង់បាន នៅពេលកំណត់
ជំហាននៃការសន្សំសំចៃថាមពល ទៅ **ស្វ័យប្រវត្តិ**។
បិទ : បិទ **ជំហាននៃការសន្សំសំចៃថាមពល**។
អប្បបរមា / **មធ្យម** / **អតិបរមា** : ប្រើមុខងារសន្សំសំចៃថាមពល ដោយផ្អែកលើ
ជំហាននៃការសន្សំសំចៃថាមពល ដែលបានកំណត់នៅលើឧបករណ៍។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- ប្រសិនបើអ្នកប្រើមុខងារ **ជំហាននៃការសន្សំសំចៃថាមពល**
  កម្រិតពន្លឺនៃឧបករណ៍របស់អ្នកនឹងរងផលប៉ះពាល់។

បិទថាមពលដោយប្រវត្តិ

នៅពេលបើកឧបករណ៍ វានឹងបិទដោយស្វ័យប្រវត្តិ
ប្រសិនបើអ្នកមិនចុចប៊ូតុងណាមួយក្នុងរយៈពេលដែលបានកំណត់ទេ។

- អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

បិទអេក្រង់

អេក្រង់ត្រូវបានបិទ និងបន្លឺតែសំឡេងប៉ុណ្ណោះ។
ចុចប៊ូតុងណាមួយ លើកលែងតែប៊ូតុងថាមពល និងកម្រិតសំឡេង ដើម្បីបើកអេក្រង់វិញ។

- វាប្រហែលជាមិនអាចប្រើបានទេ ដោយផ្អែកលើមុខងារ ឬកម្មវិធីដែលដំណើរការ។

ជំនួយ

ការអាប់ដេតផ្នែកទន់

→ → **ជំនួយ** → **ការអាប់ដេតផ្នែកទន់**

ប្រើប្រាស់ការធ្វើបច្ចុប្បន្នភាពសូហ្វវែរដើម្បីពិនិត្យមើល និងទទួលបានកំណែចុងក្រោយបង្អស់។

អាប់ដេតដោយស្វ័យប្រវត្តិ

នៅពេលកំណត់វាទៅ **បើក** ការអាប់ដេតត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិ
ដោយគ្មានបែបបទនៃការបញ្ជាក់ដាច់ដោយឡែកឡើយ
លើកលែងតែការអាប់ដេតសំខាន់ៗមួយចំនួន។

រកមើលការអាប់ដេត

នៅពេលកំពុងពិនិត្យកំណែបច្ចុប្បន្នភាពចុងក្រោយបង្អស់
អ្នកអាចអនុវត្តបានតែការធ្វើបច្ចុប្បន្នភាព ប្រសិនបើឯកសារបច្ចុប្បន្នភាព
នៃកំណែចុងក្រោយអាចប្រើបាន។
ឧបករណ៍ពិនិត្យមើលកំណែកម្មវិធីរបស់អ្នកដោយស្វ័យប្រវត្តិ ប៉ុន្តែប្រសិនបើចាំបាច់
អ្នកអាចធ្វើការពិនិត្យមើលដោយផ្ទាល់។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។
- កំណែថ្មីចុងក្រោយបំផុតអាចប្រើបានតាមរយៈ សញ្ញាផ្សព្វផ្សាយឌីជីថល ឬភ្ជាប់អ៊ីនធឺណិត។
- ការប្តូរប៉ុស្តិ៍ពេលកំពុងទាញយកសូហ្វវែរដោយប្រើសញ្ញាផ្សព្វផ្សាយឌីជីថលធ្វើឲ្យរំខានដល់ដំណើរការទាញយក។ ការថយមកប៉ុស្តិ៍ដើមវិញធ្វើឲ្យការទាញយកបន្តវិញ។
- ប្រសិនបើសូហ្វវែរមិនត្រូវបានធ្វើបច្ចុប្បន្នភាពទេ នោះមុខងារមួយចំនួននឹងមិនដំណើរការឡើយ។
- នៅក្នុងប្រទេសខ្លះ **អាប់ដេតដោយស្វ័យប្រវត្តិ** មិនត្រូវបានបង្ហាញទេ ប្រសិនបើអ្នកមិនត្រូវបានតភ្ជាប់អ៊ីនធឺណិត។

ការស្វ័យវិភាគអេក្រង់

→ → **ជំនួយ** → **ការស្វ័យវិភាគអេក្រង់**

បន្ទាប់ពីធ្វើតេស្តដើម្បីផ្ទៀងផ្ទាត់ថា រលកសញ្ញារូបភាពត្រូវបានបញ្ចេញធម្មតារួច
អ្នកអាចជ្រើសរើសថាតើវាមានលក្ខណៈប្រក្រតីនៅលើអេក្រង់ឬអត់។
បើគ្មានបញ្ហានៅក្នុងការធ្វើតេស្តទេនោះ ពិនិត្យមើលឧបករណ៍ខាងក្រៅដែលបានតភ្ជាប់ ឬ
សញ្ញាផ្សាយ។

ការស្វ័យវិភាគសំឡេង

→ → **ជំនួយ** → **ការស្វ័យវិភាគសំឡេង**

ចាប់ផ្តើមដំណើរការធ្វើតេស្តសំឡេង ដើម្បីពិនិត្យឲ្យដឹងថា លទ្ធផលនៃសញ្ញាសំឡេងចេញមាន
លក្ខណៈធម្មតាឬក៏អត់ រួចហើយជ្រើសរើសលក្ខខណ្ឌដែលកើតមានកំហុស។
បើគ្មានបញ្ហានៅក្នុងការធ្វើតេស្តទេនោះ ពិនិត្យមើលឧបករណ៍ខាងក្រៅដែលបានតភ្ជាប់ ឬ
សញ្ញាផ្សាយ។

មុខងារបង្កើនប្រសិទ្ធភាពអង្គចងចាំ

→ → **ជំនួយ** → **មុខងារបង្កើនប្រសិទ្ធភាពអង្គចងចាំ**

អ្នកអាចបង្កើនប្រសិទ្ធភាពឧបករណ៍របស់អ្នកបានដោយសម្អាតកម្មវិធីដែលមិនប្រើ ឬអង្គចងចាំដែលមិនចាំបាច់។

ដើម/របៀបហាង

→ → **ជំនួយ** → **ដើម/របៀបហាង**

អ្នកអាចជ្រើសរើសរវាង **របៀបនៅផ្ទះ** និង **របៀបហាង**។
ដើម្បីប្រើឧបករណ៍នៅផ្ទះ សូមជ្រើសរើស **របៀបនៅផ្ទះ**។
ជ្រើសរើសតែ **របៀបហាង** ប៉ុណ្ណោះ នៅពេលដែលឧបករណ៍នឹងត្រូវបានបង្ហាញនៅក្នុងហាង។
របៀបហាង ផ្តល់ជូនការកំណត់ដែលស្របតាមបុគ្គលសម្រាប់ការបង្ហាញនៅក្នុងហាង។

ព័ត៌មានអំពីទូរទស្សន៍

→ → **ជំនួយ** → **ព័ត៌មានអំពីទូរទស្សន៍**

អ្នកអាចមើលព័ត៌មានដូចជា **ម៉ូដែល**, **លេខស៊េរី**, **ឈ្មោះឧបករណ៍** បាន។

ការកំណត់ការគ្រប់គ្រង IP

→ → **ជំនួយ** → **ការកំណត់ការគ្រប់គ្រង IP**

ប្រើឧបករណ៍គ្រប់គ្រង IP ដើម្បីគ្រប់គ្រងឧបករណ៍ដែលបានភ្ជាប់ទៅបណ្តាញ។

ឯកជនភាព និងលក្ខខណ្ឌ

→ → **ជំនួយ** → **ឯកជនភាព និងលក្ខខណ្ឌ**

កិច្ចព្រមព្រៀងអ្នកប្រើប្រាស់

ទាំងនេះគឺជាលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មដែលពាក់ព័ន្ធនឹងមុខងារឆ្លាតវៃ និងការការពារឯកជនភាព។

កំណត់សម្គាល់ផ្នែកច្បាប់

នេះជាការជូនដំណឹងផ្នែកច្បាប់សម្រាប់សេវាកម្មដែលផ្តល់តាមរយៈឧបករណ៍។

កំណត់សម្គាល់ផ្នែកទន់នៃប្រភពបើកចំហ

អ្នកអាចមើលការណែនាំសម្រាប់ធាតុនីមួយៗបាន។

ការផ្សាយពាណិជ្ជកម្ម

អ្នកអាចកំណត់ឡើងវិញនូវព័ត៌មានដែលបានប្រមូលសម្រាប់គោលបំណងក្នុងការផ្តល់ការផ្សាយពាណិជ្ជកម្មតាមបំណង
ឬបដិសេធចំពោះការប្រមូលព័ត៌មានដែលពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្ម។

ដាក់កម្រិតការតាមដានការផ្សាយពាណិជ្ជកម្ម

ប្រសិនបើកំណត់ទៅ **បើក** នោះការផ្សាយពាណិជ្ជកម្មដែលស្របនឹងបុគ្គល
ដែលផ្អែកលើចំណាប់អារម្មណ៍របស់អ្នកប្រើប្រាស់ប្រហែលជាមិនត្រូវបានផ្តល់ជូនឡើយ។

កំណត់ AD ID ឡើងវិញ

ព័ត៌មានអំពីចំណាប់អារម្មណ៍របស់អ្នកប្រើប្រាស់ត្រូវបានប្រមូលថ្មីៗ
ហើយការផ្សាយពាណិជ្ជកម្មត្រូវបានផ្តល់ជូនទៅតាមព័ត៌មាននោះ។

ការអនុញ្ញាតកម្មវិធី

កាមេរ៉ា

អ្នកអាចកំណត់ការអនុញ្ញាតឱ្យចូលប្រើកាមេរ៉ាសម្រាប់កម្មវិធីនីមួយៗ។

មីក្រូហ្វូន

អ្នកអាចកំណត់ការអនុញ្ញាតឱ្យចូលប្រើមីក្រូហ្វូនសម្រាប់កម្មវិធីនីមួយៗ។

ឧបករណ៍នៅជិត

សិទ្ធិចូលប្រើឧបករណ៍នៅជិតនឹងត្រូវប្តូរតាមបំណងសម្រាប់កម្មវិធីនីមួយៗ។

លុបព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំ

លុបព័ត៌មានអំពីការមើល

អ្នកអាចលុបព័ត៌មានអំពីការមើលដែលបានប្រមូលពីឧបករណ៍ទៅកាន់ម៉ាស៊ីនមេបាន។
ការលុបព័ត៌មាននេះអាចនឹងប៉ះពាល់ដល់សេវាកម្មណែនាំដែលបានផ្តល់ជូន
ដោយផ្អែកលើប្រវត្តិនៃការប្រើប្រាស់ឧបករណ៍ ឬការមើលរបស់អ្នក។

លុបព័ត៌មានអំពីសំឡេង

អ្នកអាចលុបព័ត៌មានអំពីសំឡេងដែលបានប្រមូលពីឧបករណ៍ទៅកាន់ម៉ាស៊ីនមេបាន។
ការលុបព័ត៌មាននេះអាចនឹងប៉ះពាល់ដល់សេវាកម្មណែនាំដែលបានផ្តល់ជូន
ដោយផ្អែកលើប្រវត្តិសំឡេងរបស់អ្នក។

- ការលុបព័ត៌មាននេះតម្រូវឱ្យមានការតភ្ជាប់បណ្តាញ និងការយល់ព្រមតាមលក្ខខណ្ឌ។

លុបលេខសម្គាល់សំឡេង

លុបព័ត៌មានអំពីលេខសម្គាល់សំឡេងដែលបានប្រមូលពីឧបករណ៍។

- ធាតុដែលអាចកំណត់រចនាសម្ព័ន្ធបានខុសគ្នាទៅតាមម៉ូដែល។

ការដោះស្រាយបញ្ហា

ធ្វើការត្រួតពិនិត្យដោយប្រើ Quick Help

ធ្វើការត្រួតពិនិត្យដោយប្រើ Quick Help

នៅពេលដែលឧបករណ៍ដំណើរការមិនប្រក្រតីទេ
អ្នកអាចទទួលបានជំនួយដើម្បីដោះស្រាយបញ្ហានេះបាន។
ចុចប៊ូតុង ⚙ នៅលើតេឡេបញ្ជា រួចជ្រើសរើស ⚙ → **ជំនួយ** → **Quick Help**។
អ្នកក៏អាចចុចប៊ូតុងលេខ **9** របស់តេឡេបញ្ជាឱ្យជាប់ ដើម្បីដំណើរការ **Quick Help** ផងដែរ។

ការកំណត់ការបង្កើនប្រសិទ្ធភាព

អ្នកអាចពិនិត្យមើលស្ថានភាពទូទៅរបស់ឧបករណ៍អ្នក និងមើលឃើញ
ព្រមទាំងប្តូរតម្លៃការកំណត់ដែលបានណែនាំដោយស្វ័យប្រវត្តិ។

បណ្ណាល័យជំនួយ

ជ្រើសរើសធាតុដែលត្រូវនឹងបញ្ហា
ដើម្បីអាចរកឃើញការណែនាំដែលអាចជួយឱ្យអ្នកដោះស្រាយបញ្ហានោះបាន។

ការថែទាំ និងការស្វ័យវិភាគ

អ្នកអាចពិនិត្យមើលស្ថានភាពបច្ចុប្បន្នរបស់ឧបករណ៍អ្នក
ដើម្បីមើលធាតុដែលបានជ្រើសរើស។

សេវាកម្មតេឡេបញ្ជា LG

អ្នកទទួលបានជំនួយក្នុងការដោះស្រាយបញ្ហា តាមរយៈតេឡេបញ្ជា។
សម្រាប់ **សេវាកម្មតេឡេបញ្ជា LG**
សូមទាក់ទងមជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់ក្រុមហ៊ុនផលិត។

- មុខងារនេះប្រហែលជាមិនអាចប្រើនៅក្នុងម៉ូដែល ឬប្រទេសមួយចំនួនបានទេ។

- នៅពេលដែលគ្មានមាតិកាដែលពាក់ព័ន្ធនៅក្នុង **Quick Help** សូមពិនិត្យមើល **ការដោះស្រាយបញ្ហា** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។
- ប្រសិនបើបញ្ហានៅតែបន្តកើតមាន
  សូមទាក់ទងមជ្ឈមណ្ឌលសេវាកម្មអតិថិជនរបស់ក្រុមហ៊ុនផលិត។

ការដោះស្រាយបញ្ហាតេឡេបញ្ជា/ថាមពល

ការដោះស្រាយបញ្ហាតេឡេបញ្ជា/ថាមពល

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល
សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

ខ្ញុំមិនអាចបើកឧបករណ៍បានទេ។

- ពិនិត្យមើលថាថាមពល ពន្លឺរង់ចាំ នៅលើឧបករណ៍មានពណ៌ក្រហម។ ប្រសិនបើ ពន្លឺរង់ចាំ
  ត្រូវបានបិទ សូមពិនិត្យមើលការតភ្ជាប់ដុំដោតថាមពលឧបករណ៍
  ដូចដែលបង្ហាញខាងក្រោម។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ព្រឹភ្លើងច្រើន ពិនិត្យ ថាតើវាកំពុងដំណើរការត្រឹមត្រូវទេ។
  ដើម្បីពិនិត្យមើលថាតើគំនូសថាមពលកំពុងដំណើរការត្រឹមត្រូវឬអត់
  សូមដោតឧបករណ៍ដោយផ្ទាល់ទៅនឹងរន្ធព្រីនៅជញ្ជាំង
  ហើយសង្កេតមើលប្រតិបត្តិការរបស់អ្នក។
- សាកល្បងបើកថាមពលដោយប្រើប៊ូតុងនៅលើឧបករណ៍របស់អ្នក។

ថាមពលត្រូវបានបើក ប៉ុន្តែអេក្រង់បង្ហាញនៅពេលក្រោយ។

- នេះគឺដោយសារមានដំណើរការលុបសំឡេងចេញ ដើម្បីបំបាត់សំឡេង
  មួយចំនួនចោលដែលអាចកើតមាននៅពេលបើក។
  នេះមិនមែនមានន័យថាផលិតផលខូចទេ។

សញ្ញាព្រួញរបស់ Magic Remote មិនបង្ហាញនៅលើអេក្រង់ទេ។

- តម្រង់តេឡេបញ្ជាឱ្យចំឧបករណ៍ រួចចុចប៊ូតុង ⌂ និង ⚙ ដំណាលគ្នាឱ្យបានលើសពី 5 វិនាទី
  រហូតដល់បង្ហាញការណែនាំ។ តេឡេដែលបានចុះឈ្មោះពីមុនត្រូវបានលុបចោល
  ហើយចុះឈ្មោះម្តងទៀត។
- ប្តូរថ្ម នៅពេលដែលមានសារបង្ហាញឱ្យអ្នកធ្វើបែបនោះនៅលើអេក្រង់របស់អ្នក។ (ប្រើប្រាស់ថ្ម
  អាល់កាឡាំង។)
- ប្រសិនបើ ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ការណែនាំជាសំឡេង** ត្រូវបានកំណត់ទៅ

បើក សញ្ញាព្រួញរបស់ Magic Remote នឹងមិនបង្ហាញទេ។ កំណត់ **ការណែនាំជាសំឡេង** ទៅជា **បិទ**។ (អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)

ខ្ញុំមិនអាចបើកឧបករណ៍ដោយប្រើតេឡេបញ្ជាបានទេ។

- សូមប្រាកដថា ដុំដោតថាមពលរបស់ឧបករណ៍ត្រូវបានដោតចូលព្រីភ្លើង។
- ប្តូរថ្មនៅក្នុងតេឡេ។ (ប្រើប្រាស់ថ្មអាល់កាឡាំង។)
- ប្រសិនបើអ្នកដាក់ឧបសគ្គ ដូចជារបារសំឡេង
  នៅពីមុខឧបករណ៍ទទួលបញ្ជាពីចម្ងាយរបស់ឧបករណ៍
  វាអាចរំខានដល់ការទទួលសញ្ញាបញ្ជាពីចម្ងាយ។ ដំឡើងវានៅចម្ងាយយ៉ាងតិច 10 cm
  ពីឧបករណ៍ទទួលរបស់តេឡេបញ្ជាឧបករណ៍។
- នៅពេលប្រើតេឡេបញ្ជារបស់ប្រអប់ចាប់ប៉ុស្តិ៍
  ប្រសិនបើមុខងារបញ្ជាឧបករណ៍ដែលបានរួមបញ្ចូលនៃតេឡេបញ្ជារបស់ប្រអប់ចាប់ប៉ុស្តិ៍ត្រូវបានបិទ អ្នកមិនអាចបើក ឬបិទឧបករណ៍ដែលមានតេឡេបញ្ជារបស់ប្រអប់ចាប់ប៉ុស្តិ៍បានទេ។
  សូមទាក់ទងក្រុមហ៊ុនផ្តល់ប្រអប់ចាប់ប៉ុស្តិ៍របស់អ្នក។

ថាមពលដាច់ភ្លាមៗ។

- ពិនិត្យមើលថាតើការកំណត់ខាងក្រោមត្រូវបានបើកឬអត់។
  ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ម៉ោង និងកម្មវិធីកំណត់ម៉ោង** → **កម្មវិធីកំណត់ម៉ោង** → **បិទកម្មវិធីកំណត់ម៉ោង**
- ឧបករណ៍នឹងត្រូវបានបិទដោយស្វ័យប្រវត្តិ ប្រសិនបើអ្នកមិនចុចប៊ូតុងណាមួយក្នុងរយៈពេល 4 ម៉ោង ទោះបីជាក្រោយពីបើកទូរទស្សន៍ នៅម៉ោងដែលបានកំណត់ដោយ **ការរំលឹក** ឬ **បើកកម្មវិធីកំណត់ម៉ោង** ក៏ដោយ។
- សៀគ្វីសម្រាប់ការពារខាងក្នុងក៏នឹងអាចត្រូវបានបើកដំណើរការផងដែរ
  ដោយសារតែសីតុណ្ហភាពខាងក្នុងរបស់ផលិតផលបានកើនឡើងខុសពីធម្មតា ឬលើសកម្រិត។
- ប្រសិនបើអ្នកកំពុងប្រើប្រអប់ចាប់ប៉ុស្តិ៍ នោះឧបករណ៍អាចនឹងត្រូវបានកំណត់ទៅបិត
  នៅពេលប្រអប់ចាប់ប៉ុស្តិ៍នោះត្រូវបានបិទ។ ដើម្បីទប់ស្កាត់ឧបករណ៍មិនឱ្យបិត
  នៅពេលអ្នកបិទប្រអប់ចាប់ប៉ុស្តិ៍
  សូមបិទមុខងារធ្វើសមកាលកម្មថាមពលឧបករណ៍នៅលើប្រអប់ចាប់ប៉ុស្តិ៍។

រាល់ពេលដែលខ្ញុំបើកឧបករណ៍ អេក្រង់ដើមនឹងបង្ហាញ។

- អេក្រង់ដើមត្រូវបានបង្ហាញដោយស្វ័យប្រវត្តិ នៅពេលណាដែលអ្នកបើកឧបករណ៍។
  ដើម្បីបិទលក្ខណៈពិសេសនេះ សូមចូលទៅកាន់ ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ការកំណត់ទំព័រដើម** រួចកំណត់ **បើកថាមពលអេក្រង់** ទៅ **ការបញ្ចូលថ្មីៗ**។

ខ្ញុំមិនអាចបើក ឬដំណើរការឧបករណ៍ដែលមានតេឡេបញ្ជារបស់ឧបករណ៍បានទេ ទោះបីជាបន្ទាប់ពីកំណត់តេឡេបញ្ជាសកលហើយក៏ដោយ។

- សូមប្រាកដថា ដុំដោតថាមពលរបស់ឧបករណ៍ត្រូវបានដោតចូលព្រីភ្លើង។
- ប្តូរថ្នៅក្នុងតេឡេ។ (ប្រើប្រាស់ថ្មអាល់កាឡាំង។)
- ពិនិត្យមើលថាតើមានឧបសគ្គរារាំងរលកសញ្ញានៅពីមុខឧបករណ៍ទទួលសញ្ញាពីតេឡេបញ្ជារបស់ឧបករណ៍ឬអត់។

ការដោះស្រាយបញ្ហាអេក្រង់

ការដោះស្រាយបញ្ហាអេក្រង់

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល
សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

ជាដំបូង សូមដំណើរការ → → **ជំនួយ** → **ការស្វ័យវិភាគអេក្រង់**
ដើម្បីពិនិត្យមើលភាពមិនប្រក្រតីណាមួយនៅក្នុងឧបករណ៍។
ប្រសិនបើអ្នកកំពុងប្រើset-top box, បិទវា ហើយបន្ទាប់មកបើកវាវិញ។
ត្រូវប្រាកដថាប្រអប់ចាប់ប៉ុស្តិ៍ត្រូវបានភ្ជាប់ជាមួយឧបករណ៍របស់អ្នក។

វានិយាយថាមិនមានរលកសញ្ញានៅលើអេក្រង់ទេ។

- ត្រូវប្រាកដថាខ្សែពីអង់តែន
ឬឧបករណ៍ខាងក្រៅត្រូវបានភ្ជាប់យ៉ាងត្រឹមត្រូវជាមួយឧបករណ៍នេះ។
- ចូលទៅ ដើម្បីជ្រើសរើសការចូលដែលបានតភ្ជាប់។
- ពិនិត្យថាតើឧបករណ៍ខាងក្រៅ ដូចជាឧបករណ៍ចាប់រលកសញ្ញា ឬឧបករណ៍ចាក់ Blu-ray
បើកឬនៅ។

ខ្ញុំមិនអាចមើលប៉ុស្តិ៍មួយចំនួនបានទេ។

- បើកដំណើរការ → → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) →
ការរាវប៉ុស្តិ៍ដោយស្វ័យប្រវត្តិ។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

អេក្រង់ត្រូវបានកាត់ផ្តាច់។

- ចូលទៅកាន់ → → **រូបភាព** រួចប្តូរ **អត្រាទ្រង់ទ្រាយ**។
- នៅពេលមើលវីដេអូតាមរយៈឧបករណ៍ខាងក្រៅ (ប្រអប់ចាប់ប៉ុស្តិ៍ ហ្គេម កុងសូល ។ល។)
ឬកម្មវិធីខ្លីមសារ
សូមពិនិត្យមើលការកំណត់ទំហំអេក្រង់នៅក្នុងម៉ឺនុយការកំណត់របស់ឧបករណ៍/កម្មវិធី។

អាចមានភាពខុសគ្នានៅក្នុងសមាមាត្រអេក្រង់ដែលផ្តល់ដោយឧបករណ៍/កម្មវិធីនីមួយៗ។

អេក្រង់ញ័រឬបន្ទាប់ពីបន្ទាត់ផ្តេក/បញ្ឈរបង្ហាញមួយស្របក់ និងមានក្រឡា។

- ការរំខានអាចកើតឡើងពីរលកវិទ្យុខ្លាំង ដូចជារលកវិទ្យុពីឧបករណ៍អគ្គិសនីផ្សេងទៀត ដូច្នេះចូរប្រើឧបករណ៍ ដូចជាម៉ាស៊ីនសម្លុតសក់ ឬម៉ាស៊ីនស្វានអគ្គិសនីនៅក្នុងហាងផ្សេងៗគ្នា។

ប៉ុស្តិ៍នីមួយៗមានគុណភាពរូបភាពខុសៗគ្នា។

- ប៉ុស្តិ៍អាចមានគុណភាពរូបភាពខុសគ្នា ដោយអាស្រ័យលើប្រភេទវីដេអូដែលផ្តល់ជូនដោយក្រុមហ៊ុនផ្សាយ។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។
- ដំណើរការ **ការស្វ័យវិភាគអេក្រង់** ជាមុនសិន។ ប្រសិនបើវាដំណើរការធម្មតា មានន័យថាអាចមានបញ្ហាទាក់ទងនឹងរលកសញ្ញាផ្សាយ។

គុណភាពរូបភាពពីវីដេអូដែលមើលឃើញនៅហាងគឺមានភាពខុសគ្នា។

- គុណភាពរូបភាពពីវីដេអូដែលបញ្ចាំងនៅហាងអាចមានភាពខុសគ្នា ដោយអាស្រ័យលើប្រភេទវីដេអូដែលផ្តល់ជូនដោយក្រុមហ៊ុនផ្សាយ។
- ដំណើរការ **ការស្វ័យវិភាគអេក្រង់** ជាមុនសិន។ ប្រសិនបើវាដំណើរការធម្មតា មានន័យថាអាចមានបញ្ហាទាក់ទងនឹងរលកសញ្ញាផ្សាយ។

កម្មវិធីបានផ្សាយជាលក្ខណៈឌីជីថលបញ្ឈប់ ឬអេក្រង់របស់វាខូច។

- វាកើតឡើងនៅពេលសញ្ញាខ្សោយ ឬការទទួលមិនស្ថិតស្ថេរ។ កែតម្រូវទិសអង់តែន ឬពិនិត្យមើលការតភ្ជាប់ខ្សែ។
- ⚙ → ⚙ → **ទូទៅ** → **ប៉ុស្តិ៍** → **ការរាវប៉ុស្តិ៍** (**ការរាវប៉ុស្តិ៍ និងការកំណត់**) → **ការរាវប៉ុស្តិ៍ដោយផ្ទាល់** ប្រសិនបើកម្លាំងសញ្ញាខ្សោយពេកក្នុង **ការរាវប៉ុស្តិ៍ដោយផ្ទាល់**, ទាក់ទងស្ថានីយផ្សាយឬការិយាល័យគ្រប់គ្រងឲ្យពិនិត្យមើលសញ្ញា។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

នៅពេលរន្ធ HDMI កំពុងត្រូវបានប្រើប្រាស់ បន្ទាត់បញ្ឈរ ឬពណ៌ព្រាលនឹងបង្ហាញនៅលើគែមខាងលើ/ខាងក្រោម/ខាងឆ្វេង/ខាងស្តាំនៃអេក្រង់។

- ⚙ → ⚙ → **រូបភាព** → **អត្រាទ្រង់ទ្រាយ** → **ទើបស្កេន** កំណត់ **ទើបស្កេន** ទៅ **បិទ**។ **ទើបស្កេន** បង្ហាញអ្នកនូវរូបភាពដើមដូចទ្រង់ទ្រាយរបស់អ្នក។ ប្រសិនបើសេវាខ្សោយ ផ្នែកខាងលើ/ខាងក្រោម/ខាងឆ្វេង/ខាងស្តាំនៃអេក្រង់អាចនឹងបង្ហាញដង្កូវទឹក។

ខ្ញុំមិនឃើញអ្វីទេ ឬរូបភាពនៅតែលោតភ្លឺបន្តែតៗនៅពេលខ្ញុំព្យាយាមតភ្ជាប់ខ្សែ HDMI ។

- ពិនិត្យមើលថាតើខ្សែ HDMI® របស់អ្នកត្រូវតាមលក្ខណៈនេះ។ អ្នកអាចឃើញវាលោតភ្លឺបន្តែតៗ ឬអេក្រង់ទទេប្រសិនបើខ្សែ HDMI® មានបញ្ហា (រមួល, ខូច)។
- សូមប្រាកដថាខ្សែត្រូវបានតភ្ជាប់ជាមួយរន្ធបានត្រឹមត្រូវ។ ការភ្ជាប់មិនល្អ ឬរលុងអាចបណ្តាលឲ្យមានបញ្ហាក្នុងការបង្ហាញលើអេក្រង់។
- ប្រសិនបើកំពុងប្រើប្រាស់ UHD set-top box តែតម្រូវ ⚙ → ⚙ → **ទូទៅ** → **ឧបករណ៍ខាងក្រៅ** → **ការកំណត់ HDMI** → **HDMI Deep Color**។

អេក្រង់មើលទៅស្រអាប់ ឬព្រិលៗ។

- ⚙ → ⚙ → **រូបភាព** → **របៀបជ្រើសរើស**
  ប្តូរ **របៀបជ្រើសរើស** ទៅតាមទម្រង់រូបភាពដែលអ្នកចង់បាន។ (**ស្តង់ដារ**, **ពណ៌ឌិត**។ល។)
  វាអនុវត្តចំពោះតែទម្រង់ចូលបច្ចុប្បន្នប៉ុណ្ណោះ។
- ⚙ → ⚙ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កម្រិតពន្លឺ** → **ការថែរក្សាចលនាភ្នែក**
  ប្តូរ **ការថែរក្សាចលនាភ្នែក** ទៅ **បិទ**។ វាអនុវត្តចំពោះតែទម្រង់ចូលបច្ចុប្បន្នប៉ុណ្ណោះ។
- ⚙ → ⚙ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កាត់បន្ថយពន្លឺពណ៌ខៀវ**
  ប្តូរ **កាត់បន្ថយពន្លឺពណ៌ខៀវ** ទៅ **បិទ**។
- ⚙ → ⚙ → **ទូទៅ** → **ការសន្សំសំចៃថាមពល**
  ប្តូរ **ជំហាននៃការសន្សំសំចៃថាមពល** ទៅ **បិទ** ឬ **អប្បបរមា**។

អេក្រង់ហ្គេមងងឹតពេក។

- ប្រសិនបើអ្នកភ្ជាប់ឧបករណ៍ខាងក្រៅដើម្បីដំណើរការហ្គេម HDR
  នោះពន្លឺអេក្រង់ត្រូវបានបង្កើនប្រសិទ្ធភាពទៅតាមការកំណត់ដែលចង់បាន
  ខណៈពេលបង្កើតហ្គេម។
  ប្រសិនបើអ្នកចង់ប្តូរពន្លឺអេក្រង់ដែលបានបង្កើនប្រសិទ្ធភាព សូមប្តូរការកំណត់ខាងក្រោម។
  ⚙ → ⚙ → **រូបភាព** → **ការកំណត់កម្រិតខ្ពស់** → **កម្រិតពន្លឺ** → **ការធ្វើឲ្យចេញជាពណ៌តែមួយ**
  ប្តូរ **ការធ្វើឲ្យចេញជាពណ៌តែមួយ** ទៅ **បិទ**។

ពន្លឺអេក្រង់ប្រែប្រួលជានិច្ច។

- ⚙ → ⚙ → **ទូទៅ** → **ការសន្សំសំចៃថាមពល**
  ប្តូរ **ជំហាននៃការសន្សំសំចៃថាមពល** ទៅ **បិទ** ឬ **អប្បបរមា**។

អេក្រង់ក្លាយជាពណ៌ស ខ្មៅ ឬបង្ហាញពណ៌ចម្លែក។

- ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **មាត្រដ្ឋានប្រផេះ**
  ប្តូរ **មាត្រដ្ឋានប្រផេះ** ទៅ **បិទ**។
- ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **បញ្ហាសពណ៌**

ប្តូរ **បញ្ជ្រាសពណ៌** ទៅ **បិទ**។

វីដេអូ ULTRA HD មិនបង្ហាញទេ។

- តាមរយៈការប្រើប្រាស់ខ្សែ HDMI មួយចំនួន រលកសញ្ញាអាចនឹងមិនទទួលបានទេ។
- ប្តូរការកំណត់នៃឧបករណ៍ផ្ទុកទៅរលកសញ្ញាដែលស្គាល់។

ការដោះស្រាយបញ្ហាសំឡេង

ការដោះស្រាយបញ្ហាសំឡេង

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល
សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

ជាដំបូង សូមដំណើរការ ⚙ → ⚙ → **ជំនួយ** → **ការស្វ័យវិភាគសំឡេង**
ដើម្បីពិនិត្យមើលភាពមិនប្រក្រតីណាមួយនៅក្នុងឧបករណ៍។
ប្រសិនបើអ្នកកំពុងប្រើset-top box, បិទវា ហើយបន្ទាប់មកបើកវាវិញ។
ត្រូវប្រាកដថាប្រអប់ចាប់ប៉ុស្តិ៍ត្រូវបានភ្ជាប់ជាមួយឧបករណ៍របស់អ្នក។

អេក្រង់គ្មានបញ្ហាទេ ប៉ុន្តែវាមិនឮសំឡេង។

- សាកល្បងប៉ុស្តិ៍ផ្សេង។
- កែតម្រូវកម្រិតសំឡេងដោយប្រើតេឡេបញ្ជាសម្រាប់ឧបករណ៍។
- នៅពេលប្រើប្រអប់ចាប់ប៉ុស្តិ៍ សំឡេងនឹងមិនត្រូវបានផលិតទេ
  ប្រសិនបើកម្រិតសំឡេងនៃប្រអប់ចាប់ប៉ុស្តិ៍ត្រូវបានកំណត់ទៅ 0 ឬបិទសំឡេង។
  កំណត់កម្រិតសំឡេងទៅតាមចំណូលចិត្តរបស់អ្នកដោយប្រើប៊ូតុងកម្រិតសំឡេងនៅលើតេឡេប
  ញ្ជារបស់ប្រអប់ចាប់ប៉ុស្តិ៍។
- ⚙ → ⚙ → **សំឡេង** → **សំឡេងចេញ**
  កំណត់ **សំឡេងចេញ** ទៅ **ឧបករណ៍អុបទិកចេញ + ឧបករណ៍បំពងសំឡេងទូរទស្សន៍** ឬឬ
  ប្រើឧបករណ៍បំពងសំឡេងទូរទស្សន៍ បន្ទាប់មកពិនិត្យមើលវាម្តងទៀត។
  ប្រសិនបើអ្នកអាចស្តាប់ឮសំឡេងដោយគ្មានបញ្ហាទេ
  សូមពិនិត្យមើលការតភ្ជាប់ឧបករណ៍បំពងសំឡេងខាងក្រៅ ដូចជារបារសំឡេង
  និងការកំណត់ឧបករណ៍បំពងសំឡេងខាងក្រៅទាំងនោះ។

មិនមានសំឡេងចេញពីអូប៉ាល់ទេ។

- ⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **លំនឹង**

តែតម្រូវសមតុល្យតាមការចាំបាច់ជាមួយប៊ូតុងរុករកនៅក្នុង **លំនឹង**។

សំឡេងមិនត្រូវបានធ្វើសមកាលកម្មជាមួយរូបភាព ឬពេលខ្លះបែកសំឡេង។

- ប្រសិនបើវាកើតឡើងតែលើប៉ុស្តិ៍មួយចំនួន វាប្រហែលជាបណ្តាលមកពីសញ្ញាបញ្ជូនរបស់ក្រុមហ៊ុនផ្សាយ។ សូមឲ្យក្រុមហ៊ុនផ្តល់សេវាកម្មផ្សាយរបស់អ្នក(ខ្សែកាប/ខ្សែ)ដោះស្រាយបញ្ហា។
- ប្រសិនបើប៉ុស្តិ៍ទាំងអស់មិនធ្វើសមកាលកម្មទេ ចូលទៅ ⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ផ្គូផ្គងអេក្រង់ជាមួយសំឡេង** និងកែសម្រួលការធ្វើសមកាលកម្ម។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

កម្រិតសំឡេងប្តូរនៅពេលខ្ញុំប្តូរប៉ុស្តិ៍។

- កម្រិតសំឡេងនៃលទ្ធផលបញ្ជូនពីស្ថានីយផ្សាយផ្សេងៗអាចខុសគ្នា។
- ⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ការកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ** កំណត់ **ការកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ** ទៅ **បើក**។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ set-top box សូមពិគ្រោះយោបល់ជាមួយអ្នកចែកចាយ។

កម្រិតសំឡេងប្រែប្រួលជានិច្ច។

- ⚙ → ⚙ → **សំឡេង** → **ការកំណត់កម្រិតខ្ពស់** → **ការកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ** កំណត់ **ការកែសម្រួលកម្រិតសំឡេងដោយស្វ័យប្រវត្តិ** ទៅ **បើក**។

សំឡេងមិនដំណើរការ ឬលេងតែតន្ត្រីក្នុងផ្នែខាងក្រោយក្នុងកម្មវិធីមួយចំនួន។

- កំណត់ចំណូលចិត្តភាសារបស់អ្នកនៅក្នុង ••• → **ភាសាជាសំឡេង**។

សំឡេងបន្លឺឡើងខ្លាំងពេក។

- ⚙ → ⚙ → **សំឡេង** → **របៀបជ្រើសរើស**
  កំណត់ **របៀបជ្រើសរើស** ទៅជា **សំឡេងច្បាស់/សំឡេងច្បាស់ Pro**។

សំឡេងត្រូវបានបញ្ចេញ នៅពេលម៉ឺនុយការកំណត់ ឬប៉ុស្តិ៍ដែលដំណើរការ កម្រិតសំឡេង។ ល។ ប្រើតែឡេបញ្ជា។

- ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ការណែនាំជាសំឡេង**
  ⚙ → ⚙ → **ទូទៅ** → **លទ្ធភាពប្រើប្រាស់** → **ការពិពណ៌នាជាសំឡេង**
  កំណត់ទៅជា **បិទ**។

  - មុខងារមួយចំនួនមិនអាចប្រើបានទេ អាស្រ័យទៅតាមម៉ូដែល។

ការដោះស្រាយបញ្ហានៃការតភ្ជាប់ឧបករណ៍

ការដោះស្រាយបញ្ហានៃការតភ្ជាប់ឧបករណ៍

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល
សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

Screen Share មិនដំណើរការទេ។

- សូមពិនិត្យមើលថាតើឧបករណ៍ឆ្លាតរបស់អ្នកអាចប្រើមុខងារ Screen Share បានឬអត់។
- ប្រសិនបើឧបករណ៍នេះមិនត្រូវបានរកឃើញនៅលើឧបករណ៍ឆ្លាតរបស់អ្នកទេ
  សូមបិទឧបករណ៍ទាំងអស់ ហើយបើកវិញម្តងទៀត។
- សូមប្រាកដថាអ្នកបានជ្រើសរើសឧបករណ៍ពីបញ្ជីឧបករណ៍ដែលមាននៅលើឧបករណ៍ឆ្លាតរបស់អ្នក។
- ឈ្មោះឧបករណ៍អាចប្តូរបាននៅក្នុង **ឈ្មោះឧបករណ៍** នៅលើ → → **ជំនួយ** → **ព័ត៌មានអំពីទូរទស្សន៍**។
- នៅពេលប្រើមុខងារ AirPlay សូមប្រាកដថាឧបករណ៍ត្រូវបានភ្ជាប់ Wi-Fi តែមួយ។
  សូមប្រាកដថា **មណ្ឌលទំព័រដើម** → **AirPlay** ត្រូវបានកំណត់ទៅ **បើក**។
  ម៉ូដែលមួយចំនួនមិនអាចប្រើ AirPlay បានទេ។

អេក្រង់នៅតែទទេបន្ទាប់ពីវាត្រូវបានតភ្ជាប់ជាមួយកុំព្យូទ័រ។

- ពិនិត្យមើលថាកុំព្យូទ័រត្រូវបានភ្ជាប់ជាមួយឧបករណ៍របស់អ្នកត្រឹមត្រូវឬអត់។
- បិទឧបករណ៍ រួចបើកវិញដោយប្រើតេឡេបញ្ជា។
- ចាប់ផ្តើមកុំព្យូទ័រឡើងវិញ នៅពេលឧបករណ៍បើក។
- ត្រូវប្រាកដថា កម្រិតច្បាស់នៃរូបភាពបង្ហាញដែលកំណត់នៅលើកុំព្យូទ័រ
  ត្រូវបានកំណត់ទៅគុណភាពបង្ហាញរបស់ HDMI-PC ដែលឧបករណ៍អាចប្រើបាន។
- ដើម្បីប្រើម៉ូនីទ័រពីរ ពិនិត្យមើលថាកុំព្យូទ័រ ឬកុំព្យូទ័រយួរដៃគាំទ្រទម្រង់ម៉ូនីទ័រពីរ។
- តភ្ជាប់ខ្សែ HDMI ល្បឿនលឿនឡើងវិញ។
- ប្រសិនបើអ្នកបានភ្ជាប់រន្ធចេញ RGB ជាមួយ HDMI នៃឧបករណ៍របស់អ្នក
  អ្នកត្រូវការឧបករណ៍ប្តូរពី RGB ទៅ HDMI។
  អ្នកនឹងមិនឃើញអ្វីទេលើអេក្រង់ បើអ្នកប្រើក្បាលតភ្ជាប់ HDMI ទៅ RGB ។

អេក្រង់បង្ហាញមិនពេញលេញ ឬម្ខាងធំម្ខាងតូច នៅពេលភ្ជាប់ទៅកុំព្យូទ័រ។

- កំណត់កម្រិតច្បាស់របស់កុំព្យូទ័រជាមួយឧបករណ៍ដែលឧបករណ៍នេះស្គាល់។
  សម្រាប់ព័ត៌មានបន្ថែម សូមមើល **ការទទួលបានព័ត៌មាន** → **គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-PC** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

- កំណត់ឈ្មោះរបស់ឧបករណ៍ HDMI ដែលបានតភ្ជាប់ជាមួយកុំព្យូទ័រ។
ដំណើរការ **មណ្ឌលទំព័រដើម** ដោយចុចប៊ូតុង នៅលើតេឡេបញ្ជា។ ជ្រើសរើស → **កែសម្រួលធាតុបញ្ចូល** នៅជ្រុងខាងលើផ្នែកខាងស្តាំ។ ប្តូរឈ្មោះបន្ទះ HDMI ដែលភ្ជាប់ជាមួយ **ធាតុបញ្ចូល** ទៅកុំព្យូទ័រ រួចជ្រើសរើស **រក្សាទុក**។

សំឡេងមិនឮ នៅពេលកុំព្យូទ័រត្រូវបានតភ្ជាប់ជាមួយខ្សែ HDMI ។

- នៅក្នុងការកំណត់កុំព្យូទ័រ សូមចូលទៅកាន់ផ្ទាំងគ្រប់គ្រង → សំឡេង → ការចាក់ ដើម្បីធានាបាននូវការជ្រើសរើសឧបករណ៍ត្រឹមត្រូវជាលំនាំដើម។
- សូមពិគ្រោះយោបល់ជាមួយអ្នកផលិតថាតើកាតក្រាហ្វិករបស់អ្នកគាំទ្រការចេញសំឡេង HDMI ដែរឬទេ។

ខ្ញុំមិនអាចកំណត់ហ្វ្រេកង់ផ្ទុកឡើងវិញទៅ 144 Hz សម្រាប់កុំព្យូទ័រដែលបានភ្ជាប់ជាមួយម៉ូដែលដែលស្គាល់ 144 Hz បានទេ។

- កំណត់ **មុខងារ 144Hz** នៅក្នុង → → **ទូទៅ** → **កម្មវិធីកែលម្អហ្គេម** ទៅ**បើក**។

អេក្រង់របស់ប្រអប់ចាប់ប៉ុស្តិ៍ដែលបានភ្ជាប់ជាមួយម៉ូដែលដែលស្គាល់ 144 Hz មិនបង្ហាញទេ។

- ឧបករណ៍មួយចំនួនអាចមានបញ្ហាភាពត្រូវគ្នាជាមួយ 144 Hz។ កំណត់ **មុខងារ 144Hz** នៅក្នុង → → **ទូទៅ** → **កម្មវិធីកែលម្អហ្គេម** ទៅ**បិទ**។

ការដោះស្រាយបញ្ហានៃការចាក់ភាពយន្ត

ការដោះស្រាយបញ្ហានៃការចាក់ភាពយន្ត

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។
ព័ត៌មានបន្ថែមអំពីឯកសារដែលស្គាល់គឺមាននៅ **ការទទួលបានព័ត៌មាន** → **ទម្រង់ឯកសារវីដេអូដែលស្គាល់** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ខ្ញុំមិនអាចរកឃើញឯកសារក្នុង **កម្មវិធីចាក់មេឌៀ**។

- ពិនិត្យមើលថាឯកសារក្នុងឧបករណ៍ផ្ទុកយូអេសប៊ីអាចអានបានលើកុំព្យូទ័រដែរឬទេ។
- ពិនិត្យមើលថាផ្នែកបន្ថែមឯកសារត្រូវបានគាំទ្រដែរឬទេ។

- ប្តូរតម្រងទៅ **ទាំងអស់**។

ខ្ញុំឃើញសារមួយដែលនិយាយថា មិនគាំទ្រឯកសារ។

- ពិនិត្យមើលថាឯកសារលេងដោយគ្មានបញ្ហាលើកម្មវិធីលេងវីដេអូក្នុងកុំព្យូទ័រដែរឬទេ។ (ពិនិត្យមើលឯកសារក្រែងលោវាខូច។)
- ពិនិត្យមើលថាផ្នែកបន្ថែមឯកសារត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាគុណភាពបង្ហាញត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាកូឌិកវីដេអូត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាវាស្គាល់អត្រាហ្វ្រេមដែរឬអត់។

ខ្ញុំទទួលបានសារមួយនិយាយថា “សំឡេងនេះមិនត្រូវបានគាំទ្រទេ” ឬវីដេអូកំពុងលេងធម្មតា ប៉ុន្តែមិនមានសំឡេង។

- ពិនិត្យមើលថាឯកសារលេងដោយគ្មានបញ្ហាលើកម្មវិធីលេងវីដេអូក្នុងកុំព្យូទ័រដែរឬទេ។ (ពិនិត្យមើលឯកសារក្រែងលោវាខូច។)
- ពិនិត្យមើលថាផ្នែកបន្ថែមឯកសារត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាកូឌិកសំឡេងត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាអត្រាប៊ីតត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាវាស្គាល់ប្រេកង់គំរូដែរឬអត់។
- ពិនិត្យមើលថាវាស្គាល់ចំនួនប៉ុស្តិ៍សំឡេងដែរឬអត់។

ខ្ញុំមិនអាចឃើញអក្សររត់។

- ពិនិត្យមើលថាឯកសារលេងដោយគ្មានបញ្ហាលើកម្មវិធីលេងវីដេអូក្នុងកុំព្យូទ័រដែរឬទេ។ (ពិនិត្យមើលឯកសារក្រែងលោវាខូច។)
- ពិនិត្យមើលថាឯកសារវីដេអូ និងអក្សររត់មានឈ្មោះដូចគ្នាដែរឬទេ។
- ពិនិត្យមើលផងដែរថាទាំងឯកសារវីដេអូ និងឯកសារអក្សររត់នៅក្នុងថតឯកសារតែមួយ។
- ពិនិត្យមើលថាឯកសារអក្សររត់ត្រូវបានគាំទ្រដែរឬទេ។
- ពិនិត្យមើលថាភាសាត្រូវបានគាំទ្រដែរឬទេ។
  (អ្នកអាចពិនិត្យមើលភាសារបស់ឯកសារអក្សររត់ ដោយបើកឯកសារក្នុងកម្មវិធី Notepad ។)
- ប្រសិនបើការអ៊ីនកូដអក្សររត់ត្រូវបានកំណត់ត្រឹមត្រូវ អក្សររត់អាចមិនត្រូវបានបង្ហាញត្រឹមត្រូវដែរ។
  ចុចប៊ូតុង ⌄ លើអេក្រង់ ខណៈពេលកំពុងប្រើការគ្រប់គ្រងការចាក់។ ជ្រើសរើស SUB និងប្តូរតម្លៃ **ទំព័រលេខកូដ**។
- ប្រសិនបើអ្នកលេងឯកសារវីដេអូបានរក្សាទុកក្នុងឧបករណ៍ផ្សេង ដោយប្រើមុខងារចែករំលែកមាតិកា អក្សររត់មិនអាចប្រើបាន អាស្រ័យលើកម្មវិធីដែលអ្នកប្រើ។
- ឧបករណ៍ NAS មួយចំនួនអាចនឹងមិនស្គាល់អក្សររត់ទេ នៅពេលចាក់វីដេអូ។

ឧបករណ៍ផ្ដុកយូអេសប៊ីរបស់ខ្ញុំមិនបានស្គាល់នៅពេលបានតភ្ជាប់។

- ពិនិត្យមើលថាឧបករណ៍ផ្ដុក USB អាចប្រើជាមួយឧបករណ៍នេះឬអត់។
  សម្រាប់ព័ត៌មានបន្ថែម សូមមើល **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការភ្ជាប់ឧបករណ៍ផ្ដុក USB** ក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់**។

ការដោះស្រាយបញ្ហានៃការថត

ការដោះស្រាយបញ្ហានៃការថត

សូមយោងតាម **វីការយនឹង Live Channel** → **ការថត** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានលម្អិតអំពីការថត។

តើខ្ញុំអាចចាប់ផ្ដើមថតដោយរបៀបណា?

- តភ្ជាប់ឧបករណ៍ផ្ដុកយូអេសប៊ីជាមួយទំហំផ្ដុកសរុបយ៉ាងហោចណាស់ 4 ជីកាបៃ។
  អាស្រ័យលើប្រតិបត្តិការនៃអង្គចងចាំ USB មុខងារថតប្រហែលជាមិនអាចប្រើបានទេ។
  ដើម្បីឱ្យការថតមានភាពរលូន យើងសូមណែនាំឱ្យប្រើហាតឌីស USB។ (សូមយោងតាម **ការភ្ជាប់ទៅឧបករណ៍ខាងក្រៅ** → **ការភ្ជាប់ឧបករណ៍ផ្ដុក USB** នៅក្នុង **ការណែនាំសម្រាប់អ្នកប្រើប្រាស់** សម្រាប់ព័ត៌មានលម្អិតអំពីឧបករណ៍ផ្ដុកយូអេសប៊ី។)
  ចុចប៊ូតុង ••• នៅលើតេឡេបញ្ជា រួចជ្រើសរើស **ថត**។ ប្រសិនបើតេឡេបញ្ជារបស់អ្នកគ្មានប៊ូតុង ••• ទេ សូមចុចប៊ូតុង លឿង ឱ្យជាប់។
  អ្នកក៏អាចចាប់ផ្ដើមថតដោយចុចប៊ូតុង ក្រហម នៅលើ ការគ្រប់គ្រងពីចម្ងាយ ឱ្យជាប់បានផងដែរ។
- ឧបករណ៍ផ្ដុក USB មួយចំនួនតម្រូវឱ្យមានការឈូសនៅលើឧបករណ៍នេះ។
  ការឈូសនឹងលុបទិន្នន័យដែលរក្សាទុកនៅលើឧបករណ៍ផ្ដុក USB ទាំងអស់
  ហើយឧបករណ៍នេះត្រូវបានឈូសដោយប្រើប្រព័ន្ធឯកសារ FAT32, exFAT ឬ NTFS។
  មុនពេលភ្ជាប់ឧបករណ៍ផ្ដុក USB ជាមួយឧបករណ៍នេះ
  សូមបម្រុងទុកទិន្នន័យដែលរក្សាទុកនៅលើឧបករណ៍នេះទៅក្នុងកុំព្យូទ័ររបស់អ្នក។

តើសញ្ញាណាមួយគាំទ្រដល់ការថត?

- អ្នកអាចថតបានតែនៅក្នុងមុខងារ **Live TV**
  ដែលត្រូវបានទទួលតាមរយៈរន្ធអង់តែននៅលើឧបករណ៍នេះប៉ុណ្ណោះ។
- មាតិកាដែលបានការពារមិនត្រូវបានថតទេ។

តើខ្ញុំអាចប្រើ **ការថតដែលបានកំណត់ពេល** បានទេ ទោះបីជាខ្ញុំបិទឧបករណ៍នេះក៏ដោយ?

- ទោះបីជានៅពេលដែលបិទឧបករណ៍ក៏ដោយ ក៏វានឹងចាប់ផ្តើម ហើយបញ្ចប់ការថតនៅពេលដែលបានកំណត់សម្រាប់ **ការថតដែលបានកំណត់ពេល** ដែរ។
- ប្រសិនបើបិទឧបករណ៍ទាំងស្រុងដូចខាងក្រោម មិនអាចប្រើ **ការថតដែលបានកំណត់ពេល** បានទេ។
  - នៅពេលមិនបានភ្ជាប់ឧបករណ៍នេះជាមួយព្រីភ្លើង
  - នៅពេលកុងតាក់នៃព្រីភ្លើងច្រើនដែលដុំដោតថាមពលរបស់ឧបករណ៍នេះបានភ្ជាប់ទៅត្រូវបានបិទ
  - នៅពេលកុងតាក់ផ្តាច់ថាមពលដែលផ្អាកដំណើរការត្រូវបានបើក ដើម្បីកុំឱ្យថាមពលផ្តត់ផ្តង់ទៅឧបករណ៍នេះ

ការដោះស្រាយបញ្ហានៃការតភ្ជាប់បណ្តាញ

ការដោះស្រាយបញ្ហានៃការតភ្ជាប់បណ្តាញ

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។
មុនពេលភ្ជាប់បណ្តាញឥតខ្សែ សូមពិនិត្យមើលឈ្មោះ និងពាក្យសម្ងាត់របស់ឧបករណ៍ Wi-Fi ដែលត្រូវភ្ជាប់។

អ្នកអាចពិនិត្យស្ថានភាពតភ្ជាប់បណ្តាញ ដូចបង្ហាញនៅខាងក្រោម។

- ⚙ → ⚙ → **ទូទៅ** → **បណ្តាញ** → **ការតភ្ជាប់ដោយប្រើខ្សែ (អ៊ីសឺណិត)**
- ⚙ → ⚙ → **ទូទៅ** → **បណ្តាញ** → **ការតភ្ជាប់ Wi-Fi** → **ការកំណត់បណ្តាញផ្សេងទៀត** → **ការកំណត់ Wi-Fi កម្រិតខ្ពស់**

- ម៉ូដែលមួយចំនួនអាចស្គាល់តែមុខងារ **ការតភ្ជាប់ Wi-Fi** ប៉ុណ្ណោះ។

ការតភ្ជាប់បណ្តាញឥតខ្សែមិនដំណើរការទេ។

- 1. ប្តូរ ⚙ → ⚙ → **ទូទៅ** → **ប្រព័ន្ធ** → **ការកំណត់បន្ថែម** → **ចាប់ផ្តើមរហ័ស+** ទៅ **បិទ**។
  2. បិទឧបករណ៍ រួចបើកវាវិញ បន្ទាប់មកភ្ជាប់ទៅបណ្តាញឥតខ្សែ។
- ប្រសិនបើវាមិនអាចភ្ជាប់ទៅរ៉ោទ័រទេ
  សូមសាកល្បងភ្ជាប់វាទៅហតស្ប៉តឧបករណ៍ចល័តនៅលើទូរសព្ទឆ្លាតរបស់អ្នក។
  ប្រសិនបើវាអាចត្រូវបានភ្ជាប់ទៅហតស្ប៉តឧបករណ៍ចល័ត
  ការណ៍នេះបង្ហាញថាវាគឺជាបញ្ហារ៉ោទ័រ។ ក្នុងករណីនេះ សូមពិនិត្យមើលរ៉ោទ័រ។
  ប្រសិនបើអ្នកប្រើបណ្តាញដែលមានឧបករណ៍បានភ្ជាប់ទៅហតស្ប៉តឧបករណ៍ចល័ត
  អ្នកអាចនឹងត្រូវបានគិតថ្លៃ ផ្អែកលើកិច្ចសន្យាជាមួយក្រុមហ៊ុនសេវាទូរសព្ទរបស់អ្នក។



នៅពេល X បង្ហាញនៅជិតឧបករណ៍

- សូមពិនិត្យមើលឧបករណ៍ ឬ AP (រ៉ោទ័រ)។
- ពិនិត្យមើលស្ថានភាពនៃការតភ្ជាប់របស់ឧបករណ៍ AP (រ៉ោតទ័រ) និងម៉ូឌឹមខ្សែកាប។
- បិទ និងបើកតាមលំដាប់ដូចខាងក្រោម
  1. បិទ រួចបើកម៉ូដឹមមានខ្សែរបស់អ្នកវិញ ហើយរង់ចាំឱ្យឧបករណ៍កំណត់ឡើងវិញ។
  2. បិទ រួចបើករ៉ោតទ័រមានខ្សែ/ឥតខ្សែវិញ ហើយរង់ចាំឱ្យឧបករណ៍កំណត់ឡើងវិញ។
  3. បើក និងបិទឧបករណ៍។
- ប្រសិនបើអ្នកចង់បង្កើតការតភ្ជាប់ LAN ដែលប្រើខ្សែ សូមពិនិត្យមើលថាតើអាសយដ្ឋាន IP អាចទាញយកពីរ៉ោតទ័ររបស់អ្នកបានត្រឹមត្រូវឬអត់។
  ប្រសិនបើអ្នកកំពុងរៀបចំបណ្តាញរបស់អ្នកដោយផ្ទាល់
  សូមពិនិត្យមើលថាតើការកំណត់ទាំងអស់ត្រឹមត្រូវឬអត់។
- ប្រសិនបើអ្នកចង់បង្កើតការតភ្ជាប់ឥតខ្សែ សូមពិនិត្យមើលចំណុចខាងក្រោមផងដែរ។
  ① កំណត់ SSID (ឈ្មោះបណ្តាញ) រ៉ោតទ័រឬប៉ុស្តិ៍ឥតខ្សែរបស់អ្នក។
  ② កំណត់សោសុវត្ថិភាពរ៉ោតទ័ររបស់អ្នក។
  ប្រសិនបើអ្នកមិនអាចបញ្ចប់ការកំណត់នេះបានទេ
  សូមមើលសៀវភៅណែនាំអំពីការប្រើប្រាស់រូតទ័រ
  និងការណែនាំដែលផ្តល់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
  ប្រសិនបើអ្នកនៅតែមិនអាចបង្កើតការកំណត់រចនាសម្ព័ន្ធរបស់អ្នកបានទេ
  សូមទាក់ទងក្រុមហ៊ុនផលិតរ៉ោតទ័ររបស់អ្នក ឬក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់ IP ថេរ សូមបញ្ចូល IP ដោយផ្ទាល់។



នៅពេលអក្សរ X លេចឡើងនៅក្បែរច្រកចេញចូល

- ពិនិត្យ AP (រ៉ោតទ័រ) ឬពិគ្រោះជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
- ដកម៉ូដឹមខ្សែ/រូតទ័រចេញពីព្រឺភ្លើងជាប់ជញ្ជាំង រង់ចាំរយៈពេល 10 វិនាទី រួចភ្ជាប់វាឡើងវិញ។
- ចាប់ផ្តើម (កំណត់ឡើងវិញ)នៅលើ AP (រ៉ោតទ័រ) ឬម៉ូដឹមប្រើខ្សែ។
- ពិនិត្យវេបសាយរបស់អ្នកផលិត AP (រ៉ោតទ័រ) ដើម្បីប្រាដកថា
  រ៉ោតទ័ររបស់អ្នកមានកំណែកម្មវិធីបង្កប់ចុងក្រោយបំផុត។
- ប្រសិនបើអ្នកមិនអាចបញ្ចប់ការកំណត់នេះបានទេ
  សូមមើលសៀវភៅណែនាំអំពីការប្រើប្រាស់រូតទ័រ
  និងការណែនាំដែលផ្តល់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
  ប្រសិនបើអ្នកនៅតែមិនអាចបង្កើតការកំណត់រចនាសម្ព័ន្ធរបស់អ្នកបានទេ
  សូមទាក់ទងក្រុមហ៊ុនផលិតរ៉ោតទ័ររបស់អ្នក ឬក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។



នៅពេលអក្សរ X លេចឡើងនៅក្បែរ DNS

- ពិនិត្យ AP (រ៉ោតទ័រ) ឬពិគ្រោះជាមួយអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
- ដកម៉ូដឹមខ្សែ/រូតទ័រចេញពីព្រឹត្តិភ្លើងជាប់ជញ្ជាំង រង់ចាំរយៈពេល 10 វិនាទី រួចភ្ជាប់វាឡើងវិញ។
- ចាប់ផ្តើម (កំណត់ឡើងវិញ)នៅលើ AP (រ៉ោតទ័រ) ឬម៉ូដឹមប្រើខ្សែ។
- ពិនិត្យមើលថាអាសយដ្ឋាន MAC របស់ឧបករណ៍/AP (រ៉ោទ័រ)
ត្រូវបានចុះឈ្មោះជាមួយក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតរបស់អ្នក។ (អាសយដ្ឋាន MAC
ដែលបានបង្ហាញនៅលើផ្ទាំងនៃស្ថានភាពបណ្តាញ
វិនដូគួរតែត្រូវបានចុះឈ្មោះជាមួយក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិតរបស់អ្នក។)
- ប្រសិនបើអ្នកមិនអាចបញ្ចប់ការកំណត់នេះបានទេ
សូមមើលសៀវភៅណែនាំអំពីការប្រើប្រាស់រូតទ័រ
និងការណែនាំដែលផ្តល់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។
ប្រសិនបើអ្នកនៅតែមិនអាចបង្កើតការកំណត់រចនាសម្ព័ន្ធរបស់អ្នកបានទេ
សូមទាក់ទងក្រុមហ៊ុនផលិតរ៉ោតទ័ររបស់អ្នក ឬក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតរបស់អ្នក។

ការដោះស្រាយបញ្ហាគណនី LG

ការដោះស្រាយបញ្ហាគណនី LG

ខ្ញុំបានចុះឈ្មោះជាសមាជិកភាពនៅលើឧបករណ៍រួចហើយ។ តើខ្ញុំត្រូវចុះឈ្មោះម្តងទៀតនៅលើគេហទំព័រ (www.lgappstv.com) ដែរទេ?

- អ្នកអាចប្រើគេហទំព័រ និងកម្មវិធី LG ThinQ
តាមរយៈព័ត៌មានសមាជិកដែលបានចុះឈ្មោះនៅលើឧបករណ៍បាន។

ខ្ញុំភ្លេចពាក្យសម្ងាត់របស់ខ្ញុំហើយ។ តើខ្ញុំគួរធ្វើដូចម្តេច?

- នៅលើអេក្រង់ចូលរបស់ឧបករណ៍ សូមជ្រើសរើសប៊ូតុង **ភ្លេចពាក្យសម្ងាត់ឬ?**
ដើម្បីចូលទៅកាន់ទំព័រស្វែងរកពាក្យសម្ងាត់។
សូមបញ្ចូលអាសយដ្ឋានអ៊ីមែលរបស់អ្នកនៅលើទំព័រស្វែងរកពាក្យសម្ងាត់
នោះយើងនឹងផ្ញើតំណមួយទៅអ្នក ដើម្បីកំណត់ពាក្យសម្ងាត់របស់អ្នកឡើងវិញ។
- អ្នកក៏អាចកំណត់ពាក្យសម្ងាត់របស់អ្នកនៅក្នុងគណនី LG បានផងដែរ →
កំណត់ពាក្យសម្ងាត់ឡើងវិញនៅលើគេហទំព័រ (www.lgappstv.com)។

ខ្ញុំចង់លុបគណនីដែលបានរក្សាទុកនៅលើឧបករណ៍។

- នៅពេលអ្នកចូលគណនី LG របស់អ្នកនៅលើឧបករណ៍
គណនីនោះនឹងត្រូវបានរក្សាទុកទៅក្នុងឧបករណ៍។
អ្នកអាចលុបគណនីដែលបានរក្សាទុកនៅលើឧបករណ៍បានគ្រប់ពេល ដូចខាងក្រោម។

01 សូមជ្រើសរើស ⌂ → **គណនី LG**។

02 ជ្រើសរើស ⋮ → **ព័ត៌មានបន្ថែមអំពីគណនី** នៅផ្នែកខាងលើនៃអេក្រង់។

03 ជ្រើសរើស ✎។

04 ការចុច **លុប** នឹងលុបគណនី។
ការធ្វើបែបនេះនឹងមិនលុបប្រវត្តិចូលគណនី ឬបិទគណនីទេ។

ខ្ញុំចង់លុបព័ត៌មានអំពីការមើលដែលបានប្រមូល ដោយផ្អែកលើគណនី LG ពីឧបករណ៍។

- អ្នកអាចលុបព័ត៌មានអំពីការមើលដែលបានរក្សាទុក ដោយផ្អែកលើគណនី LG ដែលបានចូលបានគ្រប់ពេល។

01 សូមជ្រើសរើស ⌂ → **គណនី LG**។

02 ជ្រើសរើស ⋮ → **ព័ត៌មានបន្ថែមអំពីគណនី** នៅផ្នែកខាងលើនៃអេក្រង់។

03 ជ្រើសរើស **ការគ្រប់គ្រងគណនី** សម្រាប់គណនីដែលអ្នកចង់រៀបចំ។

04 ជ្រើសរើស **លុបព័ត៌មានអំពីការមើល** រួចអនុវត្តតាមការណែនាំនៅលើអេក្រង់ ដើម្បីលុបព័ត៌មាននោះ។

ខ្ញុំចង់បិទគណនីរបស់ខ្ញុំនៅលើឧបករណ៍។

- អ្នកក៏អាចបិទគណនី LG របស់អ្នកនៅលើឧបករណ៍ដូចខាងក្រោមបានផងដែរ។

01 សូមជ្រើសរើស ⌂ → **គណនី LG**។

02 ជ្រើសរើស ⋮ → **ព័ត៌មានបន្ថែមអំពីគណនី** នៅផ្នែកខាងលើនៃអេក្រង់។

03 ជ្រើសរើស **ការគ្រប់គ្រងគណនី** សម្រាប់គណនីដែលអ្នកចង់រៀបចំ។

04 ជ្រើសរើស **បិទគណនីរបស់ខ្ញុំ**។

05 បញ្ចូលពាក្យសម្ងាត់របស់អ្នក រួចចុច **OK** ដើម្បីបិទគណនីរបស់អ្នក។

- ក្នុងប្រទេសមួយចំនួន លទ្ធភាពប្រើប្រាស់វេបសាយ (www.lgappstv.com) អាចត្រូវបានរឹតត្បិត។

ការដោះស្រាយបញ្ហាខ្លឹមសារ

ការដោះស្រាយបញ្ហាខ្លឹមសារ

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

អ្នកមិនអាចមើលមាតិកាមួយចំនួននៅក្នុងអេក្រង់ដើមបានទេ។

- អ្នកអាចមិនអាចមើលមាតិកាបានទេ ប្រសិនបើការកំណត់ប្រទេសដែលផ្តល់សេវាត្រូវបានផ្លាស់ប្តូរ។ ប្តូរទៅប្រទេសដែលអ្នកនឹងប្រើប្រាស់សេវាពី → → **ទូទៅ** → **ប្រព័ន្ធ** → **ទីតាំង** → **ប្រទេសផ្តល់សេវាកម្ម LG**។
(អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។)
- ប្រសិនបើអ្នកមិនឃើញកម្មវិធីមួយចំនួន វាអាចបណ្តាលមកពីអ្នកបានលុបពួកវា។ សូមដំឡើងកម្មវិធីដែលត្រឹមត្រូវម្តងទៀត។
- ប្រសិនបើកម្មវិធីត្រូវបានលុប អ្នកអាចទាញយកកម្មវិធីនៅ **Apps** រួចដំឡើងវាម្តងទៀតបាន។ សូមចូលទៅកាន់ → **Apps** ដើម្បីស្វែងរក និងដំឡើងកម្មវិធីដែលអ្នកចង់ប្រើ។
- ប្រភេទមាតិកាដែលគាំទ្រមានខុសគ្នាទៅតាមប្រទេស។
- មាតិកាដែលផ្តល់អាចត្រូវបានកែប្រែ ឬរំខានដោយអ្នកផ្តល់សេវា។

ការដោះស្រាយបញ្ហាកម្មវិធីរុករកនៅលើអ៊ីនធឺណិត

ការដោះស្រាយបញ្ហាកម្មវិធីរុករកនៅលើអ៊ីនធឺណិត

ប្រសិនបើអ្នកជួបបញ្ហាមួយចំនួនដូចខាងក្រោម នៅពេលកំពុងប្រើប្រាស់ផលិតផល សូមពិនិត្យដូចខាងក្រោម។ វាប្រហែលមិនមានបញ្ហាជាមួយផលិតផលទេ។

ផ្នែកមួយចំនួនរបស់វេបសាយជាក់លាក់មិនអាចមើលឃើញ នៅពេលខ្ញុំកំពុងប្រើអ៊ីនធឺណិត។

- **កម្មវិធីរុករកលើអ៊ីនធឺណិត** ស្គាល់តែមេឌៀដើរលើ HTML5 ប៉ុណ្ណោះ គឺវាស្គាល់តែកម្មវិធីដំនួយ Flash។
- **កម្មវិធីរុករកលើអ៊ីនធឺណិត** មិនជួយដល់ការបញ្ចូលកម្មវិធីដំនួយទេ។
- នៅលើ **កម្មវិធីរុករកលើអ៊ីនធឺណិត** វាមិនអាចចាក់ឯកសារមេឌៀនៅក្នុងទម្រង់ផ្សេងពី៖ JPEG/PNG/GIF
- ប្រសិនបើបើកលក្ខណៈពិសេស **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ផ្នែកនៅលើគេហទំព័រដែលបង្ហាញការផ្សាយពាណិជ្ជកម្មនឹងទទេ។
ប្រសិនបើលាក់មាតិកាមួយចំនួននៅលើគេហទំព័រ និងមើលមាតិកាទាំងនោះមិនឃើញទេ សូមសាកល្បងកំណត់ → **ការកំណត់** → **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ទៅ **បិទ** នៅក្នុង **កម្មវិធីរុករកលើអ៊ីនធឺណិត**។ **ពាណិជ្ជកម្មដែលបានឧបត្ថម្ភ** នៅលើទំព័រផ្ទាំងថ្មីនឹងបង្ហាញ ទោះបីជាអ្នកកំណត់លក្ខណៈពិសេស **ប្រើការរារាំងការផ្សាយពាណិជ្ជកម្ម** ទៅ **បិទ** ក៏ដោយ។

កម្មវិធីរុករកលើអ៊ីនធឺណិត បិទដោយស្វ័យប្រវត្តិ នៅពេលខ្ញុំចូលទៅកាន់គេហទំព័រណាមួយ។

- កម្មវិធីអ៊ីនធឺណិតអាចត្រូវបានបង្ខំឲ្យបិទ ប្រសិនបើទំហំអង្គចងចាំដែលមានមិនគ្រប់គ្រាន់ ដើម្បីសម្រួលព័ត៌មានរូបភាពសម្រាប់វេបសាយ។
ពិនិត្យមើលថាតើអ្នកអាចចូលប្រើគេហទំព័រពាក់ព័ន្ធនឹងបញ្ហានេះនៅលើកុំព្យូទ័ររបស់អ្នកឬអត់។

នៅពេលមើលវីដេអូនៅក្នុង **កម្មវិធីរុករកលើអ៊ីនធឺណិត**វីដេអូត្រូវបានបង្ខំឲ្យបិទ។

- អ្នកអាចកែបញ្ហា ដោយកំណត់ ⋮ → **ការកំណត់** → **បច្ចេកវិទ្យាស្ទ្រីមមានភាពប្រែប្រួលដែលប្រើ JavaScript** ទៅជា **បិទ** នៅក្នុង **កម្មវិធីរុករកលើអ៊ីនធឺណិត**។ ការកំណត់មិនត្រូវបានអនុវត្តចំពោះផ្ទាំងដែលត្រូវបានបើក មុនពេលផ្លាស់ប្តូរ ហើយត្រូវបានអនុវត្តតែចំពោះផ្ទាំងដែលបានបើកបន្ទាប់ពីការផ្លាស់ប្តូរ។

ការទទួលបានព័ត៌មាន

ទម្រង់ឯកសាររូបថតដែលស្គាល់

ទម្រង់ឯកសាររូបថតដែលស្គាល់

ផ្នែកបន្ថែម	កម្រិតគុណភាព
jpeg, jpg, jpe	អប្បបរមា : 64 × 64 អប្បបរមា ប្រភេទធម្មតា : 15360 (W) × 8640 (H) ប្រភេទទំនើប : 4800 (W) × 3600 (H)
png	អប្បបរមា : 64 × 64 អប្បបរមា : 5760 (W) × 5760 (H)
bmp	អប្បបរមា : 64 × 64 អប្បបរមា : 1920 (W) × 1080 (H)

avif, heic, heif	អប្បបរមា : 64 × 64 អប្បបរមា : 4800 (W) × 3600 (H) 9600 (W) × 7200 (H) (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ)

ទម្រង់ឯកសារវីដេអូដែលស្គាល់

ទម្រង់ឯកសារវីដេអូដែលស្គាល់

អត្រាផ្ទេរទិន្នន័យអប្បបរមា៖

- វីដេអូ HD ពេញលេញ
  H.264 1920 × 1080@60P BP/MP/HP@L4.2 អតិបរមា 40Mbps
  HEVC 1920 × 1080@60P Main/Main10@L4.1 អតិបរមា 40Mbps
- វីដេអូ HD ធំសម្បើម (សម្រាប់ម៉ូដែល ULTRA HD តែប៉ុណ្ណោះ)
  H.264 3840 × 2160@30P BP/MP/HP@L5.1 អតិបរមា 50Mbps
  HEVC 3840 × 2160@60P Main/Main10@L5.1 អតិបរមា 60Mbps
- វីដេអូ HFR (សម្រាប់ម៉ូដែលដែលស្គាល់ HFR តែប៉ុណ្ណោះ)
  HEVC 3840 × 2160@120P Main/Main10@L5.2 អតិបរមា 60Mbps
- វីដេអូរូបភាព Dolby (សម្រាប់ម៉ូដែលដែលស្គាល់ Dolby Vision តែប៉ុណ្ណោះ)
  HEVC 3840 × 2160@60P Main/Main10@L5.1 អតិបរមា 50Mbps
- វីដេអូ 8K (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ)
  AV1 7680 × 4320@60P អតិបរមា 50Mbps
  HEVC 7680 × 4320@60P Main/Main10@L6.1 អតិបរមា 100Mbps

អក្សរអត់ខាងក្រៅដែលបានគាំទ្រ

smi, srt, sub (MicroDVD, SubViewer 1.0/2.0), ass, ssa, txt (TMPlayer), psb (PowerDivX), dcs (DLP Cinema)

ទ្រង់ទ្រាយអក្សរអត់បានបង្កប់ដែលបានគាំទ្រ៖

Matroska (mkv) : អាល់ហ្វាស្តានីយរង (SSA), អាល់ហ្វាស្តានីយរងកម្រិតខ្ពស់ (ASS), SRT
MP4 : Timed Text

កូឌិកវីដេអូដែលបានគាំទ្រ

ផ្នែកបន្ថែម	កូឌិក	
asf wmv	វីដេអូ	ទម្រង់កម្រិតខ្ពស់ VC-1 (លើកលែងសម្រាប់ WMVA), ទម្រង់VC-1 ធម្មតា និងចម្បង
	តន្ត្រី	ស្តង់ដារ WMA (លើកលែងសម្រាប់ WMA v1/WMA Speech)
avi	វីដេអូ	Xvid (GMC មិនអាចប្រើបានទេ), H.264/AVC, Motion Jpeg, MPEG-4
	តន្ត្រី	MPEG-1 Layer I, II, MPEG-1 Layer III (MP3), Dolby Digital, LPCM, ADPCM
mp4 m4v mov	វីដេអូ	H.264/AVC, MPEG-4, HEVC, AV1
	តន្ត្រី	Dolby Digital, Dolby Digital Plus, AAC, MPEG-1 Layer III (MP3), Dolby AC-4, DTS, DTS-HD, DTS:X
3gp 3g2	វីដេអូ	H.264/AVC, MPEG-4
	តន្ត្រី	AAC, AMR-NB, AMR-WB
mkv	វីដេអូ	MPEG-2, MPEG-4, H.264/AVC, VP8, VP9, HEVC, AV1
	តន្ត្រី	Dolby Digital, Dolby Digital Plus, AAC, PCM, DTS, DTS-HD, DTS:X, MPEG-1 Layer I, II, MPEG-1 Layer III (MP3)
ts trp tp mts	វីដេអូ	H.264/AVC, MPEG-2, HEVC
	តន្ត្រី	MPEG-1 Layer I, II, MPEG-1 Layer III (MP3), Dolby Digital, Dolby Digital Plus, AAC, PCM, DTS, DTS-HD, DTS:X, Dolby AC-4
mpg mpeg dat	វីដេអូ	MPEG-1, MPEG-2
	តន្ត្រី	MPEG-1 Layer I, II, MPEG-1 Layer III (MP3)

vob	វីដេអូ	MPEG-1, MPEG-2
	តន្ត្រី	Dolby Digital, MPEG-1 Layer I, II, DVD-LPCM

- Dolby AC-4 , DTS , DTS-HD , DTS:X : អាចនឹងមិនស្គាល់ម៉ូដែលមួយចំនួន។

ប្រយ័ត្នចំពោះការលេងវីដេអូឡើងវិញ

- អក្សរត់ដែលបានបង្កើតដោយអ្នកប្រើមួយចំនួនមិនអាចដំណើរការបានត្រឹមត្រូវ។
- ឯកសារវីដេអូ និងឯកសារអក្សរត់របស់វាត្រូវតែស្ថិតនៅក្នុងថតតែមួយ។
  ដើម្បីឱ្យអក្សរត់បង្ហាញបានត្រឹមត្រូវ ត្រូវប្រាកដថាឯកសារវីដេអូ
  និងឯកសារអក្សរត់មានឈ្មោះដូចគ្នា។
- អក្សរត់លើឧបករណ៍ផ្ទុកដែលបានភ្ជាប់បណ្តាញ (NAS) មិនអាចត្រូវបានគាំទ្រអាស្រ័យលើ
  ក្រុមហ៊ុនផលិត និងម៉ូដែល។
- ការផ្សាយដែលរួមមានការត្រឡប់ចលនាសកល (GMC) និងការប៉ាន់ស្មានចលនាខ្វែរធើកែល
  (Qpel) មិនត្រូវបានគាំទ្រទេ។
- វីដេអូ HD ធំសម្បើម (សម្រាប់ម៉ូដែល ULTRA HD តែប៉ុណ្ណោះ) : 3840 × 2160, 4096 × 2160
  មិនអាចចាក់វីដេអូ ULTRA HD ដែលបានបំប្លែងកូដ HEVC
  មួយចំនួនក្រៅពីមាតិកាដែលបានផ្តល់ជាផ្លូវការដោយក្រុមហ៊ុនផលិតបានទេ។
  កូឌិកមួយចំនួនអាចត្រូវបានគាំទ្របន្ទាប់ពីធ្វើបច្ចុប្បន្នកម្មវិធី។

ផ្នែកបន្ថែម	កូឌិក	
mkv/mp4/ts	វីដេអូ	H.264/AVC, HEVC
	តន្ត្រី	Dolby Digital, Dolby Digital Plus, AAC

- គាំទ្រតែWindow Media Audio V7 និងថ្មីជាងនេះ។
- ទម្រង់AAC ចម្បងមិនត្រូវបានគាំទ្រ។
- ឯកសារវីដេអូដែលបានបង្កើតដោយកម្មវិធីកូឌិកមួយចំនួនមិនអាចលេងបានទេ។
- ឯកសារវីដេអូមានទ្រង់ទ្រាយផ្សេងពីទ្រង់ទ្រាយបានបញ្ជាក់មិនលេងបានត្រឹមត្រូវទេ។
- ឯកសារវីដេអូបានរក្សាទុកក្នុងឧបករណ៍ផ្ទុកយូអេសប៊ីដែលមិនគាំទ្រល្បឿនលឿនមិនអាចលេង
  បានត្រឹមត្រូវទេ។

ទម្រង់ឯកសារតន្ត្រីដែលស្គាល់

ទម្រង់ឯកសារតន្ត្រីដែលស្គាល់

ទ្រង់ទ្រាយឯកសារ	ព័ត៌មាន	
mp3	អត្រាប៊ីត	32 kbps ~ 320 kbps
	ប្រេកង់គំរូ	16 kHz ~ 48 kHz
	គាំទ្រ	MPEG-1, MPEG-2
	ប៉ុស្តិ៍	ម៉ូណូ, ស្តេរីអូ
wav	អត្រាប៊ីត	-
	ប្រេកង់គំរូ	8 kHz ~ 96 kHz
	គាំទ្រ	PCM
	ប៉ុស្តិ៍	ម៉ូណូ, ស្តេរីអូ
ogg	អត្រាប៊ីត	64 kbps ~ 320 kbps
	ប្រេកង់គំរូ	8 kHz ~ 48 kHz
	គាំទ្រ	Vorbis
	ប៉ុស្តិ៍	ម៉ូណូ, ស្តេរីអូ
wma	អត្រាប៊ីត	128 kbps ~ 320 kbps
	ប្រេកង់គំរូ	8 kHz ~ 48 kHz
	គាំទ្រ	WMA

	ប៉ុស្តិ៍	រហូតដល់6 ប៉ុស្តិ៍
flac	អត្រាប៊ីត	-
	ប្រេកង់គំរូ	8 kHz ~ 96 kHz
	គាំទ្រ	FLAC
	ប៉ុស្តិ៍	ម៉ូណូ, ស្តេរីអូ

- ចំនួនប៉ុស្តិ៍ដែលបានគាំទ្រអាចខុសគ្នា អាស្រ័យលើប្រេកង់គំរូ។

គុណភាពបង្ហាញដែលបានគាំទ្រ៖ HDMI-DTV

ម៉ូដគាំទ្រ HDMI-DTV

កម្រិតគុណភាព	ហ្វ្រេកង់ផ្តេក (kHz)	ហ្វ្រេកង់បញ្ឈរ
640 × 480p	31.46	59.94
	31.5	60
720 × 480p	31.46	59.94
	31.5	60
720 × 576p	31.25	50
1280 × 720p	37.5	50
	44.95	59.94

	45	60
1920 × 1080i	28.12	50
	33.71	59.94
	33.75	60
1920 × 1080p	26.97	23.97
	27	24
	28.12	25
	33.71	29.97
	33.75	30
	56.25	50
	67.43	59.94
	67.5	60
1920 × 1080p (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	112.5	100
	134.86	119.88
	135	120
2560 × 1080p[4) 5)] (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	66	60

2560 × 1080p [4) 5)] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	131.74	120
3840 × 2160p (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	53.94	23.97
	54	24
	56.25	25
	67.43	29.97
	67.5	30
	112.5	50
	134.86	59.94
	135	60
3840 × 2160p [1) 2) 3)] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	225	100
	269.73	119.88
	270	120
4096 × 2160p (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	53.94	23.97
	54	24
	56.25	25
	67.43	29.97

	67.5	30
	112.5	50
	134.86	59.94
	135	60
4096 × 2160p [1) 2) 3)] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	225	100
	269.73	119.88
	270	120
7680 × 4320p [1) 2)] (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ)	107.89	23.97
	108	24
	110	25
	131.87	29.97
	132	30
	220	50
	263.74	59.94
	264	60

[1] ដំណើរការបាននៅពេល **HDMI Deep Color** ត្រូវកំណត់ទៅជា **4K**។
[2] ដំណើរការបាននៅពេល **HDMI Deep Color** ត្រូវកំណត់ទៅជា **8K**។
[3] (សម្រាប់ម៉ូដែល ULTRA HD តែប៉ុណ្ណោះ) ស្គាល់តែរន្ធនៃធាតុបញ្ចូល HDMI មួយចំនួនប៉ុណ្ណោះ។
[4] ដំណើរការបាននៅពេល **អត្រាទ្រង់ទ្រាយធំទូលាយ** ត្រូវកំណត់ទៅជា **21:9**។
[5] ដំណើរការបាននៅពេល **អត្រាទ្រង់ទ្រាយធំទូលាយ** ត្រូវកំណត់ទៅជា **32:9**។

គុណភាពបង្ហាញដែលបានគាំទ្រ HDMI-PC

ម៉ូដគាំទ្រ HDMI-PC

កម្រិតគុណភាព	ហ្វ្រេកង់ផ្តេក (kHz)	ហ្វ្រេកង់បញ្ឈរ
640 × 350	31.46	70.09
720 × 400	31.46	70.08
640 × 480	31.46	59.94
800 × 600	37.87	60.31
1024 × 768	48.36	60
1152 × 864	54.34	60.05
1360 × 768[3]	47.71	60.01
1280 × 1024 (សម្រាប់ម៉ូដែល Full HD, ULTRA HD, 8K តែប៉ុណ្ណោះ)	63.98	60.02
1920 × 1080	67.5	60

1920 × 1080 (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	134.86	119.88
	135	120
1920 × 1080 [6] (អាចប្រើបានសម្រាប់តែម៉ូដែល 144 Hz ប៉ុណ្ណោះ)	166.58	144
2560 × 1080 [4] [5] (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	66	60
2560 × 1080 [4] [5] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	131.74	120
2560 × 1080 [4] [6] (អាចប្រើបានសម្រាប់តែម៉ូដែល 144 Hz ប៉ុណ្ណោះ)	166.54	144
2560 × 1440 [1] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 60 Hz, 8K 60 Hz ប៉ុណ្ណោះ)	88.78	59.95
2560 × 1440 [1] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	182.99	119.99
2560 × 1440 [6] (អាចប្រើបានសម្រាប់តែម៉ូដែល 144 Hz ប៉ុណ្ណោះ)	222.15	144
3840 × 1080 [5] (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	66.62	60
3840 × 1080 [5] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	137.25	120

3840 × 1080 [5) 6)] (អាចប្រើបានសម្រាប់តែម៉ូដែល 144 Hz ប៉ុណ្ណោះ)	166.56	144
3840 × 1600 [4)] (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	99.41	60
3840 × 1600 [4) 6)] (អាចប្រើបានសម្រាប់តែម៉ូដែល 144 Hz ប៉ុណ្ណោះ)	246.81	144
3840 × 2160 (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	53.94	23.97
	54	24
	56.25	25
	67.43	29.97
	67.5	30
	112.5	50
	134.86	59.94
	135	60
3840 × 2160 [1)] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	225	100
	269.73	119.88
	270	120
3840 × 2160 [6)] (អាចប្រើបានសម្រាប់តែម៉ូដែល 144 Hz ប៉ុណ្ណោះ)	333.18	144

4096 × 2160 (សម្រាប់ម៉ូដែល ULTRA HD, 8K តែប៉ុណ្ណោះ)	53.94	23.97
	54	24
	56.25	25
	67.43	29.97
	67.5	30
	112.5	50
	134.86	59.94
	135	60
4096 × 2160 [1)] (អាចប្រើបានសម្រាប់តែម៉ូដែល UltraHD 120/144 Hz, 8K 120/144 Hz ប៉ុណ្ណោះ)	225	100
	269.73	119.88
	270	120
7680 × 4320 [2)] (សម្រាប់ម៉ូដែល 8K តែប៉ុណ្ណោះ)	107.89	23.97
	108	24
	110	25
	131.87	29.97
	132	30
	220	50

263.74	59.94
264	60

[1] ដំណើរការបាននៅពេល **HDMI Deep Color** ត្រូវកំណត់ទៅជា **4K**។
[2] ដំណើរការបាននៅពេល **HDMI Deep Color** ត្រូវកំណត់ទៅជា **8K**។
[3] ដំណើរការបាននៅពេល **HDMI Deep Color** ត្រូវកំណត់ទៅជា **បិទ**។
[4] ដំណើរការបាននៅពេល **អត្រាទ្រង់ទ្រាយធំទូលាយ** ត្រូវកំណត់ទៅជា **21:9**។
[5] ដំណើរការបាននៅពេល **អត្រាទ្រង់ទ្រាយធំទូលាយ** ត្រូវកំណត់ទៅជា **32:9**។
[6] ដំណើរការបាននៅពេល **មុខងារ 144Hz** ត្រូវកំណត់ទៅជា **បើក**។

- រន្ធ HDMI-PC ខុសគ្នាតាមប្រភេទម៉ូដែល។
  សូមមើលសៀវភៅណែនាំដែលមានភ្ជាប់មកជាមួយផលិតផល។

ព័ត៌មានអំពីអាជ្ញាប័ណ្ណ

ព័ត៌មានអំពីអាជ្ញាប័ណ្ណ

អាជ្ញាបណ្ណដែលស្គាល់អាចខុសគ្នាទៅតាមម៉ូដែល។

Dolby

Manufactured under license from Dolby Laboratories. Dolby, Dolby Vision, Dolby Vision IQ, Dolby Audio, Dolby Atmos, and the double-D symbol are trademarks of Dolby Laboratories Licensing Corporation.

DTS

សម្រាប់ប៉ាតង់ DTS សូមមើល http://patents.dts.com។ បានផលិតក្រោមអាជ្ញាបណ្ណពី DTS, Inc. (សម្រាប់ក្រុមហ៊ុនដែលមានស្នាក់ការនៅក្នុងសហរដ្ឋអាមេរិក/ជប៉ុន/តៃវ៉ាន់) ឬក្រោមអាជ្ញាបណ្ណពី DTS Licensing Limited (សម្រាប់ក្រុមហ៊ុនផ្សេងទៀតទាំងអស់)។ DTS, DTS:X និងនិមិត្តសញ្ញា DTS:X គឺជាពាណិជ្ជសញ្ញា DTS, Inc.
ឬពាណិជ្ជសញ្ញាដែលបានចុះបញ្ជីនៅក្នុងសហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀត។ © 2021 DTS, Inc. រក្សាសិទ្ធិគ្រប់យ៉ាង។

HDMI

The terms HDMI, HDMI High-Definition Multimedia Interface, HDMI Trade Dress and the HDMI Logos are trademarks or registered trademarks of HDMI Licensing

Administrator, Inc.

Bluetooth

The Bluetooth® word mark and logos are registered trademarks owned by the Bluetooth SIG, Inc. and any use of such marks by LG Electronics Inc. is under license. Other trademarks and trade names are those of their respective owners.

Quickset

HEVC